សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ ធ្នូ ឆ្នាំ ២០១៧

# លីអាហូណា



តើយើងនឹងថ្វាយបង្គំទ្រង់តាមរបៀបណា ? ទំព័រ ៤, ១០, ១៦

ក្មេងប្រុសម្នាក់ដែលមានមន្ទិលសង្ស័យ អ្នកមើលធុតដ៏ជម្រើសម្នាក់ ទំព័រ ២០

តើអ្នកធ្លាប់មានអារម្មណ៍ថា មានគេមិនសូវយកចិត្តទុកដាក់នឹងអ្នកដែរឬទេ ? ទំព័រ ២៨

គោលការណ៍នៃដំណឹងល្អទាំង ៧ ដែលផ្ដល់ការការពារ ទំព័រ ៣៤



*រូបថត យ៉ូសែប អេហ្វ ស្ម៊ីធ ដែលបានបម្រើជាប្រធានសាសនាចក្រពីឆ្នាំ ១៩០១ ដល់ឆ្នាំ ១៩១៨ ដែលបានបង្ហាញនៅត្រង់នេះគឺជារូបថតមួយឆ្នាំមុនពេលលោកបានទទួលមរណភាពក្នុងវ័យ ៨០ ឆ្នាំ ។ ឪពុករបស់លោកឈ្មោះ ហៃរុម ស្ម៊ីធ ត្រូវបានគេធ្វើទុក្ករកម្មជាមួយនឹងយ៉ូសែប ស្ម៊ីធ នៅឆ្នាំ១៨៤៤ ។ ក្នុងវ័យ ២៧ ឆ្នាំ យ៉ូសែប អេហ្វ ស្ម៊ីធ ត្រូវបានតែងតាំងជាសាវកក្នុងឆ្នាំ ១៨៦៦ ដោយប្រធាន ព្រិកហាំ យ៉ង់ ហើយលោកបានបម្រើជាទីប្រឹក្សារបស់ប្រធានសាសនាចក្របួនរូប ។ ដោយបានបម្រើជាអ្នកមានសិទ្ធិអំណាចទូទៅម្នាក់អស់រយៈពេល ៥២ ឆ្នាំ ការបង្រៀនដ៏ច្រើនរបស់លោកត្រូវបានបោះពុម្ពនៅក្រោមចំណងជើងថា គោលលទ្ធិនៃដំណឹងល្អ ។ លោកក៏បានទទួលវិវរណៈដែលឥឡូវនេះបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា កណ្ឌទី ១៣៨ ផងដែរ ។*

រូបថតទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីបណ្ណាល័យប្រវត្តិសាសនាចក្រ

# លីអាហូណា ខែ ធ្នូ ឆ្នាំ ២០១៧




## សារលិខិត


៤ **សារលិខិតគណៈប្រធានទីមួយ ៖ ការស្វែងរកព្រះគ្រីស្ទនៅបុណ្យគ្រីស្ទម៉ាស់**
ដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ

៧ **សារលិខិតបង្រៀនសួរសុខទុក្ខ ៖ យល់ព្រមទទួលបន្ទុកគ្នាទៅវិញទៅមក**


## អត្ថបទពិសេសៗ


១០ **សរសើរដល់ព្រះដ៏ខ្ពស់បំផុត**
ដោយអែលឌើរ រ៉ូណាល អេ រ៉ាសបាន
*តើអ្នកនឹងជ្រើសដើម្បីធ្វើជាសាក្សីម្នាក់របស់ព្រះគ្រីស្ទនារដូវកាលបុណ្យឈប់សម្រាកនេះយ៉ាងដូចម្ដេច ?*

១៦ **ព្រឹត្តិការណ៍ទាំងដប់បួននៃប្រសូតកម្ម**
ដោយ ជេសីកា ហ្គ្រីហ្វីធ
*សូមរុករកព្រឹត្តិការណ៍នានាដែលដឹកនាំទៅរកការប្រសូតរបស់ព្រះអង្គសង្គ្រោះដែលមាននៅក្នុងបទគម្ពីរ ។*

២០ **យ៉ូសែប ស្ម៊ីធ ៖ កម្លាំងដែលកើតចេញពីភាពទន់ខ្សោយ**
ដោយអែលឌើរ ម៉ាកឹស ប៊ី ណាស
*អព្ភូតហេតុកើតមានពេលយើងស្គាល់ ហើយបង្វែរភាពទន់ខ្សោយរបស់យើងទៅរកព្រះអម្ចាស់ ដូចដែលវាបានកើតឡើងចំពោះព្យាការី យ៉ូសែប ដែរ ។*

២៨ **យើងអាចធ្វើបានប្រសើរជាង ភាគ ២ ៖ ការស្វែងរកកន្លែងរបស់អ្នកនៅក្នុងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ**
ដោយ បេ៊តសី វ៉ាន់ឌេនប៊ឺហ្គហេ
*តើអ្នកធ្លាប់មានអារម្មណ៍ថា មិនចុះសម្រុងនឹងគេដែរឬទេ ? នេះគឺជាវិធីមួយចំនួនដើម្បីស្វែងរកដំណោះស្រាយមួយ ។*

៣៤ **ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ៖ ជម្រក និងការការពារមួយ**
ដោយ ហ្គេទូលីយ៉ូ វ៉លថឺ ចាហ្គី អ៊ី ស៊ីលវ៉ា
*ដកស្រង់ចេញពីគោលលទ្ធិ និងសេចក្ដីសញ្ញា ៖ វិធីប្រាំពីរយ៉ាងដែលយើងត្រូវបានសន្យាថា នឹងមានការការពារនៅក្នុងជីវិតរបស់យើង ។*


## ផ្នែកនានា


៨ **ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ ៖ ការលើកកម្ពស់ដល់ការពិភាក្សានៅក្នុងគ្រួសាររបស់យើង**
ដោយ ដ័ហ្គ ហាត

៤០ **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

៤៤ **ការបង្ហាញអំពីសេចក្ដីជំនឿ ៖ យ៉ូសេហ្វីន ស្តែរ**

៨០ **លុះត្រាយើងជួបទៀត ៖ ភាពក្លាហាននៅក្នុងបុព្វហេតុនៃព្រះគ្រីស្ទ**
ដោយប្រធាន យ៉ូសែប ស្ម៊ីធ




នៅលើក្របមុខ
*ប្រសូតកម្មដោយ ប្រ៊ូស ហ៊ីកសុន ស្ម៊ីធ*

យុវមជ្ឈិមវ័យ




៤៨

៤៦ **កម្មវិធីប្រកួតប្រជែងផ្នែកទេពកោសល្យរបស់ម៉ុងហ្គោលី**
ដោយ ប៉ូ នៀន ( ហ្វេលីប៉េ ) ឈូ, កេត្រា ឈូ និង អូដហ្គេរេល អូឈើចាវ
*របៀបដែលក្រុមចម្រៀងយុវមជ្ឈិមវ័យមួយក្រុមបានប្រើចម្រៀងដើម្បីធ្វើឲ្យប្រទេសមួយចាប់អារម្មណ៍ — ហើយចែកចាយដំណឹងល្អ ។*

៤៨ **អំណោយរបស់ខ្ញុំថ្វាយទៅព្រះអង្គសង្គ្រោះ**
ដោយ ឈើស្តេន ភីកស្តុន
*ខ្ញុំត្រូវឈប់គិតពីខ្លួនឯង ហើយចាប់ផ្ដើមគិតពីបងប្អូនប្រុសស្រីរបស់ខ្ញុំវិញ ។*

យុវវ័យ

៥០ **ស្វែងរកសេចក្ដីជំនឿរបស់នាងម្ដងទៀត**
ដោយ ដេវីឌ ឌីកសុន
*ទីបន្ទាល់របស់ តេ អូរ៉ាណូអា បានចុះខ្សោយ ប៉ុន្តែនាងនៅតែនឹកចាំពីបទពិសោធន៍ដ៏ផ្អែមល្ហែមមកពីអតីតកាលរបស់នាង ។*

៥២ **ឥទ្ធិពលនៃចម្រៀងបុណ្យគ្រីស្ទម៉ាស់**
*ដំណើររឿងពីរអំពីពរជ័យដ៏អស្ចារ្យនៃការច្រៀងចម្រៀង ។*

៥៤ **ហេតុផលប្រាំបីយ៉ាងដែលបុណ្យគ្រីស្ទម៉ាស់គឺជាគ្រាដ៏អស្ចារ្យមួយដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនា**
ដោយ ឆាឡុត ឡាកាបាល
*តើមាននរណាបានដឹងថា ការធ្វើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់អាចជារឿងងាយស្រួលដែរឬទេ ?*

៥៨ **ប័ណ្ណប្រកាស: បន្ទប់សម្រាប់ទ្រង់**

៥៩ **ចម្លើយមកពីថ្នាក់ដឹកនាំនៃសាសនាចក្រ: របៀបទទួលអារម្មណ៍ពីអត្ថន័យពិតនៃបុណ្យគ្រីស្ទម៉ាស់**
ដោយប្រធាន ថូម៉ាស អេស ម៉នសុន

៦០ **សំណួរ និង ចម្លើយ**
*ខ្ញុំបានអធិស្ឋានទូលសុំអ្វីមួយដែលសំខាន់ ប៉ុន្តែខ្ញុំពុំដឹងឡើយថា ខ្ញុំបានទទួលចម្លើយឬអត់នោះទេ ។ តើខ្ញុំនឹងដឹងរឿងនេះយ៉ាងដូចម្ដេច ?*

៦២ **ទីកន្លែងរបស់យើង**

កុមារ



៧៦

៦៤ **ភ្ញៀវនៅថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់**
ដោយ ហូលី ខេ វ៉ែធីងតុន
*អូ៎ អត់ទេ ! រាត្រីដែលត្រូវចូលចិត្តបំផុតនៅក្នុងមួយឆ្នាំកំពុងតែជួបភាពហិនហោច ។*

៦៦ **ចូរភ្លក្សាហាន ហើយចែកចាយ !**
ដោយ អែលឌើរ ប៉ូល ប៊ី ផៃបកើរ
*តើអ្នកនឹងជួយមិត្តរបស់អ្នកឲ្យរៀនអំពី ព្រះយេស៊ូវគ្រីស្ទដែរឬទេ ?*

៦៧ **រូបភាពប្រវត្តិសាសនាចក្រ ៖ សាសនាចក្របច្ចុប្បន្ន**

៦៨ **សំបុត្រពណ៌ក្រហម**
ដោយ ដាសី ជេនសិន ម័ររីស
*ម៉ាតេអូ ចង់ក្លាយជាមិត្តដ៏ល្អមួយ ដូចជាព្រះយេស៊ូវ ។ តើគាត់អាចធ្វើអ្វីខ្លះ ?*

៧០ **ចម្លើយមកពីសាវក ៖ តើការប្រែចិត្តអាចជួយខ្ញុំឲ្យមានចិត្តរីករាយតាមរបៀបណា ?**
ដោយអែលឌើរ ឌេល ជី រេនឡាន់

៧២ **ការបង្រៀនរបស់ព្រះយេស៊ូវ**
*នេះគឺជាវិធីដ៏សប្បាយមួយដើម្បីរាប់ថយក្រោយរហូតដល់បុណ្យគ្រីស្ទម៉ាស់ ដោយធ្វើតាមការបង្រៀនមួយចំនួនរបស់ព្រះយេស៊ូវ ។*

៧៤ **តន្ត្រី ៖ រៀបចំបន្ទប់សម្រាប់ទ្រង់**
ដោយ ឡារី ហិលើរ និង ម៉ៃឃើល អេហ្វ ម៉ូឌី

៧៥ **ទំព័ររបស់យើង**

៧៦ **រឿងអំពីព្រះយេស៊ូវ ៖ ព្រះយេស៊ូវប្រសូតក្នុងភូមិបេថ្លេហិម**
ដោយ គីម វិប វៀដ

៧៩ **ទំព័រផាត់ពណ៌**




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើព្រះវិញ្ញាណបរិសុទ្ធជួយអ្នកឲ្យធ្វើជាមិត្តល្អម្នាក់យ៉ាងដូចម្ដេច ?***



៥៤

**ខែ ធ្នូ ឆ្នាំ ២០១៧ វ៉ុល ១៦ លេខ ៦**
**លីអាហូណា 14452 258**
ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃ ចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេស្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អឹម. រ័សុល បាឡឺដ, រ៉ូបឺត ឌី ហែល, ជែហ្វ្រី អ័រ ហូឡិន, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវែនសុន, ឌេល ជី រេនឡាន់

**និពន្ធនាយក ៖** ហ៊ូហ្គូ អ៊ី ម៉ាទីណេ
**ជំនួយការនិពន្ធនាយក ៖** រ៉េនដល យេ បិនណ្ណិត, ខារ៉ូ អេហ្វ ម៉ាកខន់ឃី
**អ្នកប្រឹក្សា ៖** ប្រែន ខេ អាស្តុន, ប៊ូនី អេច ខរឌុន, ឡឺហ្ក្រង់ ឬ ខឺធីស ជុញ្ញ័រ, អេដវួដ ដាប់, ស្សារ៉ុន អិល អ៊ើបែង, ដូណាល អិល ហលស្ត្រម, ដូហ្គ្លាស ឌី ហូលមែស, អ៊ីរិក ដុបឃ្យូរ កូពីស្កេ

**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយបិហ្គ
**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់
**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អរដោម ស៊ី អូស្លុន
**ជំនួយការ ការគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ាយអិន ខារ

**ជំនួយការបោះពុម្ព ៖** រេមិលដា អាំម៉ារ៉ាល់
**និពន្ធ និងកែសម្រួលដោយ ៖** ម៉ារីសា ខែននី, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាធ្យូ ឌី ហ្វ៊ីតុន, ឡរី ហូលើរ, ហ្គារែត អេច ហ្គាហ្វ, ឡារ៉ែន ផតទើរ ហ្គាន, ចូន រ៉ាយអែន ជែនសិន, ឆាលឡុត ឡាកាបាល់, ម៉ៃយល អរ ម៉ូរីស, អ៊ីរិក ប៊ី ម៉ដុក សាលី ចនសុន អូដេយ៉ិក, យ៉ូស្វេ ជេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី អាន សេលូ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ថៃដ អ័រ ភីធើរសុន
**រចនាប្លង់ដោយ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, ស៊ី ឃីមប៊ឹល បុត, ថូម៉ាស ឆាល, ដេវីឌ ហ្គ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្គ្រីន, ស្កត អិម ម៉ូយ, អេមីលី ឈីកូ រេម៉ុងតុន, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ធៀរ, យេ នីកូល វ៉ែកឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នៃបេឃើ អាននី
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ហ្វែន អាឡៀ, ថូម៉ាស ជី ក្រូនីន, ខេទី ដានខាន, ប្រៃអិន ដ័បុលយូ ជីជី, ជីន្នី ជេ និលសុន
**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស

**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ធី លេវីស
**នាយកចែកចាយ ៖** ត្រយ ខេ វេលីនហ្

សូមផ្ញើអត្ថបទ និង សំណួរនានា តាមអ៊ិនធើរណែតនៅគេហទំព័រ liahona .lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ុអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, នរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។

( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2017 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

ព័ត៌មានអំពីកម្មសិទ្ធិបញ្ញា ៖ លុះត្រាមានការបញ្ជាក់ បុគ្គលម្នាក់ៗអាចថតចម្លងឯកសារចេញពីលីអាហូណានេះសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬ ពុំមែនដើម្បីធ្វើអាជីវកម្ម ( រួមទាំងការហៅបម្រើក្នុងសាសនាចក្រ ) ។ សិទ្ធិនេះអាចត្រូវបានលុបចោលវិញគ្រប់ពេល ។ រូបភាពពុំអាចថតចម្លងបានឡើយ ប្រសិនបើឃើញមានការដាក់បម្រាមបង្ហាញនៅក្នុងជួរបន្ទាត់នៃការដកស្រង់នៃរូបភាពនោះ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., FL 13, Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
December 2017 Vol. 16 No. 6. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $10.00 per year; Canada, $12.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# ការអញ្ជើញមកកាន់កម្មវិធីសិល្បករទូទាំងពិភពលោក

*« ទូលបង្គំនឹងរំឭកពីអស់ទាំងការនៃព្រះយេហូវ៉ា ដ្បិតទូលបង្គំនឹកឃើញអស់ទាំងការអស្ចារ្យដែលទ្រង់បានធ្វើកាលពីដើម ។ ទូលបង្គំនឹងរំពឹងគិតពីគ្រប់ទាំងការរបស់ទ្រង់ ហើយពិចារណាពីកិច្ចដែលទ្រង់ធ្វើទាំងប៉ុន្មាន » ( ទំនុកដំកើង ៧៧:១១–១២ ) ។*




*ភួយសំឡីរបស់គ្រួសារស្ដីមេលប៊ុស*, ដោយគ្រីស្តា ស្ដីមេលប៊ុស, *ខ្យល់ព្យុះ—ភាពសុខសាន្ត ចូរស្ងប់ចុះ* ដោយ ជ័គ កុកកូ សាន់តាន់ជេឡូ

អ្នកត្រូវបានអញ្ជើញឲ្យបង្កើតគំនូរ ថ្មីសម្រាប់ការប្រកួតគំនូរ អន្តរជាតិលើកទី១១ ដែលឧបត្ថម្ភដោយសារៈមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រនៅទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ ។

- ប្រធានបទ ៖ « ការសញ្ជឹងគិតអំពីជំនឿ » ដែលបានបំផុសមកពី ទំនុកដំកើង ៧៧:១១–១២ ។ រាល់ប្រព័ន្ធផ្សព្វផ្សាយ រចនាប័ទ្ម និងបែបបទតាមវប្បធម៌ខាងគំនូរទាំងអស់ត្រូវបានស្វាគមន៍ !
- កាលបរិច្ឆេទការដាក់ស្នើ ៖ ថ្ងៃទី ១ ខែកុម្ភៈ រហូតដល់ថ្ងៃទី ១ ខែមិថុនា ឆ្នាំ២០១៨ ។
- អាយុ ៖ អ្នកចូលរួមត្រូវមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ។
- រង្វាន់ ៖ ក្រោយបានជ្រើសរើសដោយគណៈវិនិច្ឆ័យហើយ រង្វាន់នឹងត្រូវប្រកាសនៅខែតុលា ឆ្នាំ ២០១៨ ។ គំនូរដែលបានចូលរួមនឹងត្រូវដាក់បង្ហាញនៅឯសារៈមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ និងនៅលើអ៊ិនធើរណែត ។

សូមចូលទៅគេហទំព័រ **lds.org/artcompetition** សម្រាប់ច្បាប់លម្អិត តម្រូវការលក្ខខណ្ឌគ្រប់គ្រាន់ និងការចុះឈ្មោះនៅលើអ៊ិនធើរណែត ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

***ការគោរពប្រតិបត្តិ***, ៣៤
***ការចូលរួមសាសនាចក្រ***, ២៨
***ការទទួលខុសត្រូវ***, ៦៣, ៦៨
***ការធ្វើជាឪពុកម្ដាយ***, ៨
***ការបង្រៀន***, ៨
***ការបន្ទាបខ្លួន***, ២០
***ការបម្រើ***, ៧, ១០, ៤១, ៤២, ៤៣, ៥២, ៥៤, ៧៥
***ការប្រែចិត្ត***, ២៨, ៦៨, ៧០, ៧១
***ការសិក្សាព្រះគម្ពីរ***, ១០, ៧២
***ការអធិស្ឋាន***, ២០, ៦០
***កិច្ចការផ្សព្វផ្សាយសាសនា***, ៣៤, ៤៦, ៤៨, ៥៤, ៦៤, ៦៦
***គោលលទ្ធិ និង សេចក្ដីសញ្ញា***, ៣៤
***គំរូ***, ៨, ៦២
***គ្រួសារ***, ១០, ៥២, ៥៤
***ដង្វាយមួយភាគក្នុងដប់***, ៣៤
***តន្ត្រី***, ១០, ៤៣, ៤៦, ៥២, ៧៤
***បុណ្យគ្រីស្ទម៉ាស់***, ៤, ១០, ១៦, ៤០, ៤១, ៤២, ៤៣, ៤៨, ៥២, ៥៤, ៥៨, ៥៩, ៦៤, ៧២, ៧៤, ៧៦, ៧៩
***ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ***, ៣៤
***ព្យាការី***, ២០, ៣៤, ៦៧
***ព្រះគម្ពីរមរមន***, ២០, ៥០, ៦៣, ៦៦, ៦៧
***ព្រះជាព្រះវរបិតា***, ២០, ២៨, ៧៥
***ព្រះយេស៊ូវគ្រីស្ទ***, ៤, ១០, ១៦, ៤២, ៤៣, ៤៨, ៥៨, ៥៩, ៧២, ៧៦, ៧៩, ៨០
***ព្រះវិញ្ញាណបរិសុទ្ធ***, ៣៤, ៤០, ៦០, ៦៤
***ព្រះវិហារបរិសុទ្ធ***, ៣៤, ៤៤, ៦៧, ៧៥
***មិត្តភាព***, ៦២, ៦៨
***យ៉ូសែប ស្ម៊ីធ***, ២០
***សេចក្ដីជំនឿ***, ៤, ២០, ២៨, ៤៤, ៥០, ៨០
***សេចក្ដីពិត***, ៤៤
***សេចក្ដីសប្បុរស***, ៧
***សេចក្ដីសញ្ញា***, ៧, ៣៤, ៤៤
***អាពាហ៍ពិពាហ៍***, ៣៤
***អំណោយ***, ៤១, ៤៣, ៤៨, ៥៩

## សារលិខិតគណៈប្រធានទីមួយ



**ដោយប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ**
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ

# ការស្វែងរកព្រះគ្រីស្ទនៅបុណ្យគ្រីស្ទម៉ាស់

ជូនចំពោះអស់អ្នកដែលប្រាថ្នាចង់យល់អំពីអត្តសញ្ញាណរបស់យើងក្នុងនាមជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ខ្ញុំចង់ផ្តល់ចំណុចចាប់ផ្តើមមួយដែលកំណត់ពាក្យបីម៉ាត់នេះ ៖ យើងស្វែងរកព្រះគ្រីស្ទ ។

យើងព្យាយាមដើម្បីរៀនអំពីទ្រង់ ។ ដើម្បីធ្វើតាមទ្រង់ ។ ដើម្បីប្រែក្លាយកាន់តែដូចជាទ្រង់ ។

រៀងរាល់ថ្ងៃពេញមួយឆ្នាំ យើងស្វែងរកទ្រង់ ។ ប៉ុន្តែជាពិសេសនៅគ្រានេះ — ជាបុណ្យគ្រីស្ទម៉ាស់ ពេលយើងសាទរដល់ការប្រសូតរបស់ព្រះអង្គសង្គ្រោះជាទីស្រឡាញ់របស់យើង — កាន់តែបង្វែរដួងចិត្តរបស់យើងទៅរកទ្រង់កាន់តែខ្លាំង ។

ជាផ្នែកមួយនៃការរៀបចំខ្លួនរបស់យើងសម្រាប់ការសាទរដល់បុណ្យគ្រីស្ទម៉ាស់ ចូរយើងពិចារណាអំពីរបៀបដែលមនុស្សកាលពីពីរពាន់ឆ្នាំមុនបានត្រៀមខ្លួនស្វាគមន៍ដល់ការយាងមករបស់ព្រះអង្គសង្គ្រោះ ។

### ពួកអ្នកគង្វាល

យើងពុំបានដឹងច្រើនអំពីពួកអ្នកគង្វាលនោះទេ អ្វីដែលយើងបានដឹងគឺថា ពួកគេកំពុង « ចាំយាម រក្សាហ្វូងចៀមរបស់ខ្លួន នៅឯវាល ក្នុងវេលាយប់ » ។[១] ពួកអ្នកគង្វាលគឺទំនងជាប្រជាជនសាមញ្ញច្រើនជាង ដូចគ្នានឹងមនុស្សដែលគួរឲ្យសរសើរជាច្រើនដែលបានចេញទៅធ្វើការដើម្បីចិញ្ចឹមជីវិត ។

ពួកគេអាចតំណាងឲ្យមនុស្សដែលគ្រាមួយនោះ ពុំបានស្វែងរកព្រះគ្រីស្ទយ៉ាងសកម្មទេ ប៉ុន្តែដួងចិត្តរបស់ពួកគេបានផ្លាស់ប្តូរ ពេលស្ថានសួគ៌បានបើកឡើង ហើយបានប្រកាសដល់ពួកគេអំពីព្រះគ្រីស្ទ ។

បន្ទាប់ពីបានស្តាប់ឮសំឡេងរបស់ពួកទេវតា គឺពួកគេទាំងនេះហើយដែលបានទៅភូមិបេថ្លេហិមភ្លាមដោយចង់ឃើញអំពីព្រឹត្តិការណ៍នោះ ។[២]

### ពួកហោរា

ពួកហោរាគឺជាពួកអ្នកសិក្សាដែលបានសិក្សាអំពីការយាងមកដល់នៃព្រះមែស៊ីជាព្រះរាជបុត្រានៃព្រះ ។ តាមរយៈការរៀនសូត្រនេះ ពួកគេបានស្គាល់អំពីទីសម្គាល់ដែលចង្អុលបង្ហាញទៅការប្រសូតរបស់ទ្រង់ ។ ពេលពួកគេបានស្គាល់ពីទីសម្គាល់ទាំងនោះ ពួកគេបានចាកចេញពីផ្ទះសម្បែងរបស់ពួកគេ ធ្វើដំណើរទៅទីក្រុងយេរូសាឡិម ដោយចោទសួរថា « តើព្រះអង្គដែលប្រសូតមក ធ្វើជាស្តេចសាសន៍យូដា ទ្រង់គង់នៅឯណា ? »[៣]

ចំណេះដឹងរបស់ពួកគេអំពីព្រះគ្រីស្ទពុំបានបន្តនៅជាការសិក្សាតែម្យ៉ាងទៀតឡើយ ។ ពេលពួកគេបានឃើញទីសម្គាល់នៃការប្រសូតរបស់ទ្រង់ ពួកគេបានអនុវត្តតាម ។ ពួកគេបានចេញទៅរកព្រះគ្រីស្ទ ។

ពួកហោរាអាចតំណាងឲ្យអស់អ្នកដែលស្វែងរកព្រះគ្រីស្ទតាមរយៈការរៀនសូត្រ និងការសិក្សា ។ ការលះបង់របស់ពួកគេចំពោះសេចក្តីពិត នៅទីបំផុតដឹកនាំពួកគេឲ្យរកឃើញព្រះគ្រីស្ទ ហើយថ្វាយបង្គំទ្រង់ជាស្តេចនៃអស់ទាំងស្តេច ជាព្រះអង្គសង្គ្រោះនៃមនុស្សលោក ។[៤]

### ស៊ីម្មាន និងអាណ

ស៊ីម្មាន និងអាណា អាចតំណាងឲ្យអស់អ្នកដែលស្វែងរកព្រះគ្រីស្ទតាមរយៈព្រះវិញ្ញាណ ។ បុគ្គលដ៏អស្ចារ្យទាំងអស់នេះគឺជាអ្នកដែលកាន់សាសនាយ៉ាងស្មោះ ហើយតាមរយៈការតមអាហារ និងការអធិស្ឋាន ព្រមទាំងតាមរយៈការដឹកនាំជីវិតនៃការលះបង់ និងការគោរពប្រតិបត្តិ បានរង់ចាំយ៉ាងអន្ទះសារចង់ឃើញថ្ងៃនៃការយាងមករបស់ព្រះរាជបុត្រានៃព្រះ ។

តាមរយៈភាពស្មោះត្រង់ ភាពរាបសា និងសេចក្តីជំនឿ ពួកគេបានទន្ទឹងរង់ចាំដោយអត់ធ្មត់ចំពោះការយាងមករបស់ព្រះអង្គសង្គ្រោះ ។



ថ្ងៃនៃអំណរ និងសេចក្ដីមេត្តាករុណាបានបង្កើតដោយ សារ៉ា អ៊ែដវូបស៍ ម៉ាហ្គិន ទទួលបានសិទ្ធិអនុញ្ញាតដោយក្ដីករុណាពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ ។

នៅទីបំផុត ភាពស្មោះត្រង់របស់ពួកគេបានទទួលនូវរង្វាន់ កាលម៉ារា និងយ៉ូសែបបានបង្ហាញដល់ពួកគេនូវព្រះឱរសដែលនៅថ្ងៃមួយនឹងលើកដាក់មកលើអង្គទ្រង់នូវអំពើបាបនៃមនុស្សលោក ។[៥]

## ពួកអ្នកជឿនៅក្នុងចំណោមពួកសាសន៍នីហ្វៃ និងសាសន៍លេមិន

ដំណើររឿងដ៏រំជួលចិត្តស្ដីអំពីរបៀបដែលពួកអ្នកជឿនៅក្នុងទ្វីបអាមេរិក បានទន្ទឹងរង់ចាំទីសម្គាល់នៃការប្រសូតរបស់ព្រះអង្គសង្គ្រោះដែលមាននៅក្នុងព្រះគម្ពីរមរមន ។

បងប្អូននៅចាំថា អស់អ្នកដែលមានសេចក្ដីជំនឿលើព្រះគ្រីស្ទត្រូវបានគេសើចចំអក ហើយបៀតបៀន ។ ពួកអ្នកចេះដឹងនៅសម័យនោះបានចោទប្រកាន់ពួកអ្នកជឿថា ជឿទៅលើរឿងអបិយជំនឿដ៏ល្ងង់ខ្លៅ ។ ពិតណាស់ ពួកអ្នកមិនជឿបានបង្កើនសំឡេងសើចចំអករបស់ពួកគេរហូតដល់ពួកគេបានបង្កើត « ចលាចលយ៉ាងធំ » មួយនៅក្នុងដែនដីនោះ ( នីហ្វៃទី ៣ ១:៧ ) ។ ពួកគេបានមើលងាយដល់អស់អ្នកដែលបានជឿថា ព្រះអង្គសង្គ្រោះនឹងប្រសូតមក ។

កំហឹង និងអំពើឃោរឃៅរបស់ពួកគេបានកើនឡើងយ៉ាងខ្លាំងរហូតដល់ពួកគេកាន់តែងងឹតងងល់ទៅបំបិទមាត់អស់អ្នកដែលជឿលើព្រះអង្គសង្គ្រោះ ។

**ការបង្រៀនចេញពីសារលិខិតនេះ**

តើយើងអាចស្វែងរកព្រះគ្រីស្ទឲ្យកាន់តែប្រសើរ ដូចជាអ្វីដែលប្រធាន អុជដូហ្វ បានណែនាំតាមរបៀបណា ? អ្នកអាចលើទឹកចិត្តសមាជិកដែលអ្នកបង្រៀនឲ្យសួរខ្លួនឯងថា « តើខ្ញុំនឹងស្វែងរកព្រះគ្រីស្ទតាមរបៀបណា ? » សូមពិចារណាធ្វើការអញ្ជើញពួកគេឲ្យចាប់ផ្ដើមចែកចាយរបៀប ដែលពួកគេម្នាក់ៗនឹងស្វែងរកព្រះគ្រីស្ទ នៅអំឡុងការសិក្សាព្រះគម្ពីរប្រចាំថ្ងៃជាគ្រួសាររបស់ពួកគេ ។ អ្នកក៏អាចមើលនៅលើគេហទំព័រ Mormon.org ផងដែរនូវវីដេអូបុណ្យគ្រីស្ទម៉ាស់ជាមួយនឹងសមាជិកដែលអ្នកបង្រៀន ហើយអញ្ជើញពួកគេឲ្យចូលរួមនៅក្នុងឱកាសរៀងរាល់ឆ្នាំនេះដើម្បីស្វែងរកព្រះគ្រីស្ទតាមរយៈការធ្វើតាមការបង្រៀនរបស់ទ្រង់ ។



ព្រះគម្ពីរមរមនកត់ត្រាដំណោះស្រាយដ៏រន្ធត់ចិត្តនោះ ។[៦]

ពួកអ្នកជឿដែលបានរស់នៅគ្រានេះអាចតំណាងឲ្យអស់អ្នកដែលស្វែងរកព្រះគ្រីស្ទ សូម្បីតែអ្នកផ្សេងសើចចំអកឡកឡឺយឲ្យក្ដី ។ ពួកគេស្វែងរកព្រះគ្រីស្ទ សូម្បីតែពេលមនុស្សដទៃព្យាយាមនិយាយបំផ្លើសដល់ពួកគេថាជាមនុស្សមិនបរិសុទ្ធ ខ្វះសុជីវធម៌ ឬងាយជឿ ។

ប៉ុន្តែការមើលងាយរបស់អ្នកដទៃពុំបានធ្វើឲ្យពួកអ្នកជឿពិតបាក់ទឹកចិត្តឈប់ស្វែងរកព្រះគ្រីស្ទឡើយ ។

**យើងស្វែងរកព្រះគ្រីស្ទ**

នៅក្នុងឆ្នាំនេះ ហើយពិសេសនៅរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ វានឹងផ្ដល់ប្រយោជន៍ដល់យើងឲ្យសួរសំណួរនេះម្ដងទៀតថា « តើខ្ញុំនឹងស្វែងរកព្រះគ្រីស្ទតាមរបៀបណា ? »

អំឡុងគ្រាដ៏លំបាកមួយនៃជីវិតរបស់ទ្រង់ ស្ដេចដាវីឌដ៏អស្ចារ្យបានសរសេរថា « ឱព្រះអង្គអើយ ទ្រង់ជាព្រះនៃទូលបង្គំ ទូលបង្គំនឹងស្វែងរកទ្រង់អស់ពីចិត្ត ព្រលឹងទូលបង្គំស្រេករកទ្រង់ រូបសាច់ទូលបង្គំរឭកចង់បានទ្រង់ » ។[៧]

ប្រហែលជាឥរិយាបថនៃការស្វែងរកព្រះនេះ គឺជាហេតុផលមួយដែលដាវីឌត្រូវបានពិពណ៌នាថាជាបុរសដែលជាទីគាប់ព្រះទ័យរបស់ព្រះ ។[៨]

អំឡុងរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ និងពេញមួយឆ្នាំ សូមឲ្យយើងស្វែងរកព្រះអង្គសង្គ្រោះជាទីស្រឡាញ់របស់យើង ជាព្រះនៃមេត្រីភាព ជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែលឲ្យអស់ពីដួងចិត្ត និងព្រលឹងរបស់យើង ។ ភាគច្រើនចំពោះបំណងប្រាថ្នានេះពុំត្រឹមតែបង្ហាញថា តើយើងជានរណាក្នុងនាមជាសមាជិកសាសនាចក្រនៃពួកបរិសុទ្ធថ្ងៃចុងក្រោយប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះទៀតវាកំណត់អំពីអត្តសញ្ញាណពិតរបស់យើងក្នុងនាមជាពួកសិស្សរបស់ព្រះគ្រីស្ទ ។ ■

**កំណត់ចំណាំ**

១. លូកា ២:៨ ។
២. សូមមើល លូកា ២:១៥ ។
៣. សូមមើល ម៉ាថាយ ២:១–២ ។
៤. សូមមើល ម៉ាថាយ ២:១១ ។
៥. សូមមើល លូកា ២:២២–៣៨ ។
៦. សូមមើលនីហ្វៃទី៣ ១ ។
៧. ទំនុកដំកើង ៦៣:១ ។
៨. សូមមើល កិច្ចការ ១៣:២២ ។

## កុមារ

# ការរង់ចាំព្រះយេស៊ូវ

មាននុស្សជាច្រើនបានទន្ទឹងរង់ចាំឲ្យព្រះយេស៊ូវបានប្រសូតមក ។ ឥឡូវនេះ យើងទន្ទឹងរង់ចាំឲ្យទ្រង់យាងមកម្ដងទៀត ! យើងអាចត្រៀមខ្លួនជាស្រេចតាមរយៈការរៀនអំពីព្រះយេស៊ូវ ហើយធ្វើតាមទ្រង់ ។ តើប្អូនៗធ្វើតាមព្រះយេស៊ូវតាមរបៀបណា ? សូមសរសេរគំនិតរបស់ប្អូនៗនៅលើផ្កាយទាំងនេះ ។



ប្រសូតកម្មជាមួយនឹងពួកគង្វាល និងពួកហោរាដោយ ហ្វីលិស ឡាធ

សារលិខិតបង្រៀនសួរសុខទុក្ខ

# យល់ព្រមទទួលបន្ទុកគ្នាទៅវិញទៅមក

*សូមសិក្សាអត្ថបទនេះប្រកបដោយការអធិស្ឋាន និងស្វែងរកការបំផុសគំនិត ដើម្បីដឹងអំពីអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងអំពីគោលបំណងនៃសមាគមសង្គ្រោះនឹងរៀបចំបុត្រីទាំងឡាយរបស់ព្រះសម្រាប់ពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ចបានយ៉ាងដូចម្ដេច ?*



សេចក្ដីជំនឿ
ក្រុមគ្រួសារ
ការសង្គ្រោះ

ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា « យើងត្រូវបានហ៊ុមព័ទ្ធដោយអ្នកដែលត្រូវការការយកចិត្តទុកដាក់ ការលើកទឹកចិត្ត ការគាំទ្រ ការលួងលោម និងសណ្ដានចិត្តល្អរបស់យើង » ។ « យើងគឺជាព្រះហស្តរបស់ព្រះអម្ចាស់នៅលើផែនដីនេះ ដោយទទួលបានបញ្ជាឲ្យបម្រើ ហើយជួយដល់កូនចៅទ្រង់ ។ ទ្រង់ពឹងលើយើងម្នាក់ៗ » ។[១]

ប្រធាន ហិនរី ប៊ី អាវរិង ជាទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ថា « ការផ្លាស់ប្ដូរដ៏ធំមួយបានចាប់ផ្ដើមមានក្នុងដួងចិត្តបងប្អូន នៅពេលបងប្អូនបានចូលមកក្នុងសាសនាចក្រនេះ ។ បងប្អូនបានធ្វើសេចក្ដីសញ្ញាមួយ ហើយបងប្អូនបានទទួលការសន្យាមួយ ដែលបានចាប់ផ្ដើមផ្លាស់ប្ដូរចរិតរបស់បងប្អូន ។ . . .

« . . . បងប្អូនបានសន្យាថា នឹងជួយព្រះអម្ចាស់សម្រាលបន្ទុក [ របស់មនុស្សដទៃ ] និងទទួលបានការលួងលោមចិត្ត ។ ពេលបងប្អូនទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ បងប្អូនត្រូវបានប្រទានឲ្យនូវអំណាចដើម្បីជួយសម្រាលបន្ទុកទាំងនោះ » ។[២]

ជីន ប៊ី ប៊ីងហាំ ជាប្រធានសមាគមសង្គ្រោះទូទៅ បានមានប្រសាសន៍ថា « យើងចង់ប្រើពន្លឺនៃដំណឹងល្អដើម្បីមើលឃើញអ្នកដទៃដូចជាព្រះអង្គសង្គ្រោះទ្រង់ទតឃើញពួកគេ — ដោយក្ដីអាណិតអាសូរ ក្ដីសង្ឃឹម និងក្ដីសប្បុរស ។ « ថ្ងៃនោះនឹងមកដល់ ពេលយើងនឹងមានការយល់ទាំងស្រុងដល់ចិត្តអ្នកដទៃ ហើយយើងនឹងមានអំណរគុណចំពោះសេចក្ដីមេត្តាដែលបានបង្ហាញដល់យើង — គឺដូចជាយើងផ្ដល់គំនិត និងពាក្យសម្ដីដោយសេចក្ដីសប្បុរសទៅកាន់អ្នកដទៃ ។ . . .

« កាតព្វកិច្ច និង ឯកសិទ្ធិរបស់យើងគឺត្រូវទទួលយកការរីកចម្រើននៅក្នុងខ្លួន *មនុស្សគ្រប់រូប* ពេលយើងព្យាយាមក្លាយឲ្យកាន់តែដូចជាព្រះអង្គសង្គ្រោះរបស់យើង » ។[៣]

ពេលយើងរែកបន្ទុកគ្នាទៅវិញទៅមក ហើយរក្សាសេចក្ដីសញ្ញារបស់យើង នោះយើងកាន់តែស្គាល់នូវព្រះចេស្ដាព្យាបាលរបស់ព្រះយេស៊ូវគ្រីស្ទ ។ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « ពេលពិចារណាអំពីតម្លៃដែលមិនអាចកាត់ថ្លៃបាននៃការឆ្កាង និងដង្វាយធួន នោះខ្ញុំសន្យាដល់បងប្អូនថា ទ្រង់នឹងពុំបោះបង់យើងចោលនៅពេលនេះឡើយ ។ ពេលទ្រង់មានបន្ទូលទៅកាន់អ្នកកម្សត់ខាងវិញ្ញាណថា ‹ ចូរមកឯខ្ញុំ › នោះទ្រង់មានន័យថា ទ្រង់ស្គាល់ផ្លូវចេញ ហើយទ្រង់ស្គាល់ផ្លូវដែលត្រូវឡើង ។ ទ្រង់ស្គាល់វា ដោយសារទ្រង់បានដើរលើផ្លូវនោះហើយ ។ ទ្រង់ស្គាល់ផ្លូវនោះ ដោយសារទ្រង់គឺជា*ផ្លូវ* » ។[៤]

**បទគម្ពីរបន្ថែម**
ម៉ាថាយ ២៥:៤០, កាឡាទី ៦:២,
ម៉ូសាយ ២:១៧, ១៨:៨–៩
reliefsociety.lds.org

កំណត់ចំណាំ
១. ថូម៉ាស អេស ម៉នសុន « Serve the Lord with Love » *Liahona,* ខែកុម្ភៈ ឆ្នាំ ២០១៤ ទំព័រ ៤ ។
២. ហិនរី ប៊ី អាវរីង « The Comforter » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១៨ ។
៣. ជេន ប៊ី ប៊ីងហាំ « I Will Bring the Light of the Gospel into My Home » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ ៦, ៨ ។
៤. ជែហ្វ្រី អ័រ ហូឡិន « Broken Things to Mend » *Liahona,* ខែ ឧសភា ឆ្នាំ ២០០៦ ទំព័រ ៧១ ។

សូមពិចារណាអំពីសំណួរនេះ

តើការជួយរែកបន្ទុកមនុស្សដទៃ និងការរក្សាសេចក្ដីសញ្ញារបស់យើងបើកផ្លូវថ្វាយព្រះយេស៊ូវគ្រីស្ទដើម្បីព្យាបាលដល់ជនដែលខ្វះខាតយ៉ាងដូចម្ដេច ?

# ការលើកកម្ពស់ ដល់ការពិភាក្សា

*តើយើងអាចជួយកូនចៅរបស់យើងឲ្យក្លាយជាអ្នករៀនសូត្រកាន់តែសកម្មបានយ៉ាងដូចម្ដេច ?*

ដោយ ដ័ហ្គ ហាត

កាលពីពេលកន្លងទៅ ភរិយារបស់ខ្ញុំ និងខ្ញុំបានខ្វល់ខ្វាយអំពីរបៀបនៃការអភិវឌ្ឍឥរិយាបថមួយនៅក្នុងខ្លួនកូនៗពេញជំទង់មួយចំនួនរបស់យើង អំឡុងការសិក្សាព្រះគម្ពីរជាគ្រួសារ រាត្រីជួបជុំក្រុមគ្រួសារ ព្រមទាំងនៅក្នុងការសន្ទនាមួយទល់នឹងមួយអំពីដំណឹងល្អដែលឥតបម្រុងទុករបស់យើងផងដែរ ។ ពួកគេមានលក្ខណៈសម្បត្តិត្រូវតាមបទដ្ឋានរៀនសូត្រដ៏តូចបំផុត — រួមមានវត្តមាន ការផ្ដោតអារម្មណ៍ម្ដងម្កាល និងចម្លើយប្រើពាក្យតែមួយម៉ាត់ — ប៉ុន្តែពួកគេពុំបានប្រឡូកយ៉ាងសកម្មនៅក្នុងការរៀនសូត្រឡើយ ។

យើងបានដឹងថា ដើម្បីឲ្យពួកគេទទួលបានទីបន្ទាល់ដ៏រឹងមាំ ហើយមានបទពិសោធន៍ពីការប្រែចិត្តជឿដ៏សីជម្រៅផ្ទាល់ខ្លួនមួយ តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះពួកគេត្រូវធ្វើរឿងច្រើនទៀត ។ ព្រះអង្គសង្គ្រោះសព្វព្រះទ័យឲ្យពួកសិស្សរបស់ទ្រង់ពុំគ្រាន់តែស្ដាប់បន្ទូលរបស់ទ្រង់ប៉ុណ្ណោះទេ — ទ្រង់សព្វព្រះទ័យឲ្យពួកគេធ្វើតាមការបង្រៀនរបស់ទ្រង់ដោយសេចក្ដីជំនឿផងដែរ ( សូមមើល *ការបង្រៀនតាមរបៀបរបស់ព្រះអម្ចាស់* [ ឆ្នាំ ២០១៦ ] ទំព័រ ៣០ ) ។

មានយប់មួយ យើងបាននិយាយនឹងពួកគេអំពីអារម្មណ៍របស់យើង ។ គោលបំណងរបស់យើងគឺដើម្បីប្រឹក្សានឹងពួកគេនៅក្នុងការពិភាក្សាមួយដែលដឹកនាំដោយព្រះវិញ្ញាណ ។ ប៉ុន្តែរំពេចនោះ ការពិភាក្សារបស់យើងក្លាយទៅជាការនិទានឃោសនាតែឯកឯងវិញ ។ ពួកកូនប្រុសរបស់យើងបានឮសាររបស់យើង ប៉ុន្តែវាពុំបានប៉ះពាល់ដល់គំនិត និងដួងចិត្តរបស់ពួកគេឡើយ ។

បទពិសោធន៍នោះបានធ្វើឲ្យយើងខ្វល់ខ្វាយ ដូច្នេះភរិយារបស់ខ្ញុំ និងខ្ញុំបានចាប់ផ្ដើមពិចារណាអំពីរបៀបដែលយើងអាចជួយកូនរបស់យើងឲ្យកាន់តែសកម្មក្នុងការរៀនសូត្រដំណឹងល្អ ដោយបំផុសពួកគេឲ្យធ្វើសកម្មភាពជំនួសឲ្យការរង់ចាំយើងនិយាយ និងបង្រៀន ។ សំណួររបស់យើងបានដឹកនាំយើងទៅរកការបង្កើតផែនការមួយ ដោយផ្អែកលើអ្វីដែលយើងបានរៀនមកពីការសិក្សាបទគម្ពីរ ប្រសាសន៍របស់ពួកព្យាការីថ្ងៃចុងក្រោយ និងធនធានផ្សេងទៀតរបស់សាសនាចក្រដែលទាក់ទងនឹងការបង្រៀន និងការរៀនសូត្រ ។ ផែនការរបស់យើងចែងថា

**ការដឹកនាំកូនចៅរបស់យើងឲ្យស្វែងរកព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការពិភាក្សាជាគ្រួសារ**

*បណ្ដុះសេចក្ដីស្រឡាញ់ និង ការគោរព* ។ សេចក្ដីស្រឡាញ់បន្ទន់ដួងចិត្ត ។ ការបង្ហាញសេចក្ដីស្រឡាញ់នឹងជួយរៀបចំកូនៗរបស់យើងសម្រាប់ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ វាក៏នឹងបំពាក់បំប៉នបំណងប្រាថ្នា និងឆន្ទៈរបស់ពួកគេដើម្បីចូលរួមក្នុងការរៀនសូត្រខាងវិញ្ញាណយ៉ាងសកម្មផងដែរ ។ ការគោរពដល់កូនៗរបស់យើងដោយការស្ដាប់ និងគោរពទស្សនៈ និងអារម្មណ៍របស់ពួកគេនឹងជួយពួកគេឲ្យមានអារម្មណ៍សុវត្ថិភាព ហើយកាន់តែយល់ព្រមដើម្បីចែកចាយអារម្មណ៍ដែលពួកគេមាន ។

*បង្រៀនដោយព្រះវិញ្ញាណ* ។ ការសង្កេតមើល និងស្ដាប់ដោយប្រុងប្រយ័ត្នដល់កូនៗរបស់យើងនឹងរៀបចំយើងឲ្យចេះអាកាត់តាមរយៈព្រះវិញ្ញាណនូវពាក្យសម្ដីដែលត្រូវនិយាយបន្ទាប់ទៀត សំណួរដែលត្រូវសួរ ឬការអញ្ជើញត្រូវធ្វើដែលនឹងដឹកនាំពួកគេឲ្យស្វែងរកព្រះចេស្ដានៃព្រះវិញ្ញាណនៅក្នុងការរៀនសូត្ររបស់ពួកគេ ។

# នៅក្នុងគ្រួសារ របស់យើង

*ពង្រឹងរាល់ការពិភាក្សានៅក្នុងបន្ទូលរបស់ព្រះ* ។ កាលការចែកចាយគំនិត និងទស្សនៈផ្ទាល់ខ្លួនរបស់យើងអំពីដំណឹងល្អរួមគ្នាអាចជួយ ជារឿយៗ បទគម្ពីរ និងប្រសាសន៍របស់ពួកព្យាការីនៃពួកបរិសុទ្ធថ្ងៃចុងក្រោយនឹងផ្ដល់នូវការតភ្ជាប់ទៅនឹងព្រះវិញ្ញាណឲ្យកាន់តែមានឥទ្ធិពល ហើយស៊ីជម្រៅ ( សូមមើល គ. និង ស. ៨៤:៨៥ ) ។

*ធ្វើឲ្យព្រះអង្គសង្គ្រោះក្លាយជាមូលដ្ឋានគ្រឹះនៃការពិភាក្សាអំពីដំណឹងល្អ* ។ ខ្លឹមសារ និងអនុភាពនឹងកើតមានដល់ការពិភាក្សារបស់យើង ពេលកូនចៅរបស់យើងមើលឃើញនូវអ្វីដែលយើងកំពុងពិភាក្សានោះទាក់ទងនឹងព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់ដែលជា « ឫសគល់នៃគោលលទ្ធិជាគ្រិស្តសាសនិក » ( ប៊យដ៍ ឃេ ផាកកឺ « The Mediator » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៧៧ ទំព័រ ៥៦ ) ។

*សួរសំណួរបំផុសគំនិតទាំងឡាយ* ។ សំណួរដែលមានប្រសិទ្ធភាពនឹងដឹកនាំកូនចៅរបស់យើងឆ្ពោះទៅកាន់សេចក្ដីពិត ហើយយល់ដោយផ្ទាល់មកពីបទគម្ពីរ និងប្រសាសន៍របស់ពួកព្យាការីដោយមានជំនួយពីព្រះវិញ្ញាណ ។ អ្វីដែលពួកគេរៀនតាមរបៀបនោះនឹងមានន័យច្រើនចំពោះពួកគេជាងការពន្យល់ដ៏ច្បាស់បំផុតរបស់យើងស្ដីពីឯកសារដូចគ្នានោះទៅទៀត ។

*លើកទឹកចិត្តសមាជិកគ្រួសារឲ្យនិយាយ* ។ ពេលកូនចៅរបស់យើងប្រើពាក្យសម្ដីរបស់ពួកគេផ្ទាល់ដើម្បីបង្ហាញនូវអ្វីដែលពួកគេកំពុងមើលឃើញ គិត ឬ មានអារម្មណ៍ នោះពួកគេអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យជួយពួកគេដឹងអំពីអ្វីដែលត្រូវនិយាយ និងរបៀបដើម្បីប្រើវា ។ ដំណើរការនោះ នឹងជួយពួកគេឲ្យមើលឃើញ ហើយយល់កាន់តែច្បាស់អំពីអ្វីដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យពួកគេរៀនសូត្រ ហើយទទួលអារម្មណ៍ ។

*ចូរអត់ធ្មត់* ! ព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើការជាមួយនឹងកូនចៅរបស់យើង ពេលពួកគេស្វែងយល់ពីសេចក្ដីពិតនៅក្នុងគំនិត និងដួងចិត្តរបស់ពួកគេ ។ យើងត្រូវតែទប់នឹងការល្បួងដើម្បីបង្អាក់ដល់ការស្វែងរករបស់ពួកគេ ដោយការចូលទៅបង្អាក់ភ្លាមជាមួយនឹងទស្សនៈផ្ទាល់ខ្លួន និងដំណោះស្រាយដោយខ្លួនឯង ។

*ដឹកនាំដោយគំរូ* ។ ការខិតខំរៀនសូត្រ ហើយរស់នៅតាមដំណឹងល្អតាមរបៀបដូចគ្នាដែលយើងសុំឲ្យកូនចៅរបស់យើងធ្វើនឹងជួយយើងឲ្យមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានការគាំទ្រ និងការដឹកនាំពីព្រះវិញ្ញាណនៅក្នុងការពិភាក្សារបស់យើង ។

ពេលយើងបានព្យាយាមអនុវត្តផែនការរបស់យើង យើងកំពុងរៀនថា ការអញ្ជើញព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធឲ្យចូលមកក្នុងការពិភាក្សាជាគ្រួសាររបស់យើងនឹងត្រូវការការហ្វឹកហាត់ និងពេលវេលា ។ ប៉ុន្តែ យើងពុំបាក់ទឹកចិត្ត ឬបោះបង់ចោលឡើយ ។ ដូចជាកាលពីយប់មុន កូនស្រីរបស់យើងអាយុ ១០ ឆ្នាំ បានបំផុសគំនិតដោយបទគម្ពីរមួយនៅក្នុងព្រះគម្ពីរមរមនដែលយើងបានអានជាគ្រួសារ បានសួរសំណួរដោយភាពស្មោះត្រង់ផ្អែមល្ហែមថា « តើប៉ាម៉ាក់រៀនដោយព្រះវិញ្ញាណបរិសុទ្ធតាមរបៀបណា ? » ខ្ញុំបានញញឹម ។ ខ្ញុំបានដឹងថា យើងកំពុងមកដល់ផ្លូវផ្សេងហើយ ! ■

*សព្វថ្ងៃនេះ អ្នកនិពន្ធកំពុងបម្រើជាប្រធានបេសកកម្មនៅកីរីទីបា ប្រទេសប្រេស៊ីល* ។

សៀវភៅណែនាំការបង្រៀនថ្មី *ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ* មានដាក់បញ្ចូលនូវយោបល់សម្រាប់ការបង្រៀនដល់ក្មេងជំទង់ និងកុមារតូចៗផងដែរ ។ សូមមើល **teaching.lds.org** ។





**ដោយអែលឌើរ**
**រ៉ូណល អេ រ៉ាសបាន**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# សរសើរដល់ព្រះដ៏ខ្ពស់បំផុត

*ពេលណាយើងធ្វើការរួមនឹងព្រះអម្ចាស់ — ធ្វើអ្វីដែលទ្រង់បញ្ជា ហើយបំផុសគំនិតដល់មនុស្សជុំវិញយើង — យើងកំពុងធ្វើជាសាក្សីថា ទ្រង់មានព្រះជន្មរស់ ហើយថាទ្រង់ស្រឡាញ់យើង ។*

ប្រាំពីររយឆ្នាំមុនការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទនៅភូមិបេថ្លេហិម ក្នុងស្រុកយូដា នោះព្យាការីអេសាយបានប្រកាសថា « មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រាមួយ ហើយនឹងឲ្យព្រះនាមថា អេម៉ាញូអែល » ( អេសាយ ៧:១៤ ) ។

នៅ ១២៥ ឆ្នាំមុនការប្រសូតរបស់ព្រះអង្គសង្គ្រោះ នោះស្ដេចបេនយ៉ាមីនបានព្យាករថា « ទ្រង់នឹងត្រូវបានហៅថា ព្រះយេស៊ូវគ្រីស្ទ ព្រះរាជបុត្រានៃព្រះ ព្រះវរបិតានៃស្ថានសួគ៌ និងផែនដី ព្រះដែលបង្កើតវត្ថុសព្វសារពើចាប់តាំងពីដំបូងមក ហើយមាតារបស់ព្រះអង្គនឹងត្រូវបានហៅថា ម៉ារា » ( ម៉ូសាយ ៣:៨ ) ។

នៅមួយថ្ងៃមុនការប្រសូតរបស់ព្រះឱរសយេស៊ូវ នីហ្វៃ ជាកូនប្រុសរបស់នីហ្វៃ បានស្ដាប់ឮសំឡេងមួយបន្លឺឡើងថា « ថ្ងៃស្អែកឡើង យើងនឹងចុះមកឯលោកិយ » ( នីហ្វៃទី ៣ ១:១៣ ) ។

លុះស្អែកឡើង នៅជ្រុងម្ខាងទៀតនៃពិភពលោក ព្រះគ្រីស្ទបានប្រសូត ។ វាច្បាស់ណាស់ថា មាតាទ្រង់ ម៉ារា បានសម្លឹងមើលទៅបុត្រខ្លួនដែលទើបប្រសូត ដែលជាបុត្រាបង្កើតតែមួយគត់របស់ព្រះវរបិតាខាងសាច់ឈាម ដោយសេចក្ដីអស្ចារ្យ ។

នៅលើភ្នំយូដាជុំវិញភូមិបេថ្លេហិម លូកាប្រាប់យើងថា ពួកអ្នកគង្វាលបាននៅទីវាល ( សូមមើលលូកា ២:៨ ) ។ ពួកអ្នកគង្វាលទាំងនេះគឺជា « មនុស្សសុចរិត ហើយបរិសុទ្ធ » ( សូមមើលអាលម៉ា ១៣:២៦ ) ដែលបានធ្វើជាសាក្សីដល់ព្រះគ្រីស្ទ ។

« នោះមើល មានទេវតានៃព្រះអម្ចាស់មកឈរជិតគេ ឯសិរីល្អរបស់ទ្រង់ក៏ភ្លឺឆ្វាត់ជុំវិញ ហើយគេមានសេចក្ដីភ័យខ្លាចជាខ្លាំង ។

« តែទេវតាប្រាប់ថា កុំខ្លាចអី មើល ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្ដីអំណរយ៉ាងអស្ចារ្យ ដែលសម្រាប់បណ្ដាជនទាំងអស់គ្នា ។

« ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ ១ អង្គប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌគឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ ។ . . .

ព្រះប្រសូតិកុមារ ដោយ អ៊ិន ស៊ី អេ



« នោះស្រាប់តែមានពួកពលបរិវារកកកុញស្ថានសួគ៌មកនៅជាមួយនឹងទេវតានោះ ក៏ពោលសរសើរដល់ព្រះថា

« សួស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្ដីសុខសាន្តនៅផែនដី នៅកណ្ដាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់ » ( លូកា ២:៩–១១, ១៣–១៤ ) ។

សូមស្រមៃគិតអំពីទិដ្ឋភាពនៅក្នុងស្រុកយូដា — ផ្ទៃមេឃដ៏ភ្លឺចែងចាំងដោយពន្លឺនៃផ្កាយមួយដ៏ភ្លឺត្រចះត្រចង់ ហើយក្រុមចម្រៀងពីស្ថានសួគ៌បានអបអរដល់ព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ ។ រួចពួកអ្នកគង្វាលបានទៅ« ជាប្រញាប់ » ( លូកា ២:១៦ ) ដើម្បីមើលព្រះឱរសផ្ទែកនៅក្នុងស្នូក ។ ក្រោយមក ពួកគេ « បានរ៉ាយរ៉ាប់ » ( លូកា ២:១៧ ) អំពីអ្វីដែលគេបានឃើញ ។

នៅបុណ្យគ្រីស្ទម៉ាស់រៀងរាល់ឆ្នាំ យើងធ្វើជាសាក្សីបន្ថែមទៀតថា ព្រះយេស៊ូវគ្រីស្ទ ជាបុត្រាពិតប្រាកដនៃព្រះដ៏មានព្រះជន្មរស់ ទ្រង់បានយាងមកកាន់ផ្នែកមួយនៃផែនដី ដែលយើងហៅថា ដែនដីបរិសុទ្ធ ។

ពួកអ្នកគង្វាលបានដើរចូលទៅដោយគារវភាព ដើម្បីថ្វាយបង្គំដល់ស្ដេចនៃអស់ទាំងស្ដេច ។ តើយើងនឹងថ្វាយបង្គំទ្រង់បែបណាដែរក្នុងរដូវកាលនេះ ? ជាពេលដើរទិញទំនិញរបស់មិនចេះចប់នោះមែនទេ ? តើយើងនឹងថ្វាយបង្គំទ្រង់តាមរយៈការប្រញាប់ប្រញាល់តុបតែងផ្ទះរបស់យើង និងខ្ចប់អំណោយរបស់យើងមែនទេ ? តើហ្នឹងជារបៀបដែលយើងថ្វាយបង្គំទ្រង់ឬ ? ឬថា យើងនឹងនាំយកសន្តិភាពមកកាន់ដួងចិត្តដែលសោកសៅ ធ្វើល្អដល់ជនដែលត្រូវការព្រះចេស្ដាទ្រង់ សរសើរដល់ព្រះដោយព្រមធ្វើអ្វីដែលទ្រង់សុំឲ្យយើងធ្វើវិញ ?

ព្រះយេស៊ូវបានបន្ទូលដោយសាមញ្ញថា « ចូរមកតាមខ្ញុំចុះ » ( លូកា ១៨:២២ ) ។

ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលស្ដារឡើងវិញតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ បានជះឥទ្ធិពលដល់ពួកអ្នកជឿជុំវិញពិភពលោក ។ ខ្ញុំបានឃើញផ្ទាល់ភ្នែកនូវការលះបង់នៃជនដែលបានទទួលយកបន្ទូលដ៏ពិសិដ្ឋរបស់ទ្រង់ ចាប់តាំងពីកោះទាំងឡាយរហូតដល់ប្រជាជាតិដ៏ធំក្នុងប្រទេសរុស្ស៊ី ។

## សារលិខិតនៃបុណ្យគ្រីស្ទម៉ាស់

នៅក្នុងចំណោមពួកបរិសុទ្ធកាលពីដើមដែលបានប្រមូលផ្ដុំគ្នាទៅទីក្រុងស៊ីយ៉ូន គឺមានស្ត្រីម្នាក់ឈ្មោះហាន់ណា ឡាស ខ័រណាបាយ ដែលបានតាំងលំនៅក្នុងក្រុងស្ពេនីស ហ្វ៊ក រដ្ឋយូថាហ៍ ស.រ.អា. ។ នៅគ្រាដ៏លំបាកនៃការចាប់ផ្ដើមសាសនាចក្រដែលបានស្ដារឡើងវិញនោះ ពេលខ្លះបុណ្យគ្រីស្ទម៉ាស់គឺមានតែផ្លែក្រូច ឬតុក្កតាធ្វើពីឈើ ឬជាកូនក្រមុំធ្វើពីក្រណាត់ — តែពុំមែនជានិច្ចកាលនោះទេ ។ ហាន់ណាបានសរសេរពីថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៨៥៦ ថា

« យប់មុនបុណ្យគ្រីស្ទម៉ាស់បានចូលមកដល់ តាមជំនឿរបស់ក្មេងតូចៗ កូនៗខ្ញុំបានព្យួរស្រោមជើងវែងរបស់ពួកគេដោយជំនឿ ទាំងងឿងឆ្ងល់ថាតើ [ វា ] នឹង [ មាន ] របស់នៅក្នុងនោះដែរទេ ។ ខ្ញុំបានប្រាប់គេថា គេនឹងបានអ្វីដែលគេចង់បានដោយខំលាក់បាំងនូវភាពសោកសៅដែលខ្ញុំមានក្នុងចិត្ត ហើយគេបានដេកលក់ដោយការទន្ទឹងរង់ចាំនៅថ្ងៃស្អែកដោយភាពរីករាយ ។

« ដោយគ្មានចំណីចំណុកមានជាតិស្ករ ខ្ញុំមិនដឹងថា ខ្ញុំត្រូវធ្វើអ្វីនោះទេ ។ ប៉ុន្តែគេមិនត្រូវទទួលការខកចិត្តឡើយ ។ រួចខ្ញុំបានគិតអំពីផ្លែឃ្លោកមួយចំនួននៅក្នុងផ្ទះដោយខ្ញុំបានស្ងោរ រួចចម្រាញ់ទឹកចេញ រំងាស់ទុកពីរបីម៉ោង វានឹងក្លាយជាទឹកស្ករ ។ ដោយមានទឹកស្កនេះ និងគ្រឿងទេសតិចតួច ខ្ញុំបានធ្វើជាម្សៅនំប៉័ង ដោយកាត់វាជារាងផ្សេងៗ ហើយដុតវាលើខ្ទះ ( ខ្ញុំគ្មានជើងក្រានដុតនំទេ ) រួចខ្ញុំដាក់នំទាំងនោះពេញស្រោមជើងវែងរបស់ពួកគេ ជានំដែលបានធ្វើឲ្យពួកគេរីករាយ » ។[1]

អត្ថន័យពិតនៃរឿងនេះ គឺជារឿងដំណាលអំពីម្ដាយម្នាក់ដែលបានធ្វើការពេញមួយយប់ទាំងគ្មានជើងក្រានទៀតផង ។ ប៉ុន្តែគាត់បានតាំងចិត្តធ្វើឲ្យកូនៗរបស់គាត់រីករាយ ដើម្បីពង្រឹងជំនឿរបស់ពួកគេ ដើម្បីបញ្ជាក់ថា ក្នុងផ្ទះរបស់ពួកគេ « មានភាពរីករាយ ! និងក្ដីសុខ ! »[2] តើរឿងនោះពុំមែនជាសារលិខិតនៃបុណ្យគ្រីស្ទម៉ាស់ទេឬអី ?

ប្រធាន ថូម៉ាស អេស ម៉នសុន បានបង្រៀនថា « ឱកាសនានារបស់យើងដើម្បីលះបង់ខ្លួនគឺគ្មានទីបញ្ចប់ឡើយ ប៉ុន្តែក៏ពុំមានជានិច្ចដែរ ។ យើងគួរជួយអ្នកដទៃឲ្យមានអារម្មណ៍រីករាយ ។ មានពាក្យសម្ដីល្អៗជាច្រើនដើម្បីនិយាយ ។ មានអំណោយជាច្រើនដើម្បីផ្ដល់ » ។[3]

ពេលណាយើងធ្វើការរួមនឹងព្រះអម្ចាស់ — ធ្វើអ្វីដែលទ្រង់បញ្ជា ហើយលើកស្ទួយដល់មនុស្សជុំវិញយើង — យើងកំពុងធ្វើជាសាក្សីថា ទ្រង់មានព្រះជន្មរស់ ហើយថាទ្រង់ស្រឡាញ់យើង មិនថាយើងមានការលំបាកបែបណានៅក្នុងជីវិតនេះទេ ។

បន្ទាប់ពីអ្នកប្រែចិត្តជឿជនជាតិស្កុតឡង់ឈ្មោះ ចន មេនហ្ស៊ីស ម៉ាកហ្វាឡែន បានចូលក្នុងសាសនាចក្រជាមួយនឹងម្ដាយជាស្ត្រីមេម៉ាយ និងប្អូនប្រុសរបស់ខ្លួន នោះពួកគេទាំងបីនាក់បានធ្វើដំណើរទៅទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ ក្នុងឆ្នាំ ១៨៥២ ។ គាត់មានអាយុ ១៨ ឆ្នាំ ។ នៅក្នុងជីវិតគាត់ គាត់បានក្លាយជាអ្នកស្ទង់វាស់ដី អ្នកសង់អគារ ថែមទាំងជាចៅក្រមស្រុក តែមនុស្សទូទៅស្គាល់គាត់ដោយសារតន្ត្រីរបស់គាត់ ។

គាត់បានរៀបចំក្រុមចម្រៀងដំបូងរបស់គាត់នៅក្រុង សេដា រដ្ឋយូថាហ៍ ហើយនាំក្រុមចម្រៀងរបស់គាត់ទៅច្រៀងពេញភាគខាងត្បូងរដ្ឋយូថាហ៍ ។ បន្ទាប់ពីការសម្ដែងនៅសេន ចច អែលឌើរ អេរ៉ាស្ដាស់ ស្នូ ( ១៨១៨–៨៨ ) ជាសាវក និងជាអ្នកដឹកនាំជនភៀសខ្លួន បានលើកទឹកចិត្តចនឲ្យផ្លាស់ទៅ សេន ចច ហើយនាំយកគ្រួសារ និងតន្ត្រីរបស់គាត់ទៅជាមួយផង ។

ក្នុងឆ្នាំ ១៨៦៩ ជាគ្រាមួយដ៏លំបាក ហើយ អែលឌើរ ស្នូ បានសុំបងប្រុស ម៉ាកហ្វាឡែន ឲ្យសម្ដែងកម្មវិធីបុណ្យគ្រីស្ទម៉ាស់ដើម្បីជួយមនុស្សទូទៅឲ្យមានចិត្តរីករាយ ។ បងប្រុស ម៉ាកហ្វាឡែន បានចង់និពន្ធបទចម្រៀងថ្មីសម្រាប់កម្មវិធីនោះ ។ ប៉ុន្តែទោះជាគាត់ខំនិពន្ធយ៉ាងណាក្ដី ក៏គាត់នៅតែគ្មានគំនិតអ្វីសោះ ។ គាត់បានអធិស្ឋានម្ដងហើយម្ដងទៀតសូមការបំផុសគំនិត ។



គំនូរពណ៌ដោយ ដាក់ ហ្វេគឡេវ

នាយប់មួយ គាត់បានដាស់ភរិយាគាត់ ហើយស្រែកឡើងថា « បងនឹកឃើញអំពីទំនុកច្រៀងមួយហើយ ហើយបងគិតថាបងក៏នឹកឃើញអំពីទំនុកភ្លេងដែរ ! » គាត់បានប្រញាប់ប្រញាល់ទៅព្យាណូខ្យល់តូចរបស់គាត់ ហើយលេងបទនោះ ព្រមទាំងនិពន្ធនូវទំនុកច្រៀង ខណៈដែលភរិយារបស់គាត់កាន់ចង្កៀងដុតប្រេងខ្លាញ់បំភ្លឺឲ្យគាត់ ។ នេះជាទំនុកច្រៀងនៃបទចម្រៀងដែលគាត់បាននឹកឃើញ ៖

*ឆ្ងាយ ឆ្ងាយ នៅលើទីវាលទំនាបយូដា ។*
*ពួកគង្វាលចៀមច្រៀងបទដ៏ពិរោះអស្ចារ្យ*
*សរសើរដល់ព្រះ*
*សរសើរដល់ព្រះ*
*សរសើរដល់ព្រះដ៏ខ្ពស់បំផុត ។*
*សូមក្ដីសុខមានដល់មនុស្សលោក !*
*សូមក្ដីសុខមានដល់មនុស្សលោក !*[៤]

បងប្រុស ម៉ាកហ្វាឡែន មិនដែលទៅស្រុកយូដា ហើយឃើញទីវាលទំនាប ដែលស្រដៀងគ្នានឹងជាយភ្នំពាសពេញដោយថ្មឡើយ ប៉ុន្តែសារលិខិតដែលបំផុសគំនិតក្នុងចម្រៀងរបស់គាត់នោះបានផុសចេញពីដួងចិត្តរបស់គាត់ ទុកជាសាក្សីមួយអំពីការប្រសូតរបស់ព្រះគ្រីស្ទនៅភូមិបេថ្លេហិម ជាការចាប់ផ្ដើមមួយដែលបានផ្លាស់ប្ដូរពិភពលោកនេះជារៀងរហូត ។[៥]

ចន មេនហ្វីស ម៉ាកហ្វាឡែន បានថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទតាមរយៈតន្ត្រីរបស់គាត់ ហើយហាន់ណា ឡាស ខំណាបាយ បានថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទតាមរយៈការបម្រើដល់កូនៗរបស់គាត់ ។ យើងក៏ដូចគ្នាដែរ យើងអាចបម្រើព្រះអម្ចាស់ ហើយថ្លែងជាសាក្សីអំពីទ្រង់តាមរយៈទង្វើដ៏សាមញ្ញនៃសេចក្ដីសប្បុរសនានា ។ យើងក៏អាចធ្វើឲ្យមានការផ្លាស់ប្ដូរនៅក្នុងក្រុមគ្រួសារ វួដ កន្លែងធ្វើការ និងផ្នែកផ្សេងទៀតនៃការទទួលខុសត្រូវរបស់យើងផងដែរ ។

**ធ្វើឲ្យមានភាពខុសប្លែក**

របៀបដ៏សាមញ្ញមួយដែលយើងអាចធ្វើឲ្យមានការផ្លាស់ប្ដូរមួយគឺការចូលប្រឡូកនៅក្នុងយុទ្ធនាការស្ដីអំពីបុណ្យគ្រីស្ទម៉ាស់ប្រចាំឆ្នាំរបស់សាសនាចក្រនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ។ យុទ្ធនាការនោះត្រូវបានរៀបចំឡើងដើម្បីជួយដល់ពួកបរិសុទ្ធ — និងកូនចៅរបស់ព្រះទូទាំងពិភពលោក — ឲ្យផ្ដោតលើព្រះអង្គ




*បងស្រីរបស់ខ្ញុំបានធ្វើភួយសំឡីដ៏ស្រស់ស្អាតមួយ ហើយបានហៅវាថា « ព្រះនាមលើនាមទាំងអស់ » ។ ភួយនោះមានព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទចំនួន ២៦ ។*

សង្គ្រោះ ។ នៅឆ្នាំនេះ សាសនាចក្រកំពុងចាប់ផ្តើមការខិតខំជាសាកលមួយទៀត ដើម្បីសាទរចំពោះការប្រសូតរបស់ព្រះគ្រីស្ទ ហើយលើកទឹកចិត្តមនុស្សទូទៅឲ្យធ្វើតាមទ្រង់តាមរយៈការបម្រើមនុស្សដទៃនៅអំឡុងរដូវកាលបុណ្យគ្រីស្ទម៉ាស់ ។

សាសនាចក្រនឹងប្រើប្រធានបទរបស់ខ្លួនដែលទទួលបានជោគជ័យកាលពីឆ្នាំមុនគឺ ៖ « ពន្លឺលោកីយ៍ » ( សូមមើល Mormon.org ) ។ ប្រធានបទនេះដកស្រង់ចេញពី យ៉ូហាន ៨:១២ ដែលចែងថា « ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅគេម្តងទៀតថា ខ្ញុំជាពន្លឺលោកីយ៍ អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្តីងងឹតឡើយ គឺនឹងមានពន្លឺនៃជីវិតវិញ » ។

យុទ្ធនាការនេះរួមមានប្រតិទិនមួយ និងបទគម្ពីរដែលទាក់ទងដែលផ្តល់ជាគំនិតសម្រាប់មនុស្សទូទៅដើម្បីបម្រើ ហើយចែកចាយពន្លឺនៃបុណ្យគ្រីស្ទម៉ាស់ ។

ប្រធាន ម៉នសុន បានមានប្រសាសន៍ថា « យើងម្នាក់ៗមកកាន់ផែនដីនេះ ដោយត្រូវបានផ្តល់ឲ្យនូវពន្លឺព្រះគ្រីស្ទ ។ « នៅពេលយើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ហើយរស់នៅដូចដែលទ្រង់បានធ្វើ និងដូចដែលទ្រង់បានបង្រៀន ពន្លឺនោះនឹងបំភ្លឺក្នុងខ្លួនយើង ហើយនឹងបំភ្លឺផ្លូវរបស់មនុស្សដទៃទៀត » ។[៦]

យើងស្គាល់ព្រះអង្គសង្គ្រោះតាមរយៈការធ្វើអ្វីដែលទ្រង់បានធ្វើ ។ នៅពេលយើងបម្រើមនុស្សដទៃ យើងនាំពួកគេ — ព្រមទាំងខ្លួនយើងដែរ — ខិតទៅជិតទ្រង់ ។

**« ព្រះនាមលើនាមទាំងអស់ »**

អំឡុងបុណ្យគ្រីស្ទម៉ាស់ ខ្ញុំនឹកដល់ចៅតូចរបស់យើងឈ្មោះ ផាកស៊្តុន ជាពិសេស ។ ដោយកើតមានជំងឺតាមពូជហ្សែនដ៏កម្រ ផាកស្តុនបានទទួលបញ្ហាសុខភាពជាច្រើន ។ ព្រះវរបិតាសួគ៌បានបង្រៀនគ្រួសាររបស់យើងនូវមេរៀនដ៏ពិសេសជាច្រើនអំឡុងពេលបីឆ្នាំដែលផាកស្តុនបាននាំយកពរជ័យមកឲ្យយើង ។

បងស្រីរបស់ខ្ញុំឈ្មោះ ណានស៊ី ស៊្តីនលើរ បានធ្វើភួយសំឡីមួយដើម្បីជាកោតគោរពដល់ផាកស្តុន ។ គាត់បានឈ្មោះភួយនោះថា « ព្រះនាមលើនាមទាំងអស់ » ។ ភួយនោះមានព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ ចំនួន ២៦ — ព្រះនាមទាំងនោះចាប់ផ្តើមដោយអក្សរ អេ រហូតដល់អក្សរហ្ស៊ី ។ ភួយនោះរំឭកខ្ញុំអំពីការជួបជុំជាគ្រួសារដ៏រុងរឿងនាពេលអនាគតជាមួយនឹងផាកស្តុនអាចកើតមានឡើងតាមរយៈការរងទុក្ខ ពលិកម្ម និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ ។

ភួយនោះបានបំផុសគំនិតរបស់ខ្ញុំឲ្យចាប់ផ្តើមការសិក្សាមួយអំពីព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទដូចដែលបានបើកសម្តែងនៅក្នុងបទគម្ពីរ ។ ការស្រាវជ្រាវព្រះនាមរបស់ទ្រង់បានក្លាយជាផ្នែកមួយនៃការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ខ្ញុំ ។ មកដល់ពេលនេះ ខ្ញុំបានរកឃើញព្រះនាមរបស់ព្រះអង្គសង្គ្រោះចំនួន ១០០ ។

ការទទួលខុសត្រូវមួយរបស់ខ្ញុំក្នុងនាមជាសមាជិកមួយរូបនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ហើយដូចដែលបានថ្លែងនៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា គឺដើម្បីថ្លែងជាសាក្សីអំពីព្រះយេស៊ូវគ្រីស្ទ ។ គោលលទ្ធិ និង សេចក្តីសញ្ញា ថ្លែងថា « ពួកអ្នកប្រឹក្សា ១២ នាក់ដែលធ្វើដំណើរ ត្រូវបានហៅឲ្យធ្វើជាពួកសាវក ១២ នាក់ ឬ *ជាពួកសាក្សីពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទ* នៅពេញសព្វក្នុងពិភពលោក » ( គ. និង ស. ១០៧:២៣, ការគូសបញ្ជាក់បានបន្ថែម ) ។

ថ្មីៗនេះ ខ្ញុំត្រូវសូមឲ្យនិយាយនៅក្នុងការប្រជុំសាក្រាម៉ង់មួយនៅឯមន្ទីរពេទ្យកុមារនៅទីក្រុង សលត៍ លេក ។ ខ្ញុំបានបំផុសគំនិតឲ្យនិយាយអំពីព្រះយេស៊ូវគ្រីស្ទ និងព្រះនាមរបស់ទ្រង់ ។ ខ្ញុំបានថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះថាជា « ផ្កាយព្រឹកដ៏ភ្លឺចិញ្ចែង » ( វិវរណៈ ២២:១៦ ) « សំដេចសង្ឃ ខាងឯសេចក្តីល្អដែលត្រូវមក » ( ហេព្រើរ ៩:១១ ) « ព្រះនៃអព្ភូតហេតុទាំងឡាយ » ដែលមានព្រះជន្មរស់ឡើងវិញ « ដោយអំណាចប្រោសឲ្យជានៅក្នុងចំអេងស្លាបទ្រង់ » ( នីហ្វៃទី ២ ២៧:២៣, ២៥:១៣ ) « ម្ចាស់នៃមេត្រីភាព »( អេសាយ ៩:៦, នីហ្វៃទី ២ ១៩:៦ ) និង « សេចក្តីរស់ឡើងវិញ ហើយជាជីវិត » ( យ៉ូហាន ១១:២៥ ) ។

នៅបុណ្យគ្រីស្ទម៉ាស់ ខ្ញុំចង់សូត្រព្រះនាមខុសៗគ្នារបស់ព្រះអង្គសង្គ្រោះពេលខ្ញុំដើរទៅវិញទៅមកការិយាល័យរបស់ខ្ញុំកាត់ភ្លើងបុណ្យគ្រីស្ទម៉ាស់នៅវិសាលដ្ឋានព្រះវិហារបរិសុទ្ធ ។ ខ្ញុំចាប់ផ្តើមជាមួយនឹង « អាល់ផា និងអូមេកា » ( វិវរណៈ ១:៨ ) ព្រះឱរស « នៃភូមិបេថ្លេហិម » ( លូកា ២:១២, ១៦ ) « ព្រះដ៏ជួយគំនិត » ( អេសាយ ៩:៦ សូមមើល នីហ្វៃទី ២ ១៩:៦ ) « ព្រះដ៏ប្រោសឲ្យរួច » ( រ៉ូម ១១:២៦ ) អង្គដែលបាន « តាំងឡើង » ( ទំនុកដំកើង ៨៩:១៩ ) « ម្ចាស់នៃសេចក្តីសុខសាន្ត » ( ម៉ូសាយ ១៥:១៨ ) ។ ល ។

ពេញរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ ខ្ញុំទន្ទឹងរង់ចាំដើម្បីទន្ទេញចាំព្រះនាមរបស់ទ្រង់ឲ្យបានច្រើន ហើយរកមើលឱកាសដើម្បីគោរពថ្វាយព្រះនាមរបស់ទ្រង់ ។ ពេលបងប្អូនខិតខំធ្វើឲ្យមានការផ្លាស់ប្តូរមួយនៅក្នុងរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ ខ្ញុំសង្ឃឹមថា បងប្អូននឹងធ្វើឲ្យព្រះអង្គសង្គ្រោះក្លាយជាអង្គដ៏សំខាន់នៅក្នុងការខិតខំប្រឹងប្រែងរបស់បងប្អូន ហើយថាបងប្អូននឹងនាំយកសិរីល្អថ្វាយទ្រង់ ពេលបងប្អូនបម្រើដល់មនុស្សដទៃនៅក្នុងព្រះនាមរបស់ទ្រង់ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ខ្ញុំថា ព្រះវរបិតាយើងមានព្រះជន្មរស់ ។ ផែនការសុភមង្គលរបស់ទ្រង់បានប្រទានពរយ៉ាងធំធេងដល់ជីវិតកូនចៅទ្រង់ម្នាក់ៗនៅគ្រប់ជំនាន់ ។ ខ្ញុំដឹងថា ព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ជាព្រះឱរសប្រសូតនៅភូមិបេថ្លេហិម គឺជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះនៃពិភពលោកនេះ ។

ពាក្យសរសើរតម្កើងទាំងនេះថ្លែងការពិតដល់ខ្ញុំថា « សរសើរដល់ព្រះដ៏ខ្ពស់បំផុត សូមក្តីសុខមានដល់មនុស្សលោក » ។[៧] ■

*ដកស្រង់ពីសុន្ទរកថាដែលធ្វើឡើងទៅកាន់ថ្នាក់គ្រប់គ្រង ប៊ី.វ៉ាយ.យូ–នៅទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ ស.រ.អា. នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ ។*

**កំណត់ចំណាំ**

១. ហាន់ណា ខ័រណាបាយ Autobiography and Poems ( ឆ្នាំ ១៨៨១ ) ទំព័រ ៤៥–៤៦ ។
២. « មកមកពួកបរិសុទ្ធ » *ទំនុកតម្កើង*, លេខ ១៨ ។
៣. ថូម៉ាស អេស ម៉នសុន « May We So Live » *Liahona,* ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៥ ។
៤. « ឆ្ងាយ ឆ្ងាយ នៅលើទីវាលទំនាបយូដា » *ទំនុកតម្កើង*, ល.រ. ១៣២ ។
៥. សូមមើល ខារេន លីន ដេវីដសុន *Our Latter-day Hymns: The Stories and the Messages* ( ឆ្នាំ ១៩៨៨ ) ទំព័រ ២២៣–២៤ ។
៦. ថូម៉ាស អេស ម៉នសុន « Be an Example and a Light » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៨៦ ។
៧. *ទំនុកតម្កើង*, ល.រ. ១៣២ ។

# ព្រឹត្តិការណ៍ទាំង ១៤ នៃប្រសូតកម្ម

ដោយ ដេសីកា ហ្វ្រើហ្វីធ

**កា**រប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានសាទររៀងរាល់ឆ្នាំ — យើងច្រៀងទំនុកតម្កើង យើងរីករាយនឹងទំនៀមទម្លាប់គ្រួសារ ហើយយើងចងចាំដល់ព្រះអម្ចាស់របស់យើងតាមរយៈការគោរពប្រសូតកម្មរបស់ទ្រង់ ។ ប៉ុន្តែតើព័ត៌មានលម្អិតអ្វីទៅអំពីប្រសូតកម្មដែលយើងរកឃើញនៅក្នុងព្រះគម្ពីរ ?

| ព្រឹត្តិការណ៍ | ការប្រសូតរបស់ព្រះគ្រីស្ទត្រូវបានព្យាករ | ទេវតាកាព្រីយ៉ែលយាងមកជួបនឹងឳពុកម្ដាយរបស់យ៉ូហានបាទីស្ទ |
| --- | --- | --- |
| | លោកុប្បត្តិ ៤៩:១០, អេសាយ ៧:១៤, ៩:១–៧, មីកា ៥:២, ម៉ូសាយ ៣:៨, អាលម៉ា ៧:១០, ហេលេមិន ១៤:២–៥ | ម៉ាថាយ ១៧:១២–១៣, លូកា ១:៥–២៥ ( ជាពិសេស ខទី ១៧ ), គោលលទ្ធិ និងសេចក្ដីសញ្ញា ២៧:៧, សេចក្ដីណែនាំដល់បទគម្ពីរ « អេលីយ៉ាស » |
| ទីតាំងនៃ | ទីក្រុងយេរូសាឡិម និងទ្វីបអាមេរិកកាលពីបុរាណ | យូដា |
| | ជាច្រើនឆ្នាំមុននឹងការប្រសូតរបស់ព្រះអង្គសង្គ្រោះ ពួកព្យាការីបានទទួលវិវរណៈអំពីព្រះយេស៊ូវគ្រីស្ទ ។ ពួកព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់បានថ្លែងពីស្ដេចមួយអង្គដែលជាពូជហ្លួងដាវីឌដែលនឹងប្រសូតមកនៅភូមិបេថ្លេហិម — គឺជាព្រះមេស៊ី ។ យោងតាមការបកស្រាយរបស់សាសន៍យូដា ព្រះមែស៊ីអង្គនេះនឹងក្លាយជាស្ដេចមួយអង្គដែលនឹងរំដោះរាស្ត្ររបស់ទ្រង់ ជាពួកសាសន៍យូដាពីការគាបសង្កត់ខាងនយោបាយ ហើយគ្រងផែនដីដោយភាពយុត្តិធម៌ ។ ប៉ុន្តែអ្វីដែលពួកសាសន៍យូដាកាលពីបុរាណពុំបានរំពឹងទុកគឺជាស្ដេចមួយអង្គដែលនឹងរំដោះរាស្ត្ររបស់ទ្រង់ឲ្យរួចពីការគាបសង្កត់ខាងវិញ្ញាណ ។ ផ្ទុយពីសេចក្ដីសង្គ្រោះខាងសាច់ឈាម និងនគរលើផែនដី ព្រះយេស៊ូវគ្រីស្ទបានប្រទានសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ចមួយ និងនគរនៃព្រះវរបិតាទ្រង់ ។ | យ៉ូហាន បាទីស្ទ គឺជាអេលីយ៉ាស ឬអ្នករៀបចំផ្លូវថ្វាយព្រះគ្រីស្ទ ។ ទេវតាកាព្រីយ៉ែលបានប្រាប់សាការី ជាឳពុករបស់យ៉ូហាន ថាប្រពន្ធរបស់គាត់ឈ្មោះ អេលីសាបិត នឹងមានកូនមួយ ហើយថាកូនរូបនេះគួរដាក់ឈ្មោះថា យ៉ូហាន ។ សាការីបានឆ្លើយតបដោយការសង្ស័យ ដែលជាលទ្ធផលគាត់បានក្លាយទៅជាថ្លង់ ហើយគ ។ |









**អត្ថន័យពិតនៃបុណ្យគ្រីស្ទម៉ាស់**

« យើងមានអំណរនៅរដូវកាលនេះ ដោយសារទ្រង់បានយាងមកក្នុងពិភពលោកនេះ ។ សេចក្ដីសុខសាន្តដែលកើតមានតាមរយៈទ្រង់ សេចក្ដីស្រឡាញ់គ្មានទីបញ្ចប់របស់ទ្រង់ដែលយើងម្នាក់ៗអាចទទួលបាន និងអារម្មណ៍ដ៏លើសលុបមួយនៃអំណរគុណដែលទ្រង់ប្រទានឲ្យយើងដោយសេរីដែលទ្រង់បានធ្វើពលិកម្មយ៉ាងធំធេង — ទាំងនេះ គឺជាអត្ថន័យពិតនៃបុណ្យគ្រីស្ទម៉ាស់ » ។

**ប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី ( ១៩១០–២០០៨ ) « The Wondrous and True Story of Christmas »** ***Liahona*** **ខែ ធ្នូ ឆ្នាំ ២០០០ ទំព័រ ៦ ។**

| ទេវតាកាព្រីយ៉ែលបានជួបនឹងម៉ារា | ម៉ារាទៅលេងអេលីសាបិត | យ៉ូហាន បាទីស្ទ បានចាប់កំណើត | ទេវតាកាព្រីយ៉ែលបានទៅជួបនឹងយ៉ូសែប |
|---|---|---|---|
| ម៉ាថាយ ១:១៨, លូកា ១:២៦–៣៨ | លូកា ១:៣៩–៥៦ | លូកា ១:៥៧–៨០ | ម៉ាថាយ ១:១៨–២៣ |









| ណាសារ៉ែត និងកាលីឡេ | យូដា | យូដា | ណាសារ៉ែត |
|---|---|---|---|



នៅប្រាំមួយខែក្រោយមកទៀត កាព្រីយ៉ែលបានទៅជួបម៉ារាជាបងប្អូនជីដូនមួយនឹងអេលីសាបិត ។ ទ្រង់បានប្រាប់ម៉ារាថា ទោះបីនាងជាស្ត្រីព្រហ្មចារិយក្ដី ប៉ុន្តែនាងនឹងមានបុត្រមួយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ហើយបុត្រនោះគឺជាព្រះយេស៊ូវគ្រីស្ទ ។ ម៉ារាបានទទួលយកដោយចិត្តរាបសា ចំពោះការហៅនោះ ជាមាតារបស់ព្រះរាជបុត្រានៃព្រះ ។ ទេវតាអង្គនេះក៏បានប្រាប់នាងដែរថា អេលីសាបិតជាបងប្អូនជីដូនមួយនាងបានមានគត៌ ។



បន្ទាប់ពីទេវតាបានមកជួបនឹងម៉ារា នាងបានចេញពីភូមិណាសារ៉ែតទៅលេងនឹងអេលីសាបិតជាបងប្អូនជីដូននាងនៅស្រុកយូដាអស់រយៈពេលបីខែ ។ កាលម៉ារាស្នាក់នៅទីនោះ អេលីសាបិតបានទទួលទីបន្ទាល់មួយតាមរយៈព្រះវិញ្ញាណបរិសុទ្ធថា បុត្ររបស់ម៉ារាគឺជាព្រះរាជបុត្រានៃព្រះ ។ ម៉ារាក៏បានថ្លែងទីបន្ទាល់របស់នាងអំពីព្រះដែរ ។

កាលយ៉ូហាន បាទីស្ទ បានចាប់កំណើតមក ប្រជាជនទូទៅបានគិតថា លោកត្រូវបានដាក់ឈ្មោះឲ្យថាសាការី ដាក់ឈ្មោះតាមឪពុករបស់លោក ។ អេលីសាបិតបានបដិសេធឈ្មោះនោះ ដោយប្រាប់មិត្ត និងអ្នកជិតខាងរបស់នាងថា លោកឈ្មោះ យ៉ូហាន ។ កាលមិត្ត និងអ្នកជិតខាងទាំងនេះចោទសួរសាការីអំពីរឿងនេះ លោកបានយល់ព្រមនឹងអេលីសាបិត ។ ដោយលោកបានធ្វើតាមបង្គាប់របស់កាព្រីយ៉ែលសម្រាប់ការដាក់ឈ្មោះដល់កូនប្រុសរបស់លោក សាការីអាចនិយាយបានវិញ ហើយលោកបានប្រើការស្ដាប់ឮរបស់លោក ហើយថ្លែងសរសើរព្រះ ។





ដោយមើលឃើញពីស្ថានភាពមានគត៌របស់ម៉ារា កាលនាងបានត្រឡប់មកពីភូមិណាសារ៉ែតវិញ យ៉ូសែបដែលជាគូដណ្ដឹងរបស់ម៉ារាមានបំណងចង់ « លែងនាងដោយសម្ងាត់វិញ » ឬលុបចោលការភ្ជាប់ពាក្យរបស់ពួកគេដោយស្ងៀមស្ងាត់វិញ ។ ប៉ុន្តែពីមុនលោកអាចធ្វើដូច្នេះ ទេវតាកាព្រីយ៉ែលបានមកជួបលោកក្នុងសុបិន ដោយថ្លែងទីបន្ទាល់ថា បុត្ររបស់ម៉ារាចាប់ទំផ្ទៃមកពីព្រះវិញ្ញាណបរិសុទ្ធទេ ហើយថាបុត្រនោះនឹងក្លាយជាអង្គដែលនឹងសង្គ្រោះរាស្ត្រទ្រង់ចេញពីអំពើបាបរបស់ពួកគេ ។ ជំនួសឲ្យការបែកចេញពីម៉ារា យ៉ូសែបបានសម្រេចចិត្តរៀបការនឹងនាង ។

*ព្យាការីអេសាយព្យាករពីការប្រសូតរបស់ព្រះគ្រីស្ទ* ដោយហារី អេនឌើរសុន រចនារូបភាពទេវតាកាព្រីយ៉ែល ដោយ ម៉ៃខល ម៉ម *ក្នុងបណ្ដាពួកស្រីៗ នាងជាស្ត្រីមានពរពិត* ដោយវ៉លធើរ រេន រឿងលម្អិតដកស្រង់ពី *ការយាងមកជួប* ដោយ រេមប្រាន ហាមេនស៍ ( ១៦០៩–៦៩ ) ស្ថាប័នសិល្បៈដេត្រូយ, USA/Bridgeman Images; *ទេវតាកាព្រីយ៉ែលធ្វើឲ្យសាការីគ* ផ្ទៃខាងក្រោយ ស៊ុម បុរស ជាមួយនឹងសត្វអូតមកពី GETTY IMAGES; *សាការីសរសេរឈ្មោះសម្រាប់កូន* ទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការមកពី FCIT; *ការអបអរសាទរចំពោះយ៉ូសែប* ដោយយ៉ូសែប ប្រ៊ីកឃី

## មនុស្សទាំងអស់ត្រូវបង់ពន្ធ

លូកា ២:១–៤, ជេម អ៊ី ថាល់មេហ្គ, *Jesus the Christ* ( ឆ្នាំ ១៩១៦ ) ទំព័រ ៩១–៩២



ចក្រភពរ៉ូម



ការបង់ពន្ធនេះមាននូវគោលបំណងពីរយ៉ាង ជាការបង់ពន្ធ និងការចុះជំរឿនប្រជាជនដែលធ្វើឡើងដោយពួករ៉ូម ។ ជាធម្មតា ពួករ៉ូមបានចុះឈ្មោះប្រជាជនស្របតាមកន្លែងស្នាក់នៅបច្ចុប្បន្នរបស់ពួកគេ ប៉ុន្តែតាមទំនៀមទម្លាប់របស់សាសន៍យូដាគឺត្រូវចុះឈ្មោះប្រជាជនដោយផ្អែកទៅលើស្រុកកំណើតជីដូនជីតារបស់ពួកគេ ។ ដោយសារហេតុផលនេះ ភូមិបេថ្លេហិមដែលជាស្រុកកំណើតជីដូនជីតារបស់យ៉ូសែបមានមនុស្សច្រើនកុះករ ហើយផ្ទះសំណាក់គឺពេញទាំងអស់ផងដែរ ។



## ព្រះយេស៊ូវគ្រីស្ទបានប្រសូតមក

លូកា ២:៦–៧



ណាសារ៉ែត បេថ្លេហិម និងយូដា



*បេថ្លេហិមមានន័យថា « ផ្ទះនៃនំប៉័ង » ហើយគឺជាទីប្រសូតដែលបានព្យាករសម្រាប់ព្រះមែស៊ី ។*

យ៉ូសែប និងម៉ារាបានធ្វើដំណើរទៅភូមិបេថ្លេហិមដើម្បីបង់ពន្ធ ។ កាលព្រះយេស៊ូវបានប្រសូតមក ម៉ារាច្នៃគ្រែសម្រាប់កូនង៉ែតមួយដោយដាក់ព្រះយេស៊ូវផ្ទុំក្នុងស្នូក ឬចង្អូរទឹកមួយសម្រាប់ទុកឲ្យសត្វផឹក ។ ពុំមានការរៀបរាប់ពីប្រភេទសត្វនៅទីនោះឡើយ ។

## ទីសម្គាល់ដែលបានព្យាករលេចចេញមកនៅទ្វីបអាមេរិក

ហេលេមិន ១៤:១–៥, នីហ្វៃទី ៣ ១:១៥–២១



ទ្វីបអាមេរិក

ដូចដែលបានព្យាករទុក នៅថ្ងៃប្រសូតរបស់ព្រះគ្រីស្ទ មានមួយថ្ងៃ និងមួយយប់ដែលភ្លឺពេញមួយថ្ងៃនៅទ្វីបអាមេរិក ។ ផ្កាយថ្មីមួយបានរះឡើងនៅលើមេឃ ។



## ពួកគង្វាលស្ដាប់ឮពីការប្រសូតរបស់ព្រះគ្រីស្ទ

លូកា ២:៨–១៧



ក្បែរភូមិបេថ្លេហិម



រៀងរាល់ឆ្នាំ នាពេលនេះ ពួកគង្វាលបានរក្សាហ្វូងសត្វរបស់ខ្លួននៅទីវាលទាំងយប់ទាំងថ្ងៃ ។ នេះគឺជាកន្លែងដែលមានទេវតាមួយអង្គលេចមកឯពួកគេ ហើយប្រាប់ពួកគេអំពីការប្រសូតរបស់ព្រះអង្គសង្គ្រោះ ។ បន្ទាប់ពីការប្រកាសប្រាប់របស់ទេវតាអង្គនោះ មានពលទេវតាបានលេចមកដោយថ្វាយសិរីល្អជូនព្រះ ។ បន្ទាប់ពីស្ដាប់ឮរឿងនេះហើយ ពួកគង្វាលបានប្រញាប់ប្រញាល់ទៅភូមិបេថ្លេហិមដើម្បីបានឃើញព្រះយេស៊ូវ ។ ពេលពួកគេបានឃើញទ្រង់ហើយ ពួកគេបានលាយ៉ូសែប និងម៉ារា ហើយបានថ្លែងទីបន្ទាល់ដល់មនុស្សដទៃទៀតអំពីអ្វីដែលពួកគេបានឃើញ ។

## ព្រះយេស៊ូវត្រូវបានកាត់ស្បែក ដាក់ឈ្មោះ ហើយនាំទៅព្រះវិហារបរិសុទ្ធ

លូកា ២:២១–៣៨, ជេម អ៊ី ថាល់មេហ្គ, *Jesus the Christ* ទំព័រ ៩៥



បេថ្លេហិម

ក្រោយពីប្រសូតបានប្រាំបីថ្ងៃមក ព្រះគ្រីស្ទត្រូវបានកាត់ស្បែក ហើយដាក់ឈ្មោះ ស្របតាមទំនៀមទម្លាប់របស់សាសន៍យូដា ។ ទ្រង់ត្រូវបានថ្វាយព្រះនាមថា យេស៊ូវ ឬ « យេសូ៎វ » មានន័យថា « ព្រះអង្គសង្គ្រោះ » ជាភាសាហេព្រើរ ។ ទំនៀមទម្លាប់សាសន៍យូដាចង្អុលបង្ហាញថា ស្ត្រីម្នាក់ត្រូវរង់ចាំរយៈពេល ៤០ ថ្ងៃបន្ទាប់កំណើតរបស់កូន ដើម្បីចូលទៅក្នុងព្រះវិហារបរិសុទ្ធ ។ បន្ទាប់ពីរយៈពេល ៤០ ថ្ងៃត្រូវបានបញ្ចប់ ម៉ារា និងយ៉ូសែបបាននាំព្រះយេស៊ូវទៅបង្ហាញនៅព្រះវិហារបរិសុទ្ធ ។ នៅទីនោះ ពួកគាត់បានជួបនឹងស៊ីម៉ូនដែលបានសន្យាថា លោកនឹងបានឃើញព្រះគ្រីស្ទពីមុនលោកស្លាប់ ។ លោកបានស្គាល់ព្រះគ្រីស្ទ បានបីត្រកងទ្រង់ក្នុងដៃ ហើយបានសរសើរតម្កើងព្រះ ។ លោកក៏បានព្យាករផងដែរអំពីបេសកកម្មរបស់ព្រះគ្រីស្ទនៅលើផែនដី ។ អាណ ដែលជាហោរាស្រីម្នាក់ក៏បានធ្វើសាក្សីអំពីព្រះគ្រីស្ទនៅឯព្រះវិហារបរិសុទ្ធដែរ ។ គាត់ក៏បានថ្លែងទីបន្ទាល់អំពីបេសកកម្មរបស់ទ្រង់ផងដែរ ។

## ពួកហោរាសួរស្ដេចហេរូឌអំពីព្រះគ្រីស្ទ

ម៉ាថាយ ២:១–១០



យេរូសាឡិម

មានចំនួនពុំជាក់លាក់មួយអំពីពួកហោរា « មកពីទិសខាងកើត » បានមកកាន់ទីក្រុងយេរូសាឡិមដើម្បីស្វែងរកព្រះគ្រីស្ទ ។ ពួកគេបានឃើញផ្កាយថ្មីមួយនៅលើមេឃដែលបានបង្ហាញថា ព្រះគ្រីស្ទបានប្រសូតហើយ ។ ពួកគេបានទូលសួរស្ដេចហេរូឌ ស្ដេចស្រុកយូដាដែលពួករ៉ូមបានតែងតាំង ពីកន្លែងទៅស្វែងរកព្រះរាជកុមារអង្គនោះ ។ ស្ដេចហេរូឌមានការភ័យខ្លាចចំពោះស្ដេចថ្មីអង្គនោះ ជាព្រះមែស៊ី ដែលទ្រង់បានគិតថានឹងយាងមកគ្រប់គ្រងនគររបស់ទ្រង់ ។ ដោយពុំបានប្រាប់ពួកហោរាពីភាពភ័យខ្លាចរបស់ទ្រង់ នោះទ្រង់បានបង្គាប់ឲ្យពួកគេទៅ ហើយត្រឡប់មកប្រាប់ទ្រង់វិញពីកន្លែងពួកគេរកឃើញព្រះគ្រីស្ទ ។ ទ្រង់មានផែនការដើម្បីធ្វើគុតព្រះគ្រីស្ទ ។

## ពួកហោរារកឃើញព្រះគ្រីស្ទ ហើយថ្វាយដង្វាយ

ម៉ាថាយ ២:៩–១២; Bible Dictionary, « *Magi* »



បេថ្លេហិម

នៅទីបំផុតពួកហោរាបានរកឃើញព្រះគ្រីស្ទ ។ ម៉ាថាយបញ្ជាក់យ៉ាងច្បាស់ថា ពួកគេបានរកឃើញព្រះយេស៊ូវក្នុងផ្ទះរបស់ទ្រង់ជា « បុត្រតូច » ដោយចង់បង្ហាញថា ពួកគេបានមកដល់យ៉ាងហោចណាស់មួយឆ្នាំបន្ទាប់ពីការប្រសូតរបស់ព្រះគ្រីស្ទ ។ ពួកគេបានថ្វាយដង្វាយជាមាស ជាកំញាន ជាជ័រល្វីងទេស ចំពោះទ្រង់ — ជាអំណោយដ៏មានតម្លៃដែលបានទទួលស្គាល់ពីឋានៈជាហ្លួងរបស់ព្រះយេស៊ូវ ។ នៅក្នុងសុបិនមួយ ពួកហោរាបានប្រាប់កុំឲ្យទូលប្រាប់ស្ដេចហេរូឌពីការរកឃើញរបស់ពួកគេឡើយ ។





## យ៉ូសែបត្រូវបានព្រមានឲ្យគេចខ្លួនទៅស្រុកអេស៊ីព្ទ

ម៉ាថាយ ២:១៣–១៦, ១៩–២៣



បេថ្លេហិម អេស៊ីព្ទ និងណាសារ៉ែត

ពួកហោរាពុំបានរាយការណ៍ដល់ស្ដេចហេរូឌ ដូចដែលពួកគេបានប្រាប់នោះឡើយ ។ ស្ដេចហេរូឌបានមានប្រតិកម្មដោយចេញបញ្ជាថា រាល់កុមារទាំងអស់ដែលកើតនៅ ភូមិបេថ្លេហិម មានអាយុពីពីរឆ្នាំចុះក្រោមត្រូវតែសម្លាប់ចោល ។ ដោយត្រូវបានព្រមាននៅក្នុងការនិមិត្តមួយ យ៉ូសែបបាននាំម៉ារា និងព្រះយេស៊ូវទៅស្រុកអេស៊ីព្ទ ។ ពួកគេបានស្នាក់នៅទីនោះរហូតដល់ស្ដេចហេរូឌបានសុគត ។ ពេលស្ដេចហេរូឌបានសុគត នោះមានទេវតាមួយអង្គបានមកជួបយ៉ូសែបក្នុងការនិមិត្តមួយ ប្រាប់លោកថា វាមានសុវត្ថិភាពដើម្បីត្រឡប់ទៅស្រុកអ៊ីស្រាអែលវិញ ។ ប៉ុន្តែដោយឮថាបុត្រារបស់ស្ដេចហេរូឌគឺជាអ្នកគ្រប់គ្រងបច្ចុប្បន្ន នោះយ៉ូសែបបាននាំគ្រួសាររបស់លោកទៅភូមិណាសារ៉ែតស្រុកកាលីឡេវិញ ជំនួសឲ្យស្រុកយូដា ហេតុដូច្នេះហើយព្រះជន្មរបស់ព្រះគ្រីស្ទក្នុងនាមជាព្រះយេស៊ូវនៃភូមិណាសារ៉ែតបានចាប់ផ្ដើម ។ ច្រើនឆ្នាំក្រោយមកទ្រង់បានទទួលបុណ្យជ្រមុជទឹក ធ្វើអព្ភូតហេតុជាច្រើន ហើយបញ្ចប់ដង្វាយធួនដ៏អស្ចារ្យអស់កល្បជានិច្ចរបស់ទ្រង់ ។

© LARS JUSTINEN/LICENSED FROM GOODSALT.COM; © THE CLASSIC BIBLE ART COLLECTION/LICENSED FROM GOODSALT.COM; FIGHT, )/PRIVATE COLLECTION/©LOOK AND LEARN/BRIDGEMAN IMAGES





ដោយ អែលឌើរ
ម៉ាកឹស ប៊ី នែស
ក្នុងពួកចិតសិបនាក់

# យ៉ូសែប ស្ម៊ីធ ៖ កម្លាំងដែលកើតចេញពីភាពទន់ខ្សោយ

[កំណត់ចំណាំរបស់អ្នកបកប្រែ ៖ អត្ថបទនេះដកស្រង់មកពីការសរសេរផ្ទាល់របស់យ៉ូសែប ស្ម៊ីធ ជាច្រើនដង ។ ជាភាសាអង់គ្លេស ពាក្យដកស្រង់ទាំងឡាយមាននូវកំហុសមួយចំនួននៅក្នុងការប្រកបសញ្ញាវណ្ណយុត្ត ការសរសេរដោយអក្សរពុម្ពធំ ។ ( ការប្រកបនៃភាសាអង់គ្លេសរបស់អាមេរិកាំងពុំទានចាប់ផ្ដើមបទដ្ឋានត្រឹមត្រូវឡើយរហូតដល់ចុងទសវត្សរ៍ឆ្នាំ ១៨២០ ) ។ ប៉ុន្តែដើម្បីធ្វើឲ្យការអានមានភាពងាយស្រួល ពាក្យដកស្រង់ទាំងឡាយនឹងត្រូវបានបកប្រែដោយគ្មានកំហុសទាំងនោះជាថ្មីឡើយ ] ។

រាប់ពាន់ឆ្នាំកន្លងទៅ យ៉ូសែបពីបុរាណបានព្យាករថា « ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំដូច្នេះ ៖ មានអ្នកមើលឆុតម្នាក់ដ៏ជម្រើស ដែលយើងនឹងបង្កើតឡើងពីផលនៃពោះអ្នក . . . ហើយចំពោះអ្នកនោះ នោះយើងនឹងប្រទានអំណាចឲ្យនាំពាក្យរបស់យើង . . . ហើយចេញពីភាពទន់ខ្សោយ អ្នកនោះនឹងត្រូវបានធ្វើឲ្យមាំមួន » ( នីហ្វៃទី ២ ៣:៧, ១១, ១៣ ) ។

ខ្ញុំត្រូវបានធ្វើឲ្យរំភើបចិត្ត ហើយត្រូវបានបំផុសគំនិតដោយការព្យាករនេះ ថា « ចេញពីភាពទន់ខ្សោយ អ្នកនោះនឹងត្រូវបានធ្វើឲ្យមាំមួន » ។ វាទំនងដូចជាពុំសមហេតុផលសោះដែលព្រះអម្ចាស់តែងតែហៅមនុស្សទន់ខ្សោយឲ្យសម្រេចកិច្ចការមួយដ៏ធំនោះ ។ ប៉ុន្តែអស់អ្នកដែលស្គាល់ពីភាពទន់ខ្សោយរបស់ខ្លួន អាចត្រូវបានជម្រុញដោយភាពទន់ខ្សោយនោះ ដើម្បីស្វែងរកកម្លាំងរបស់ព្រះអម្ចាស់ ។ ដូច្នេះហើយអស់អ្នកដែលបន្ទាបខ្លួននៅក្នុងសេចក្ដីជំនឿនឹងទទួលបានកម្លាំងពីទ្រង់ដែលមានគ្រប់ព្រះចេស្ដានៅលើស្ថានសួគ៌ និងផែនដី ( សូមមើល ម៉ាថាយ ២៨:១៨, ម៉ូសាយ ៤:៩ ) ។[1]

តាំងពីនៅជាយុវវ័យ យ៉ូសែប ស្ម៊ីធ បានស្វែងរកព្រះអម្ចាស់តាមលក្ខខណ្ឌទាំងនេះ ។ ពេលយ៉ូសែបមានវ័យ ១៥ ឆ្នាំ លោកចង់បានការអភ័យទោសពីអំពើបាប ហើយចង់ដឹងថាតើព្រះវិហារណាមួយត្រឹមត្រូវ ។ លោកបានសរសេរថា « ប៉ុន្តែទោះជាខ្ញុំមានគំនិតគិតដ៏ជ្រាលជ្រៅ ហើយជួនកាលដ៏ខ្លាំងក្លាក្ដី គង់តែ . . . ពិបាកដល់ជនដូចរូបខ្ញុំ ដែលនៅវ័យក្មេង ហើយមិនសូវស្គាល់មនុស្ស និងដឹងក្ដី ឲ្យចេះសម្រេចចិត្តថានរណាមួយត្រូវ ហើយនរណាមួយខុសនោះឡើយ » ( សូមមើលយ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១:៨ ) ។

ការដឹងអំពីភាពទន់ខ្សោយនេះយ៉ាងពេញលេញ លោកបានចូលទៅក្នុងព្រៃពិសិដ្ឋដើម្បីដឹងអំពីកន្លែងដែលលោកអាចរកឃើញសាសនាចក្ររបស់ព្រះ ។ លោកបានទូលសូម ដើម្បីលោកអាច *ធ្វើ* អ្វីមួយទាក់ទងនឹងរឿងនេះ ដើម្បីលោកអាច*ចូលរួម* នឹងព្រះវិហារនោះ ( សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៨ ) ។ ជាចម្លើយចំពោះការទូលសូមដ៏ស្មោះរាបសារបស់លោក ព្រះជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ បានយាងមកជួបនឹងយ៉ូសែប ។ តាមរយៈការយាងមកជួបនេះ ទ្រង់ទាំងពីរអង្គបាន

*ដូចជាយ៉ូសែប ស្ម៊ីធដែរ ប្រសិនបើយើងស្គាល់ភាពទន់ខ្សោយរបស់យើង ហើយបែរទៅរកព្រះអម្ចាស់វិញដោយសេចក្ដីជំនឿ នោះយើងនឹងត្រូវបានធ្វើឲ្យមាំមួន ។*

រឿងលម្អិតដកស្រង់ពី *THE PURPOSE OF LIFE,* ដោយ យ៉ូសែប ប្រ៊ីកឃើ




រំដោះលោកឲ្យរួចពីអំណាចរបស់អារក្ស ហើយបានរៀបចំផ្លូវសម្រាប់ការស្ដារឡើងវិញ ( សូមមើលយ៉ូសែបស្ម៊ីធ — ប្រវត្តិ ១:១៤–១៩ ) ។

យ៉ូសែប ស្ម៊ីធ ពុំបានប្រកែកថា លោកគឺជាមនុស្សម្នាក់នៃ « ពួកកំសោយនៅពិភពលោក » នេះឡើយ ( គ. និង ស. ១:១៩, ៣៥:១៣ ) ។ ច្រើនឆ្នាំក្រោយមកទៀត ព្រះអម្ចាស់បានមានបន្ទូលប្រាប់លោកបែបនេះ ៖ « ចំពោះការណ៍នេះហើយ ដែលយើងបានលើកអ្នកឡើង ប្រយោជន៍ឲ្យយើងអាចបង្ហាញនូវប្រាជ្ញារបស់យើងតាមរយៈពួកកម្សោយនៃផែនដី » ( គ. និង ស. ១២៤:១ ) ។

### ក្មេងប្រុសម្នាក់ដែលមិនសូវមានគេឯងស្គាល់

យ៉ូសែប បានរៀបរាប់ខ្លួនលោកជា « ក្មេងប្រុសម្នាក់ដែលមិនសូវមានគេឯងស្គាល់ . . . ដែលត្រូវទ្រាំធ្វើការជារៀងរាល់ថ្ងៃ ដើម្បីទ្រទ្រង់ជីវិត » ( យ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១:២៣ ) ។ លោកបានកើតមកនៅក្នុងស្រទាប់សង្គមថ្នាក់ទាបជាមួយនឹងការអប់រំតិចតួចយ៉ាងស្ដួចស្ដើង ។ ការប៉ុនប៉ងសរសេរអំពីប្រវត្តិរបស់លោកជាលើកដំបូងបានគូសបញ្ជាក់ពីស្ថានភាពទន់ខ្សោយដែលលោកត្រូវបានហៅឲ្យធ្វើកិច្ចការនេះ ។

« ខ្ញុំបានកើតនៅភូមិឆារ៉ុន [ សារ៉ុន ] នៅរដ្ឋវ័រម៉ុនខាងជើង ប្រទេសអាមេរិក នៅថ្ងៃទី២៣ ខែ ធ្នូ គ.ស. ១៨០៥ ដែលមានឪពុកម្ដាយដ៏ល្អ ដែលខិតខំណែនាំខ្ញុំអំពីគ្រិស្តសាសនា [ ។ ] នៅវ័យប្រហែលជាដប់ឆ្នាំ លោកឪពុករបស់ខ្ញុំ យ៉ូសែប ស្ម៊ីធ សុញ្ញ័រ បានផ្លាស់លំនៅទៅភូមិបាល់ម៉ៃរ៉ា ឃុំអុនតារីយ៉ូ នៅរដ្ឋនូវយ៉ក ហើយដោយស្ថិតនៅក្នុងកាលៈទេសៈខ្វះខាត លោកត្រូវមានកាតព្វកិច្ចខិតខំធ្វើការដើម្បីផ្គត់ផ្គង់គ្រួសារដ៏ធំមួយ ដែលមានកូនប្រាំបួននាក់ ហើយដោយសារវាតម្រូវឲ្យមានការខិតខំពីសំណាក់សមាជិកគ្រួសារដែលអាចជួយផ្គត់ផ្គង់ដល់គ្រួសារបាន ហេតុដូច្នេះហើយ យើងត្រូវបានដកយកនូវអត្ថប្រយោជន៍នៃការអប់រំគ្រប់គ្រាន់ និយាយទៅខ្ញុំគ្រាន់តែបានបង្រៀនឲ្យចេះអានអក្សរ និងចេះច្បាប់មូលដ្ឋាននៃនព្វន្តសាស្ត្រប៉ុណ្ណោះ » ។[2]

យ៉ូសែប បានមានអារម្មណ៍យ៉ាងច្បាស់ថា លោកខ្វះការអប់រំរហូតមានពេលមួយនោះ លោកបានធ្លាប់ទួញសោកថា « លោកជាប់នៅក្នុងគុកតូច ដែលមានភាពងងឹតស្ទើរតែទាំងស្រុង ដោយប្រើប្រាស់ក្រដាស ប៉ិច និងទឹកខ្មៅ សរសេរពាក្យមិនល្អឥតខ្ចោះ » ។[3] ទោះបីយ៉ាងណាក្ដី ព្រះអម្ចាស់បានហៅលោកឲ្យបកប្រែព្រះគម្ពីរមរមន — ទាំងអស់មាន ៥៨៨ ទំព័រនៃច្បាប់ដើមដែលបានបោះពុម្ព — ដែលលោកបានធ្វើកិច្ចការនេះតិចជាង ៩០ ថ្ងៃ ។

មនុស្សណាក៏ដោយដែលគិតយ៉ាងច្បាស់នឹងសន្និដ្ឋានថា វាពុំអាចកើតឡើងបានឡើយ ដែលយ៉ូសែប ជាបុគ្គលដែលមានការអប់រំតិចតួចអាចសម្រេចរឿងមួយបែបនេះបានដោយខ្លួនលោកនោះ ហើយការពន្យល់ដែលមនុស្សខ្លះបានបង្កើតឡើងគឺពិបាកជឿជាងការពន្យល់ពិតថា លោកគឺជាព្យាការីដែលបានបកប្រែដោយអំណោយទាន និងព្រះចេស្ដានៃព្រះទៅទៀត ។

### សាក្សីរបស់អិមម៉ា

រយៈពេលក្រោយមកទៀតនៅក្នុងជីវិតរបស់នាង នោះ អិមម៉ា ស្ម៊ីធ បាននឹកចាំថា នៅ គ្រាដែលស្វាមីរបស់នាងបានបកប្រែផ្ទាំងចំណារមាសនោះ គាត់ « មិនអាចសរសេរ ឬអានពាក្យបានច្បាស់លាស់ទេ ប៉ុន្តែត្រូវបានអនុញ្ញាតឲ្យសរសេរសៀវភៅមួយដូចជាព្រះគម្ពីរមរមនតែម្នាក់ឯង ។ ហើយទោះបីជាខ្ញុំគឺជាអ្នកចូលរួមយ៉ាងសកម្មម្នាក់នៅក្នុងព្រឹត្តិការណ៍ដែលបានកើតឡើងក្ដី ក៏វាធ្វើឲ្យខ្ញុំមានការ




*ខាងឆ្វេង ៖ ការកត់ត្រាមួយមកពីប្រវត្តិរបស់ យ៉ូសែប ស្ម៊ីធ ដែលបានសរសេរដោយដៃរបស់លោកផ្ទាល់ ។ ទំព័រម្ខាងទៀត ៖ ទំព័រមួយមកពីសៀវភៅកំណត់ហេតុរបស់ យ៉ូសែប ស្ម៊ីធ ។ សូមកត់ចំណាំថា មានពាក្យពេចន៍គូសចោល ។*







រឿងឆ្ងល់ដែរ ‹ ជាកិច្ចការធំ និងអស្ចារ្យ › ហើយវាដូចគ្នាចំពោះមនុស្សម្នាក់ផ្សេងទៀតដែរ » ។[4]

ជាមួយនឹងបរិបទនៃប្រវត្តិសាស្ត្រនេះ វាគឺជារឿងដ៏គួរឲ្យចាប់អារម្មណ៍ដើម្បីមើលទំព័រទីមួយនៃសៀវភៅកំណត់ហេតុដំបូងរបស់យ៉ូសែប ដែលចុះនៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៨៣២ ( ដូចបានបង្ហាញនៅខាងស្ដាំ ) ។ លោកបានសរសេរសៀវភៅនេះប្រមាណជាបីឆ្នាំកន្លះ បន្ទាប់ពីលោកបានបញ្ចប់ការបកប្រែព្រះគម្ពីរមរមន ។ សូមកត់ចំណាំថា លោកសរសេរ រួចហើយឆូតពាក្យដូចតទៅនេះចោល ៖

« យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ — សៀវភៅកំណត់ត្រាដែលបានទិញសម្រាប់កត់ចំណាំរាល់កាលៈទេសៈដែលកើតមាននៅក្រោមការសង្កេតមើលរបស់ខ្ញុំ » ។

ពេលខ្ញុំកាន់សៀវភៅកំណត់ហេតុនេះ ហើយអានពាក្យដែលបានឆូតចោលទាំងនេះ នោះខ្ញុំបាននឹកស្រមៃឃើញយ៉ូសែប អង្គុយនៅក្នុងមជ្ឈដ្ឋានជនបទក្នុងទ្វីបអាមេរិក ដោយសរសេរប្រយោគចាប់ផ្ដើមនោះ រួចហើយគិតថា « ទេ ប្រយោគនោះដូចជាមិនត្រូវទេ ខ្ញុំត្រូវសាកល្បងម្ដងទៀត » ។ ដូច្នេះ លោកបានឆូតប្រយោគនោះចោល ហើយសរសេរថា « សៀវភៅកំណត់ត្រារបស់យ៉ូសែប ស្ម៊ីធ ជុញ្ញ័រដែលបានទិញនៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៨៣២ ក្នុងគោលបំណងកំណត់ត្រាដំណើររឿងនៃកិច្ចការទាំងអស់ដែលកើតមាននៅក្រោមការសង្កេតមើលរបស់ខ្ញុំ និង — — » ។

នៅទីបំផុត ប្រហែលជាដោយសារតែ មិនបានពេញចិត្តទាំងស្រុងជាមួយនឹងភាសាពាក្យសម្ដីមិនច្បាស់លាស់ដែលលោកទើបតែសរសេរ លោកបានសរសេរថា « ឱ សូមឲ្យព្រះប្រទានពរដល់ខ្ញុំ ដើម្បីខ្ញុំត្រូវបានដឹកនាំនូវរាល់គំនិតរបស់ខ្ញុំ ឱសូមប្រទានពរដល់អ្នកបម្រើរបស់ទ្រង់ផង អាម៉ែន » ។[5] នៅក្នុងប្រយោគនេះ ខ្ញុំទទួលអារម្មណ៍ថា យ៉ូសែបកំពុងមានអារម្មណ៍អំពីការខ្វះ សមត្ថភាព និងភាពទន់ខ្សោយរបស់លោក ហើយកំពុងទូលសូមព្រះដោយសេចក្ដីជំនឿដើម្បីដឹកនាំលោកនៅក្នុងកិច្ចការដែលលោកធ្វើនោះ ។

ឥឡូវ សូមមើលភាពខុសគ្នារវាងការសរសេរនៅក្នុងកំណត់ហេតុនោះ និងសំណៅនៃទំព័រសរសេរដៃច្បាប់ដើមមួយនៃព្រះគម្ពីរមរមនដែលបានកត់ត្រានៅចន្លោះខែ មេសា និងខែ មិថុនា ឆ្នាំ ១៨២៩ ( ដូចបានបង្ហាញនៅទំព័របន្ទាប់ ) ។

សូមកត់ចំណាំអំពីលំហូរពាក្យរាយ — ដោយគ្មានវណ្ណយុត្តិ ដោយគ្មានការឆូតចោលពាក្យ ។ នេះពុំមែនជាការរៀបអក្សរមួយទេ ។ យ៉ូសែបបានសរសេរវាមួយពាក្យម្ដងៗ ពេលលោកបានសម្លឹងមើលទៅក្នុងឧបករណ៍ដែលព្រះអម្ចាស់បានរៀបចំសម្រាប់លោក ដូចជា យូរីម និង ធូមីម ហើយជាថ្មីអ្នកមើលឆុតមួយដោយប្រើមួកការពារភ្នែករបស់លោកពីពន្លឺចម្លែក ដើម្បីមើលឃើញច្បាស់ពាក្យទាំងឡាយពេលវាលេចឡើងមក ( សូមមើលនីហ្វៃទី ២ ២៧:៦, ១៩–២២, ម៉ូសាយ ២៨:១៣ ) ។ ដូចជាអ្នកមើលឃើញហើយ មាននូវភាពខុសគ្នាដ៏ធំមួយរវាងការបកប្រែព្រះគម្ពីរមរមន និងកំណត់ត្រានៅក្នុងសៀវភៅកំណត់ហេតុ ៖ មួយជាផលិតផលរបស់យ៉ូសែប ស្ម៊ីធ ជាព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈមួយទៀតជាផលិតផលរបស់យ៉ូសែប ស្ម៊ីធ ជាមនុស្សធម្មតា ។ ប្រសិនបើអ្នកមើលឲ្យជិតនូវច្បាប់ដើមនៃការសរសេរដោយដៃនៃការបកប្រែនោះ អ្នកនឹងអានពាក្យដែលបានលើកទឹកចិត្តដល់យ៉ូសែបថា

« ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាននិយាយទៅឪពុកខ្ញុំថា ៖ ខ្ញុំនឹងទៅ ហើយធ្វើនូវអ្វីៗ ដែលព្រះអម្ចាស់ទ្រង់បានបញ្ជា ដ្បិតខ្ញុំដឹងថា ព្រះអម្ចាស់ទ្រង់មិនចេញបញ្ញាដល់កូនចៅមនុស្សណាឡើយ លើកលែងតែទ្រង់នឹងរៀបចំផ្លូវ ដើម្បីឲ្យគេអាចសម្រេចនូវអ្វីៗ ដែលទ្រង់បានបញ្ជាដល់ពួកគេទុកជាមុនសិន » ( នីហ្វៃទី ១ ៣:៧ ) ។

ពីមុនបកប្រែពាក្យទាំងនេះ មិនយូរប៉ុន្មាន លោកបានបកប្រែពាក្យដូចតទៅនេះ ៖ « ប៉ុន្តែ មើលចុះ ខ្ញុំនីហ្វៃនឹងបង្ហាញដល់អ្នករាល់គ្នាថា សេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់ទាំងឡាយនៃព្រះអម្ចាស់មានមកលើជន ទាំងអស់ណា ដែលព្រះទ្រង់បានរើស



ដោយសារសេចក្ដីជំនឿរបស់គេ ដើម្បីធ្វើឲ្យគេខ្លាំងពូកែស្មើនឹងអំណាចនៃសេចក្ដីដោះលែងឲ្យរួចផុត » ( នីហ្វៃទី ១ ១:២០ ) ។

ពិតណាស់ ផ្ទៃរឿងមួយនៃព្រះគម្ពីរមរមន — និងជីវប្រវត្តិរបស់ព្យាការី យ៉ូសែប — គឺថា មនុស្សទន់ខ្សោយដែលស្វែងរកព្រះអម្ចាស់ដោយរាបសានៅក្នុងសេចក្ដីជំនឿ ត្រូវបានធ្វើឲ្យមាំមួន ហើយខ្លាំងក្លានៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ ការពង្រឹងនេះនឹងកើតមាន សូម្បីតែកិច្ចការដែលហាក់ដូចជារឿងតូចតាចក្ដី ។

ឧទាហរណ៍ យ៉ូសែប ជាមនុស្សដែលមិនសូវចេះប្រកបពាក្យ ត្រូវបានកែតម្រូវការប្រកបឈ្មោះ*Coriantumr* ( *កូរីអានទុមើរ* ) ( សូមមើល ហេលេមិន ១:១៥ ) ពីសំណាក់អ្នកសរសេរទីមួយរបស់លោកឈ្មោះ អូលីវើរ ខៅឌើរី ។ លើកទីមួយដែលយ៉ូសែបបានសរសេរឈ្មោះនោះឲ្យទៅអូលីវើរ អូលីវើរបានសរសេរថា *Coriantummer* ( *កូរីអានទុមើរ* ) ។ នេះគឺជារឿងសមហេតុផល ដោយសារក្នុងភាសាអង់គ្លេសគ្មានពាក្យណាដែលបញ្ចប់ដោយពាក្យ « mr » នោះទេ ។ ប៉ុន្តែ យ៉ូសែប — ដែលជាមនុស្សមិនពូកែប្រកបពាក្យយល់ព្រមទទួលយកការប្រកបពាក្យនោះដែលព្រះអម្ចាស់បានប្រទានដល់លោក — ដោយបានកែតម្រូវការប្រកបពាក្យនោះ ក្នុងអំឡុងពេលធ្វើការបកប្រែ ។ ឥឡូវនេះ យើងដឹងថា ខណៈដែលឈ្មោះនោះគឺជាការប្រកបដ៏ចម្លែកមួយជាភាសាអង់គ្លេស ប៉ុន្តែវាគឺជាការប្រកបដ៏ល្អបំផុតជាភាសាអេស៊ីព្ទ ហើយត្រូវគ្នានឹងមជ្ឈដ្ឋាននៃព្រះគម្ពីរសញ្ញាចាស់ ។ យ៉ូសែបនឹងពុំបានដឹងអំពីរឿងនេះឡើយ លើកលែងតែតាមរយៈវិវរណៈប៉ុណ្ណោះ ។[៦]

**យើងអាចត្រូវបានធ្វើឲ្យមាំមួន**

អព្ភូតហេតុនៃការបកប្រែព្រះគម្ពីរមរមនគឺជាគំរូមួយនៃរបៀបដែលយ៉ូសែបត្រូវបានធ្វើឲ្យមាំមួនចេញពីភាពទន់ខ្សោយ ។ មាននូវមេរៀនកាន់តែផ្ទាល់ខ្លួនមួយទៀត ៖ ដូចជាយ៉ូសែបដែរ ប្រសិនបើយើងនឹងស្គាល់ពីភាពទន់ខ្សោយរបស់យើង ហើយងាកទៅរកព្រះអម្ចាស់នៅក្នុងសេចក្ដីជំនឿឲ្យអស់ពីដួងចិត្តរបស់យើង ដោយតាំងចិត្តធ្វើតាមព្រះទ័យរបស់ទ្រង់ យើងក៏នឹងត្រូវបានធ្វើឲ្យមាំមួនចេញពីភាពទន់ខ្សោយដែរ ។ នេះពុំមែនមានន័យទាំងស្រុងថា ភាពទន់ខ្សោយទាំងអស់ត្រូវបានលុបចោលពីក្នុងជីវិតរមែងស្លាប់នោះទេ — ប៉ុន្តែវាមានន័យថា បុគ្គលបែបនេះនឹងត្រូវបានព្រះធ្វើឲ្យមានភាពមាំមួន ។

យ៉ូសែបបានសារភាពពីភាពពុំល្អឥតខ្ចោះរបស់លោកដោយចិត្តរាបសា ។ លោកបានកត់សម្គាល់ថា កាលលោកនៅជាយុវវ័យ លោក « បានសម្ដែងនូវការទន់ខ្សោយនៃយុវវ័យ និងការឆ្កួតលីលានៃមនុស្សលោក » ( យ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១:២៨ ) ។ លុះក្រោយមកទៀត លោកបានប្រាប់ពួកបរិសុទ្ធនៅទីក្រុង ណៅវូ ថា លោក « ជាមនុស្សម្នាក់ ហើយពួកគេកុំរំពឹងថា [ លោក ] ល្អឥតខ្ចោះ . . . ប៉ុន្តែបើពួកគេទទួលនូវភាពទន់ខ្សោយរបស់ [ លោក ] និង ភាពទន់ខ្សោយរបស់បងប្អូនប្រុស នោះ [ លោក ] នឹងទទួលនូវភាពទន់ខ្សោយរបស់គេវិញដែរ » ។[៧]

យ៉ូសែបពុំដែលធ្វើពុតថា លោកជាមនុស្សល្អឥតខ្ចោះ ឬមិនចេះភាន់ច្រឡំនោះទេ ប៉ុន្តែលោកទទួលស្គាល់ព្រះចេស្ដារបស់ព្រះដែលបានប្រើតាមរយៈលោកពេលបំពេញភារកិច្ចជាព្យាការី ៖ « ពេលខ្ញុំនិយាយជាមនុស្សធម្មតាម្នាក់ នោះគឺជាយ៉ូសែបតែប៉ុណ្ណោះដែលនិយាយ ។ ប៉ុន្តែពេលព្រះអម្ចាស់មានបន្ទូលតាមរយៈខ្ញុំ នោះគឺយ៉ូសែប ស្ម៊ីធ មិននិយាយទៀតឡើយ ប៉ុន្តែគឺជាព្រះវិញ » ។[៨]

ដូច្នេះចេញពីភាពទន់ខ្សោយ យ៉ូសែបត្រូវបានធ្វើឲ្យមាំមួន — មាំមួនល្មមគ្រប់គ្រាន់ដើម្បី « សម្រេចច្រើនជាងគេ លើកលែងតែព្រះយេស៊ូវប៉ុណ្ណោះសម្រាប់សេចក្ដីសង្គ្រោះដល់មនុស្ស » ( គ. និង ស. ១៣៥:៣ ) ច្រើនជាងព្យាការីផ្សេងទៀតនៅក្នុងប្រវត្តិសាស្ត្រ ។

ព្រះដ៏មិនផ្លាស់ប្ដូររបស់យើងក៏នឹងធ្វើឲ្យអ្នក និងខ្ញុំមាំមួនចេញពីភាពទន់ខ្សោយដូចគ្នាដែរ — ប្រសិនបើយើងនឹងងាកទៅរកទ្រង់ដោយសេចក្ដីជំនឿជាមួយនឹងដួងចិត្តដ៏ពេញលេញ ដូចជាយ៉ូសែបបានធ្វើ ។





*សេចក្ដីដកស្រង់មួយមកពីព្រះគម្ពីរមរមនដែលសរសេរដោយដៃដែលត្រូវគ្នានឹងនីហ្វៃទី ១ ៣:៧ ។*




**ការអធិស្ឋាន និងសេចក្ដីរាបសា**

យោងតាមការគ្រាស់ដឹងខាងសេឡេស្ទាលរបស់ទ្រង់ ព្រះអម្ចាស់ប្រទានដល់យើងនូវភាពទន់ខ្សោយដើម្បីជួយសម្របសម្រួលយើងឲ្យមានភាពមាំមួនតាមរបៀបមួយគាត់ដែលចាំបាច់នៅក្នុងជីវិតនេះ និងភាពអស់កល្បជានិច្ច — គឺ តាមរយៈទ្រង់ ។ ទ្រង់មានបន្ទូលថា « បើសិនជាមនុស្សលោកមករកយើង នោះយើងនឹងបង្ហាញដល់ពួកគេនូវភាពទន់ខ្សោយរបស់ពួកគេ ។ យើងឲ្យភាពទន់ខ្សោយទៅមនុស្ស ដើម្បីឲ្យពួកគេអាចបានរាបសា ហើយគុណរបស់យើងមានគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់ ដែលបន្ទាបខ្លួននៅចំពោះយើង ដ្បិតបើសិនជា ពួកគេបន្ទាបខ្លួននៅចំពោះយើង ហើយមានសេចក្ដីជំនឿដល់យើងលំដាប់នោះយើងនឹងធ្វើឲ្យអ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែចំពោះពួកគេវិញ » ( អេធើរ ១២:២៧ ) ។

យោងតាមបទគម្ពីរនេះ យើងត្រូវបានប្រទានឲ្យនូវភាពទន់ខ្សោយ ដើម្បីយើងអាចមានចិត្តរាបសា ។ អស់អ្នកដែលជ្រើសមានចិត្តរាបសា ហើយអនុវត្តសេចក្ដីជំនឿលើទ្រង់នឹងត្រូវបានធ្វើឲ្យមាំមួន ។ បន្ទាប់មក សេចក្ដីរាបសារបស់យើងនៅចំពោះព្រះគឺជាកត្តាដ៏ចាំបាច់មួយដើម្បីឲ្យកម្លាំង និងព្រះចេស្ដានៃព្រះបើកសម្ដែងឡើងនៅក្នុងជីវិតរបស់យើង ។







មានមនុស្សដែល « គិតស្មានថា គេបានដឹងដោយខ្លួនគេសព្វគ្រប់ហើយ ហេតុដូច្នោះហើយ ប្រាជ្ញារបស់គេនោះ គឺជាសេចក្ដីឆ្កួតលីលា ហើយមិនផ្ដល់ប្រយោជន៍អ្វីដល់ពួកគេឡើយ ហើយពួកគេនឹងត្រូវវិនាសទៅ » ( នីហ្វៃទី ២ ៩:២៨ ) ។ ថ្នាំបន្សាបចំពោះអំនួតនេះគឺត្រូវ « ព្រមទទួលខ្លួនថា ល្ងង់ល្ងើនៅចំពោះព្រះ ហើយបន្ទាបខ្លួនចុះដល់ជម្រៅនៃភាពទន់ទាប » ( នីហ្វៃទី ២ ៩:៤២ ) ។

កាលលោកនៅជាយុវវ័យ យ៉ូសែបបានយល់ថា គន្លឹះដ៏សំខាន់មួយដើម្បីអភិវឌ្ឍសេចក្ដីរាបសាគឺ ត្រូវស្វែងរកព្រះវរបិតាសួគ៌របស់យើងតាមរយៈការអធិស្ឋានដោយចិត្តស្មោះអស់ពីដួងចិត្ត ។ ដានីយ៉ែល ថៃលើរ ជាសមាជិកសាសនាចក្រម្នាក់កាលពីជំនាន់មុន បាននឹកចាំពីគ្រាមួយនៅទីក្រុងខឺតឡង់ដែលមានមនុស្សជាច្រើនបានបែរមកទាស់នឹងព្យាការី ។ បងប្រុស ថៃលើរ ដែលមានវត្តមាននៅក្នុងការប្រជុំមួយដែលព្យាការីបានអធិស្ឋានជាមួយនឹងក្រុមជំនុំទូលសូមជំនួយរបស់ព្រះអម្ចាស់ បានរៀបរាប់អំពីបទពិសោធន៍នោះនៅក្នុងពាក្យពេចន៍ទាំងនេះថា

« ខ្ញុំធ្លាប់ស្ដាប់ឮបុរសស្ត្រីអធិស្ឋាន . . . ប៉ុន្តែទើបតែពេលនោះទេដែលខ្ញុំបានស្ដាប់ឮបុរសម្នាក់ទូលទៅព្រះរបស់លោកហាក់ដូចជាទ្រង់កំពុងគង់នៅស្ដាប់ប្រៀបបាននឹងឪពុកដ៏មានសន្ដានចិត្តល្អមួយកំពុងស្ដាប់អំពីទុក្ខសោករបស់កូនម្នាក់ដែលកំពុងយកចិត្តទុកដាក់នឹងកាតព្វកិច្ចដែរ ។ យ៉ូសែបនៅគ្រានោះពុំបានដឹងនោះទេ ប៉ុន្តែការអធិស្ឋាននោះ ដែលធ្វើឡើងទុកជាប្រយោជន៍ដល់អស់អ្នកដែលបានចោទប្រកាន់លោកថាបានបែកវង្វេង . . . បានទទួលនូវការរៀនសូត្រ និងទេពកោសល្យមកពីស្ថានសួគ៌ ។ . . . វាបង្ហាញឲ្យខ្ញុំឃើញថា លើកលែងតែវាំងននត្រូវបានដកចេញនោះដូចជាខ្ញុំអាចមើលឃើញព្រះអម្ចាស់កំពុងឈរនៅពីមុខអ្នកបម្រើដ៏រាបសាបំផុតក្នុងចំណោមពួកអ្នកបម្រើរបស់ទ្រង់ទាំងអស់ដែលខ្ញុំធ្លាប់បានឃើញ » ។[៩]

**កម្លាំងចេញពីភាពទន់ខ្សោយ**

ពេលយ៉ូសែបមានវ័យ ១៧ ឆ្នាំ ម៉ូរ៉ូណៃបានប្រាប់លោកថា « ព្រះទ្រង់មានកិច្ចការឲ្យខ្ញុំធ្វើ ហើយថាឈ្មោះរបស់ខ្ញុំ នឹងមានដើម្បីសេចក្ដីល្អ និងសេចក្ដីអាក្រក់ក្នុងគ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស ហើយគ្រប់ទាំងភាសា ឬថាឈ្មោះខ្ញុំនឹងត្រូវនិយាយដល់ទាំងសេចក្ដីល្អ និងសេចក្ដីអាក្រក់នៅក្នុងចំណោមបណ្ដាជនទាំងអស់ » ( យ៉ូសែប ស៊្មីធ — ប្រវត្តិ ១:៣៣ ) ។

ខ្ញុំជឿជាក់ថា នៅពេលនោះ មានមនុស្សជាច្រើនបានគិតថា ការប្រកាសមួយបែបនេះគឺជាកស្ដុតាងនៃភាពរវើរវាយនៃភាពអួតអាង ប៉ុន្តែនៅក្នុងពិភពលោកសព្វថ្ងៃនេះដោយមាននូវអ៊ិនធើណែត ឈ្មោះក្មេងប្រុសស្រុកស្រែដែលមិនសូវមានគេឯងស្គាល់នោះ *ត្រូវបាន* ស្គាល់ជុំវិញសាកលលោក ហើយគេនិយាយអំពីលោកទាំងសេចក្ដីល្អ និងសេចក្ដីអាក្រក់ ។






*ពីមុនយ៉ូសែប និងហៃរុម ស៊្មីធ បានទទួលមរណភាពនៅគុកកាតធេច រដ្ឋអិលលីណោយបន្តិច ហៃរុមបានអានឮៗឲ្យយ៉ូសែប និងអ្នកផ្សេងទៀតចេញពីសំណៅនៃព្រះគម្ពីរមរមន ។*

ពីមុនយ៉ូសែប និងហៃរុម ស៊្មីធ បានទទួលមរណភាពនៅគុកកាតធេច រដ្ឋអិលលីណោយបន្តិច ហៃរុមបានអានឮៗឲ្យយ៉ូសែប និងអ្នកផ្សេងទៀតដែលនៅក្នុងបន្ទប់ក្នុងគុកនោះជាមួយពួកលោកស្ដាប់ រួចហើយបានបត់ទំព័រនោះដែលមានពាក្យពេចន៍ដូចតទៅនេះ ៖

« ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានអំពាវនាវដល់ព្រះអម្ចាស់ សូមឲ្យទ្រង់ប្រទានដល់ពួកសាសន៍ដទៃនូវព្រះគុណ ដើម្បីឲ្យពួកគេអាចមានសេចក្ដីសប្បុរស ។

« ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា ៖ បើសិនជាពួកគេគ្មានសេចក្ដីសប្បុរសទេ វាមិនជាសំខាន់អ្វីដល់អ្នកទេ គឺអ្នកបានស្មោះត្រង់ ហេតុដូច្នោះហើយ សំលៀកបំពាក់របស់អ្នកនឹងត្រូវបានធ្វើឲ្យជ្រះស្អាត ។ ពីព្រោះអ្នកបានឃើញភាពទន់ខ្សោយរបស់ខ្លួន នោះអ្នកនឹងត្រូវបានធ្វើឲ្យខ្លាំងពូកែ រហូតដល់បានអង្គុយឯទីកន្លែង ដែលយើងបានរៀបចំទុក នៅក្នុងវិមានទាំងឡាយនៃព្រះវរបិតារបស់យើង » ( អេធើរ ១២:៣៦–៣៧ ) ។

នៅក្នុងន័យត្រឹមត្រូវមួយ គឺយ៉ូសែបត្រូវបានធ្វើឲ្យមាំមួន *ចេញពីទន់ខ្សោយ* ។ ដោយបានទាក់ទាញទឹកចិត្តមួយចំណែក តាមរយៈភាពទន់ខ្សោយរបស់លោក លោកបានស្វែងរកជំនួយរបស់ព្រះដោយសេចក្ដីជំនឿ ដោយបានតាំងចិត្តធ្វើសកម្មភាពស្របតាមព្រះទ័យរបស់ទ្រង់ ។ លោកបានខិតទៅជិតព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌តាមលក្ខខណ្ឌទាំងនេះពេញមួយជីវិតរបស់លោក ។ ជាលទ្ធផល លោកបានដកពិសោធន៍នូវការនិមិត្តដំបូង បានបកប្រែព្រះគម្ពីរមរមន បានទទួលកូនសោបព្វជិតភាព បានរៀបចំសាសនាចក្ររបស់ព្រះគ្រីស្ទដែលបានស្ដារឡើងវិញ ហើយបាននាំមកកាន់ផែនដីនេះនូវភាពពេញលេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ ព្យាការីយ៉ូសែបបានមាំមួនឡើង លោកពុំត្រូវបានធ្វើឲ្យខ្លាំងក្លាតែមួយគ្រានោះទេ ។ វាបានកើតឡើងចំពោះលោក ហើយវានឹងកើតឡើងចំពោះអ្នក និងខ្ញុំដែរ « មួយបន្ទាត់ម្ដងៗមួយសិក្ខាបទម្ដងៗ ឯណេះបន្តិច ឯណោះបន្តិច» ( គ. និង ស. ១២៨:២១, សូមមើលផងដែរ អេសាយ ២៨:១០, នីហ្វៃទី ២ ២៨:៣០ ) ។

ដូច្នេះសូមកុំបាក់ទឹកចិត្ត ។ ដំណើរការនៃការធ្វើឲ្យមាំមួនមានបន្តិចម្ដងៗ ហើយវាតម្រូវឲ្យមានការអត់ធ្មត់ជាមួយនឹងការតាំងចិត្តដ៏ខ្ជាប់ខ្ជួនដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ ហើយប្រតិបត្តិតាមព្រះទ័យរបស់ទ្រង់ ទោះជាមានអ្វីកើតឡើងក្ដី ។

**អំណោយទាននោះបានត្រឡប់មកវិញហើយ**

វិល្លាម ធីនឌេល ដែលបានបកប្រែ ហើយបានបោះពុម្ពព្រះគម្ពីរប៊ីបជាភាសាអង់គ្លេសនៅសតវត្សរ៍ទី ១៦ បានថ្លែងទៅកាន់បុរសដែលមានចំណេះដឹងម្នាក់ដែលបានបដិសេធមិនឲ្យបញ្ចេញព្រះគម្ពីរប៊ីបទៅដល់មនុស្សសាមញ្ញថា « ប្រសិនបើព្រះទុកជីវិតឲ្យខ្ញុំ ជាច្រើនឆ្នាំទៅមុខទៀត *ខ្ញុំនឹងធ្វើឲ្យក្មេងប្រុសម្នាក់ដែលភ្ជួររាស់ស្រែបានដឹងច្រើនអំពីបទគម្ពីរជាងអ្នកទៅទៀត* » ។[១០]

នៅក្នុងភាពស្រដៀងគ្នាមួយ ៣០០ ឆ្នាំក្រោយមក នេនស៊ី ថូយឡេ ជាគ្រូគង្វាលដ៏ល្បីល្បាញម្នាក់ក្នុងទសវត្សរ៍ឆ្នាំ ១៨៣០ បានមកទស្សនកិច្ចនៅទីក្រុងខឺតឡង់ ដើម្បីសង្កេតមើលដោយផ្ទាល់អំពី « សាសនាមរមន » ។ នៅក្នុងការសន្ទនាជាមួយនឹងយ៉ូសែប ស៊្មីធ និងថ្នាក់ដឹកនាំផ្សេងទៀតក្នុងសាសនាចក្រ លោកស្រីបានរិះគន់ដល់សាសនាចក្រយ៉ាងខ្លាំង ។

ស្របតាមកំណត់ត្រារបស់ ថូយឡេ យ៉ូសែបពុំបានថ្លែងអ្វីទាំងអស់រហូតដល់លោកស្រីបានត្រឡប់មករកលោកវិញ ហើយបានទាមទារឲ្យលោកស្បថថា មានទេវតាមួយអង្គដែលបានបង្ហាញលោកអំពីកន្លែងទៅរកផ្ទាំងចំណារមាសនោះ ។ លោកបានឆ្លើយតបទាំងរីករាយថា លោកពុំធ្លាប់ស្បថពីមុនឡើយ ! ដោយចាប់កំហុសលោកពុំបាន លោកស្រីបានព្យាយាមបង្ខូចកិត្តិយសលោក ។ លោកស្រីបានសួរថា « តើលោកពុំខ្មាស់គេទេឬអី ដែលលាក់ពុតបែបនេះ ? « លោកគ្មានអ្វីលើសពីក្មេងស្រុកស្រែដ៏ល្ងង់ខ្លៅនៅក្នុងប្រទេសជាតិរបស់យើងឡើយ ! »

យ៉ូសែបបានឆ្លើយតបទាំងចិត្តស្ងប់ថា « អំណោយទាននោះបានត្រឡប់មកវិញហើយ ដូចកាលពីបុរាណដែរ គឺដល់អ្នកនេសាទដែលមិនចេះអក្សរ » ។[១១]



ដូច្នេះពាក្យសម្ដីរបស់ ធីនឌេល ត្រូវបានព្យាករទុកថា ក្មេងប្រុសស្រុកស្រែម្នាក់ពិតជាដឹងបទគម្ពីរច្រើនជាង ប្រហែលជាច្រើនជាងមនុស្សណាៗទាំងអស់ លើកលែងតែព្រះអង្គសង្គ្រោះ ។

ពិតណាស់ សាសនាចក្រ និងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញពុំមែនជាកិច្ចការ *របស់* យ៉ូសែប ស្ម៊ីធ ដែលជាក្មេងប្រុសស្រុកស្រែនៅអាមេរិកនោះទេ ។ ប៉ុន្តែវាគឺជាកិច្ចការរបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ដែលបានស្ដារឡើងវិញ *តាមរយៈ* យ៉ូសែប ស្ម៊ីធ ជាព្យាការី ។ ពេលលោកសញ្ជឹងគិតអំពីជីវិតរបស់លោក យ៉ូសែបអាចនឹងបន្លឺសំឡេងជាមួយការសង្កេតមើលរបស់យ៉ាកុបថា « ព្រះអម្ចាស់ដ៏ជាព្រះទ្រង់បានបង្ហាញយើងនូវភាពទន់ខ្សោយរបស់យើងដើម្បីអោយយើងដឹងថា គឺដោយសារព្រះគុណ និងការបន្ទាបខ្លួនដ៏មហិមារបស់ទ្រង់ចំពោះកូនចៅមនុស្ស ទើបយើងមានអំណាចដើម្បីធ្វើនូវកិច្ចការទាំងនេះបាន » ( យ៉ាកុប ៤:៧ ) ។

ខ្ញុំដឹងថា យ៉ូសែប ស្ម៊ីធ ធ្លាប់ និង ជាព្យាការីរបស់ព្រះ ដែលត្រូវបានធ្វើឲ្យមាំមួនចេញពីភាពទន់ខ្សោយ ។ ប្រធាន ព្រិកហាំ យ៉ង់ ( ១៨០១–៧៧ ) បានថ្លែងថា « ខ្ញុំមានអារម្មណ៍ដូចជាស្រែកច្រៀងបទហាឡេលូយ៉ា រាល់ពេលដែលខ្ញុំគិតថា ខ្ញុំធ្លាប់ស្គាល់យ៉ូសែប ស្ម៊ីធ ជាព្យាការី » ។[១២] ខណៈដែលខ្ញុំគ្មានឱកាសបែបនោះនៅក្នុងជីវិតរមែងស្លាប់ ខ្ញុំមានចិត្តយ៉ាងស្កប់ស្កល់ក្នុងការធ្វើការសន្យាថា « មនុស្សរាប់លាននាក់នឹងស្គាល់ ‹ បងប្រុសយ៉ូសែប › ម្ដងទៀត » ។[១៣] ខ្ញុំមានអំណរគុណយ៉ាងខ្លាំងចំពោះព្យាការី និងសេចក្ដីរាបសារបស់លោកនៅចំពោះព្រះរបស់យើង ជាអង្គដែលបានធ្វើឲ្យលោកមាំមួន ។ ខ្ញុំក៏ទទួលបានការលើកទឹកចិត្តតាមរយៈដំណើររឿងប្រវត្តិសាស្ត្រនេះ និងគោលលទ្ធិថា ព្រះអម្ចាស់នឹងធ្វើឲ្យយើងម្នាក់ៗមាំមួនចេញពីភាពទន់ខ្សោយ ប្រសិនបើយើងបន្ទាបខ្លួនយើងនៅចំពោះទ្រង់ដោយរាបសា ហើយអនុវត្តសេចក្ដីជំនឿរបស់យើងលើទ្រង់ដោយមានការតាំងចិត្តយ៉ាងខ្ជាប់ខ្ជួនដើម្បីធ្វើតាមព្រះទ័យរបស់ទ្រង់ ។ ■

*ដកស្រង់ចេញពីសុន្ទរកថា* « Out of Weakness He Shall Be Made Strong » *( ចេញពីភាពទន់ខ្សោយ អ្នកនោះនឹងត្រូវបានធ្វើឲ្យមាំមួន ) ដែលធ្វើឡើងនៅការប្រជុំធម្មនិដ្ឋានរំឭកដល់ យ៉ូសែប ស្ម៊ីធ ប្រចាំឆ្នាំលើកទី ៧០ នៅទីក្រុងឡូហ្គែន រដ្ឋយូថាហ៍ ស.រ.អា. នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ។*

**កំណត់ចំណាំ**


១. ខ្ញុំសូមអរគុណដល់មិត្តរួមការងាររបស់ខ្ញុំ ជាពិសេស រីឆាត អ៊ី ធើរលី ជុញ្ញ័រ និងជេដ វូដវស់ នៅក្នុងនាយកដ្ឋានប្រវត្តិសាស្ត្រសាសនាចក្រសម្រាប់គំនិតដ៏មានន័យរបស់ពួកគេ ។
២. យ៉ូសែប ស្ម៊ីធ នៅក្នុង The Joseph Smith Papers, Histories, Volume 1: 1832–1844, និពន្ធដោយ ខារេន លីន ដេវីឌសុន និងអ្នកនិពន្ធផ្សេងទៀត ( ឆ្នាំ២០១២ ) ទំព័រ ១១ ។
៣. យ៉ូសែប ស្ម៊ីធ « Letter to William W. Phelps, 27 November 1832, » ទំព័រ ៤, josephsmithpapers.org ។
៤. អិមម៉ា ស្ម៊ីធ នៅក្នុង « Last Testimony of Sister Emma » *Saints' Herald,* ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៨៧៩ ទំព័រ ២៩០, សូមមើលផងដែរ រ័សុល អិម ណិលសុន « A Treasured Testament » *Ensign,* ខែ កក្កដា ឆ្នាំ ១៩៩៣ ទំព័រ ៦២–៦៣ ។
៥. យ៉ូសែប ស្ម៊ីធ នៅក្នុង *The Joseph Smith Papers, Histories, Volume 1: 1832–1839,* និពន្ធដោយ ឌីន ស៊ី ជេសស៊ី និងអ្នកនិពន្ធផ្សេងទៀត ( ឆ្នាំ២០០៨ ) ទំព័រ ៩ ។
៦. ស្ដីពី « Coriantumr » និងការប្រកបនៃឈ្មោះត្រឹមត្រូវ សូមមើល Royal Skousen, in *Book of Mormon Authorship Revisited: The Evidence for Ancient Origins,* និពន្ធដោយ ណូអេល ប៊ី រេណុល ( ឆ្នាំ១៩៩៧ ) ទំព័រ ៦១–៩៣ ។ ដោយប្រើភស្តុតាងមកពីច្បាប់ដើមនៃការសរសេរដោយដៃ ស្កូសិន បង្ហាញថា លើកទីមួយឈ្មោះត្រឹមត្រូវបានលេចឡើងនៅលើអត្ថបទ ឈ្មោះនោះត្រូវបានប្រកបយ៉ាងត្រឹមត្រូវ ។ នៅក្នុងការបង្ហាញបន្តបន្ទាប់មកទៀត ឈ្មោះនោះប្រហែលជាប្រកបមិនត្រឹមត្រូវទេ ដោយផ្ដល់យោបល់ថា យ៉ូសែប ស្ម៊ីធ ប្រកបឈ្មោះនីមួយៗឮៗជាលើកដំបូងសិន ប៉ុន្តែក្រោយមកលោកពឹងផ្អែកលើការចងចាំរបស់អ្នកសរសេរ ។
៧. *Teachings of Presidents of the Church: Joseph Smith,* ( ឆ្នាំ ២០០៧ ) ទំព័រ ៥២២ ។
៨. អ៊ែតវើឌ ស្ទីវែនសុន នៅក្នុង Hyrum L. Andrus and Helen Mae Andrus, comps., *They Knew the Prophet,* ( ឆ្នាំ ១៩៧៤ ) ទំព័រ ៨៧ ។
៩. ដានីយ៉ែល ថៃលើរ នៅក្នុង « Recollections of the Prophet Joseph Smith » *Juvenile Instructor,* ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៨៩២ ទំព័រ ១២៧, សូមមើលផងដែរ *Teachings: Joseph Smith,* ទំព័រ ១២៧ ។
១០. វិល្លាម ធីនឌេល នៅក្នុង S. Michael Wilcox, *Fire in the Bones: William Tyndale — Martyr, Father of the English Bible* ( ឆ្នាំ ២០០៤ ) ទំព័រ ៤៧ ។
១១. *Vicissitudes Illustrated, in the Experience of Nancy Towle, in Europe and America* ( ឆ្នាំ ១៨៣៣ ) ទំព័រ ១៥៦, ១៥៧ ។
១២. *Teachings of Presidents of the Church: Brigham Young* ( ឆ្នាំ ១៩៩៧ ) ទំព័រ ៣៤៣ ។
១៣. « សរសើរដល់លោក » *ទំនុកតម្កើង,* លរ.១៦ ។




**ការទទួលបានចំណេះដឹង និងភាពចាស់ទុំជាបន្តបន្ទាប់របស់យ៉ូសែប**

« ផ្នែកដ៏សំខាន់នៅក្នុងការងារបម្រើទាំងមូលរបស់ព្យាការី យ៉ូសែប គឺនៅក្នុងយុវវ័យរបស់លោក ការអប់រំបន្ថែមរបស់លោក និងការទទួលបានយ៉ាងច្រើននូវចំណេះដឹង និងភាពចាស់ទុំជាបន្តបន្ទាប់របស់លោក ។ លោកមានវ័យ ១៤ ឆ្នាំ ពេលមានការនិមិត្តដំបូង និងមានវ័យ ១៧ ឆ្នាំ ពេលទេវតាម៉ូរ៉ូណៃមកជួបលើកដំបូង ។ លោកមានវ័យ ២១ ឆ្នាំពេលលោកបានទទួលផ្ទាំងចំណារមាស ហើយឈានចូលវ័យ ២៣ ឆ្នាំពេលលោកបញ្ចប់ការបកប្រែព្រះគម្ពីរមរមន ( តិចជាង ៦០ថ្ងៃ ) ។ វិវរណៈច្រើនជាងពាក់កណ្ដាលនៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញាត្រូវបានប្រទានឲ្យតាមរយៈព្យាការី ខណៈលោកមានវ័យ ២៥ ឆ្នាំ ឬក្មេងជាងនេះ ។ លោកមានវ័យ ២៦ ឆ្នាំពេលគណៈប្រធានទីមួយត្រូវបានរៀបចំឡើង ហើយក្នុងវ័យ ៣០ ឆ្នាំពេលព្រះវិហារបរិសុទ្ធខឺតឡង់ត្រូវបានឧទ្ទិសឆ្លង » ។

អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « **Joseph, the Man and the Prophet,** » ***Ensign,*** ខែ ឧសភា ឆ្នាំ ១៩៩៦ ទំព័រ ៧១ ។



យើងអាចធ្វើបានប្រសើរជាង ភាគ ២ ៖

# ការស្វែងរកកន្លែងរបស់អ្នក នៅក្នុងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ

*សូមកុំបណ្ដោយឲ្យមនុស្សដទៃរារាំងអ្នកពីការរីករាយនឹងពរជ័យនៃសមាជិកភាពនៅក្នុងសាសនាចក្ររបស់ព្រះគ្រីស្ទឡើយ ។*



ដោយ ប៊េតសី វ៉ាន់ឌេនប៊ឺហ្គហេ

*សារខ្លីរបស់និពន្ធនាយក ៖ មិនថាជំនឿរបស់យើងលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទខ្លាំងដល់កម្រិតណាទេ ការបន្តស្មោះត្រង់អាចនឹងមានភាពពិបាក ប្រសិនបើយើងមានអារម្មណ៍ថាយើងគ្មានចំណែកនោះ ។ ថ្មីៗនេះ ថ្នាក់ដឹកនាំក្នុងសាសនាបានលើកឡើងពីការប្រឈមនេះនៅក្នុងស៊េរីវីដេអូដែលមានចំណងជើងថា សាមគ្គីភាពនៅក្នុងភាពទីទៃពីគ្នា ។ នៅក្នុងការចេញផ្សាយខែ កញ្ញា ឆ្នាំ ២០១៧ « យើងអាចធ្វើបានប្រសើរ ៖ ការស្វាគមន៍មនុស្សដទៃចូលមកក្នុងក្រុម » បានកំណត់អំពីការទទួលខុសត្រូវរបស់យើងដើម្បីស្វាគមន៍ដល់មនុស្សដទៃ ។ អត្ថបទភាគ ២ នេះសម្លឹងមើលអំពីរបៀបដែលយើងអាចបំពេញការទទួលខុសត្រូវរបស់យើងសម្រាប់ជំនឿផ្ទាល់ខ្លួនរបស់យើង មិនថាយើងមានអារម្មណ៍ថា យើងមានចំណែកដែរឬអត់នោះទេ ។*

បន្ទាប់ពីពុំបានទៅព្រះវិហារអស់រយៈពេលប្រាំបីឆ្នាំ ផៅឡូ ( ឈ្មោះទាំងអស់ត្រូវបានផ្លាស់ប្ដូរ ) បានទទួលទូរស័ព្ទមួយមកពីប៊ីស្សពរបស់គាត់នៅប្រទេសប្រេស៊ីលដោយសួរថា គាត់សុខទុក្ខយ៉ាងណា ។ ផៅឡូចង់ត្រឡប់ទៅវិញយូរហើយ ប៉ុន្តែមានកង្វល់ជាច្រើនដែលរារាំងគាត់ពីការសកម្មដ៏ពេញលេញ ។ តើគាត់អាចចៀសវាងពីការប្រៀបធៀបខ្លួនឯងដែលនៅលីវទៅនឹងអ្នកដែលបានរៀបការ ហើយមានកូនតាមរបៀបណា ? តើគាត់នឹងមានមិត្តភក្តិណាម្នាក់នៅឯព្រះវិហារដែរឬទេ បន្ទាប់ពីគាត់ពុំបានទៅយូរហើយ ហើយប្រសិនបើគាត់មាន តើពួកគេគិតយ៉ាងដូចម្ដេចអំពីគាត់ ? តើគាត់នៅតែអាចមានអារម្មណ៍អំពីព្រះវិញ្ញាណដូចដែលគាត់ធ្លាប់មា នពេលគាត់ប្រែចិត្តជឿ និងក្នុងបេសកកម្ម ឬមានសេចក្ដីជំនឿគ្រប់គ្រាន់ដើម្បីទទួលការហៅនានាដែរឬទេ ?

បន្ទាប់ពីបានទទួលទូរសព្ទនោះមួយខែមក ផៅឡូបានមើលប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ ថ្លែងសុន្ទរកថាក្នុងសន្និសីទមួយដែលមានចំណងជើងថា « មក ចូលរួមជាមួយយើង » ។[1] គាត់នៅចាំថា « សុន្ទរកថានោះចាក់ក្នុងដួងចិត្តរបស់គាត់ខ្លាំងណាស់ » ហើយតែពីរបីសប្ដាហ៍ប៉ុណ្ណោះ គាត់បានបើករថយន្តទៅចំណតរថយន្តរបស់ព្រះវិហារ ហើយធ្វើការអធិស្ឋានដោយស្ងៀមស្ងាត់មួយទាំងញ័រខ្លួនចំប្រប់ទូលសូមកម្លាំងដើម្បីចេញពីរថយន្តនោះ ហើយដើរចូលទៅក្នុងអគារ ។

គាត់នឹកចាំពីឆ្នាំដំបូងបន្ទាប់ពីគាត់ត្រឡប់មកវិញថា « អ្វីៗគ្រប់យ៉ាងពុំល្អឥតខ្ចោះនោះទេ » ។ វាពុំងាយសម្របខ្លួនបានឡើយ ។ ប៉ុន្តែអារម្មណ៍មួយនៃការនៅជាប់នឹងព្រះអង្គសង្គ្រោះ និងបំណងប្រាថ្នាដ៏មោះមុតមួយដើម្បីទទួលបានប័ណ្ណចូលព្រះវិហារបរិសុទ្ធបានជួយគាត់ឲ្យយកឈ្នះលើភាពភ័យខ្លាចរបស់គាត់ ។ គាត់បានចាប់ផ្ដើមអានព្រះគម្ពីររបស់គាត់ ហើយអធិស្ឋានជាថ្មីឡើងវិញ ។ គាត់ណែនាំដល់អស់អ្នកដែលមានអារម្មណ៍ថាពុំមានគោរាប់អានថា « ប្រសិនបើអ្នកពុំសុខចិត្តចុះចាញ់ទេ អ្នកនឹងទទួលបានកម្លាំង ហើយអាចមានអារម្មណ៍ថាព្រះអម្ចាស់កំពុងប្រទានពរដល់អ្នក » ។ « ខ្ញុំមានទីបន្ទាល់មួយថា នេះគឺជាសាសនាចក្ររបស់ព្រះគ្រីស្ទ ប៉ុន្តែគឺអ្នកនឹងរកឃើញអារម្មណ៍ពិតនៃការមានចំណែកនោះ នៅក្នុងទ្រង់ » ។

រឿងរបស់ផៅឡូតំណាងឲ្យចំណុចជាច្រើនដែលថ្នាក់ដឹកនាំសាសនាចក្ររៀបរាប់នៅក្នុងស៊េរីវីដេអូ*សាមគ្គីភាពនៅក្នុងភាពទីទៃពីគ្នា* ។ សារលិខិតរបស់ពួកលោកផ្ដល់នូវសេចក្ដីសង្ឃឹម និងការណែនាំដល់អស់អ្នកដែលពុំមានអារម្មណ៍ថាខ្លួនគ្មានបង្អែក ។ ពេលខ្លះយើងមានអារម្មណ៍ឯកោ សូម្បីតែនៅក្នុងព្រះវិហារ ប៉ុន្តែដូចដែលថ្នាក់ដឹកនាំ និងសមាជិកទាំងនេះលើកឡើង មានរឿងជាច្រើនដែលយើងអាចធ្វើដើម្បីជួយខ្លួនយើងឲ្យឆ្លងផុតការប្រឈមនានា ដែលមានដូចជាការមិនរាប់បញ្ចូល ឬការមិនសូវរាក់ទាក់ពីសំណាក់មនុស្សដទៃទៀត ។ យើងអាចចៀសវាងពីការប្រៀបធៀប ដើរឆ្ពោះទៅមុខក្នុងភាពមិនច្បាស់លាស់ ទាំងដឹងថាតែងតែមានការត្រឡប់មកវិញជានិច្ច ហើយសំខាន់ជាងនេះទៀតគឺទុកចិត្តលើព្រះអង្គសង្គ្រោះ ។

**ចៀសវាងការប្រៀបធៀប ៖ នៅទីបំផុតយើងទាំងអស់គ្នានឹងទទួលបានពរជ័យ**

*« ពេលអ្នកចាប់ផ្ដើមប្រៀបធៀបពីគ្នាទៅវិញទៅមក វានាំទៅរកការបាក់ទឹកចិត្ត ឬវាដឹកនាំទៅរកអំនួត ។ . . . ពរជ័យនានាអាចកើតមានក្នុងរយៈពេលខ្លី ។ ពរជ័យនានាអាចកើតមានក្នុងរយៈពេលវែង ។ ខ្ញុំជឿថា ពេលខ្លះពរជ័យនានាកំពុងរង់ចាំយើង បន្ទាប់ពីយើងឆ្លងកាត់រាំងននោះ ។ . . . នៅទីបំផុត យើងអាចទទួលការអះអាងថា ការសន្យានៃជីវិតដ៏នៅអស់កល្បជានិច្ចគឺមានសម្រាប់មនុស្សគ្រប់គ្នា » ។*

— អែលឌើរ ហ្គែរី អ៊ី ស្ទីវែនសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

រ៉ូឆេលបានផ្លាស់លំនៅទៅរស់នៅក្នុងផ្ទះដ៏តូចមួយនៅតំបន់អ្នកមាននៃភាគខាងលិចសហរដ្ឋអាមេរិក បន្ទាប់ពីចំណាយពេលរស់នៅក្នុងទីជម្រករបស់មនុស្សដែលគ្មានផ្ទះសម្បែងមួយ ។ ដោយបានលះលែងពីស្វាមី ហើយត្រូវមើលថែកូនបីប្អូននាក់ នាងបានធ្វើការងារពីរ ពេលខ្លះបី ដើម្បីអាចមានលទ្ធភាពបង់ថ្លៃអាហារ និងថ្លៃឈ្នួលផ្ទះ ហើយបានអសកម្មចាប់តាំងពីនាក់បានប្រែចិត្តជឿមក ។

នាងបានពន្យល់ថា « ទោះជាមនុស្សស្ទើរតែគ្រប់គ្នានៅក្នុងវួដថ្មីរបស់ខ្ញុំទំនងជាមានជីវភាពប្រសើរជាងខ្ញុំក្ដី ក៏ពួកគេបានមករាក់ទាក់ខ្ញុំ ហើយបានទទួលយករបៀបដែលខ្ញុំស្លៀកពាក់ដែរ ។ មនុស្សគ្រប់គ្នាបានខ្វាយខ្វល់ពិតមែន » ។

ទោះបីជាស្ថិតនៅក្រោមសម្ពាធខាងហិរញ្ញវត្ថុដ៏ធំក្ដី ក៏រ៉ូឆេលពុំដែលខឹងនឹងមនុស្សដទៃចំពោះស្ថានភាពដ៏សុខស្រួលរបស់ពួកគេដែរ ។ នាងនឹកចាំថា « ពិតណាស់ ខ្ញុំចង់មានជីវភាពសមរម្យ ប៉ុន្តែខ្ញុំពុំដែលក្រឡេកទៅផ្ទះរបស់អ្នកជិតខាងខ្ញុំ ហើយមានអារម្មណ៍ថា ព្រះបានទុកខ្ញុំចោលនោះទេ ។ ខ្ញុំអាចទទួលអារម្មណ៍ថាទ្រង់កំពុងយាងដើរនៅក្បែរខ្ញុំ សូម្បីតែនៅពេលខ្ញុំធ្វើការជ្រើសរើសខុសក្ដី » ។

ទោះជាកាលវិភាគការងាររបស់រ៉ូឆេលមានភាពមមាញឹកនៅពេលខ្លះក្ដី ក៏នៅទីបំផុតថ្នាក់ដឹកនាំវួដ និងមិត្តភក្ដិបានជួយនាងឲ្យបំពេញការទន្ទឹងចង់បានដើម្បីចូលទៅក្នុងព្រះវិហារបរិសុទ្ធ ។ នាងសង្កេតឃើញថា « ការទៅព្រះវិហារបរិសុទ្ធជាទៀងទាត់ជួយខ្ញុំឲ្យមានអំណរគុណដែលខ្ញុំអាចធ្វើបានមកដល់ពេលនេះ ។ ខ្ញុំពុំបារម្ភថាមនុស្សដទៃទៀតទំនងជាដើរទៅមុខខ្ញុំនោះ ទេ » ។

រ៉ូឆេល និងកូនស្រីរបស់នាងបានជួបបញ្ហាស្មុគស្មាញ ហើយ« ពុំមែនជាគ្រួសារអិល.ឌី.អេស.ដ៏ល្អឥតខ្ចោះនោះទេ » ។ ប៉ុន្តែនាងក៏បានឃើញផងដែរថា « មនុស្សគ្រប់គ្នាមានបញ្ហា ហើយគ្មានគ្រួសារណាមួយល្អឥតខ្ចោះនោះទេ » ជាទស្សនៈមួយដែលជួយនាងឲ្យឈប់ផុតពីការមើលទៅមនុស្សដទៃ ប៉ុន្តែផ្ទុយទៅវិញផ្ដោតលើទំនាក់ទំនងរបស់នាងជាមួយនឹងព្រះ ។

នាងថ្លែងថា « កូនស្រីរបស់ខ្ញុំអាចនមើលឃើញអ្វីខុសគ្នាមួយដែលដំណឹងល្អបានផ្ដល់ឲ្យនៅក្នុងជីវិតរបស់ខ្ញុំ ។ ខ្ញុំអាចទទួលអារម្មណ៍ថាខុសប្លែកផងដែរ ហើយខ្ញុំមានការមមាញឹកល្មមគ្រប់គ្រាន់ជាមួយនឹងការងារ គ្រួសារ និងសាសនាចក្រ រហូតដល់ខ្ញុំគ្មានពេលដើម្បីប្រៀបធៀបនឹងមនុស្សដទៃឡើយ ។ ខ្ញុំគ្រាន់តែកាយនៅលើផ្លូវដ៏ត្រឹមត្រូវនេះ » ។



**សូមរឹងមាំ ៖ ព្រះគ្រីស្ទអាចកែប្រែអ្នកបាន**

*« ទោះជាមនុស្សដែលកំពុងអង្គុយក្បែរខ្ញុំមិនអើពើនឹងខ្ញុំ ឬក៏ចង់ងាកចេញឆ្ងាយពីខ្ញុំក្ដី . . . វាពុំផ្លាស់ប្ដូរជាគុតពិតនៃអ្វីដែលព្រះគ្រីស្ទមានព្រះទ័យចំពោះខ្ញុំ និងឱកាសដែលខ្ញុំមាននៅក្នុងព្រះគ្រីស្ទឡើយ ។ . . . បុគ្គលគ្រប់រូបត្រូវតាំងចិត្តថា ពួកគេនឹងមានកន្លែងមួយនៅក្នុងនគរព្រះ [ និងនៅក្នុង ] ព្រះកាយរបស់ព្រះគ្រីស្ទ ហើយមនុស្សដទៃដែលមិនចេះគិត ឬធ្វេសប្រហែស ឬកាន់តែអាក្រក់ជាងនេះទៀតពុំអាចបញ្ឈប់ការតាំងចិត្តនោះឡើយ » ។*

— អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

តាំងពីធំដឹងក្ដីមក ម៉ាថាយបានទៅព្រះវិហារក្នុងសាខាតូចៗ ។ គាត់ និងភរិយារបស់គាត់ ជាអ្នកប្រែចិត្តជឿមកពីប្រទេសអ៊ុយក្រែន ធ្លាប់មានការហៅបម្រើជាច្រើន ហើយចូលប្រឡូកយ៉ាងពេញលេញជាមួយនឹងសហគមន៍អិលឌីអេសអន្តរជាតិ ប៉ុន្តែក្រោយមកបានផ្លាស់ទៅរស់នៅសហរដ្ឋអាមេរិក ។ គាត់នឹកចាំថា វួដដ៏ធំ និងការរំពឹងទុកខាងវប្បធម៌ខុសគ្នាបានធ្វើឲ្យពួកគាត់មានអារម្មណ៍ថា « គ្មានអ្នកត្រូវការពួកគេ ហើយគ្មានគោលបំណង » ។ « យើងទំនងជាពុំចុះសម្រុងនឹងគេទេ ។ យើងបានមានអារម្មណ៍ថា គ្មានអ្នកអើពើ ដោយខ្វះនូវការលើកស្ទួយ និងទំនាក់ទំនងនៅថ្ងៃអាទិត្យ » ។

ការខកចិត្តរបស់ពួកគាត់បានទៅដល់ចំណុចធ្ងន់ធ្ងរមួយ បន្ទាប់ពីផ្លាស់ទៅទីក្រុងផ្សេងទៀតមួយទៀត ពេលម៉ាថាយ និងភរិយារបស់គាត់ទន្ទឹងរង់ចាំការមកសួរសុខទុក្ខមួយពីសំណាក់ថ្នាក់ដឹកនាំបព្វជិតភាពក្នុងមូលដ្ឋានម្នាក់ ប៉ុន្តែគោលបំណងដែលគាត់មកសួរសុខទុក្ខនោះ គឺដើម្បីសុំឲ្យពួកគេមើលថែកូនពើសរបស់ពួកគាត់កុំឲ្យពើសក្នុងអំឡុងការប្រជុំសាក្រាម៉ង់ទៅវិញ ។ ដោយមានការឈឺចាប់ខ្លាំងពេក ម៉ាថាយបានគិតថាឈប់ទៅព្រះវិហារ ។ គាត់ពន្យល់ថា « អ្វីដែលបានជួយខ្ញុំគឺជាទីបន្ទាល់របស់ខ្ញុំ នេះគឺជាសាសនាចក្ររបស់ព្រះអម្ចាស់ ហើយថាព្រះអង្គសង្គ្រោះសព្វព្រះទ័យឲ្យខ្ញុំត្រឡប់ទៅទីនោះវិញ ។ ការចូលរួមនៅក្នុងដំណឹងល្អមានសារៈសំខាន់ហួសពីការឈឺចាប់ ឬបញ្ហាផ្ទាល់ខ្លួននានាដែលខ្ញុំនឹងជួបនៅក្នុងជីវិតនេះទៅទៀត » ។

ពេលខ្លះស្ថានភាពក្នុងសាសនាចក្រអាចធ្វើឲ្យយើងមានអារម្មណ៍ឯកោ គ្មានគេឯងអើពើ និងមិនត្រូវការ ជាកាលៈទេសៈមួយដែលពុំមែនជារឿងចម្លែកចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយឡើយ ។ អ្នកនិពន្ធនិកាយកាតូលិកឈ្មោះ ដើវីឌ មីលស៍ រៀបរាប់ពីការប្រឈមដែលអ្នកទៅព្រះវិហារជួបប្រទះនៅក្នុងទំនាក់ទំនងជាមួយនឹងមនុស្សដែល « មានទ្រព្យសម្បត្តិច្រើនជាង ឬក្រជាង មានការអប់រំច្រើន ឬ តិចជាងអ្នក ។ ពួកគេប្រហែលជាមានពូជអម្បូរ ឬជាតិសាសន៍ ឬវ័យខុសពីអ្នក » ។ លោកពន្យល់ថា យើងអាចនឹងពុំជ្រើសយកពួកគេធ្វើជាបណ្ដាញផ្សេងៗនៅក្នុងសង្គមរបស់យើងឡើយ ។ ប៉ុន្តែការតាំងចិត្តខាងសាសនាវាទាក់ទងនឹងការចូលរួម









នឹងមនុស្សដែលយើងពុំជ្រើសយក ហើយ « ផ្ដល់កន្លែងមួយដែលវាប្រៀបបានទៅនឹងសហគមន៍មួយជាជាងបណ្ដាញ ។ . . . អ្នកត្រូវរៀនស្រឡាញ់មនុស្សទាំងនេះ ឬយ៉ាងហោចណាស់ប្រព្រឹត្តដោយសេចក្ដីស្រឡាញ់ ពេលអ្នកពុំចង់ធ្វើវា » ។[២] ចូរពឹងផ្អែកលើព្រះពេលអ្នកពុំអាចទប់ ឬមិនចង់រាប់អានមនុស្សនៅក្នុងសហគមន៍សាសនារបស់អ្នក ជារឿយៗវិធីល្អតែមួយគត់គឺត្រូវយកឈ្នះបញ្ហានោះ ។

ម៉ាថាយបានរកឃើញការពឹងផ្អែកលើព្រះសំខាន់ណាស់ដើម្បីបន្តសកម្មនៅក្នុងសាសនាចក្រ ។ គាត់ពន្យល់ថា « ពេលខ្លះ រឿងតែមួយគត់ដែលជួយខ្ញុំឲ្យនៅបន្តនៅសកម្មគឺជាទីបន្ទាល់របស់ខ្ញុំអំពីព្រះគ្រីស្ទ » ។ « ដំណឹងល្អគឺសំខាន់ជាងយើងទាំងអស់គ្នា ។ ព្រះគ្រីស្ទទតឃើញអ្វីដែលយើងមើលមិនឃើញ ត្រាស់ដឹងអំពីអ្វីដែលយើងអាចប្រែក្លាយ ហើយមានបន្ទប់សម្រាប់មនុស្សទាំងអស់ » ។

ចាស្មីន ជាសមាជិកម្នាក់នៅសហរដ្ឋអាមេរិកភាគខាងត្បូង សារភាពថា « ខ្ញុំពិបាកត្រូវគ្នាជាមួយនឹងបងស្រីម្នាក់នៅក្នុងវួដរបស់ខ្ញុំដែលហាក់ដូចជាជ្រៀតជ្រែកក្នុងជីវិតរបស់ខ្ញុំខ្លាំងណាស់ ហើយខ្ញុំបណ្ដោយឲ្យរឿងនោះទាញខ្ញុំឲ្យឃ្លាតឆ្ងាយ » ។ ប៉ុន្តែពេលភាពខ្វាយខ្វល់ចំពោះកូនប្រុសតូចរបស់នាងបានចាប់ផ្ដើមមានទម្ងន់ធ្ងន់ជាងភាពមិនច្បាស់លាស់អំពីស្ថានភាពពេលត្រឡប់ទៅវិញ នោះចាស្មីនបានដឹងថា វាគឺជាពេលដែលមិនត្រូវ « បណ្ដោយឲ្យគំនិតរបស់មនុស្សដទៃគិតអំពីការទាញខ្ញុំឲ្យឃ្លាតឆ្ងាយពីព្រះគ្រីស្ទ — មិនថាខ្ញុំមានអារម្មណ៍ថា មនុស្សម្នាក់នៅក្នុងវួដមើលងាយខ្ញុំដែរឬអត់នោះទេ » ។

នាងបានប្រមូលភាពក្លាហានគ្រប់គ្រាន់ដើម្បីដើរចូលទៅក្នុងព្យុះភ្លៀងដ៏ធំនាថ្ងៃអាទិត្យមួយឆ្ពោះទៅកាន់កន្លែងដែលគ្រួសារដ៏តូចរបស់នាងបានទទួលអារម្មណ៍នូវការឱបក្រសោបពីសំណាក់មិត្តភក្ដិ ដែលអាចជួយពួកគេឲ្យរីកចម្រើននៅក្នុងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទក្នុងពេលបន្តិចទៀត ។ នាងថ្លែងថា « ខ្ញុំសោកស្ដាយដែលដើរចេញ » ។ « ប៉ុន្តែខ្ញុំមានអំណរគុណដែលខ្ញុំពុំចុះចាញ់ ហើយថាខ្ញុំបានខិតខំឆ្ពោះមុខ ដោយសារដំណឹងល្អគឺពុំទាក់ទងនឹងរឿងដែលមនុស្សដទៃ — ឬ ខ្ញុំគិតឡើយ — ប៉ុន្តែវាទាក់ទងនឹងព្រះអង្គសង្គ្រោះរបស់ខ្ញុំ » ។

### ឈានមួយជំហានចូលទៅក្នុងភាពងងឹត ៖ ពន្លឺនឹងមានតាមក្រោយ

*« បុរសស្ត្រីខាងសាច់ឈាមថ្លែងថា ‹ គ្មានផ្លូវណាសោះ ដែលខ្ញុំឈានមួយបោះជំហាននេះ [ ហើយ ] រំកិលចូលទៅក្នុងភាពងងឹតរហូតដល់ពន្លឺរំកិលមក ហើយខ្ញុំអាចឃើញទីកន្លែងដែលខ្ញុំនឹងទៅបានឡើយ ។ តម្រូវការនោះគឺថា យើងត្រូវឈានជំហាននោះ ដោយរំពឹងថា ពេលយើងជើងរបស់យើងប៉ះនឹងដី នោះពន្លឺនឹងរំកិលមក » ។*

— អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

ពេលខ្លះវាពិបាកសម្រាប់សមាជិកថ្មីដើម្បីបន្តចាក់គ្រឹះក្នុងដំណឹងល្អ ពេលពួកគេគ្មានការអះអាងពេញលេញមួយអំពីអនាគតនោះ ។ ចំពោះ ម៉ែ ឈីន ជាស្ត្រីមេផ្ទះម្នាក់នៅប្រទេសតៃវ៉ាន់ ដែលបានស្ដាប់តាមការដាស់តឿននៃដំណឹងល្អ ដើម្បីនាំយកកូនចៅមកកាន់ពិភពលោកនេះ ការរៀនសូត្រអំពីកត្ដានៃ សេចក្ដីជំនឿនេះគឺជាជំហានមួយដ៏លំបាក ដោយសារ នាងបានសង្កេតឃើញថា « មានមនុស្សជាច្រើននៅក្នុងប្រទេសរបស់ខ្ញុំ មានកូនម្នាក់ ឬចិញ្ចឹមសត្វមួយក្បាលជំនួសវិញ » ។ ការមានគត៌ម្ដងៗតម្រូវឲ្យនាងត្រូវមានសេចក្ដីជំនឿដើម្បីឈានចូលទៅក្នុងរឿងដែលនាងពុំដឹងថានឹងមានអ្វីកើតឡើង ហើយពេលខ្លះមិនអើពើនឹងការរិះគន់យ៉ាងខ្លាំងពីសំណាក់សាច់ញាតិ និងពីសង្គម ។

ជារឿយៗ ការដើរឆ្ពោះទៅមុខតម្រូវឲ្យមានការបោះជំហានទៅក្នុងរឿងដែលយើងពុំដឹងថានឹងមានអ្វីកើតឡើង ដែលវាអាចជារឿងគួរឲ្យភ័យខ្លាចចំពោះពួកអ្នកថ្មីថ្មោងនៅក្នុងសេចក្ដីជំនឿនេះ ។ វាតម្រូវឲ្យមានការអភិវឌ្ឍទំនុកចិត្តថា











ព្រះអម្ចាស់នឹងជួយពួកគេនៅតាមផ្លូវនោះ ។ អែលឌើរ បែដណា អះអាងថា ការមានភាពលំបាក និងភាពមិនច្បាស់លាស់គឺជាផ្នែកធម្មតាមួយនៃដំណើរការរៀនសូត្រ និងការរីកចម្រើនរបស់យើង ប៉ុន្តែពេលខ្លះជំហានរបស់យើងចូលទៅក្នុងរឿងដែលយើងពុំដឹងថានឹងមានអ្វី កើតឡើងនោះ — មិនថាវាទាក់ទងនឹងការបង្កើតគ្រួសារ ឬការត្រឡប់មកចូលរួមនៅក្នុងសាសនាចក្រវិញយ៉ាងណានោះទេ — វាអាចជារឿងមួយដ៏លំបាកបំផុត ដោយសារសាក្សីកើតមានបន្ទាប់ពីការសាកល្បងនៃសេចក្ដីជំនឿរបស់យើង ( សូមមើល អេធើរ ១២:៦ ) ។ ម៉ៃ ឈីន និងស្វាមីរបស់នាងបានទទួលសាក្សីមួយនេះបន្ទាប់ពីបង្កើតគ្រួសារមួយ ។ នាងថ្លែងថា « យើងមានចិត្តរីករាយ ហើយមានអំណរគុណជាខ្លាំងចំពោះកូនៗរបស់យើង » ។ « យើងបានរៀនរស់នៅតាមសមត្ថភាពរបស់យើង ដើម្បីជួយ ហើយស្រឡាញ់គ្នាទៅវិញទៅមក ។ ខ្ញុំមានអំណរគុណដែលយើងបាននាំពួកគេមកកាន់ពិភពលោកនេះ » ។

ជារឿយៗ ជំហានចាប់ផ្ដើមគឺជារឿងលំបាកបំផុត ។ យោងតាមអែលឌើរ បែដណា « លើកទីមួយដែលយើង [ ឈានចូលទៅក្នុងភាពងងឹតនោះ ] វាពុំជាការសង្ស័យទេ ប៉ុន្តែមាននូវភាពមិនច្បាស់លាស់បន្តិចបន្តួច ជាការថប់ក្នុងចិត្តបន្តិចបន្តួច ដែលវាគឺជារឿងធម្មតា » ។ កាលដំណើរការនៃការដើរឆ្ពោះទៅមុខអាចពុំមានភាពរលូនទាំងស្រុងក្ដី ( លោកពន្យល់ថា « ពុំមែនជាវដ្ដដ៏ល្អឥតខ្ចោះមួយដែលគ្មានការរំខាននោះឡើយ » ) យើងអាចរីកចម្រើនបន្តិចម្ដងៗ « មួយបន្ទាត់ម្ដងៗ » ដោយមានសេចក្ដីជំនឿរបស់យើងកើនឡើងយ៉ាងខ្លាំង ។

ការដើរឆ្ពោះទៅមុខត្រូវការការហ្វឹកហាត់ បានណែនាំរបស់ ឡាសា ចចចារ ជាអ្នកប្រែចិត្តជឿម្នាក់នៅក្នុងប្រទេសដែលមានព្រំប្រទល់ជាប់នឹងប្រទេសរុស្ស៊ី និងទ្វីបអឺរ៉ុប ។ ការរៀនទុកចិត្តលើមិត្តជាអិលឌីអែសគឺជាជំហានទីមួយរបស់គាត់ ដែលក្រោយមកគាត់បានយល់ព្រមទទួលពរជ័យមួយនៃបព្វជិតភាព ។ គាត់ពន្យល់ថា « បន្ទាប់មកខ្ញុំអាចដើរឆ្ពោះទៅមុខជាមួយទទួលយកការពិភាក្សារបស់អ្នកផ្សព្វផ្សាយសាសនា » ។ ពេលសេចក្ដីជំនឿរបស់ឡាសាមានភាពរីកចម្រើន « ខ្ញុំបានធ្វើរឿងដ៏ធំគឺពិធីបុណ្យជ្រមុជទឹក សូម្បីតែខ្ញុំមិនប្រាកដចិត្ត ១០០ ភាគរយក្ដី ។ ប៉ុន្តែព្រះអម្ចាស់បានប្រទានឲ្យខ្ញុំនូវភាពក្លាហាននៅដំណាក់កាលនីមួយៗ ហើយខ្ញុំមានអំណរគុណជាខ្លាំងនៅពេលនេះ ដែលខ្ញុំបានធ្វើរឿងនោះ » ។

## សូមកុំបោះបង់ឡើយ

*« មនុស្សដែលគិតថា ពួកគេមានអំពើបាបជាច្រើន ឬដើរហួស ឬបានចេញឆ្ងាយអស់រយៈពេលជាយូរ ហើយមិនអាចត្រឡប់ចូលមកក្នុងវនោះវិញបានទេ ៖ ការប្រកាសរបស់ខ្ញុំគឺថា គ្មាននរណាធ្លាក់ចុះទាបជាងពន្លឺនៃព្រះគ្រីស្ទឡើយ ។ វាពុំអាចទៅរួចឡើយ » ។*

— អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់

ដោយធំដឹងក្ដីឡើងនៅក្នុងគ្រួសារអិលឌីអែសដ៏ស្មោះត្រង់មួយនៅរដ្ឋយូថាហ៍ ស.រ.អា. ប្រាយអិនបានមានអារម្មណ៍ហាក់ដូចជាគាត់មិនត្រូវការសាសនាចក្រទេ ។ គាត់ថ្លែងថា « ខ្ញុំបានរីករាយនឹងល្បែងដែលធ្វើឲ្យស្រមើស្រមៃ ភាពយន្ត និងតន្ត្រីរ៉ុក ប៉ុន្តែពុំមែនក្រុមកាយឫទ្ធិ ព្រះគម្ពីរ ថ្នាក់សិក្ខាសាលា និងកីឡាទេ » ។ កាលគាត់បានចេញពីផ្ទះភ្លាម គាត់ផ្លាស់ចូលទៅរស់នៅក្នុងផ្ទះជួលមួយ ហើយ « ផ្ដល់សេរីភាពឲ្យខ្លួនឯងចំពោះរឿងលោកិយ រួមទាំងការរួមភេទ និងថ្នាំញៀនផងដែរ » ។ មួយរយៈក្រោយមកនៃអ្វីដែលប្រាយអិនហៅថា « ល្បែងហួសខ្នាត និងការដកពិសោធន៍ » គាត់បានធ្លាក់ចូលក្នុងបញ្ហាខាងហិរញ្ញវត្ថុ ហើយឪពុក

ម្ដាយរបស់គាត់បានយកគាត់មកនៅជាមួយម្ដងទៀត ទោះបីជាគាត់មិនត្រឡប់ទៅព្រះវិហារក្ដី ។

កំណើតរបស់ប្អូនស្រីម្នាក់បានធ្វើឲ្យប្រាយអិនវាយតម្លៃទស្សនៈរបស់គាត់ឡើងវិញ ។ ពេលគាត់បីនាងជាលើកដំបូង គាត់នៅចាំថា « ខ្ញុំបានដឹងថា នាងពុំមែនគ្រាន់តែជាសត្វមួយប្រភេទទៀតនោះទេ »។ គាត់បានចូលរួមការប្រសិទ្ធពរទារករបស់នាងទាំងភ័យខ្លាច ហើយពេលសាក្រាម៉ង់បានហុចឲ្យគាត់ « ខ្ញុំបានហុចវាបន្ត ប៉ុន្តែខ្ញុំមានអារម្មណ៍ស្រេកឃ្លានខាងវិញ្ញាណ » ។

ដោយព្យាយាមយល់អំពីអារម្មណ៍ច្របូលច្របល់របស់គាត់ ប្រាយអិនបានចាប់ផ្ដើមសរសេរកំណត់ហេតុមួយ ។ គាត់ថ្លែងថា « មានយប់មួយ ខ្ញុំបាននៅដល់យប់ជ្រៅសរសេរអំពីបញ្ហាខាងវិញ្ញាណរបស់ខ្ញុំ ហើយខ្ញុំបានមានបទពិសោធន៍ខាងវិញ្ញាណដំបូងរបស់ខ្ញុំ ទោះមិនមែនជារឿងល្អក្ដី » ។ គាត់បានទទួលអារម្មណ៍ថាមានកម្លាំងនៃអំពើអាក្រក់ ការស្អប់ និងកំហឹងកំពុងព្យាយាមចាប់យកព្រលឹងរបស់គាត់ ។ គាត់ពន្យល់ថា « បន្ទាប់ពីនោះមក ខ្ញុំបានដឹងថា ខ្ញុំត្រូវការព្រះអម្ចាស់ » ។ ប៉ុន្តែដោយសារតែការវង្វេងឆ្ងាយ ប្រាយអិន បានងឿងឆ្ងល់ថា « តើខ្ញុំអាចមានភាពសក្ដិសមនឹងជំនួយ និងការការពាររបស់ទ្រង់ដែរឬទេ ? » គាត់ក៏បានចោទសួរថាតើគាត់អាចទទួលសាក្រាម៉ង់ជាថ្មីបានដែរឬទេ ។

ផ្លូវត្រឡប់មកវិញគឺលំបាកណាស់ ។ ការឈប់ជក់បារីគឺមិនងាយឡើយ ការសារភាពទៅកាន់ប៊ីស្សពតម្រូវឲ្យមានភាពក្លាហាន ហើយការងាកចេញពីមិត្តភក្ដិ និងសកម្មភាពពីមុនគឺជារឿងដ៏លំបាក ។ គ្រួសារ មិត្តស្រី និងប៊ីស្សពរបស់គាត់ពួកគេទាំងអស់គ្នាបានគាំទ្រគាត់ ប៉ុន្តែប្រាយអិនបានរកឃើញប្រភពចម្បងរបស់គាត់ពីកម្លាំងនៅក្នុងព្រះយេស៊ូវគ្រីស្ទ ។

គាត់ចងចាំថា « ខ្ញុំឃើញថា ព្រះអម្ចាស់អន្ទះសារចង់ជួយដល់ខ្ញុំ » ។ « ឱកាសថ្មីៗបានបើកឡើងដើម្បីជំនួសឲ្យស្វែងរកពីមុនរបស់ខ្ញុំ ។ កាលណាខ្ញុំខិតខំរស់នៅតាមដំណឹងល្អកាន់តែខ្លាំង ផ្លូវរបស់ខ្ញុំកាន់តែមានភាពស្រឡះ » ។ ដូចដែលប្រាយអិនបានទុកចិត្តលើព្រះអម្ចាស់ ហើយបានរកឃើញពីព្រះទ័យចង់អភ័យទោស និងព្យាបាលរបស់ទ្រង់ នោះសាក្រាម៉ង់មានន័យកាន់តែខ្លាំងចំពោះគាត់ ហើយបានជួយនាំគាត់ឲ្យខិតកាន់តែជិតព្រះអង្គសង្គ្រោះ ។ « កាលខ្ញុំបានទទួលនំប៉័ង និងទឹកនៅឯព្រះវិហាររាប់រយដងកាលពីក្មេង នៅទីបំផុតខ្ញុំអាចទទួលទានសាក្រាម៉ង់ដើម្បីទទួលបានអារម្មណ៍ដូចលើកទីមួយ » ។

## គ្មាននរណាម្នាក់អាចជំនួសអ្នកបានឡើយ

ការដើរចេញពីរថយន្ត ហើយចូលទៅក្នុងព្រះវិហារ ការជួយដល់សមាជិកផ្សេងទៀត ការយកឈ្នះលើអារម្មណ៍ឈឺចាប់ ការរស់នៅតាមដំណឹងល្អដោយគ្មានការអះអាងពេញលេញអំពីអនាគត និងការសារភាពអំពើបាប — យើងទាំងអស់គ្នាដើរលើផ្លូវដ៏លំបាក ហើយមិនច្បាស់លាស់ឆ្ពោះទៅកាន់ដើមឈើជីវិត ( សូមមើល នីហ្វៃទី ១ ៨ ) ។

ការតាំងចិត្តរបស់យើងដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ គឺជារឿងចាំបាច់សម្រាប់ការទៅដល់ដោយសុវត្ថិភាព ។ ខណៈដែលការលើកទឹកចិត្ត សេចក្ដីស្រឡាញ់ និងការទទួលយកពីសំណាក់សមាជិកផ្សេងទៀតក្នុងសាសនាចក្រ និងថ្នាក់ដឹកនាំគឺជារឿងសំខាន់ យើងម្នាក់ៗអាចនឹងជួបនូវគ្រាដែលយើងត្រូវមានឆន្ទៈដើរតាមព្រះអង្គសង្គ្រោះ សូម្បីតែយើងមានអារម្មណ៍ដូចជាយើងកំពុងធ្វើវាតែម្នាក់ឯងក៏ដោយ ។

សូមទទួលកន្លែងរបស់អ្នកនៅក្នុងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមកុំប្រៀបធៀប ចូរឲ្យព្រះគ្រីស្ទកែប្រែអ្នក សូមបោះជំហាននៃសេចក្ដីជំនឿដែលនឹងទទួលបានរង្វាន់ ហើយដឹងថា ការវិលត្រឡប់មកវិញ វាពុំដែលយឺតពេលឡើយ ។ « ហេតុដូច្នោះហើយ បើសិនជាអ្នករាល់គ្នាខិតខំជឿនទៅមុខ ដោយទទួលនូវព្រះបន្ទូលនៃព្រះគ្រីស្ទ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត មើលចុះ នោះព្រះវរបិតាទ្រង់មានព្រះបន្ទូលថា ៖ អ្នករាល់គ្នានឹងមានជីវិតដ៏នៅអស់កល្បជានិច្ច » ( នីហ្វៃទី ២ ៣១:២០ ) ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

កំណត់ចំណាំ

១. សូមមើល ឌៀថើរ អេស្វ អុជដូហ្វ « Come, Join with Us » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ២១–២៤ ។
២. ដេវីឌ មីលស៍ « Go to Church, Meet Annoying People » ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ២០១៧, aleteia.org/2017/02/01/go-to-church-meet-annoying-people ។





# ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ

## ជម្រក និងការការពារមួយ

**ដោយ ហ្គេទូលីយ៉ូ ចាហ្គី អី ស៊ីលវ៉ា**
ថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន

ព្រះអម្ចាស់សព្វព្រះទ័យចង់ការពាររាស្ត្ររបស់ទ្រង់ ។ អំឡុងគ្រានៃការបៀតបៀនដ៏ធំមួយនៅក្នុងសាសនាចក្រ ទ្រង់បានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការប្រមូលផ្ដុំទៅកាន់ក្រុងស៊ីយ៉ូន « ជា *ទីការពារ* និងជា *ទីជម្រក* ពីព្យុះសង្ឃរា » ( គ. និង ស. ១១៥:៦ ការគូសបញ្ជាក់បានបន្ថែម ) ។

ទីជម្រក និងការការពារនេះកើតមានតាមរយៈការរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ពេលយើង « ពិចារណាមើលព្រះបញ្ញត្តិទាំងនេះ » ( គ. និង ស. ១:៣៧ ) ។ ហេតុដូច្នេះហើយ ចូរយើងត្រួតពិនិត្យអំពីគោលការណ៍មួយចំនួនដែលមាននៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា *ដរាបណាយើងយល់ ហើយអនុវត្តតាម* វានឹងនាំមកឲ្យយើងនូវការការពារ ហើយវានឹងក្លាយជាទីជម្រកមួយពីការល្បួង អំពើអាក្រក់ និងគ្រោះថ្នាក់ផ្សេងទៀតដែលយើងជួបប្រទះសព្វថ្ងៃនេះ ។

### យើងត្រូវបានការពារ ពេលយើងស្វែងរកព្រះវិញ្ញាណបរិសុទ្ធ

ការមានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយយើងអាចក្លាយជាទីជម្រក និងការការពារមួយពីលោកិយនេះ ។ ព្រះអម្ចាស់បានសន្យាថា ប្រសិនបើ អូលីវើរ ខៅឌើរី « អនុវត្ត » តាមអំណោយទាននៃវិវរណៈនោះ « អំណោយទាននេះនឹងដោះលែងអ្នកឲ្យរួចផុតពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវរបស់អ្នក ម្ល៉េះហើយ បើសិនជាពុំនោះសោតទេ ពួកគេនឹងប្រហារអ្នកបង់ ហើយនាំព្រលឹងរបស់អ្នកទៅរកសេចក្ដីបំផ្លិចបំផ្លាញ » ( គ. និង ស ៨:៤ ) ។ តាមរយៈការស្ដាប់តាមព្រះសូរសៀងនៃព្រះវិញ្ញាណ នោះអូលីវើរ ខៅឌើរី អាចត្រូវបានការពារពីសេចក្ដីស្លាប់ និងអំពើបាប ។

ការទទួលបានសេចក្ដីពិតតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធក៏នឹងការពារយើងពីគំនិតរបស់មនុស្ស ព្រមទាំងការកុហក និងការបោកបញ្ឆោតនានារបស់សាតាំងផងដែរ ។ ព្រះអម្ចាស់បានសន្យាថា « ដ្បិតពួកអ្នកណាដែលមានប្រាជ្ញា ហើយបានទទួលសេចក្ដីពិត ហើយ*បានទទួលយកព្រះវិញ្ញាណបរិសុទ្ធទុកជាអ្នកណែនាំរបស់ខ្លួន* ហើយដែលពុំត្រូវបានគេបញ្ឆោត យើងប្រាប់អ្នកជាប្រាកដថា ពួកគេនឹងពុំត្រូវកាប់បោះចោលទៅក្នុងភ្លើងឡើយ ប៉ុន្តែនឹងធន់នៅថ្ងៃនោះ » ( គ. និង ស. ៤៥:៥៧ ការគូសបញ្ជាក់បានបន្ថែម ) ។ ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធសរសេរសេចក្ដីពិតក្នុងដួងចិត្តរបស់យើង ហើយការពារយើងពីការបោកបញ្ឆោត ។

ប៉ុន្តែការស្ដាប់តាមការបំផុសគំនិតពីព្រះវិញ្ញាណពុំមែនមានន័យថា យើងនឹងត្រូវបានការពារពីរាល់ការសាកល្បងនោះ

ឡើយ ។ កណ្ឌ ១២២ ក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា បង្ហាញថា សូម្បីតែនៅពេលយើងមានភាពសក្ដិសមក្ដី ក៏យើងអាចជួបប្រទះនឹងទុក្ខសោក និង ឧបសគ្គដែរ ។ នៅក្នុងព្រះតំរិះ និង ព្រះប្រាជ្ញាញាណរបស់ព្រះដែលទ្រង់ « ជ្រាបសព្វគ្រប់ » ( គ. និង ស. ១២៧:២ ) « គ្រប់ការណ៍ទាំងនេះ នឹងផ្ដល់ការពិសោធន៍ដល់ [ យើង ] ហើយនឹងទៅជាការល្អដល់ [ យើង ] ទៅវិញ » ( គ. និង ស. ១២២:៧ ) ។

### យើងត្រូវបានការពារ ពេលយើងធ្វើតាមពួកព្យាការីនៅរស់

នៅថ្ងៃដែលសាសនាចក្រត្រូវបានរៀបចំឡើង ព្រះអម្ចាស់បានបង្គាប់ពួកបរិសុទ្ធរបស់ទ្រង់ឲ្យស្ដាប់តាមព្យាការី ៖

« អ្នកត្រូវស្ដាប់តាមគ្រប់អស់ទាំងពាក្យសម្ដី និងបញ្ញត្តិទាំងឡាយរបស់លោក ដែលលោកនឹងឲ្យដល់អ្នក នៅពេលលោកបានទទួលពាក្យទាំងនោះ ដើរដោយបរិសុទ្ធនៅចំពោះមុខយើង ។

« ដ្បិតពាក្យសម្ដីរបស់ [ ប្រធានសាសនាចក្រ ] នោះហើយ អ្នកនឹងបានទទួល ហាក់ដូចជាបានមកពីព្រះឱស្ឋរបស់យើងផ្ទាល់ ដោយសេចក្ដីអត់ធន់ និងសេចក្ដីជំនឿគ្រប់យ៉ាង ។

« ដ្បិតដោយសារការធ្វើការទាំងនេះហើយ ទ្វារស្ថាននរកនឹងពុំដែលឈ្នះអ្នកឡើយ មែនហើយ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងកម្ចាត់អំណាចនៃសេចក្ដីងងឹតចេញពីអ្នកទៅ ហើយនឹងបណ្ដាលឲ្យផ្ទៃមេឃញាប់ញ័រ ដើម្បីសេចក្ដីល្អដល់អ្នក និងសិរីល្អដល់ព្រះនាមរបស់ទ្រង់ » ( គ. និង ស. ២១:៤–៦ ) ។

ព្រះអម្ចាស់ប្រាប់យើងនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញាថា ជនដែល « លែងឮសំឡេងនៃព្រះអម្ចាស់ ឬសំឡេងនៃពួកអ្នកបម្រើរបស់ទ្រង់ ឬមិនស្ដាប់តាម *ពាក្យសម្ដីនៃពួកព្យាការី និង ពួកសាវក* នោះនឹងត្រូវកាត់ចេញពីចំណោមប្រជាជន » ( គ. និង ស. ១:១៤; ការគូសបញ្ជាក់បានបន្ថែម ) ។

ការស្ដាប់ និងការអនុវត្តតាមការបង្រៀនរបស់ពួកព្យាការីនៅរស់នឹងនាំមកនូវការការពារ និងសន្តិសុខ ពីព្រោះពួកលោកថ្លែងអំពីបញ្ហានាពេលបច្ចុប្បន្នរបស់យើង ហើយប្រាប់យើងអំពីអ្វីដែលយើងត្រូវធ្វើដើម្បីយកឈ្នះលើឧបសគ្គទាំងនេះ ។ ឱ ជាពរជ័យមួយដ៏អស្ចារ្យអ្វីម្ល៉េះ ដែលយើងមានថ្នាក់ដឹកនាំបច្ចុប្បន្នរបស់ព្រះអម្ចាស់ ។

នៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–៦២ ព្រះអម្ចាស់ប្រើរឿងប្រៀបប្រដូចមួយអំពីចម្ការដើមអូលីវមួយដើម្បីបង្ហាញអំពីសារៈសំខាន់នៃការស្ដាប់តាមព្យាការីមួយរូបនាពេលបច្ចុប្បន្ន ។ រឿងប្រៀបប្រដូចនោះប្រៀបធៀបព្យាការីទៅនឹងអ្នកយាមនៅលើប៉មម្នាក់ ។ កាលពីបុរាណ មនុស្សសង់ប៉មទុកជាកន្លែងដែលអ្នកយាមម្នាក់អាចមើលឃើញហួសពីទីក្រុង ហើយព្រមានប្រជាជន ពេលមានសត្រូវសំដៅចូលមក ។

រឿងប្រៀបប្រដូចនេះចាប់ផ្ដើមថា ៖ « សង់ប៉មមួយ ប្រយោជន៍ឲ្យនរណាមួយអាចសម្លឹងមើលជុំវិញដែនដី ដើម្បីឲ្យធ្វើជា



*ការបង្រៀននៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញាអាចការពារយើងពីការលំបាកដែលយើងនឹងជួបប្រទះ កាលយើងរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។*

ព្រះអង្គសង្គ្រោះរបស់យើងមកពីSUPERSTOCK/GETTY IMAGES, ផ្ទៃខាងក្រោយដោយ DAVID CLAPP/GETTY IMAGES

*អ្នកយាមនៅលើប៉ម* ប្រយោជន៍កុំឲ្យដើមអូលីវទាំងឡាយរបស់យើងត្រូវបាក់ចុះក្នុងកាលខ្យាំងសត្រូវមកបង្ខូច ហើយបេះយកដល់ខ្លួន នូវផ្លែនៃចម្ការរបស់យើងឡើយ » ( ខទី ៤៥; ការគូសបញ្ជាក់បានបន្ថែម ) ។

អែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីការការពារ និងពរជ័យដែលកើតចេញពីការធ្វើតាមពាក្យទូន្មានរបស់ព្យាការីបច្ចុប្បន្ន ៖ « បងប្អូនប្រុសស្រីរបស់ខ្ញុំអើយវាពុំមែនជារឿងតូចតាចទេ ដើម្បីមានព្យាការីម្នាក់របស់ព្រះ ក្នុងចំណោមពួកយើងនោះ ។ នៅពេលយើងស្ដាប់តាមការទូន្មានរបស់ព្រះអម្ចាស់ ដែលបង្ហាញតាមរយៈពាក្យសម្ដីរបស់ប្រធាននៃសាសនាចក្រ នោះការឆ្លើយតបរបស់យើងគួរតែវិជ្ជមាន និងទៀងទាត់ ។ ប្រវត្តិសាស្ត្របានបង្ហាញថា មានសុវត្ថិភាព សន្តិភាព ភាពរុងរឿង និងសុភមង្គល នៅក្នុងការធ្វើតាមដំបូន្មានរបស់ព្យាការី » ។[១]



អ្វីដែលសំខាន់ជាងការការពារខាងរូបកាយដែលចេញមកពីការស្ដាប់តាមពួកព្យាការីគឺការការពារខាងវិញ្ញាណ ។ វាគឺជារឿងដ៏ចាំបាច់ពីព្រោះ « អារក្សសាតាំងក៏បានព្យាយាមបោកបញ្ឆោតអ្នក ដើម្បីវាអាចបានឈ្នះលើអ្នកដែរ » ( គ. និង ស. ៥០:៣ ) ។ ការស្ដាប់តាមពួកព្យាការីការពារយើងពីទស្សនលោកិយ និង « ឧបាយកលដ៏ប្រសប់នៃមនុស្សម្លេះហើយ ទើបពួកគេពួនចាំបញ្ឆោត » ( គ. និង ស. ១២៣:១២ ) ។

### យើងត្រូវបានការពារ ពេលយើងស្មោះត្រង់នៅក្នុងអាពាហ៍ពិពាហ៍

ព្រះអម្ចាស់សន្យាយើងថា សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍អាចមានភាពអស់កល្បជានិច្ច ( សូមមើល គ. និង ស. ១៣២:១៩ ) ។ គោលលទ្ធិនៃភាពតម្កើងឡើងនេះគឺជាទីជម្រកមួយពីទំនាក់ទំនងខុសឆ្គងដែលបំផ្លាញពិភពលោករបស់យើង ។ ទោះជាមានសំឡេងខាងលោកិយជាច្រើនប្រកាសអះអាងថា អាពាហ៍ពិពាហ៍គឺជារឿងហួសសម័យ មិនស្រួល ឬពុំចាំបាច់ក្ដី ក៏សំឡេងរបស់ព្រះអម្ចាស់បានប្រកាសថា « អស់អ្នកណាដែលហាមប្រាមមិនឲ្យរៀបការ នោះពុំមែនបានតែងតាំងពីព្រះទេ ដ្បិតអាពាហ៍ពិពាហ៍ត្រូវបានតែងតាំងមកពីព្រះដល់មនុស្ស » ( គ. និង ស. ៤៩:១៥ ) ។

ព្រះអម្ចាស់បង្រៀនយើងអំពីរបៀបការពារអាពាហ៍ពិពាហ៍របស់យើង ៖ « ត្រូវស្រឡាញ់ប្រពន្ធខ្លួនឲ្យអស់ពីចិត្ត ហើយត្រូវនៅជាប់នឹងនាង ហើយគ្មាននរណាទៀតឡើយ » ( គ. និង ស. ៤២:២២ ) ។

ប្រធានស្ពែនស៊ើរ ដបុលយូ឴ ឃីមបឹល ( ១៨៩៥–១៩៨៥ ) បានពន្យល់អំពីលក្ខណៈយ៉ាងពេញលេញទាំងអស់នៃបទបញ្ញត្តិនេះ ៖

« ពេលព្រះអម្ចាស់មានបន្ទូលថា *អស់ពី* ដួងចិត្តរបស់អ្នក វាគ្មានការចែករំលែក ឬបែងចែក ឬក៏ការដកហូតឡើយ ។ ហើយចំពោះស្ត្រី វាត្រូវបានថ្លែងប្រយោគថា ‹ ត្រូវស្រឡាញ់ប្ដីខ្លួនឲ្យ *អស់ពី* ចិត្ត ហើយត្រូវនៅជាប់នឹងគាត់ ហើយគ្មាននរណាទៀតឡើយ › ។

« ពាក្យថា*គ្មាននរណាទៀតឡើយ* គឺ ដកយកមនុស្សគ្រប់គ្នា និងអ្វីៗគ្រប់យ៉ាង ។ បន្ទាប់មកស្វាមី និងភរិយាក្លាយជាទៅអាទិភាពនៅក្នុងជីវិតរបស់ស្វាមី ឬភរិយា ហើយមិនថាជាជីវិតសង្គម ឬជីវិតការងារ ឬជីវិតនយោបាយ ឬចំណាប់អារម្មណ៍ណាមួយផ្សេងទៀត ឬបុគ្គល ឬវត្ថុឡើយ វាពុំត្រូវមានអាទិភាពជាងគូស្វាមីភរិយាឡើយ » ។[២]

អ្វីដែលយើងមើលឃើញជះឥទ្ធិពលយ៉ាងខ្លាំងមកលើយើងសម្រាប់សេចក្ដីល្អ ឬ សេចក្ដីអាក្រក់ ។ ខ្ញុំគិតថា នោះជាហេតុផលដែលព្រះអម្ចាស់ព្រមានយើងនៅក្នុងខគម្ពីរដូចតទៅនេះថា « អ្នកណាដែល

រឿងដើម្បីដកពី *ការជ្រើសរើសយកអ្វីៗគ្រប់យ៉ាង* ដោយ ប្រាយអិន ឃើមស៊ឺក ត្រូវបានហាមថតចម្លង, ផ្ទៃខាងក្រោយដោយ CLAUDIO CONTRERAS/NATUREPL.COM/GETTY IMAGES



*ក្រឡេកឃើញ* ស្ត្រី ហើយមានតម្រេកសម្រើបចង់បាន នោះនឹងបោះបង់ចោលសេចក្ដីជំនឿ ហើយនឹងមិនត្រូវមានព្រះវិញ្ញាណឡើយ ហើយបើសិនជាអ្នកនោះមិនប្រែចិត្តទេ នោះនឹងត្រូវបណ្ដេញចេញ » ( គ. និង ស. ៤២:២៣; ការគូសបញ្ជាក់បានបន្ថែម ) ។

ដើម្បីទទួលបានការការពារពីការវាយប្រហារពីសំណាក់មារសត្រូវ ភ្នែក និងដួងចិត្តរបស់យើងគួរងាកតែទៅរកស្វាមីភរិយារបស់យើង និងព្រះអម្ចាស់ប៉ុណ្ណោះ ។ យើងមិនត្រូវអនុញ្ញាតឲ្យភ្នែករបស់យើងវង្វេង ឬចង់បានមនុស្សម្នាក់ទៀតក្រៅពីស្វាមីភរិយារបស់យើងឡើយ ។ យើងត្រូវបិទដួងចិត្ត និងគំនិតរបស់យើងដើម្បីទទួលបានការការពារពីការល្បួងនោះ ។ នេះគឺជារូបមន្តរបស់ព្រះអម្ចាស់សម្រាប់ភាពជោគជ័យនៅក្នុងអាពាហ៍ពិពាហ៍ ។

## យើងត្រូវបានការពារ ពេលយើងបម្រើបេសកកម្ម

យើងមានឱកាសជាច្រើនដើម្បីបម្រើនៅក្នុងសាសនាចក្រ ហើយព្រះអម្ចាស់ « សព្វព្រះហឫទ័យនឹងឲ្យកិត្តិយសដល់អស់អ្នកណាដែលបម្រើ [ ទ្រង់ ] » ( គ. និង ស. ៧៦:៥ ) ។ គោលការណ៍ដ៏អស្ចារ្យទាំងឡាយអំពីការបម្រើបេសកកម្មត្រូវបានបង្រៀននៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ។

ព្រះអម្ចាស់សន្យាថា « មនុស្សណាមួយដែលនឹងទៅ ហើយផ្សាយដំណឹងល្អនេះពីនគរ ហើយមិនខកខាន ដើម្បីមានចិត្តស្មោះត្រង់រហូតតទៅក្នុងគ្រប់ទាំងអស់នោះនឹងពុំមានភាពទន់ខ្សោយខាងគំនិត ឬក៏ងងឹតដែរ ឬខាងរូបកាយ ខាងដៃជើង ឬខាងសន្លាក់ឆ្អឹងដែរ ហើយសក់ក្បាលមួយសរសៃរបស់អ្នកនោះ ក៏នឹងមិនជ្រុះទៅដល់ដីដោយមិនដឹងនោះឡើយ ។ ហើយពួកគេនឹងពុំឃ្លាន ឬស្រេកឡើយ » ( គ. និង ស. ៨៤:៨០ ) ។ សូមកត់ចំណាំថា ព្រះអម្ចាស់ពុំបានលើកលែងឲ្យផុតពីភាពលំបាកនោះទេ ប៉ុន្តែសន្យាថា យើងនឹងស្ថិតនៅក្នុងការថែទាំរបស់ទ្រង់ ។

ទ្រង់បានបន្ថែមថា « យើងនឹងនៅខាងស្ដាំដៃអ្នក ហើយខាងឆ្វេងដៃអ្នក ហើយព្រះវិញ្ញាណរបស់យើងនឹងសណ្ឋិតនៅក្នុងដួងចិត្តរបស់អ្នក ហើយពួកទេវតារបស់យើងនៅព័ទ្ធជុំវិញអ្នក ដើម្បីទ្រអ្នកឡើង » ( គ. និង ស. ៨៤:៨៨ ) ។ ប្រសិនបើយើងបម្រើទ្រង់ « ហេតុការណ៍នឹងកើតឡើងថា អំណាចនឹងស្ថិតនៅលើអ្នក អ្នកនឹងត្រូវមានសេចក្ដីជំនឿដ៏ធំ ហើយយើងនឹងនៅជាមួយអ្នក ហើយទៅពីមុខអ្នក » ( គ. និង ស. ៣៩:១២ ) ។ អស់អ្នកដែលបម្រើបេសកកម្មដោយអស់ពីដួងចិត្តរបស់ពួកគេមាននូវការសន្យាថា ពួកគេ « នឹងបានពរទាំងខាងវិញ្ញាណ និងខាងសាច់ឈាម » ( គ. និង ស. ១៤:១១ ) ។

ព្រះអម្ចាស់ក៏ពង្រីកការការពារដល់ក្រុមគ្រួសាររបស់អស់អ្នកដែលបម្រើដែរ ៖ « យើងជាព្រះអម្ចាស់ ប្រទានដល់ពួកគេនូវសេចក្ដីសន្យាមួយថា យើងនឹងផ្គត់ផ្គង់ដល់ក្រុមគ្រួសារ របស់ពួកគេ ហើយទ្វារដ៏មានផលប្រយោជន៍នឹងត្រូវបានបើកចំហដល់ពួកគេ ចាប់ពីពេលនេះតទៅ » ( គ. និង ស. ១១៨:៣ ) ។

ហើយពួកអ្នកផ្សព្វផ្សាយសាសនាដ៏ស្មោះត្រង់ត្រូវបានសន្យាថា « បាបទាំងឡាយរបស់អ្នក ត្រូវបានអត់ទោសឲ្យហើយ ហើយអ្នកនឹងបានផ្ទុកកណ្ដាប់ស្រូវពីលើខ្នងរបស់អ្នក » ( គ. និង ស. ៣១:៥ ) ។ ពរជ័យនេះគឺជាទីជម្រកមួយសម្រាប់ព្រលឹងរបស់យើង ។

## យើងត្រូវបានការពារ ពេលយើងគោរពតាមច្បាប់ដង្វាយមួយភាគក្នុងដប់

នៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា យើងរកឃើញការបង្រៀនដូចតទៅនេះទាក់ទងនឹងដង្វាយមួយភាគក្នុងដប់ ៖ « មើលចុះ ឥឡូវត្រូវបានហៅថាថ្ងៃនេះរហូតដល់ការយាងមកនៃកូនមនុស្ស ហើយប្រាកដមែន គឺជាថ្ងៃនៃការបូជា និងជាថ្ងៃសម្រាប់ដង្វាយ ១ ភាគ ១០ នៃរាស្ត្ររបស់យើង » ( គ. និង ស. ៦៤:២៣ ) ។

ខ្ញុំចង់និយាយថា ច្បាប់ដង្វាយមួយភាគក្នុងដប់គឺផ្ទុយពីគណិតវិទ្យា ដោយសារ ៩០ នឹងធំជាង ១០០ ។ ពេលយើងថ្វាយព្រះអម្ចាស់ ១០ ភាគរយនៃប្រាក់ចំណូលរបស់យើង ទ្រង់សន្យានឹង « បើកទ្វារស្ថានសួគ៌ ដើម្បីចាក់ព្រះពរមកលើឯង ដែលនឹងគ្មានកន្លែងល្មមទុកបានទេ » ( ម៉ាឡាគី ៣:១០, សូមមើលផងដែរនីហ្វៃទី ៣ ២៤:១០ ) ។

ដើម្បីវាយតម្លៃថាតើសេចក្ដីជំនឿរបស់យើងខ្លាំងដល់កម្រិតណា យើងអាចក្រឡេកមើលទៅឥរិយាបថរបស់យើងចំពោះច្បាប់ដង្វាយមួយភាគក្នុងដប់ ។ ការបង់ដង្វាយមួយភាគក្នុងដប់គឺ



*ដូចជាអ្នកយាមនៅលើប៉មម្នាក់ដែរ ពួកព្យាការី មើលទៅឆ្ងាយ ហើយព្រមានពីការដេលរបស់ មារសត្រូវ ។*

ពុំមែនជាបញ្ហាខាងប្រាក់កាសនោះទេ វាគឺជាបញ្ហានៃសេចក្ដីជំនឿ ។

ប្រធាន ហិនរី ប៊ី អារិង ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ បង្រៀនយើងថា « តាមរយៈការសម្រេចចិត្តរបស់យើងនៅពេលនេះដើម្បីធ្វើជាអ្នកបង់ដង្វាយមួយភាគក្នុងដប់ពេញលេញ និងការខិតខំដ៏ខ្ជាប់ខ្ជួនរបស់យើងដើម្បីគោរពតាម នោះយើងនឹងទទួលបានការពង្រឹងនៅក្នុងសេចក្ដីជំនឿរបស់យើង ហើយនៅពេលនោះដែរ ដួងចិត្តរបស់យើងនឹងមានភាពទន់ភ្លន់ ។ វាគឺជាការផ្លាស់ប្ដូរដួងចិត្តរបស់យើងតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ គឺលើសពីការថ្វាយប្រាក់ ឬសម្ភាររបស់យើងទៅទៀត ដែលអាចធ្វើឲ្យព្រះអម្ចាស់សន្យាដល់ពួកអ្នកបង់ដង្វាយមួយភាគក្នុងដប់ពេញលេញនូវការការពារនៅថ្ងៃចុងក្រោយនោះ [ សូមមើល គ. និង ស. ៦៤:២៣ ] ។ យើងអាចមានទំនុកចិត្តថា យើងនឹងមានគុណសម្បត្តិគ្រប់គ្រាន់ទទួលបានពរជ័យនៃការការពារនោះ ប្រសិនបើយើងតាំងចិត្តនៅពេលនេះដើម្បីបង់ដង្វាយមួយភាគក្នុងដប់ពេញលេញ ហើយខ្ជាប់ខ្ជួនក្នុងការគោរពតាមវា » ។[៣]

### យើងត្រូវបានការពារ ពេលយើងគោរពតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ

យើងរស់នៅក្នុងគ្រាមួយដែលសុខភាពរបស់យើងអាចត្រូវបានគម្រាមកំហែងដោយសារធាតុគ្រោះថ្នាក់ជាច្រើន ។ ដោយគ្រាស់ដឹងអំពីអ្វីដែលយើងជួបប្រទះ ព្រះអម្ចាស់បានបង្រៀនដល់ព្យាការី យ៉ូសែប ស្ម៊ីធ នៅឆ្នាំ ១៨៣៣ ថា « ពីព្រោះតែអំពើអាក្រក់ទាំងឡាយ និងផែនការទាំងឡាយដែលមាន ហើយនឹងមាននៅក្នុងដួងចិត្តមនុស្ស ដែលរួមគំនិតប្រព្រឹត្តអំពើទុច្ចរិតនៅថ្ងៃចុងក្រោយបង្អស់ ទើបយើងបានព្រមានដល់អ្នក ហើយហាមអ្នកទុកជាមុន ដោយប្រទានដល់អ្នកនូវពាក្យសម្ដីនៃប្រាជ្ញាវាងវៃនេះ » ( គ. និង ស. ៨៩:៤ ) ។

ជនដែលគោរពតាមច្បាប់សុខភាពរបស់ព្រះអម្ចាស់មាននូវការសន្យាថា ពួកគេ « នឹងបានទទួលសេចក្ដីសុខស្រួលដល់ផ្ចិតពួកគេ ហើយជាខួរដល់ឆ្អឹងពួកគេ [ សុខភាពខាងរូបកាយ ] ហើយនឹងរកឃើញប្រាជ្ញា និងផលថ្លៃវិសេសនៃចំណេះវិជ្ជា គឺជាសម្បត្តិដែលលាក់ទុក [ ពរជ័យខាងប្រាជ្ញា និងខាងវិញ្ញាណ ] ហើយនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ [ សុខភាពខាងរូបកាយ ] » ។

ហើយព្រះអម្ចាស់សន្យានូវសុវត្ថិភាពដល់អស់អ្នកណាដែលគោរពតាមច្បាប់នេះ ៖ « ហើយយើងជាព្រះអម្ចាស់ប្រទានដល់ពួកគេនូវសេចក្ដីសន្យាមួយថា ទេវតាដែលបំផ្លាញនឹងបង្ហួសពួកគេ ដូចជាកូនចៅអ៊ីស្រាអែលដែរ ហើយមិនប្រហារពួកគេឡើយ » ( គ. និង ស. ៨៩:១៨–២១ ) ។

ការសន្យានេះពុំមែនមានន័យថា យើងនឹងពុំស្លាប់នោះទេ ដោយសារសេចក្ដីស្លាប់គឺជាផ្នែកមួយនៃផែនការដ៏នៅអស់កល្បជានិច្ច ។ ប៉ុន្តែ « ទេវតាបំផ្លិចបំផ្លាញ ដែលវាមកដើម្បីដាក់ទោសដល់មនុស្សទុច្ចរិតសម្រាប់អំពើបាបរបស់ពួកគេពេលដូចដែលវាបានធ្វើកាលពីបុរាណ

រូបភាពមកពី GETTY IMAGES, *ព្រះវិហារបរិសុទ្ធសម្រាប់ផ្ទះ* គំនូរដោយ សាទផ្លែ កាំស្ដី

ដល់ពួកសាសន៍អេស៊ីព្ទដែលពួករលួយនៅក្នុងសេចក្ដីទុច្ចរិតរបស់ពួកគេ [ សូមមើលនិក្ខមនំ ១២:២៣, ២៩ ] នឹងដើរកាត់ពួកបរិសុទ្ធ » ។[4]

## យើងត្រូវបានការពារ ពេលយើងឈរនៅក្នុងទីបរិសុទ្ធ

ព្រះអម្ចាស់បង្គាប់យើងជាថ្មីម្ដងទៀតឲ្យ « នៅក្នុងទីបរិសុទ្ធ » ( សូមមើល គ. និង ស. ៤៥:៣២, ៨៧:៨, ១០១:២២ ) ។ ពិតណាស់ ព្រះវិហារបរិសុទ្ធរបស់យើងគឺជាទីបរិសុទ្ធ ។ ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ( ១៨៧៦–១៩៧២ ) បានបង្រៀន ៖

« បើយើងដឹងអំពីអ្វីដែលយើងកំពុងធ្វើ នោះអំណោយទានដ៏ពិសិដ្ឋនឹងក្លាយទៅជាការការពារដល់យើងអស់មួយជីវិតយើង — ជាការការពារដែលមនុស្សម្នាក់ដែលមិនបានទៅព្រះវិហារបរិសុទ្ធពុំមាន ។

« ខ្ញុំធ្លាប់បានឮឪពុករបស់ខ្ញុំ [ ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ] មានប្រសាសន៍ថា នៅក្នុងគ្រានៃការសាកល្បង នៅក្នុងគ្រានៃការល្បួង លោកនឹងគិតអំពីសេចក្ដីសន្យា សេចក្ដីសញ្ញាដែលលោកបានធ្វើនៅក្នុងព្រះដំណាក់នៃព្រះអម្ចាស់ ហើយវាជាការការពារមួយដល់លោក » ។[5]

រួមជាមួយនឹងព្រះវិហារបរិសុទ្ធ រោងថ្វាយបង្គំ និងថ្នាក់រៀននៅក្នុងសាលាប្រជុំរបស់សាសនាចក្រ និងផ្ទះរបស់យើងត្រូវបានឧទ្ទិសឆ្លងជាទីបរិសុទ្ធ ។ កន្លែងទាំងនេះបរិសុទ្ធ ប្រសិនបើមនុស្សដែលនៅក្នុងនោះមានចិត្តបរិសុទ្ធ ហើយរស់នៅតាមបទបញ្ញត្តិរបស់ព្រះ ។ ពេលយើងគោរពបទបញ្ញត្តិ យើងរីករាយនឹងភាពជាដៃគូ ការដឹកនាំ និងការលួងលោមចិត្តមកពីព្រះវិញ្ញាណបរិសុទ្ធ ។ ប្រសិនបើទ្រង់អាចក្លាយជាដៃគូដ៏ខ្ជាប់ខ្ជួន នោះ យើងពិតជានឹងឈរនៅក្នុងទីបរិសុទ្ធ ។

## សេចក្ដីបញ្ចប់

យើងធ្លាប់ឃើញនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញានូវទម្រង់ខុសៗគ្នានៃការការពារដែលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទប្រទានឲ្យយើង ពេលយើងខិតខំរៀនសូត្រ ហើយរស់នៅតាមគោលការណ៍ទាំងនេះ ។ យើងអាចនឹងសួរថាតើត្រូវរកការការពារនេះនៅឯណា ។

ដោយបង្ហាញសេចក្ដីស្រឡាញ់ និង សេចក្ដីមេត្តាករុណារបស់ទ្រង់ដល់ពួកបរិសុទ្ធ ព្រះអម្ចាស់បានសន្យាថា ទ្រង់នឹងគង់ជាមួយយើង ៖ « ចូរសង្ឃឹមឡើង កូនក្មេងតូចអើយ ត្បិតយើងនៅកណ្ដាលពួកអ្នក ហើយយើងពុំបានបោះបង់ចោលអ្នកឡើយ » ( គ. និង ស. ៦១:៣៦ ) ។ « ចូរប្រុងស្ដាប់ . . . ព្រះអម្ចាស់ជាព្រះរបស់អ្នកទ្រង់មានព្រះបន្ទូលថាដូច្នោះ គឺជាព្រះគ្រីស្ទជាព្រះគាំទ្ររបស់អ្នក ដែលជ្រាបនូវសេចក្ដីកម្សោយនៃមនុស្ស និងចេះជួយពួកគេដែលត្រូវល្បួង » ( គ. និង ស. ៦២:១ ) ។

ពេលយើងអនុវត្តដង្វាយធួន និងការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតរបស់យើង នោះយើងអាចទទួលការការពារ និងទីជម្រកដែលផ្ដល់កម្លាំងដល់យើងដើម្បីសម្រាលបន្ទុករបស់យើង យកឈ្នះលើអំពើបាប និងការលំបាកទាំងឡាយរបស់យើង ហើយធ្វើឲ្យ



យើងក្លាយជាពួកបរិសុទ្ធ ។ ■

*អ្នកនិពន្ធរស់នៅ ទីក្រុង គីរីទីបា ប្រទេសប្រេស៊ីល ។*


**កំណត់ចំណាំ**

១. អិម រ័សុល បាឡឺដ « His Word Ye Shall Receive » *Liahona,* ខែ កក្កដា ឆ្នាំ ២០០១ ទំព័រ ៨០ ។
២. *Teachings of Presidents of the Church: Spencer W. Kimball* ( ឆ្នាំ ២០០៦ ) ទំព័រ ១៩៩ ។
៣. ហិនរី ប៊ី អាវរិង « Spiritual Preparedness: Start Early and Be Steady »*Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៤០ ។
៤. ជេ រូប៊ីន ក្លាក ជុញ្ញ័រ នៅក្នុង Conference Report ខែតុលា ឆ្នាំ ១៩៤០ ទំព័រ ១៧, សូមមើលផងដែរ *Doctrine and Covenants Student Manual* ( Church Educational System manual ឆ្នាំ ២០០១ ) ទំព័រ ២១១ ។
៥. យ៉ូសែប ហ្វីលឌិង ស្ម៊ីធ « The Pearl of Great Price » *Utah Genealogical and Historical Magazine,* ខែ កក្កដា ឆ្នាំ ១៩៣០ ទំព័រ ១០៣, សូមមើលផងដែរ *Doctrine and Covenants Student Manual* ទំព័រ ២៥៩ ។

# ការចែកចាយសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះនៅបុណ្យគ្រីស្ទម៉ាស់

ខ្ញុំមានចិត្តរំភើបដើម្បីចូលរួមនៅក្នុងយុទ្ធនាការបុណ្យគ្រីស្ទម៉ាស់ឆ្នាំ២០១៦ របស់សាសនាចក្រស្ដី ពី « បំភ្លឺពិភពលោក » ។ ខ្ញុំបានទន្ទឹងរង់ចាំដើម្បីបំពេញសំណូមពរ ប្រចាំថ្ងៃទាំងនោះ ជាពិសេសសម្រាប់ថ្ងៃទីប្រាំ ៖ « ព្រះយេស៊ូវបានជួយដល់អ្នកឈឺ ហើយអ្នកក៏អាចធ្វើដូចគ្នាដែរ » ។

នៅថ្ងៃនោះខ្ញុំបានចេញទៅធ្វើការ ហើយបានដើរកាត់ផ្លូវក្នុងក្រុងជាច្រើន ដោយមានគម្រោងទៅលេងនឹងលោកយាយលោកតារបស់ខ្ញុំ ។ ខ្ញុំបានមានចិត្តរីករាយណាស់ ។ វាជារដូវបុណ្យគ្រីស្ទម៉ាស់ ហើយពិភពលោកនេះមានភាពស្រស់ស្អាត ។ សំឡេងកណ្ដឹងនៃសេចក្ដីសប្បុរសបានរោទិ៍ឡើងនៅផ្ទៃវេហា ។ ពេលខ្ញុំបានចូលទៅជិតនឹងចំណតរថយន្តក្រុង សំឡេងកណ្ដឹងស្ទើរតែស្ដាប់ពុំឮឡើយ ដោយសារមានស្ត្រីគ្មានទីជម្រកម្នាក់បានស្រែកឲ្យអ្នករោទិ៍កណ្ដឹងនោះ ។

គាត់បានស្រែកថា « អ្នកឯងជាមនុស្សមានពុត ! » « ខ្ញុំស្រេកឃ្លាន ខ្ញុំរងារ ប៉ុន្តែអ្នកឯងគិតតែពីខ្លួនឯង ! អ្នកឯងជាមនុស្សមានពុត ! »

មនុស្សភាគច្រើនពុំបានអើពើនឹងគាត់ទេ ហើយអ្នករោទិ៍កណ្ដឹងនោះបានបន្តរោទិ៍កណ្ដឹងរបស់គាត់បន្តទៀត ។ ខ្ញុំបានយកកាសមកស្ដាប់ ប៉ុន្តែខ្ញុំនៅតែឮស្ត្រីនោះស្រែកឡើងថា « អ្នកឯងជាមនុស្សមានពុត ! ខ្ញុំឃ្លាន ។ ខ្ញុំរងារ » ។

ខ្ញុំបានចាំថា ខ្ញុំមានក្រដាសប្រាក់ ២០ ដុល្លារនៅក្នុងហោប៉ៅរបស់ខ្ញុំ ។ ខ្ញុំបានពិចារណាឲ្យ វា ទៅស្ត្រីនោះ ។ ខ្ញុំបានគិតថា « ទេ » ។ « ប្រសិនបើខ្ញុំចង់ឲ្យប្រាក់នេះទៅនរណាម្នាក់ ខ្ញុំគួរ ឲ្យទៅមនុស្សម្នាក់ដែលមានសណ្ដានចិត្តល្អ » ។ បន្ទាប់មក ព្រះវិញ្ញាណបានរំឭកខ្ញុំពីសំណូមពរនោះ និងតួអង្គដែលខ្ញុំកំពុងព្យាយាមធ្វើ ខ្លួនឲ្យដូច ។ ព្រះយេស៊ូវគឺជាស្ដេចនៃអស់ទាំងស្ដេច ប៉ុន្តែទ្រង់បានបម្រើដល់មនុស្សដ៏ទន់ទាបបំផុត ។ ខ្ញុំបានដឹងនូវអ្វីដែលខ្ញុំគប្បីនឹងធ្វើ ។

ខ្ញុំបានដើរទៅរកស្ត្រីនោះ ។ ឥឡូវនេះគាត់បានឈប់ស្រែកទៀតហើយ ប៉ុន្តែគាត់បានបិទភ្នែក ហើយបានសម្រក់ទឹកភ្នែក ។ ខ្ញុំបានយកប្រាក់ ២០ ដុល្លារនោះចេញពីហោប៉ៅមក រួចក៏ហុចទៅឲ្យគាត់ ។

ខ្ញុំបានសួរថា « ពិបាកចិត្តមែនទេ ? »

គាត់បានមើលមុខខ្ញុំ ។ គាត់បានតបថា « មែនហើយ » ។

ខ្ញុំបាននិយាយថា « ខ្ញុំសុំទោស » ។ ខ្ញុំបានឱបគាត់ ហើយគាត់បានផ្អែកក្បាលលើស្មារបស់ខ្ញុំទាំងសម្រក់ទឹកភ្នែករហូតដល់រថយន្តក្រុងបានមកដល់ ។

ពេលយើងនិយាយលាគ្នា ស្ត្រីនោះបាននិយាយថា « អរគុណ » ។ « ហើយពុំមែនសម្រាប់តែប្រាក់នេះទេ ។ ប៉ុន្តែអរគុណដែលបានមកឱបខ្ញុំ ។ ខ្ញុំត្រូវការការឱបលួងលោមចិត្តមួយ » ។

ការឱបមនុស្សមិនដែលស្គាល់គ្នាម្នាក់នៅតាមដងផ្លូវពុំមែនជាអ្វីមួយដែលខ្ញុំមានគម្រោងនឹងធ្វើឡើយ ប៉ុន្តែខ្ញុំដឹងថា វាគឺជាអ្វីមួយដែលព្រះយេស៊ូវនឹងធ្វើដូចគ្នា ។ ខ្ញុំមានអំណរគុណដែលព្រះអម្ចាស់បានប្រទានឱកាសនេះឲ្យខ្ញុំ ដើម្បីបានបម្រើដូចជាទ្រង់ ។ ព្រះយេស៊ូវបានជួយដល់អ្នកឈឺ ជនក្រីក្រ និងជនខ្វះខាត ។ ដូច្នេះខ្ញុំក៏អាចធ្វើបានដែរ ។ ■

យ៉ដោន់ វ៉ាយត៍ រដ្ឋ យូថាហ៍ ស.រ.អា.



ខ្ញុំបានដើរទៅរកស្ត្រីនោះ ។ ឥឡូវនេះគាត់បានឈប់ស្រែកទៀតហើយ ប៉ុន្តែគាត់បានសម្រក់ទឹកភ្នែក ។



មានប្រអប់ធំពីរដាក់ឈ្មោះរបស់ខ្ញុំនៅលើនោះ ប៉ុន្តែគ្មានអាស័យដ្ឋានអ្នកផ្ញើឡើយ ។

# តើជាកញ្ចប់បុណ្យគ្រីស្ទម៉ាស់សម្រាប់ខ្ញុំមែនទេ ?

ខ្ញុំធ្លាប់បម្រើនៅក្នុងបេសកកម្មសាក្រាម៉ង់តូ កាលីហ្វ័រញ៉ាអំឡុងបុណ្យគ្រីស្ទម៉ាស់នាឆ្នាំ ២០០៣ ។ ដៃគូរបស់ខ្ញុំ និងពួកអ្នកផ្សព្វផ្សាយសាសនាជាសិស្ទើរពីរនាក់ផ្សេងទៀតដែលនៅរស់នៅក្នុងផ្ទះជាមួយគ្នាបានចាប់ផ្ដើមទទួលអំណោយ និងសំបុត្រមកពីសាច់ញាតិ និងមិត្តភក្តិរបស់ពួកគេ ។ ខ្ញុំបានដឹងថា រឿងនោះពុំកើតឡើងចំពោះខ្ញុំឡើយ ។

គ្រួសាររបស់ខ្ញុំនៅប្រទេសអាហ្សង់ទីនមានធនធានស្ដួចស្ដើង ហើយជាធម្មតាសំបុត្ររបស់ពួកគេត្រូវបានពន្យារពេលពីរទៅបីខែ ។ ខ្ញុំនៅឆ្ងាយពីគ្រួសាររបស់ខ្ញុំ ប៉ុន្តែមានចិត្តរីករាយដើម្បីចំណាយពេលក្នុងបុណ្យគ្រីស្ទម៉ាស់នៅក្នុងកិច្ចការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ ។

នៅថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់ យើងបានត្រៀមខ្លួនចូលដេក មានសិស្ទើរម្នាក់បានប្រាប់ខ្ញុំថា មានមនុស្សម្នាក់បានទុកកញ្ចប់មួយចំនួននៅមាត់ទ្វារដោយមានឈ្មោះរបស់ខ្ញុំនៅលើកញ្ចប់ទាំងនោះដែរ ។

« សម្រាប់ខ្ញុំមែនឬ ? វាមិនពិតឡើយ ! ខ្ញុំពោលទាំងភ្ញាក់ផ្អើល ។

មានប្រអប់ធំពីរដាក់ឈ្មោះរបស់ខ្ញុំនៅលើនោះ ប៉ុន្តែគ្មានអាស័យដ្ឋានអ្នកផ្ញើឡើយ ។ ខ្ញុំមានចិត្តរំភើប ហើយសិស្ទើរផ្សេងទៀតក៏មានចិត្តរំភើបជំនួសខ្ញុំដែរ ។ ខ្ញុំបានបើកកញ្ចប់ទាំងនោះដែលមានសុទ្ធតែអំណោយស្ដុកស្ដម្ភ គំនូរជាច្រើនពីកុមារ និងសម្ភារផ្សេងទៀត ! ខ្ញុំពុំអាចទប់ទឹកភ្នែកបានទេ ។

« តើនរណាទៅបានផ្ញើកញ្ចប់ទាំងនេះមកឲ្យខ្ញុំ ? » ខ្ញុំមានការងឿងឆ្ងល់ ។ យើងទាំងអស់គ្នា គ្មាននរណាម្នាក់ដឹងឡើយ ប៉ុន្តែយើងទាំងអស់មានចិត្តរីករាយដោយសារតែសេចក្ដីសប្បុរសនោះ ។

ក្រោយពីបុណ្យគ្រីស្ទម៉ាស់បីបួនថ្ងៃមក ខ្ញុំនៅតែចង់ដឹងថា នរណាទៅដែលបានផ្ញើកញ្ចប់ទាំងនោះមក ។ ដូច្នេះខ្ញុំបានទូរសព្ទទៅការិយាល័យបេសកកម្ម ហើយសាកសួរលេខា ប្រសិនបើគាត់អាចប្រាប់ខ្ញុំពីឈ្មោះអ្នកផ្ញើដ៏អាថ៌កំបាំងនោះ ។ គាត់បានប្រាប់ខ្ញុំថា សមាជិកនៅក្នុងវួដមួយដែលមិនចង់ឲ្យគេស្គាល់ឈ្មោះបានសម្រេចចិត្តផ្ញើកញ្ចប់មកឲ្យខ្ញុំសម្រាប់ជាអំណោយក្នុងបុណ្យគ្រីស្ទម៉ាស់ ។ ខ្ញុំតែងអរគុណជានិច្ចចំពោះសេចក្ដីសប្បុរសរបស់សមាជិកវួដនោះដែលបាននាំមកនូវសេចក្ដីស្រឡាញ់ជាខ្លាំងនៅថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់នោះ និងចំពោះការគាំទ្រដែលខ្ញុំបានទទួលអំឡុងបេសកកម្មរបស់ខ្ញុំ ។

ខ្ញុំបានរៀនថា សមាជិកសាសនាចក្រគ្រប់រូបអាចធ្វើឲ្យពួកអ្នកផ្សព្វផ្សាយសាសនា — ទោះជានៅឆ្ងាយពីផ្ទះក្ដី — ឲ្យមានអារម្មណ៍ដូចជាបាននៅផ្ទះតាមរយៈការលើកទឹកចិត្ត និងការបម្រើរបស់ពួកគេ ។ វាគឺជាបុណ្យគ្រីស្ទម៉ាស់មួយដ៏ល្អបំផុតក្នុងជីវិតរបស់ខ្ញុំ ។ ខ្ញុំធ្លាប់បម្រើព្រះអង្គសង្គ្រោះ ហើយបានទទួលអារម្មណ៍នូវសេចក្ដីស្រឡាញ់របស់ទ្រង់តាមរយៈសមាជិកក្នុងសាសនាចក្ររបស់ទ្រង់ ។ ■

អេលីហ្សាបែត អាន់ឌើរសិន បូហ្គាដូ ទីក្រុងនូកេន ប្រទេសអាហ្សង់ទីន

រូបភាពគំនូរដោយ ខារ៉ូលីន វីបប៊ើត

រូបភាពគំនូរដោយ ជូលី រ៉ូជើស

# បុណ្យគ្រីស្ទម៉ាស់តាមរយៈកែវភ្នែករបស់កូនស្រីខ្ញុំ

មានភាពស្ងប់ស្ងាត់មួយបានកើតមានចំពោះគ្រួសាររបស់ខ្ញុំ និងរូបខ្ញុំ ពេលយើងបានដើរចូលទៅក្នុងក្រោលសេះមួយដើម្បីមើលការសម្ដែងអំពីប្រសូតកម្ម ។ មានសត្វពាហនៈដាក់តម្រៀបជួរគ្នានៅក្នុងបន្ទប់នីមួយៗ ហើយមានបុរស និងស្ត្រីម្នាក់ដែលបានស្លៀកពាក់ជាយ៉ូសែប និងម៉ារា បានឈរដោយមានទារកម្នាក់ត្រូវបានរុំនឹងសំពត់នៅក្នុងដៃរបស់ស្ត្រីនោះ ។ ពួកគាត់ស្ងៀមស្ងាត់ ហើយផ្ដោតភ្នែកទៅលើទារកតូចនោះ ។ បរិយាកាសទាំងមូលមានភាពសុខសាន្តខ្លាំងណាស់ ។

កូនធំៗរបស់ខ្ញុំ ភរិយារបស់ខ្ញុំ និងខ្ញុំបានឈរខណៈដែលកូនស្រីពៅរបស់ខ្ញុំបានអង្គុយនៅលើគំនរចំបើងនៅពីមុខយើង ។ នាងនៅស្ងៀម ហើយកែវភ្នែករបស់នាងបានផ្ដោតលើទារកនោះ ។ ពេលដែលសមាជិកគ្រួសាររបស់ខ្ញុំបានត្រៀមខ្លួនចេញពីក្រោលសេះនោះ ខ្ញុំបានដាក់ដៃលើស្មារបស់កូនស្រីខ្ញុំ ហើយខ្សឹបប្រាប់នាងថា ដល់ពេលយើងត្រូវទៅហើយ ។ នាងបានពោលថា នាងចង់នៅជាមួយនឹងព្រះឱរសយេស៊ូវ ។ ពាក្យសម្ដីរបស់នាងបានប៉ះពាល់ដល់ដួងចិត្តរបស់ខ្ញុំ ហើយខ្ញុំបានសម្រេចចិត្តនៅជាមួយនឹងនាង ។

ពីរបីនាទីក្រោយមក ខ្ញុំបានចាប់ដៃកូនស្រីរបស់ខ្ញុំថ្នមៗ ហើយប្រាប់នាងថា យើងត្រូវតែទៅផ្ទះហើយ ។ នាងបានពោលថា នាងពុំចង់ទៅទេ ។ ខ្ញុំបានលុតជង្គង់ចុះ ហើយឱបនាង ។

មិនយូរប៉ុន្មាន ខ្ញុំមានអារម្មណ៍ហាក់ដូចជាខ្ញុំបានត្រឡប់ទៅសម័យនោះ ហើយបាននៅជាមួយនឹងម៉ារា និងយ៉ូសែប ។ បន្ទាប់មក ខ្ញុំបានយល់ពីហេតុផលដែលកូនស្រីរបស់ខ្ញុំចង់នៅបន្ត ។ ខ្ញុំបានទទួលអារម្មណ៍ថា ព្រះវិញ្ញាណបានគ្រប់ដណ្ដប់មកលើខ្ញុំ ។ នៅកន្លែងនោះ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានស្ថិតនៅក្នុងវត្តមានរបស់ព្រះអង្គសង្គ្រោះ ។ ទឹកភ្នែកបានហូរស្រក់ចុះមក ពេលខ្ញុំបានទទួលអារម្មណ៍ពីសេចក្ដីស្រឡាញ់របស់ទ្រង់ ។ លុះដល់ពេលដែលត្រូវចាកចេញ ខ្ញុំបានលើកបីកូនស្រីតូចរបស់ខ្ញុំ ។ ពេលខ្ញុំបែរខ្លួនងាកទៅរកច្រកចេញ ខ្ញុំបានឮនាងនិយាយលាព្រះឱរសយេស៊ូវ និងពីទំហំនៃសេចក្ដីស្រឡាញ់ដែលនាងមានចំពោះទ្រង់ ។

នៅល្ងាចនោះ ខ្ញុំបានចែកចាយបទពិសោធន៍មួយជាមួយនឹងកូនស្រីរបស់ខ្ញុំ ដែលខ្ញុំនឹងរក្សាទុកពេញមួយជីវិត ហើយខ្ញុំស្ទើរតែភ្លេចពីវា ។ នៅយប់នោះ ខ្ញុំបានទទួលនូវអំណោយមួយ ។



កូនស្រីរបស់ខ្ញុំនៅស្ងៀម ហើយកែវភ្នែករបស់នាងបានផ្ដោតលើទារកនោះ ។

រចនារូបភាពដោយ អេលែន ហ្គានស៍

ខ្ញុំបានទទួលអារម្មណ៍នៅកាន់តែជិតនឹងព្រះ ហើយបានទទួលសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះខ្ញុំ ។ ខ្ញុំមានអំណរគុណចំពោះព្រះអង្គសង្គ្រោះ និងឱកាសដើម្បីចងចាំដល់ការប្រសូតរបស់ទ្រង់ ។ ខ្ញុំដឹងថា ព្រះជន្ម គំរូ និងដង្វាយធួនរបស់ព្រះអង្គសង្គ្រោះបង្កើតនូវអំណោយដ៏អស្ចារ្យមួយនៃសេចក្ដីស្រឡាញ់ដែលគ្មានទីបញ្ចប់មកពីព្រះទៅដល់កូនចៅរបស់ទ្រង់គ្រប់រូប ។ ខ្ញុំនឹងស្រឡាញ់អំណោយនេះជានិច្ចឲ្យអស់ពីជម្រៅដួងចិត្ត
របស់ខ្ញុំ ។ ■

អ៊ីរ៉ុន អាដាម ខារ៉ូឡៃណា
ខាងត្បូង ស.រ.អា.



# អំណោយជាគ្រួសារមួយសម្រាប់ថ្វាយព្រះអង្គសង្គ្រោះ

កាលខែធ្នូបានជិតឈានចូលមកដល់ ខ្ញុំបានរវល់រៀបចំសម្រាប់កិច្ចការដ៏មមាញឹកនារដូវបុណ្យគ្រីស្ទម៉ាស់ ។ បុណ្យគ្រីស្ទម៉ាស់បានធ្វើឡើងនៅក្នុងផ្ទះរបស់យើងអស់រយៈពេលបួនឆ្នាំហើយ ប៉ុន្តែឆ្នាំនេះ ខ្ញុំមានការបារម្ភច្រើន ។ ពេលខ្ញុំបានពិភាក្សានឹងស្វាមីរបស់ខ្ញុំអំពីអ្វីៗគ្រប់យ៉ាងដែលយើងត្រូវធ្វើ — ដូចជាទិញអំណោយ រៀបចំអាហារ និងធ្វើរឿងជាច្រើនផ្សេងទៀត — យើងបានសម្រេចចិត្តលុបចោលពិធីជប់លៀងបុណ្យគ្រីស្ទម៉ាស់ ហើយធ្វើរឿងមួយផ្សេងនៅបុណ្យគ្រីស្ទម៉ាស់នេះ ។ យើងចង់ធ្វើអ្វីមួយដែលយើងអាចថ្វាយជាអំណោយមួយ ជូនដល់ព្រះអង្គសង្គ្រោះ ។

មួយខែ ធ្នូពេញ យើងបានធ្វើរាត្រីជួបជុំក្រុមគ្រួសារអំពីព្រះជន្មរបស់ព្រះយេស៊ូវគ្រីស្ទ បានទៅព្រះវិហារបរិសុទ្ធ ហើយបានដាក់ផែនការធ្វើគម្រោងបម្រើជាគ្រួសារ ។ ស្វាមីរបស់ខ្ញុំគឺជាប៊ីស្សពនៅពេលនោះ ហើយយើងបានសម្រេចចិត្តថា នៅថ្ងៃបុណ្យគ្រីស្ទម៉ាស់ យើងនឹងច្រៀងទៅកាន់ស្ត្រីមេម៉ាយទាំងអស់នៅក្នុងវួដ ។ យើងបានចាប់ផ្ដើមហាត់ច្រៀងទំនុកតម្កើងមួយចំនួនដែលយើងនឹងច្រៀងជាគ្រួសារ ។ កូនៗរបស់ខ្ញុំចូលចិត្តច្រៀងបទ « ផ្ទុំនៅក្នុងស្នូកទីឆ្ងាយ » ( *ទំនុកតម្កើង* ល.រ. ១២៧ ) ។

នៅថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់ យើងបានធ្វើប័ណ្ណដោយមានដាក់នូវសារលិខិតពិសេសអំពីបុណ្យគ្រីស្ទម៉ាស់ ហើយបានរៀបចំនំចំណីយកទៅជាមួយនឹងយើង ។ យើងមានចិត្តរីករាយដោយឃើញគ្រួសាររបស់យើងមានសាមគ្គីភាពជាខ្លាំង ហើយរីករាយដើម្បីបម្រើដោយសេចក្ដីស្រឡាញ់បែបនេះដល់មនុស្សដទៃ ។ ខ្ញុំអាចទទួលអារម្មណ៍ពីអត្ថន័យនៃបុណ្យគ្រីស្ទម៉ាស់ ។

នៅថ្ងៃបុណ្យគ្រីស្ទម៉ាស់ កូនៗរបស់យើងបានមានចិត្តរីករាយចង់ទៅធ្វើការសួរសុខទុក្ខទាំងនោះណាស់ ។ នៅផ្ទះនីមួយៗដែលយើងបានទៅសួរសុខទុក្ខ យើងមានចិត្តរីករាយ ហើយវាហាក់ដូចជា ទំនុកតម្កើងទាំងនោះឮកាន់តែពីរោះរណ្ដំឡើង រាល់ពេលដែលយើងច្រៀងវា ។ ពេលយើងបានមកដល់ផ្ទះចុងក្រោយ វាទំនងដូចជាគ្មានមនុស្សនៅទេ ។ យើងបានរង់ចាំពីរបីនាទី ហើយកូនៗរបស់យើងបានចាប់ផ្ដើមអន្ទះសារ ។ នៅទីបំផុត មានស្ត្រីមេម៉ាយវ័យចំណាស់ម្នាក់បានចេញមកជួបយើងដោយស្លៀកពាក់សម្លៀកបំពាក់ថ្ងៃអាទិត្យរបស់គាត់ ហើយគាត់បានសិតសក់យ៉ាងស្អាត ។ ពេលគាត់បានឃើញយើង គាត់បានសម្រក់ទឹកភ្នែក ។ ខ្ញុំបានចាប់ផ្ដើមក្ដុកក្ដួលក្នុងចិត្តដូចគ្នា ហើយច្រៀងស្ទើរតែពុំរួច ។

ពេលយើងត្រឡប់មកផ្ទះវិញ កូនស្រីរបស់យើងអាយុប្រាំឆ្នាំបានប្រាប់យើងថា នាងពុំចង់ទៅផ្ទះទេ ប៉ុន្តែនាងចង់បន្តច្រៀងទៀត ។ ពីមុនខ្ញុំតប ស្រាប់តែកូនរបស់ខ្ញុំអាយុប្រាំបួនឆ្នាំបាននិយាយថា « មិនអីទេ ចាំធ្វើវាម្ដងទៀតនៅឆ្នាំក្រោយ ! »

ចំពោះគ្រួសាររបស់យើង នេះគឺជាបុណ្យគ្រីស្ទម៉ាស់ដែលពុំអាចបំភ្លេចបាន ដោយសារយើងបានលើកស្ទួយដល់មនុស្សដទៃ ហើយបានបង្ហាញសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះយេស៊ូវគ្រីស្ទ ។ ពេលខ្ញុំត្រិះរិះអំពីព្រឹត្តិការណ៍នៅថ្ងៃនោះ ខ្ញុំទទួលបានសេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ ហើយបានចងចាំអំពីបន្ទូលរបស់ទ្រង់ថា « ដែលអ្នករាល់គ្នាបានធ្វើការទាំងនេះដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថាបានធ្វើដល់យើងដែរ » ( ម៉ាថាយ ២៥:៤០ ) ។ ■

ម៉ារីយ៉ា អាប៉ារេស៊ីដា ដា គីយ៉ាម៉ា ស៊ីលវ៉ា ទីក្រុងសៅប៉ូឡូ ប្រទេស ប្រេស៊ីល





*ការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ហ្វីឡាដែលហ្វៀ ផែនស៊ីលវេញ៉ា នាឆ្នាំ ២០១៦ បានផ្ដល់ឱកាសឲ្យយ៉ូសេហ្វីនទៅចូលព្រះវិហារបរិសុទ្ធរៀងរាល់សប្ដាហ៍ ។ នៅក្នុងព្រះវិហារបរិសុទ្ធ គាត់បានរកឃើញកម្លាំង និងការដោះស្រាយចំពោះការប្រឈមមុខនឹងការសាកល្បងនៃជីវិត ។*

**ឡេសលី នីលសុន ជាងថតរូប**

# យ៉ូសេហ្វីន ស្ដែរ

*រដ្ឋផែនស៊ីលវេញ៉ា ស.រ.អា.*

ខ្ញុំបានកើតមកជួបនឹងរឿងលំបាកខ្លាំងណាស់ ។ ម្ដាយរបស់ខ្ញុំគឺជាជនអន្តោប្រវេសន៍ម្នាក់មកពីប្រទេសលីបេរីយ៉ា យើងមានជីវភាពក្រខ្សត់ ហើយកាលពីក្មេង ខ្ញុំត្រូវបានគេរំលោភបំពាន ពេលម្ដាយខ្ញុំបានទុកខ្ញុំឲ្យនៅជាមួយនឹងមនុស្សដែល គាត់ទុកចិត្តឲ្យមើលថែខ្ញុំ ។ បទពិសោធន៍នោះពិតជាបានធ្វើឲ្យរឿងខ្លះមានភាពពិបាកនៅក្នុងជីវិតរបស់ខ្ញុំ ។

អ្វីដែលធ្វើឲ្យខ្ញុំបន្តតាំងចិត្តរស់នៅតាមដំណឹងល្អគឺការសាកល្បងរបស់ខ្ញុំ ។

ជីវិតពិតជាលំបាកណាស់ មិនថាអ្នកជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ឬពុំមែននោះទេ ។ កម្លាំងរបស់ខ្ញុំកើតមានមកពីទំនាក់ទំនងរបស់ខ្ញុំនឹងព្រះអង្គសង្គ្រោះរបស់ខ្ញុំ និងជាមួយនឹងកូនប្រុសរបស់ខ្ញុំឈ្មោះ អេណុក ។ ការរក្សាសេចក្ដីសញ្ញាដែលខ្ញុំបានធ្វើនៅក្នុងព្រះវិហារបរិសុទ្ធក៏ផ្ដល់កម្លាំងដល់ខ្ញុំដែរ ។

សេចក្ដីពិតគឺជាសេចក្ដីពិត មិនថាមានរឿងអ្វីនោះទេ ។ អ្នកពុំចាំបាច់ត្រូវជជែកវែកញែកអំពីវានោះទេ ។ អ្នកពុំចាំបាច់ត្រូវបង្ហាញពីវានោះទេ ។ វាគឺជារឿងពិត ។ វាមានពិត ហើយវាមានពិតចំពោះមនុស្សគ្រប់គ្នា ។ វាមានពិតចំពោះមនុស្សដែលរស់នៅទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ ហើយវាមានពិតចំពោះមនុស្សដែលរស់នៅតំបន់ក្រីក្រនៃហ្វីឡាដែលហ្វៀនេះដែរ ។ ខ្ញុំគិតថា រឿងនោះគឺជាអ្វីដែលគួរលើកស្ទួយយើង ។

# កម្មវិធីប្រកួតប្រជែងផ្នែកទេពកោសល្យរបស់ម៉ុងហ្គោលី

ដោយ ប៉ូ នៀន ( ហ្វេលីប៉េ ) ឈូ, ភេត្រា ឈូ និងអូដហ្គេរេល អូឈើចាវ

កាលពីខែធ្នូឆ្នាំមុន មានក្រុមចម្រៀងមួយក្រុមមកពីស្តេកអ៊ូឡង់បាតាម៉ុងហ្គោលី ស្តេកខាងកើត និងខាងលិចបានឈានចូលដល់វគ្គពាក់កណ្ដាល់ផ្ដាច់ព័ត្រនៃកម្មវិធីទូរទស្សន៍ថ្នាក់ជាតិដែលហៅថា *កម្មវិធីប្រកួតប្រជែងផ្នែកទេពកោសល្យរបស់ម៉ុងហ្គោលី* ។ ក្រុមចម្រៀងនេះ — រួមមាននូវសិស្សថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន ដែលចំនួនពាក់កណ្ដាលគឺជាអ្នកដែលត្រឡប់មកពីបេសកកម្មវិញ — ពុំធ្លាប់គិតថា ពួកគេនឹងមានឱកាសបែបនេះដើម្បីចែកចាយជំនឿ និងទេពកោសល្យរបស់ពួកគេនោះឡើយ ។

នៅឆ្នាំ ២០១៥ មានពួកចិតសិបនាក់ប្រចាំតំបន់មួយរូបបានមកទស្សនកិច្ចនៅប្រទេសម៉ុងហ្គោលី ហើយបានផ្ដល់ការបំពាក់បំប៉នស្ដីពីការខិតខំប្រឹងប្រែងនៃកិច្ចការសាធារណៈរបស់សាសនាចក្រ ។ អូដហ្គេរេល អូឈើចាវ ជាប្រធានស្តេកអ៊ូឡង់បាទ័រម៉ុងហ្គោលីខាងលិច ពុំប្រាកដពីរបៀបចាប់ផ្ដើមកិច្ចការនេះឡើយ ។ បន្ទាប់មកនៅខែ មករា ឆ្នាំ ២០១៦ បងថ្លៃរបស់គាត់បានទូរសព្ទមក ហើយនិយាយថា « បងកំពុងមើល *កម្មវិធីប្រកួតប្រជែងផ្នែកទេពកោសល្យរបស់ម៉ុងហ្គោលី* ។ . . . បងមានចំណាប់អារម្មណ៍ដ៏ខ្លាំងមួយថា ក្រុមចម្រៀងសាសនាចក្ររបស់ប្អូនគួរចូលរួមកម្មវិធីនេះដែរ » ។

ប្រធាន អូឈើចាវ បានពិភាក្សាពីគំនិតនេះជាមួយនឹងនាយកក្រុមចម្រៀងគឺបងស្រី អ៊ូនើរចាហ្គាល់ពូរេវ ។ គាត់ និងសមាជិកក្រុមចម្រៀងមានចិត្តសាទរចំពោះឱកាសនេះ ។ ក្រុមចម្រៀងនេះគេស្គាល់ឈ្មោះថា ជាក្រុមចម្រៀងស៊ីយ៉ូន ឬ « *SION* » ជាពាក្យកាត់មួយក្នុងភាសាម៉ុងហ្គោលីដែលវាមានន័យថា *ស្មារតី សេចក្ដីជំនឿ គំនិត* និង *សាមគ្គីភាព* ។

## ជុំទីមួយ

សម្រាប់ជុំទីមួយនៃការប្រកួតនៅខែមីនា ឆ្នាំ ២០១៦ ក្រុមស៊ីយ៉ូនបានសម្ដែងដោយច្រៀងចម្រៀងពីរបទលាយបញ្ចូលគ្នា ។ មានចៅក្រមម្នាក់បាននិយាយថា « ខ្ញុំឃើញទឹកមុខប្អូនៗរីករាយណាស់ ! . . . យើងត្រូវដាក់វីដេអូរបស់ប្អូននៅលើយូធូបដើម្បីផ្សព្វផ្សាយកម្មវិធីនេះដល់ពិភពលោក » ។

ចៅក្រមម្នាក់ទៀតបានសួរក្រុមចម្រៀងនេះថា តើពួកគេនឹងធ្វើអ្វីខ្លះ ប្រសិនបើពួកគេឈ្នះរង្វាន់ធំដែលមានទឹកប្រាក់ចំនួន ៥០,០០០ ដុល្លារនោះ ។ គាត់បានមានចំណាប់អារម្មណ៍ជាខ្លាំង ពេលពួកគេបាននិយាយថា ពួកគេចង់បរិច្ចាគប្រាក់នោះទាំងអស់ទុកជាអំណោយពិសេសមួយសម្រាប់បុណ្យគ្រីស្ទម៉ាស់ទៅដល់មជ្ឈមណ្ឌលកុមារកំព្រាមួយ ។

## ជុំទីពីរ

ក្នុងចំណោមអ្នកចូលរួមប្រកួតចំនួន ៤០០ នាក់ ក្រុមស៊ីយ៉ូនស្ថិតនៅក្នុងចំណោមមនុស្សពីររយនាក់ដែលបានឈានទៅជុំទីពីរ ប៉ុន្តែការសម្ដែងរបស់ពួកគេត្រូវនឹងថ្ងៃជាមួយគ្នានឹងថ្ងៃសន្និសីទពហុស្តេកសម្រាប់យុវវ័យ ដែលត្រូវការសមាជិកពាក់កណ្ដាលនៃក្រុមចម្រៀងនេះដែលមានគ្នា ៣៥ នាក់ ។ ក្រុមចម្រៀងនេះបានសម្រេចចិត្តទៅការប្រកួតជុំទីពីរ ដូច្នេះពួកគេបានជួលរថយន្តក្រុងមួយ ហើយបន្ទាប់ពីការសម្ដែងរបស់ពួកគេ ពួកគេបានធ្វើដំណើររយៈពេលប្រាំបីម៉ោងទៅចូលរួមសន្និសីទយុវវ័យនោះ ។

**បើនិយាយទៅ មានប្រជាជនម៉ុងហ្គោលីតិចតួចណាស់ដែលឮអំពីសាសនាចក្រ ប៉ុន្តែក្រុមចម្រៀងមួយនេះបានជួយផ្លាស់ប្ដូរស្ថានភាពនោះ ។**

ក្នុងចំណោមការសម្ដែងចំនួន ២០០ ក្រុមស៊ីយ៉ូនគឺស្ថិតនៅក្នុងចំណោម ៣២ ក្រុមដែលឈានទៅវគ្គពាក់កណ្ដាលផ្ដាច់ព័ត្រ ។ ក្រុម



ចម្រៀងនេះបានចាប់ផ្ដើមមានគេស្គាល់នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមទាក់ទងនឹង *កម្មវិធីប្រកួតប្រជែងផ្នែកទេពកោសល្យរបស់ម៉ុងហ្គោលី* ។

**វគ្គពាក់កណ្ដាលផ្ដាច់ព័ត្រ**

ពួកគេបានហ្វឹកហាត់ពីខែ មិថុនា រហូតដល់ខែ កញ្ញាដើម្បីត្រៀមខ្លួនសម្រាប់វគ្គពាក់កណ្ដាលផ្ដាច់ព័ត្រ ។ នៅថ្ងៃនៃការសម្ដែងនោះ ពួកគេបានក្រោកពីដំណេកនៅម៉ោង ៤:00ព្រឹក ក្នុងសីតុណ្ហភាព -៣៤ អង្សា ។ ប្អូនស្រី ណូមូអូងេរេល អេនខ្ជូវឈើន ជាសមាជិកក្រុមចម្រៀងម្នាក់បាននិយាយថា « សមាជិកក្រុមយើងជាច្រើនមានជំងឺផ្ដាសាយ » ។ ប៉ុន្តែពួកគេមានអារម្មណ៍ប្រសើរឡើង ពេលយើងបានអធិស្ឋានឲ្យពួកគេ » ។

ប្រជាជននៅក្នុងប្រទេសម៉ុងហ្គោលីទាំងមូលបានទស្សនាកម្មវិធីនេះ ហើយផ្ញើសារចូលដើម្បីធ្វើការបោះឆ្នោតរបស់ពួកគេ ។

ប្អូនប្រុស ឈឺជី ពូរេវឌ៉ូជ បាននិយាយថា « ដោយសារតែកម្មវិធីទូរទស្សន៍មួយនេះ មានមនុស្សជាច្រើនកំពុងមានឥរិយាបថវិជ្ជមានចំពោះសាសនាចក្រ » ។

**ពរជ័យ**

សមាជិកក្រុមចម្រៀងផ្ទាល់ក៏បានទទួលពរជ័យផងដែរ ។ ប្អូនប្រុស អូដហ្គេរេល តូមើរសូក បាននិយាយថា « យើងបានផ្ដោតអារម្មណ៍របស់យើង ហើយបានលះបង់ពេលវេលាពេញមួយឆ្នាំ ខណៈដែលយើងគ្រប់គ្រងការងាររបស់យើង និងធុរៈផ្សេងទៀតនៅក្នុងជីវិតរបស់យើង ។ ទោះជាវាមានភាពលំបាកក្ដី ក៏យើងបានទទួលពរជ័យជាច្រើនដែរ ។ ខ្ញុំបានរៀនគ្រប់គ្រងពេលវេលារបស់ខ្ញុំ ហើយធ្វើការលះបង់ថ្វាយព្រះអម្ចាស់ » ។

បន្ថែមពីលើការបង្កើនសេចក្ដីជំនឿរបស់ពួកគេ សមាជិកក្រុមចម្រៀងនេះបានទទួលនូវទំនុកចិត្តខ្លួន បានអភិវឌ្ឍមិត្តភាព ហើយបានរៀនដើម្បីមានសាមគ្គីភាព ។ ប្អូនប្រុស ហ្គានបាអាតា អូលហ្សីឌូអូរេន បាននិយាយថា « ការច្រៀងនៅក្នុងក្រុមចម្រៀងបានជួយយើងឲ្យរៀនពីរបៀបអភ័យទោស ហើយគាំទ្រគ្នាទៅវិញទៅមក » ។ « យើងមានសាមគ្គីភាពកាន់តែខ្លាំងឡើង » ។ ប្អូនស្រី ប៊ិលហ្គូអូនហ្សាយ៉ា តូង៉ាឡាកតូអូល បានរៀនថា « ខ្ញុំពុំគួរសង្ស័យលើខ្លួនឯង ឬគិតថា ខ្ញុំពុំអាចធ្វើអ្វីមួយបានឡើយ » ។

ប្អូនប្រុស បាយ៉ាតសុគ ឡាក្វាចាវ បាននិយាយថា « ការច្រៀងនៅក្នុងក្រុមចម្រៀងបាននាំយកពរជ័យជាច្រើនដល់គ្រួសាររបស់ខ្ញុំ ហើយវាក៏ជួយខ្ញុំឲ្យទទួលបានចម្លើយដែលខ្ញុំបានស្វែងរកជាយូរមកហើយដែរ ។ ថ្នាក់ដឹកនាំរបស់យើងបានជួយផ្ដល់ដំណោះស្រាយដល់យើង ។ . . . វាបានបញ្ជាក់ដល់ទីបន្ទាល់របស់ខ្ញុំថា ថ្នាក់ដឹកនាំរបស់យើងត្រូវបានហៅមកពីព្រះ » ។

ប្អូនស្រី អូណុន ដាឡៃយូអូ បានពន្យល់ថា « ពេលខ្ញុំបានចូលរួមនៅក្នុង *កម្មវិធីប្រកួតប្រជែងផ្នែកទេពកោសល្យរបស់ម៉ុងហ្គោលី* ខ្ញុំបានរៀនថាការលើកទឹកចិត្ត និងការគាំទ្រគ្នា [ គឺជា ] គន្លឹះឆ្ពោះទៅរកជោគជ័យ [ របស់យើង ] » ។ ការទទួលខុសត្រូវរបស់ប្អូនស្រី ដាឡៃយូអូ រួមមានការរៀបចំសមាជិកក្រុម ដែលបានជួយពង្រឹងសមត្ថភាពភាពជាអ្នកដឹកនាំរបស់នាង ។ នាងបានបន្ថែមថា « យើងមានអារម្មណ៍ថា ព្រះអម្ចាស់បានដឹកនាំ ហើយបានមានឥទ្ធិពលមកលើយើង ។ ពួកយើងភាគច្រើនមានជំងឺ រវល់ អស់កម្លាំង ហើយមានការថប់បារម្ភ ។ ប៉ុន្តែពេលយើងបានអធិស្ឋានរួមគ្នា យើងហាក់ដូចជារកឃើញនូវថាមពល និងបំណងប្រាថ្នាកាន់តែខ្លាំងឡើងដើម្បីស៊ូទ្រាំ » ។

ទោះបីជាក្រុមចម្រៀងនេះពុំបានទទួលការបោះឆ្នោតឲ្យគ្រប់គ្រាន់ដើម្បីឈានទៅវគ្គផ្ដាច់ព័ត្រក្ដី ក៏ការសម្ដែងរបស់ពួកគេបានផ្ដល់នូវការផ្សព្វផ្សាយយ៉ាងសំខាន់អំពីសាសនាចក្រនៅក្នុងប្រទេសម៉ុងហ្គោលី ។ ប្រធាន អូឈើចាវ ពន្យល់ថា « យើងបានគោរពប្រតិបត្តិចំពោះការចាត់តាំងមួយមកពីថ្នាក់ដឹកនាំបព្វជិតភាពរបស់យើង ហើយព្រះអម្ចាស់បានរៀបចំផ្លូវមួយឲ្យយើង ។ . . . ឥឡូវនេះទីក្រុង [ អ៊ូឡង់បាទ័រ ] ទាំងមូលនិយាយអំពីការចូលរួមរបស់ក្រុមចម្រៀងមរមននៅក្នុង *កម្មវិធីប្រកួតប្រជែងផ្នែកទេពកោសល្យរបស់ម៉ុងហ្គោលី* » ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា និង អ៊ូឡង់បាតា ប្រទេសម៉ុងហ្គោលី ។*



រូបថតទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីអូដហ្គេរេល អូឈើចាវ, រូបភាពនៃហ្វូងមហាជន មកពី GETTY IMAGES

# អំណោយរបស់ខ្ញុំថ្វាយព្រះអង្គសង្គ្រោះ

ដោយ ឈើស្តេន ភីកស្តុន

នៅប្រទេសរុស្ស៊ីគឺមានអាកាសធាតុត្រជាក់ណាស់ និងមេឃងងឹតជារឿយៗនៅរដូវរងា ដែលបានធ្វើឲ្យថ្ងៃនីមួយៗមានភាពអាប់អួរ ហើយកម្សត់បន្តិច ។ វាស្ថិតនៅចុងខែវិច្ឆិកា ហើយលើសពីអាកាសធាតុដ៏អាប់អួរនោះទៀត គឺខ្ញុំបានមានអារម្មណ៍ឯកោ ខ្វះសមត្ថភាព ហើយគ្មានសមត្ថភាពដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនាដ៏ល្អម្នាក់ ។ ខ្ញុំទើបតាមត្រូវបានចាត់តាំងឲ្យបំពាក់បំប៉នដល់ដៃគូថ្មីម្នាក់ ហើយកាលស៊ិស្ទើរ ហាត គឺជាមនុស្សដ៏ល្អម្នាក់ នោះសម្ពាធធ្លាក់មកលើខ្ញុំដើម្បីរៀនភាសាឲ្យប្រសើរជាងមុន ធ្វើជាគំរូ ហើយរកមនុស្សម្នាក់ — នរណាក៏បាន — ដើម្បីបង្រៀន ។

យើងទើបទទួលបានដំណឹងថា ប្រធានបេសកកម្មថ្មីរបស់យើងនឹងធ្វើសន្និសីទហ្សូននៅទីក្រុងយេកាធើរីនប៊ើក ដែលមានចម្ងាយធ្វើដំណើរប្រាំម៉ោងពីតំបន់របស់យើងនៅពេម ។ នាព្រឹកព្រលឹមខែធ្នូដ៏ត្រជាក់មួយ ស៊ិស្ទើរ ហាត និងខ្ញុំបានធ្វើដំណើរទៅស្ថានីយរថភ្លើង ។

ពេលយើងបានរង់ចាំ ខ្ញុំបានពិចារណាអំពីអារម្មណ៍ដែលខ្ញុំកំពុងមាន ។ ខ្ញុំបានគិតអំពីថ្ងៃបុណ្យឈប់សម្រាកដែលខិតចូលមកដល់ និងការដែលខ្ញុំចង់នៅក្បែរនឹងគ្រួសាររបស់ខ្ញុំ ។ ចិត្តរំភើបដើម្បីធ្វើបេសកកម្មបានរសាយបាត់ ហើយពេលនេះខ្ញុំមានអារម្មណ៍ដូចជាខ្ញុំពុំបានសម្រេចកិច្ចការច្រើនទេ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ក្នុងរយៈពេលប្រាំបួនខែដែលខ្ញុំបានចេញមកផ្សព្វផ្សាយ ។ នៅទីបំផុតសម្រែកនៃការមកដល់របស់រថភ្លើងបានបន្លឺឡើង ដូច្នេះយើងបានឡើងលើរថភ្លើងនោះ ហើយអង្គុយនៅកៅអី របស់យើង ។ ខ្ញុំបានឃើញថា ខ្ញុំកំពុងគិតអំពីព្រះអង្គសង្គ្រោះ ។ ខ្ញុំបានបិទភ្នែកអធិស្ឋានឲ្យខ្ញុំអាចដឹងអំពីរបៀបដែលលុបបំបាត់អារម្មណ៍ទាំងនេះ ហើយផ្តោតទៅលើទ្រង់ឲ្យបានប្រសើរជាងមុន ។

លុះស្អែកឡើង នៅឯសន្និសីទហ្សូន សុន្ទរកថារបស់ប្រធាន វ៉ាស់ មានខ្លឹមសារល្អណាស់ ។ ពេលស៊ិស្ទើរ វ៉ាស់ ឡើងនិយាយ គាត់បានចែកចាយដំណើររឿងសាមញ្ញមួយអំពីរបៀបដែលព្រះអង្គសង្គ្រោះគឺជាអ្នកគង្វាលដែលនឹងទៅរកចៀមមួយដែលវង្វេងផ្លូវ ហើយនាំចៀមនោះត្រឡប់មកក្រោលវិញ ។ គាត់បាននិយាយអំពីពលិកម្មដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់យើង ហើយនៅទីបំផុតគាត់បានថ្លែងទីបន្ទាល់ដ៏មានអនុភាពមួយអំពីឱកាសដែលយើងជាអ្នកផ្សព្វផ្សាយសាសនាមានដើម្បីបម្រើទ្រង់ ដោយការនាំចៀមវង្វេងរបស់ទ្រង់មកកាន់ហ្វូងវិញ ។ ស៊ិស្ទើរវ៉ាស់បានសំណូមពរឲ្យយើងគិតថា តើអំណោយអ្វីទៅដែលយើងអាចថ្វាយដល់ព្រះអង្គសង្គ្រោះសម្រាប់បុណ្យគ្រីស្ទម៉ាស់ ។

ពេលគាត់បានសំណូមពរបែបនោះ ខ្ញុំមានអារម្មណ៍បំផុសគំនិតយ៉ាងខ្លាំងបំផុតថា អំណោយដែលខ្ញុំត្រូវថ្វាយព្រះអង្គសង្គ្រោះគឺគ្រាន់តែនិយាយនឹងមនុស្សឲ្យបានច្រើន ។ រហូតមកដល់ចំណុចនោះ ខ្ញុំបានភ័យខ្លាចដើម្បីចាប់ផ្តើមសន្ទនានឹងមនុស្សចម្លែក — ជាពិសេសនៅក្នុងប្រទេស

**ខ្ញុំមានអារម្មណ៍ខ្វះសមត្ថភាពក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ។ តើខ្ញុំអាចធ្វើអ្វីខ្លះ ដើម្បីឈប់ផ្តោតលើខ្លួនឯង ហើយចាប់ផ្តើមផ្តោតលើព្រះអង្គសង្គ្រោះវិញ**



រុស្ស៊ី ! ខ្ញុំពុំចង់ឲ្យពួកគេគិតថា ខ្ញុំគឺជាមនុស្សល្ងង់ខ្លៅចំពោះការមិនយល់អំពីពួកគេ ដូច្នេះអ្វីដែលល្អគឺមិនត្រូវនិយាយអ្វីទាំងអស់ ។ ប៉ុន្តែនៅគ្រានោះ ខ្ញុំបានដឹងយ៉ាងប្រាកដនូវអ្វីដែលខ្ញុំត្រូវធ្វើ ។ ខ្ញុំត្រូវឈប់គិតអំពីខ្លួនឯង ហើយចាប់ផ្ដើមគិតអំពីបងប្អូនប្រុសស្រីរបស់ខ្ញុំវិញ ។ ខ្ញុំបានដាក់គោលដៅមួយដើម្បីនិយាយអំពីដំណឹងល្អនឹងមនុស្សគ្រប់រូបរៀងរាល់ពេលយើងជិះក្នុងរថយន្ត រហូតដល់ចុងខែ ហើយខិតខំធ្វើកិច្ចការនោះទុកជាអំណោយបុណ្យគ្រីស្ទម៉ាស់ថ្វាយព្រះអង្គ សង្គ្រោះ ។

ពេលសិស្ទើរ ហាត និងខ្ញុំបានឡើងជិះរថភ្លើងមួយទៀតត្រឡប់មកទីក្រុងពារមេ វិញនៅព្រឹកស្អែក ខ្ញុំបានចាប់ផ្ដើមគោលដៅរបស់ខ្ញុំដោយនិយាយនឹងមនុស្សដែលខ្ញុំអង្គុយក្បែរ ។ ពួកគេពុំមានចំណាប់អារម្មណ៍នឹងអ្វីដែលខ្ញុំបានចែកចាយឡើយ ប៉ុន្តែយ៉ាងហោចណាស់ខ្ញុំក៏បានព្យាយាមដែរ !

រៀងរាល់ថ្ងៃ តែងតែមានឧបសគ្គ ពេលខ្ញុំបានខិតខំថ្វាយអំណោយរបស់ខ្ញុំចំពោះព្រះអង្គសង្គ្រោះ ប៉ុន្តែបន្តិចម្ដងៗ ខ្ញុំបានឃើញថា ខ្ញុំមានអារម្មណ៍រីករាយ ហើយមានទំនុកចិត្តជាងមុន — ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានបំពេញកាន់តែប្រសើរចំពោះការហៅរបស់ខ្ញុំឲ្យធ្វើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ។ បុណ្យគ្រីស្ទម៉ាស់បានមកដល់ ហើយក៏កន្លងផុតទៅ ប៉ុន្តែខ្ញុំបានសម្រេចចិត្តថា ខ្ញុំនឹងបន្តនិយាយនឹងមនុស្សដទៃទៀត ។ ខ្ញុំបានចាប់ផ្ដើមនិយាយនឹងពួកគេពុំមែនតែនៅពេលដែលយើងនៅលើមធ្យោបាយធ្វើដំណើរសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើវានៅតាមផ្លូវ នៅក្នុងផ្សារ នៅឯបណ្ណាល័យ និងនៅ គ្រប់ទីកន្លែងផ្សេងទៀតដែលយើងទៅផងដែរ ។

យើងពុំបានរកឃើញមនុស្សណាម្នាក់ដើម្បីបង្រៀនឡើយតាមរយៈការនិយាយរបស់ខ្ញុំនឹងមនុស្សជាច្រើន ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ខ្ញុំបានបណ្ដុះគ្រាប់ពូជនៃដំណឹងល្អ ។ យើងបានបង្កើតមិត្តភាពនឹងពួកអ្នកបើករថយន្តក្រុង មនុស្សនៅហាងលក់គ្រឿងទេសក្នុងមូលដ្ឋាន និងមនុស្សផ្សេងទៀត ។ រឿងដែលល្អបំផុតគឺថា ពេលយើងឃើញនរណាម្នាក់ម្ដងទៀត ជារឿយៗយើងឃើញពួកគេញញឹម ហើយពួកគេតែងនិយាយពាក្យសួស្ដីមកពួកយើងមុន ។ ខ្ញុំមានជំនឿថា គ្រាប់ពូជទាំងនោះដែលយើងបានដាំនឹងចេញជាផ្កានៅថ្ងៃណាមួយ ពេលឱកាសថ្មីបានមកដល់សម្រាប់មនុស្សទាំងនោះដើម្បីរៀនអំពីដំណឹងល្អ ។ ព្រះវរបិតាសួគ៌ធ្វើការតាមរបៀបតូច ហើយសាមញ្ញ ហើយពេលខ្លះវាចាប់ផ្ដើមជាមួយនឹងពាក្យដ៏សាមញ្ញមួយម៉ាត់ថា « សួស្ដី » ។

ឥឡូវនេះពេលនឹកគិតឡើងវិញអំពីគ្រានោះនៅលើរថភ្លើងទៅកាន់ទីក្រុងយេកាធើរិនប៊ែក ខ្ញុំដឹងថា ព្រះវរបិតាសួគ៌បានឆ្លើយតបដល់ការអធិស្ឋានរបស់ខ្ញុំ ។ ទ្រង់បានជួយខ្ញុំឲ្យមើលឃើញថា កិច្ចការផ្សព្វផ្សាយសាសនាពុំមែនតែអំពីខ្លួនខ្ញុំនោះទេ — ប៉ុន្តែអំពីមនុស្សដទៃ ហើយពេលយើងគិតដល់មនុស្សដទៃច្រើនជាងខ្លួនឯង ព្រមទាំងកង្វល់ និងភាពសោកសៅរបស់យើង នោះយើងរកឃើញសុភមង្គលដែលយើងកំពុងស្វែងរក ។ ខ្ញុំមានចិត្តស្ញប់ស្ញែងចំពោះព្រះហឫទ័យដ៏សប្បុរសគ្មានព្រំដែនរបស់ព្រះអង្គសង្គ្រោះ ទោះជាពេលយើងខិតខំថ្វាយអ្វីៗគ្រប់យ៉ាងចំពោះទ្រង់តាមដែលយើងអាចធ្វើបាន ក៏ទ្រង់ប្រទានពរយ៉ាងច្រើនលើសលុបដល់យើងវិញដែរ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ អៃដាហូ ស.រ.អា ។*




រចនារូបភាពដោយ ឌីណាក់ ម៉ៃតាលើប៉ូ

# ការស្វែងរកសេចក្ដីជំនឿ របស់នាងម្ដងទៀត

*ផ្លូវត្រឡប់ក្រោយវិញវាពុំងាយស្រួលជានិច្ច នោះទេ ប៉ុន្តែវាតែងតែ នៅទីនោះ ។*

**ដោយ ដេវីឌ ឌីកសុន**
ទស្សនាវដ្ដីសាសនាចក្រ

ពាក្យ « [ ការធ្លាក់ ] តាមផ្លូវហាមឃាត់ និង [ ការក្លាយជា ] វង្វេងបាត់អស់ទៅ » ( នីហ្វៃទី១ ៨:២៨ ) ប្រហែលភាគច្រើនយើងស្ដាប់ទៅដូចជារឿងអស់សង្ឃឹមណាស់ ពេលយើងអានពាក្យទាំងនេះនៅក្នុងព្រះគម្ពីរមរមន ។ រឿងដែលបានកើតឡើងដល់ខ្ញុំ គឺផ្ទុយគ្នាពីព្រះគម្ពីរមរមន ។ វាងាយស្រួលណាស់ដោយស្រមៃឃើញអំពីលទ្ធផលដ៏ស្រងូតស្រងាត់មួយប្រភេទសម្រាប់មនុស្សមួយក្រុម ដែល ត្រូវបានពិពណ៌នានៅក្នុងការនិមិត្តរបស់លីហៃអំពីដើមឈើជីវិត — ជាមនុស្សមួយក្រុមដែលបានភ្លក់រសជាតិផ្លែនៃដើមឈើនោះ ហើយក្រោយមក បានបោះបង់ចោលទៅនោះ ។

ប៉ុន្តែ តេ អូវ៉ាណូអា អិម អាយុ ១៧ ឆ្នាំ មកពីប្រទេសនូវែលសេឡង់មានការយល់ផ្សេងមួយអំពីរឿងទាំងឡាយ ។ នាងនិយាយថា « អ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលអំពីបទគម្ពីរនេះគឺ វាពុំបានចែងថា ពួកគេត្រូវបានវង្វេងបាត់បង់ទៅជារៀងរហូតនោះទេ » ។

ឱជាការវិនិច្ឆ័យដ៏អស្ចារ្យអ្វីម្ល៉េះ ! ហើយវាគឺជាការវិនិច្ឆ័យមួយដែលកើតមកពីបទពិសោធន៍ផ្ទាល់ខ្លួន ។ នាងនិយាយថា « ចំពោះរូបខ្ញុំផ្ទាល់ ខ្ញុំបានវង្វេងចេញពីសាសនាចក្រនេះ ប៉ុន្តែខ្ញុំអាចត្រឡប់មកវិញបាន » ។

## ការចុះទន់ខ្សោយ

តេ អូវ៉ាណូអា បានធំដឹងក្ដីឡើងនៅក្នុងសាសនាចក្រ ហើយនិយាយអំពីការទទួលបានទីបន្ទាល់របស់នាង ព្រមទាំងការដាក់គោលដៅនានាខាងវិញ្ញាណ ។ នាងនិយាយថា « ប៉ុន្តែ ទីបន្ទាល់នោះបានចុះទន់ខ្សោយ » ។

តាមរបៀបមួយចំនួន នាងបានរកឃើញខ្លួនឯងមានអាកប្បកិរិយាស្រដៀងគ្នានឹងអាមូលេក ជាពិសេសតាមរបៀបដែលគាត់បានពិពណ៌នាអំពីខ្លួនឯងប្រាប់ដល់ប្រជាជនអាំម៉ូណៃហាថា « ខ្ញុំត្រូវបានហៅជាច្រើនដង តែខ្ញុំធ្វើជាមិនឮ ហេតុដូច្នេះហើយខ្ញុំបានដឹងអំពីការណ៍ទាំងនេះ តែខ្ញុំធ្វើជាមិនដឹង » ( អាលម៉ា ១០:៦ ) ។

ចំពោះតេ អូវ៉ាណូអា បទគម្ពីរនោះមានន័យខ្លាំងណាស់ចំពោះនាង ។ « ដូចជាអាមូលេកដែរ ខ្ញុំបានដឹងអំពីរឿងខាងវិញ្ញាណទាំងអស់នេះ ហើយព្រះវិញ្ញាណបានប្រាប់ខ្ញុំឲ្យធ្វើនូវរឿងជាក់លាក់មួយចំនួន ប៉ុន្តែដោយសារតែខ្ញុំចចេស ហើយមានអំនួតបន្តិច ខ្ញុំពុំបានធ្វើរឿងទាំងនោះឡើយ ។ ក្រោយមកទៀត ទីបន្ទាល់របស់ខ្ញុំហាក់ដូចជាចុះខ្សោយ » ។

នៅទីបំផុត ដំណើររឿងរបស់អាមូលេកនឹងមានន័យកាន់តែជ្រាលជ្រៅលើសពីការគ្រាន់តែមានភាពស្រដៀងគ្នានឹងដំណើររឿងរបស់ តេ អូវ៉ាណូអា ទៅទៀត ។ វាក៏ក្លាយជាគ្រាផ្លាស់ប្ដូរដ៏សំខាន់មួយដែលបានដឹកនាំនាងឲ្យត្រឡប់មកកាន់សាសនាចក្រវិញ ។

## ការស្វែងរកអនុស្សាវរីយមួយដ៏កក់ក្ដៅ

សូម្បីតែនៅអំឡុងគ្រាដែលសេចក្ដីជំនឿរបស់នាងបានចុះទន់ខ្សោយក្ដី ក៏នាងនៅតែចងចាំពីបទពិសោធន៍ដ៏ផ្អែមល្ហែមនានាពីមុនដែរ ។ តេ អូវ៉ាណូអា ពុំដែលភ្លេចពីអារម្មណ៍របស់នាងឡើយ ពេលចូលទៅក្នុងព្រះវិហារបរិសុទ្ធជាមួយនឹងក្រុមយុវ័យរបស់នាង ឬការទៅសន្និសីទសម្រាប់យុវវ័យ ។

នាងនិយាយថា « មានគន្លងមួយ » ។ « ខ្ញុំមានអារម្មណ៍ល្អណាស់ ពេលខ្ញុំបានមកព្រះវិហារ ប៉ុន្តែខ្ញុំមានអារម្មណ៍មិនល្អសោះ ពេលខ្ញុំពុំបានទៅព្រះវិហារ » ។

នៅទីបំផុតថ្ងៃមួយក៏បានមកដល់ ជាពេលដែល តេ អូវ៉ាណូអា បានសម្រេចចិត្តសាកល្បងថាតើនាងអាចភ្ជាប់ទៅនឹងអារម្មណ៍ល្អទាំងនោះម្ដងទៀតបានដែរឬទេ ។ រឿងដំបូងដែលនាងបានធ្វើគឺអានសុន្ទរកថាសន្និសីទថ្មីៗ ។

សុន្ទរកថាមួយក្នុងសន្និសីទទូទៅឆ្នាំ ២០១៦ ដែលមានចំណងជើងថា « ចូររៀនអំពីអាលម៉ា និង



រូបថតខាងក្រោយមកពី GETTY IMAGES

អាមូលេក » ដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ បានដាស់អារម្មណ៍នៅក្នុងព្រលឹងរបស់តេ អូរ៉ាណូអា ។ នាងបានទទួលស្គាល់ច្រើនអំពីជីវិត និងអារម្មណ៍របស់នាងផ្ទាល់ ពេលប្រធាន អុជដូហ្វ បានពិពណ៌នាអំពីរបៀបដែលសេចក្តីជំនឿរបស់អាមូលេកបានចុះទន់ខ្សោយ ។ នាងក៏បានចាំយ៉ាងច្រើនអំពីសុភមង្គលដែលនាងធ្លាប់មានពីមុន ពេលសេចក្តីជំនឿរបស់នាងមានភាពរឹងមាំ ។ ភ្លាមៗនោះ នាងបានចង់ធ្វើការផ្លាស់ប្តូររឿងមួយចំនួន ។

នាងពន្យល់ថា « ខ្ញុំសង្ឃឹមថា នឹងរកឃើញអ្វីមួយដែលធ្វើឲ្យទីបន្ទាល់របស់ខ្ញុំឆេះឆួលឡើងវិញ ដូច្នេះខ្ញុំក៏អានសុន្ទរកថារបស់ប្រធាន អុជដូហ្វ ហើយពិតណាស់ ខ្ញុំបានមានអារម្មណ៍ឆេះឆួល ! »

## ការសង្ឃឹមចំពោះភាពអស់កល្បជានិច្ច

ផ្លូវត្រឡប់ទៅរកសេចក្តីជំនឿវិញរបស់តេ អូរ៉ាណូអា វាពុំងាយស្រួលជានិច្ចនោះទេ ប៉ុន្តែមានពន្លឺពិសេសមួយនៅឯចុងនៃផ្លូវក្រោមដីដែលរារាំងដំណើររបស់នាង ៖ គឺជាសេចក្តីសង្ឃឹមនៃគ្រួសារអស់កល្បជានិច្ចមួយ ។

នាងនិយាយថា « ក្រុមគ្រួសារអាចរស់នៅជានិរន្តរ » ។ « នោះគឺជាក្តីស្រមៃដ៏ធំបំផុតរបស់ខ្ញុំ វាគឺជាក្តីសង្ឃឹមដ៏ធំបំផុតរបស់ខ្ញុំនៅក្នុងជីវិតនេះ ។ ពេលណាខ្ញុំចង់រៀនអំពីរឿងមួយ ឬខ្ញុំឃើញថា គោលលទ្ធិមួយដែលពិបាកយល់ ខ្ញុំប្រឹងប្រែងអនុវត្តតាមវា ហើយបង្វែរវាទៅរកក្រុមគ្រួសារអស់កល្បជានិច្ចវិញ ។ ឧទាហរណ៍ ហេតុអ្វីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទមានសារៈសំខាន់ចំពោះខ្ញុំ ? ចំណុចមួយគឺខ្ញុំត្រូវការដង្វាយធួនរបស់ទ្រង់នៅក្នុងជីវិតរបស់ខ្ញុំ ដើម្បីខ្ញុំអាចមានភាពសក្តិសមចូលទៅក្នុងព្រះវិហារបរិសុទ្ធ ហើយបានផ្សារភ្ជាប់នឹងគ្រួសាររបស់ខ្ញុំសម្រាប់ភាពអស់កល្បជានិច្ច » ។

## ការងាកមករកព្រះ

ប្រហែលជាវាមានតម្លៃដើម្បីចងចាំថា មនុស្សនៅក្នុងការនិមិត្តរបស់លីហៃដែលបានវង្វេង បន្ទាប់ពីភ្លក់រសជាតិផ្លែឈើនោះពិតណាស់ពួកគេនៅតែ *ភ្លក់* វា ។ ពួកគេប្រហែលជាបានដឹងអំពីសេចក្តីល្អរបស់វា សូម្បីតែមួយភ្លែតក្តី ។ ហើយពួកគេអាចរកឃើញវាម្តងទៀត ។ នោះគឺជាសេចក្តីសង្ឃឹមដែលតេ អូរ៉ាណូអាតោងខ្ជាប់សម្រាប់ខ្លួននាង និងសម្រាប់មនុស្សដទៃទៀត ។

នាងនិយាយថា « អ្នកពុំចាំបាច់បន្តដើរនៅលើផ្លូវហាមឃាត់ទាំងនោះពេញមួយជីវិតឡើយ » ។ « អ្នកអាចត្រឡប់មករកព្រះអម្ចាស់វិញ នៅពេលណាដែលអ្នកចង់មកវិញ » ។ ■



« អ្នកអាចត្រឡប់មក
រកព្រះអម្ចាស់វិញ
នៅពេលណាដែល
អ្នកចង់មកវិញ »



យុវវ័យទាំងនេះពុំបានដឹងពីទំហំនៃភាពរីករាយដែលពួកគេអាចនាំមកនូវជាមួយនឹងចម្រៀងដ៏សាមញ្ញពីរបីបទនោះឡើយ ។

# ឥទ្ធិពលនៃ ចម្រៀងបុណ្យគ្រីស្ទម៉ាស់

## ចម្រៀងបុណ្យគ្រីស្ទម៉ាស់មួយចំពោះចាគ្វីន

ការច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ពុំមែនជាទំនៀមទម្លាប់សម្រាប់បុណ្យគ្រីស្ទម៉ាស់នៅប្រទេសអាហ្សង់ទីននោះទេ ។ ពិតណាស់ បុណ្យគ្រីស្ទម៉ាស់នៅទីនេះគឺខុសប្លែកពីទិដ្ឋភាពមានព្រិលធ្លាក់តាមទម្លាប់ដែលអ្នកអាចគិតឃើញ ។ ដោយសារយើងរស់នៅអឌ្ឍគោលទិសអាគ្នេយ៍ បុណ្យគ្រីស្ទម៉ាស់ធ្វើឲ្យខ្ញុំគិតពីសាទ្បាត់ផ្លែឈើយ៉ាងច្រើន !

ដូច្នេះ ពេលឪពុកម្ដាយរបស់ខ្ញុំផ្ដល់យោបល់ឲ្យយើងសាកច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ជាគ្រួសារបងប្អូនរបស់ខ្ញុំ និងខ្ញុំមានអារម្មណ៍ច្របូកច្របល់គ្នារវាងភាពភាន់ច្រឡំ និងការរំភើបចិត្ត ។ យើងពុំប្រាកដពីសមត្ថភាពខាងតន្ត្រីរបស់យើងនោះទេ ដូច្នេះយើងបានសម្រេចចិត្តធ្វើនំយុកឃីមួយចំនួន ហើយយកវាទៅឲ្យមនុស្សដែលយើងទៅលេង ដែលយ៉ាងហោចណាស់វាអាចធ្វើឲ្យពួកគេញញឹមបាន ។

មានបុរសម្នាក់ឈ្មោះ ចាគ្វីន ជាសមាជិកនៅក្នុងវួដរបស់យើងយូរហើយ ។ ក្នុងខែធ្នូនោះ គាត់បានធ្លាក់ខ្លួនឈឺធ្ងន់ ហើយពុំអាចចូលរួមការប្រជុំសាក្រាម៉ង់បានទៀតឡើយ ។ ឪពុក និងបងប្អូនប្រុសរបស់ខ្ញុំគឺនៅក្នុងចំណោមអ្នកដែលយកសាក្រាម៉ង់ទៅឲ្យគាត់នៅឯមន្ទីរពេទ្យ បន្ទាប់ពីព្រះវិហារនៅថ្ងៃអាទិត្យ ។

នៅថ្ងៃអាទិត្យមួយ ពីមុនបុណ្យគ្រីស្ទម៉ាស់គ្រួសាររបស់យើងទាំងមូលបានជិះរថយន្តទៅសួរសុខទុក្ខចាគ្វីន ដោយសង្ឃឹមថា យើងនឹងនាំយកមកជាមួយនូវវិញ្ញាណបុណ្យគ្រីស្ទម៉ាស់ដ៏កក់ក្ដៅមួយ ។ ពេលយើងបានមកដល់ គិលានុប្បដ្ឋាយិកាបាននាំយើងទៅបន្ទប់សម្រាករបស់គាត់ ។ គាត់មានព្រះគម្ពីរ និងសៀវភៅទំនុកតម្កើងនៅក្បែរគ្រែរបស់គាត់ ហាក់ដូចជាគាត់កំពុងរង់ចាំយើងដូច្នោះដែរ ។

គាត់ពិតជាមានចិត្តរីករាយខ្លាំងណាស់ដោយឃើញយើងនៅទីនោះ ហើយរំពេចនោះយើងទាំងអស់គ្នាបានមានអារម្មណ៍នៃសេចក្ដីស្រឡាញ់ជាខ្លាំងចំពោះគាត់ ។ បងប្អូនប្រុសរបស់ខ្ញុំបានរៀបចំប្រសិទ្ធពរ ហើយចែកសាក្រាម៉ង់ ។ ពីមុនយើងបានចាកចេញ យើងបានច្រៀងទំនុកច្រៀងនៅក្នុង « ឆ្ងាយ ឆ្ងាយនៅលើទីវាលទំនាបយូដា » ៖ « សរសើរដល់ព្រះដ៏ខ្ពស់បំផុត សូមក្ដីសុខមានដល់មនុស្សលោក » ( *ទំនុកតម្កើង* ល.រ. ១៣២ ) ។

ពិតណាស់ វាគឺជាសេចក្ដីសុខ និងឆន្ទៈល្អដែលបានចូលមកក្នុងដួងចិត្តរបស់យើង ពេលគាត់បានហៅយើងថា « ពួកទេវតា » ហើយបានអរគុណយើងចំពោះការមកសួរសុខទុក្ខ ពេលយើងទាំងអស់គ្នាចង់នាំយកអារម្មណ៍ទាំងនោះមកឲ្យគាត់ ។

*ដូលា ដឺ ប៊ុយណូសែ អាហ្សង់ទីន*

រចនារូបភាពដោយ ម៉ែយល មូឡាន

# ផ្ទះចុងក្រោយនារាត្រីនោះ

វាគឺជាថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់ ហើយខ្ញុំ *ពុំ* ចង់ចេញទៅច្រៀងចម្រៀងទេ ។

ប៉ុន្តែម្ដាយរបស់ខ្ញុំបានគិតថា វាគឺជារឿងដ៏សប្បាយរីករាយមួយ ប្រសិនបើគ្រួសាររបស់យើងប្រជ្រៀតគ្នាជិះក្នុងរថយន្តដ៏ចាស់របស់យើង ហើយបើកទៅតាមផ្លូវសង្កាត់ដែលមានសុទ្ធតែព្រិល ដើម្បីច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ដល់ស្ត្រីមេម៉ាយបីនាក់នៅក្នុងវួដរបស់យើង ហើយប៉ារបស់ខ្ញុំគាំទ្រយោបល់របស់អ្នកម្ដាយខ្ញុំនេះដោយក្ដីរីករាយ ។

ខ្ញុំមានអារម្មណ៍មិនស្រួលចិត្តសោះ ។ តើនរណាចង់ស្ដាប់យើងទៅ ? ខ្ញុំនឹងមានការអៀនខ្មាស់មិនខានប្រសិនបើខ្ញុំបានឃើញមនុស្សដែលខ្ញុំស្គាល់នោះ ។ ដោយរអ៊ូរទាំ ហើយមិននិយាយស្ដីអ្វីសោះ ខ្ញុំបានលូនចូលទៅអង្គុយនៅកៅអីខាងក្រោយជាមួយនឹងបងប្អូនប្រុសស្រីរបស់ខ្ញុំ ។

ការធ្វើដំណើរទៅផ្ទះទីមួយគឺមានចម្ងាយតែពីរបីផ្លូវជិតៗនោះប៉ុណ្ណោះ ។ គ្មាននរណាម្នាក់បើកទ្វារទេ ។ យើងបានបើករថយន្តទៅផ្ទះទីពីរ ។ គ្មានមនុស្សបើកទ្វារទៀត ។ អារម្មណ៍របស់ខ្ញុំបានធូរស្រាល ។

ពេលយើងបានបើកចូលទៅផ្លូវតូចមួយនៃផ្ទះចុងក្រោយរបស់យើង ខ្ញុំបានគិតថា « សូមកុំឲ្យមានមនុស្សនៅផ្ទះអី » ។

ពេលនេះ នៅខាងក្រៅមានភាពងងឹត ។ ពេលអ្នកម្ដាយរបស់ខ្ញុំបានគោះទ្វារ ហើយបានរង់ចាំនៅខាងមុខមាត់ទ្វារផ្ទះនៅតែមានភាពងងឹត ។ ល្អ ។ មិនយូរទេយើងនឹងទៅផ្ទះវិញហើយ ជាកន្លែងដែលខ្ញុំអាចគេចខ្លួនចូលទៅបន្ទប់ដេករបស់ខ្ញុំ ។

រំពេចនោះ ភ្លើងនៅមាត់ទ្វារបានភ្លឺឡើង ហើយទ្វារក៏បើក ។ ខ្ញុំមានភាពអាម៉ាស់ខ្លាំងណាស់ ។ ខ្ញុំមានអារម្មណ៍ថា យើងបានមករំខានដល់គាត់ ។

ស្ត្រីមាឌតូចស្គមរូបនោះបាននិយាយថា « សូមចូលមកក្នុងផ្ទះមក » ។ គាត់បានចង្អុលទៅព្យាណូបញ្ឈរចំណាស់របស់គាត់ ។

គាត់បានសួរអ្នកម្ដាយខ្ញុំថា « តើអ្នកស្រីចេះលេងព្យាណូទេ ? » « តោះ យើងឈរច្រៀងជុំវិញព្យាណូនេះ » ។

ភាពរាក់ទាក់ និងភាពរីករាយរបស់គាត់បានបន្ទន់ចិត្តខ្ញុំ ។ ប្រហែលជាគាត់មិនប្រកាន់ទេ ដែលយើងបាននៅទីនោះ ។ យើងបានច្រៀងចម្រៀងពីរបីបទ ពេលគាត់បានធ្វើទឹកសូកូឡាក្ដៅៗសម្រាប់យើង ។

គាត់បានសួរខ្ញុំថា « តើក្មួយអាចមកជួយអ៊ំបានទេ ? » ពេលយើងចូលទៅក្នុងផ្ទះបាយ ខ្ញុំមានចិត្តភ្ញាក់ផ្អើលដោយឃើញតុដ៏ស្រស់ស្អាតមួយដែលបានតុបតែងយ៉ាងស្រស់បំព្រងសម្រាប់បុណ្យគ្រីស្ទម៉ាស់ ។ វាមើលទៅសប្បាយខ្លាំងណាស់ ! នៅកន្លែងនីមួយៗមាននូវកញ្ចប់តូចៗដែលបានវេចខ្ចប់យ៉ាងប្រុងប្រយ័ត្ន ។

ខ្ញុំបានសួរថា « តើកញ្ចប់នេះសម្រាប់នរណា ? » ខ្ញុំបានដឹងថា គាត់រស់នៅតែម្នាក់ឯង ។

គាត់បានពន្យល់ថា « សម្រាប់អ្នកជិតខាងរបស់អ៊ុំ » ។ « រាល់បុណ្យគ្រីស្ទម៉ាស់ អ៊ុំអញ្ជើញស្ត្រីមេម៉ាយដូចជាអ៊ុំ — អ្នកដែលគ្មានគ្រួសារនៅក្បែរ — ឲ្យមកបរិភោគអាហារពេលព្រឹក និងបង្អែមបន្តិចបន្តួចសម្រាប់បុណ្យគ្រីស្ទម៉ាស់ » ។

គំនិតនោះបានផុសឡើងក្នុងគំនិតខ្ញុំដែលមានវ័យ ១៣ ឆ្នាំ ។ ការស្ញប់ស្ញែងបានគ្រប់ដណ្ដប់ដួងចិត្តរឹងរូសរបស់ខ្ញុំ ។ បន្ទប់នេះមានភាពស្រស់ស្អាតណាស់ ។ អ៊ុំស្រីមាឌតូចវ័យចំណាស់ម្នាក់នេះស្រស់ស្អាតណាស់ ។ កាលដែលម្ដាយរបស់ខ្ញុំនាំយើងមកទីនេះគឺជារឿងដ៏រីករាយណាស់ ។ នៅទីបំផុតខ្ញុំបានមានចិត្តរីករាយ ។

លុះមួយខែក្រោយមក នៅឯព្រះវិហារអ៊ុំស្រីរូបនេះបានអរគុណយើងម្ដងទៀតដែលបានទៅសួរសុខទុក្ខគាត់ ។ គាត់បានប្រាប់យើងថា យើងគឺជាគ្រួសារតែមួយគត់នៅឆ្នាំនោះ ដែលបានចងចាំដល់ *រូបគាត់* ។ ពីរបីខែក្រោយមក គាត់បានចែកឋានទៅដោយពុំបានរំពឹងទុក ។

ខ្ញុំគិតត្រឡប់ទៅវិញពីបុណ្យគ្រីស្ទម៉ាស់ពេលនោះ ហើយមាននូវអំណរគុណចំពោះឪពុកម្ដាយដ៏ល្អ និងចំពោះអ៊ុំស្រីចំណាស់រូបនេះ ដែលពួកគាត់ម្នាក់ៗចង់នាំយកភាពរីករាយនៃបុណ្យគ្រីស្ទម៉ាស់ទៅដល់មនុស្សដទៃ ។ ■

*ប្រ៊ូក យេ រដ្ឋយូថាហ៍ ស.រ.អា.*





# ហេតុផលប្រាំបីយ៉ាងដែលបុណ្យគ្រីស្ទម៉ាស់គឺជាគ្រាដ៏អស្ចារ្យមួយដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនា

*មានរឿងដ៏អស្ចារ្យមួយអំពីបុណ្យឈប់សម្រាក ដែលធ្វើឲ្យការចែកចាយដំណឹងល្អកាន់តែប្រសើរឡើង !*

**ដោយ ឆាឡុត ឡាកាបាល**

ទស្សនាវដ្ដីសាសនាចក្រ

អ្នកស្រឡាញ់មិត្តភក្តិរបស់អ្នក ។ អ្នកស្រឡាញ់ដំណឹងល្អ ។ ហើយអ្នកពុំដឹងពីរបៀបណែនាំអំពីដំណឹងល្អឡើយ ។

ប្រសិនបើអ្នកមានបញ្ហាដូចគ្នានេះ អ្នកពុំជួបរឿងនេះ តែ ម្នាក់ឯងឡើយ ។ មានមនុស្សជាច្រើនចង់ចែកចាយដំណឹងល្អជាមួយមិត្តភក្តិរបស់ពួកគេ ប៉ុន្តែភ័យខ្លាចអំពីការបង្ខំ ឬអារម្មណ៍ពុំស្រណុកចិត្ត ។ ការចែកចាយដំណឹងល្អអាចធ្វើឲ្យមានការព្រួយបារម្ភជាច្រើន ។

ប៉ុន្តែសូមកុំខ្លាចឡើយ ! សូម្បីតែអ្នកពុំធ្លាប់លើកឡើងអំពីសាសនាចក្រដល់នរណាម្នាក់ពីមុនមកក្ដី ក៏រដូវកាលនៃ បុណ្យឈប់សម្រាករបស់អ្នកអាចបំពេញជាមួយនឹងពេលវេលាជាអ្នកផ្សព្វផ្សាយសាសនាធម្មតា ងាយស្រួល ហើយអាចធ្វើបានជាច្រើនរាប់មិនអស់ដែរ ។ តើដោយរបៀបណា ?

រឿងដំបូងដែលត្រូវធ្វើគឺ អធិស្ឋាន ។ សូមសាកល្បងទូលសូមព្រះវរបិតាសួគ៌សម្រាប់ឱកាសចែកចាយដំណឹងល្អ ។ សូមអធិស្ឋានដើម្បីដឹងអំពីមនុស្សដែលត្រូវនិយាយជាមួយ ឬអញ្ជើញ ហើយអធិស្ឋានសូមភាពក្លាហានដើម្បីធ្វើវាឲ្យបាន !

រឿងទីពីរគឺត្រូវចាប់ផ្តើម ។ ហើយចាប់ផ្តើម *ឥឡូវនេះ* ។ នេះគឺជាគន្លឹះ ៖ កិច្ចការផ្សព្វផ្សាយសាសនាគឺ *ងាយស្រួល* ធ្វើខ្លាំងណាស់ក្នុងអំឡុងបុណ្យគ្រីស្ទម៉ាស់ ។ ហេតុអ្វីទៅ ? យើងមានហេតុផលប្រាំបីយ៉ាង ។

**១. មនុស្សគ្រប់គ្នាចូលចិត្តមានពិធី ជប់លៀងដ៏សប្បាយ ។**

ឱកាសនានាមានដូចជា វួដរបស់អ្នក ឬប្រហែលជាគ្រួសាររបស់អ្នកនឹងមានផែនការរៀបចំពិធី ជប់លៀងមួយសម្រាប់បុណ្យគ្រីស្ទម៉ាស់ ។ សូមអញ្ជើញមិត្តភក្តិម្នាក់ឲ្យចូលរួមការជួបជុំនោះ ! ប្រហែលជាមានតែចម្រៀងមួយបទ ឬសារលិខិតមួយអំពីព្រះអង្គសង្គ្រោះ ហើយវាគឺជាអ្វីដែលមិត្តភក្តិរបស់អ្នកត្រូវការស្តាប់ឮ ។

**២. ការអញ្ជើញមនុស្សទៅកាន់ព្រះវិហារនៅបុណ្យគ្រីស្ទម៉ាស់គឺជារឿងដ៏ សាមញ្ញបំផុត ។**

បុណ្យគ្រីស្ទម៉ាស់មាននូវរឿងដ៏អស្ចារ្យមួយដែលធ្វើឲ្យមនុស្សចង់ទៅព្រះវិហារ ! នេះគឺជាពេលដ៏អស្ចារ្យមួយដើម្បីអនុញ្ញាតឲ្យមិត្តរបស់អ្នកដឹងថា ពួកគេត្រូវបានស្វាគមន៍ដើម្បីមើលឃើញអំពី របៀបដែលសមាជិកក្នុងព្រះវិហារបរិសុទ្ធអ្នកថ្វាយបង្គំព្រះអង្គសង្គ្រោះ ។

**តែងតែគាំទ្រជានិច្ច**

ខ្ញុំធ្លាប់និយាយនឹងអ្នកជិតខាងម្នាក់ដែលមានចំណាប់អារម្មណ៍យ៉ាងខ្លាំងអំពីដំណឹងល្អ ។ ខ្ញុំបានអញ្ជើញនាងទៅកម្មវិធីម៉ូតធល ប៉ុន្តែតែងតែមានរឿងរាំងនាងជានិច្ច ។ មានយប់មួយ ខ្ញុំបាននឹកឃើញថា ខ្ញុំពុំបានអធិស្ឋានអំពីរឿងនោះឡើយ ។ ភ្លាមៗនោះ ខ្ញុំបានលុតជង្គង់ចុះអធិស្ឋានទូលសូមព្រះវិញ្ញាណបរិសុទ្ធឲ្យគង់នឹងខ្ញុំ ហើយដឹកនាំខ្ញុំ ។ បន្ទាប់ពីខ្ញុំបានអធិស្ឋានហើយ ខ្ញុំបានរង់ចាំចម្លើយ ប៉ុន្តែពុំបានទទួលសោះ ។ ដោយភាពច្របូកច្របល់ ខ្ញុំបានសាកល្បងម្តងទៀត ប៉ុន្តែពេលនេះខ្ញុំបានទទួលអារម្មណ៍ផុសគំនិតដើម្បីថ្លែងអំណរគុណព្រះសម្រាប់រាល់ពរជ័យដែលខ្ញុំមាន ។ ខ្ញុំក៏បានអធិស្ឋានផងដែរថា ខ្ញុំអាចជួយមនុស្សដទៃឲ្យស្គាល់ពរជ័យជាច្រើនដែលពួកគេមាន និងរាល់ពរជ័យដែលពួកគេអាចថ្លែងអំណរគុណចំពោះព្រះចេស្តារបស់ព្រះអង្គសង្គ្រោះ ។

ខ្ញុំមានអារម្មណ៍យ៉ាងខ្លាំងថា មិនថាវាត្រូវចំណាយពេលប៉ុន្មានទេ ព្រះវរបិតារបស់ខ្ញុំដែលគង់នៅនគរស្ថានសួគ៌នឹងគង់ជាមួយខ្ញុំគាំទ្រខ្ញុំជានិច្ច ដោយប្រទានដល់ខ្ញុំនូវការអត់ធ្មត់ និងពរជ័យយ៉ាងច្រើន ។ ក្រោយពីការអធិស្ឋានទាំងនោះមិនយូរប៉ុន្មាន មិត្តភក្តិរបស់ខ្ញុំបានមកកម្មវិធីម៉ូតធលជាមួយនឹងខ្ញុំ !

***អេឡូរ៉ា ស៊ី អាយុ ១៤ ឆ្នាំ រដ្ឋអារីហ្សូណា ស.រ.អា.***







**៣. ចំណីចំណុក សម្រាប់បុណ្យគ្រីស្ទម៉ាស់គឺជារបៀបដ៏ល្អឥតខ្ចោះមួយដើម្បីធ្វើឲ្យការអញ្ជើញមួយ ឬសារលិខិតនៃដំណឹងល្អមួយមានរសជាតិកាន់តែផ្អែមល្ហែម ។**

ចុះប្រសិនបើផ្ដល់ឲ្យនូវនំឃុកឃីមួយចានជាមួយនឹងបទគម្ពីរមួយដែលអ្នកចូលចិត្តវិញតើវាយ៉ាងណាដែរ ? ចុះប្រសិនបើផ្ដល់ឲ្យនូវបង្អែម ហើយមានពាក្យដកស្រង់មួយអំពីបុណ្យគ្រីស្ទម៉ាស់វិញ តើវាយ៉ាងណាដែរ ? ពិតជាគំនិតល្អណាស់ !

**៤. ក្រុមគ្រួសារច្រើនតែជួបជុំគ្នា ។**

ការចំណាយពេលជាមួយនឹងគ្រួសារគឺជាផ្នែកដ៏ធំមួយនៃទំនៀមទម្លាប់បុណ្យគ្រីស្ទម៉ាស់ ដូច្នេះវាងាយស្រួលណាស់ដើម្បីនិយាយនឹងគ្រួសាររបស់អ្នក ទំនៀមទម្លាប់បុណ្យឈប់សម្រាករបស់អ្នក និងជំនឿរបស់អ្នកអំពីក្រុមគ្រួសារ ។

**៥. ភ្លើង និងសូកូឡាក្ដៅគឺពេញនិយមណាស់ ។**

ការទទួលទានសូកូឡាក្ដៅ ឬមើលការតុបតែងបុណ្យគ្រីស្ទម៉ាស់នៅជុំវិញក្រុងសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ឬសកម្មភាពម្ហូតឆលមួយ ។ សកម្មភាពបុណ្យឈប់សម្រាកគឺមានភាពសប្បាយរីករាយសម្រាប់មនុស្សគ្រប់គ្នា ហើយវាគឺជាវិធីដ៏ល្អ មួយសម្រាប់មិត្តភក្តិម្នាក់មើលឃើញអំពីរបៀបដែលអ្នករស់នៅតាមសាសនារបស់អ្នក ។

**ទោះវាពុំដូចជាការណ៍ធំក៏ដោយ**

មិនយូរប៉ុន្មានកន្លងទៅ មិត្តភក្តិរបស់ខ្ញុំក្នុងព្រះវិហារបានផ្លាស់លំនៅទៅនៅឆ្ងាយ ហើយនៅសាលារៀនសល់តែខ្ញុំម្នាក់គត់ដែលជាមរមន ។ ថ្មីៗនេះ គ្រូបង្រៀនសាលាថ្ងៃអាទិត្យរបស់ខ្ញុំបាននិយាយនឹងយើងអំពីរបៀបដែលយើងអាចចែកចាយដំណឹងល្អជាមួយនឹងមិត្តភក្តិរបស់យើង ។ ខ្ញុំបានអធិស្ឋានដើម្បីដឹងអំពីរបៀបដែលខ្ញុំអាចធ្វើកិច្ចការនេះបាន ហើយខ្ញុំពិតជាបានទទួលចម្លើយ ។ ខ្ញុំបាននិយាយនឹងមិត្តរបស់ខ្ញុំម្នាក់ ហើយយើងបានចាប់ផ្ដើមនិយាយអំពីជំហររបស់គាត់ទាក់ទងនឹងការដើរលេងជាគូ ។ ខ្ញុំបានពន្យល់ថា ខ្ញុំពុំជឿលើការដើរលេងជាគូរហូតដល់អាយុ ១៦ ឆ្នាំ ហើយខ្ញុំមានការភ្ញាក់ផ្អើល ពេលគាត់មានបទដ្ឋានមួយចំនួនដូចគ្នា ។ ទោះវាពុំដូចជាការណ៍ធំក៏ដោយ ប៉ុន្តែវាពិតជាចម្លើយមួយចំពោះការអធិស្ឋានរបស់ខ្ញុំ ហើយទីបន្ទាល់របស់ខ្ញុំអំពីការអធិស្ឋានត្រូវបានពង្រឹង ។

***ដេវីឌ អេស អាយុ ១៣ ឆ្នាំ រដ្ឋតិចសាស ស.រ.អា.***

### ៦. សារលិខិតរបស់ពួកមរមនអំពីបុណ្យគ្រីស្ទម៉ាស់គឺមានភាពអស្ចារ្យណាស់ ហើយងាយនឹងចែកចាយ ។

ការនាំយកអារម្មណ៍បុណ្យគ្រីស្ទម៉ាស់ទៅប្រព័ន្ធផ្សព្វផ្សាយសង្គមដោយចែកចាយ« វីដេអូបុណ្យគ្រីស្ទម៉ាស់ — ព្រះអង្គសង្គ្រោះបានប្រសូតហើយ » ! តើមានមិត្តភក្តិរបស់អ្នកប៉ុន្មាននាក់នៅលើហ្វេសប៊ុកដែលចង់មើលឃើញកុមារតូចម្នាក់ជួយអ្នករក្សាអគាម្ចម៉ៅម្នាក់នៅក្នុង « ហេតុផលអំពីបុណ្យគ្រីស្ទម៉ាស់ » ឬរឿងដ៏ផ្អែមល្ហែមមួយអំពីភាពពុំអាត្មានិយមនៅក្នុង « អាវរងា៖ ដំណើររឿងអំពីសេចក្ដីសប្បុរស » ? សូមស្វែងរកលើ LDS.org ឬប៉ុស្ដិ៍មរមនសម្រាប់វីដេអូទាំងនេះ និងសារលិខិតដ៏អស្ចារ្យផ្សេងទៀតសម្រាប់បុណ្យគ្រីស្ទម៉ាស់ដើម្បីចែកចាយ ។

### ៧. បុណ្យគ្រីស្ទម៉ាស់គឺជាការសាទរចំពោះព្រះអង្គសង្គ្រោះ ។

មានគ្រិស្តសាសនិកជាច្រើននឹងផ្ដោតទុកដាក់ខ្លាំងលើព្រះអង្គសង្គ្រោះក្នុងអំឡុងបុណ្យគ្រីស្ទម៉ាស់ ។ បន្ថែមពីលើការចែកចាយគំនិតបម្រើប្រចាំថ្ងៃ គេហទំព័រ Mormon.org ក៏បង្ហាញអំពីចំណុចសំខាន់ៗនៃការបង្រៀន និងរបៀបរបស់ព្រះអង្គសង្គ្រោះដើម្បីជា « ពន្លឺលោកីយ៍ » ដែរ ។ ការណ៍នោះអាចជាអ្វីដែលមិត្តភក្តិរបស់អ្នកកំពុងស្វែងរកដើម្បីសាទរចំពោះព្រះគ្រីស្ទនៅបុណ្យគ្រីស្ទម៉ាស់ ។

### ៨. មានរបៀបជាច្រើនដើម្បីផ្ដល់ ហើយបម្រើក្នុងអំឡុងបុណ្យគ្រីស្ទម៉ាស់ !

ការបម្រើគឺជារបៀបដ៏អស្ចារ្យមួយដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ហើយមានឱកាសជាច្រើនដើម្បីបម្រើមនុស្សដទៃនៅអំឡុងបុណ្យឈប់សម្រាកនេះ ។ អ្នកអាចទៅលេងមជ្ឈមណ្ឌលចាស់ជរាច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ដល់អ្នកជិតខាង ឬចែកសម្ភារដល់ជនគ្មានផ្ទះសម្បែងក្នុងមូលដ្ឋានម្នាក់ ។ អ្នកអាចស្វែងរកគំនិតបម្រើសម្រាប់ ២៥ ថ្ងៃដំបូងក្នុងខែ ធ្នូ បានតាមរយៈការចូលទៅគេហទំព័រ Mormon.org ។

តើអ្នកកំពុងរង់ចាំអ្វី ?

ដោយសារដំណឹងល្អ អ្នកស្គាល់អំពីព្រះយេស៊ូវគ្រីស្ទ និងសេចក្ដីសង្ឃឹមទាំងឡាយដែលទ្រង់នាំមក ។ នោះគឺជាអំណោយដ៏អស្ចារ្យមួយ ហើយវាគឺជាអំណោយមួយដែលអ្នកអាចផ្ដល់ឲ្យមនុស្សដទៃទៀត ។ ប្រសិនបើអ្នកទូលព្រះវរបិតាសួគ៌សូមឱកាសចែកចាយដំណឹងល្អដោយចិត្តស្មោះ នោះទ្រង់នឹងបំផុសគំនិតអ្នកឲ្យដឹងអំពីមនុស្សដែលអ្នកត្រូវនិយាយជាមួយ ។ បុណ្យគ្រីស្ទម៉ាស់គឺជាពេលមួយនៃការចែករំលែក ការផ្ដល់ឲ្យ និងការចងចាំអំពីព្រះយេស៊ូវគ្រីស្ទ ។ ■





**រដូវកាលនៃការសាទរ**

« នេះគឺជារដូវកាលនៃភាពរីករាយ ! រដូវកាលនៃការសាទរ ! ពេលដ៏ល្អមួយដែលយើងទទួលស្គាល់ថា ព្រះដ៏មានមហិទ្ធិឫទ្ធិរបស់យើងបានបញ្ជូនព្រះរាជបុត្រាបង្កើតតែមួយគត់របស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ដើម្បីប្រោសលោះដល់លោកិយ ! ដើម្បីប្រោសលោះយើង ! »

ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ជាទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ « Can We See the Christ in Christmas? » ( ការប្រជុំធម្មនិដ្ឋានបុណ្យគ្រីស្ទម៉ាស់គណៈប្រធានទីមួយថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០០៩ ), broadcasts.lds.org ។



យើងម្នាក់ៗគឺជា
**ម្ចាស់ផ្ទះសំណាក់**
ដែលសម្រេចចិត្តថា
តើមានបន្ទប់
**សម្រាប់ព្រះយេស៊ូវ**
ដែរឬអត់ !

អែលឌើរ នែល អេ ម៉ាក់ស្វែល ( ១៩២៦–២០០៤ )
« Settle This in Your Hearts » សន្និសីទទូទៅខែតុលា ឆ្នាំ១៩៩២

រូបភាពពី GETTY IMAGES

ចម្លើយមកពីថ្នាក់ដឹកនាំសាសនាចក្រ



ដោយប្រធាន
ថូម៉ាស អេស ម៉ុនសុន



# របៀប ទទួលអារម្មណ៍ពីអត្ថន័យពិតនៃបុណ្យគ្រីស្ទម៉ាស់

បុណ្យគ្រីស្ទម៉ាស់ជារដូវកាលមួយដ៏រុងរឿង ។ វាក៏ជាពេលមួយដ៏មមាញឹកសម្រាប់យើងផងដែរ ។ ខ្ញុំសង្ឃឹម ហើយអធិស្ឋានថា យើងនឹងមិនរវល់នឹងភាពមមាញឹកនៃរដូវកាលនេះ រហូតធ្វើឲ្យយើងផ្ដោតទៅលើរឿងដែលមិនសំខាន់ ហើយខកខានមិនបានទទួលក្ដីអំណរដ៏សាមញ្ញនៃការចងចាំដល់ការប្រសូតនៃព្រះដ៏បរិសុទ្ធនៅភូមិបេថ្លេហិមនោះឡើយ ។

ការស្វែងរកអំណរពិតនៃបុណ្យគ្រីស្ទម៉ាស់ពុំមែនកើតចេញពីការប្រញ៉ាប់ប្រញ៉ាល់ធ្វើកិច្ចការឲ្យបានច្រើននោះទេ ។ យើងរកឃើញក្ដីអំណរពិតនៃបុណ្យគ្រីស្ទម៉ាស់ ពេលយើង ផ្ដោតដួងចិត្តយើងទៅលើព្រះអង្គសង្គ្រោះ ។

ការអបអររបស់យើងចំពោះបុណ្យគ្រីស្ទម៉ាស់គប្បីជាការឆ្លុះបញ្ចាំងមួយពីសេចក្ដីស្រឡាញ់ និងសេចក្ដីសប្បុរសដែលព្រះអម្ចាស់បានបង្រៀន ។ ការផ្ដល់អំណោយ ឥតសំណង នាំឲ្យបុណ្យគ្រីស្ទម៉ាស់កាន់តែមានភាពរីករាយ ។ យើង មានចិត្តសប្បុរស ចំពោះគ្នាច្រើនជាងមុន ។ យើងឈោងដៃទៅជួយជនដែលទាល់ខ្វះខាត ។ ចិត្ត របស់យើងមានភាពទន់ភ្លន់ ។ យើងអត់ទោសឲ្យសត្រូវ យើងនឹកចាំពីមិត្តភក្ដិ ហើយគោរពតាមព្រះ ។ វិញ្ញាណបុណ្យគ្រីស្ទម៉ាស់បំភ្លឺឲ្យយើងឃើញយ៉ាងច្បាស់ទៅកាន់ដួងព្រលឹង ហើយពេលយើងមើលទៅជីវិតដ៏មមាញឹកក្នុងពិភពលោកនេះ យើងកាន់តែមានការចាប់អារម្មណ៍ទៅលើមនុស្ស ច្រើនជាងរបស់របរទាំងឡាយ ។ ដើម្បីយល់ពីអត្ថន័យពិតនៃគ្រីស្ទម៉ាស់ យើងត្រូវ ស្វែងរកតែព្រះវិញ្ញាណនៃព្រះគ្រីស្ទ ប៉ុណ្ណោះ ។

សូមឲ្យយើងផ្ដល់ដូចជាព្រះគ្រីស្ទបានប្រទាន ។ ការលះបង់ខ្លួនឯងជាអំណោយមួយដ៏បរិសុទ្ធ ។ យើងផ្ដល់អំណោយទុកជាការចងចាំមួយនូវអ្វីៗទាំងអស់ដែលព្រះគ្រីស្ទបានប្រទាន ។ សូមឲ្យយើងផ្ដល់អំណោយដែលមានតម្លៃដ៏អស់កល្បរួមនឹងអំណោយដែលអាចបាក់បែក ឬបំភ្លេចចោលបាននៅថ្ងៃណាមួយផងដែរ ។ តើពិភពលោកនេះនឹងប្រសើរឡើងខ្លាំងប៉ុណ្ណាទៅ បើយើងផ្ដល់អំណោយនៃការយល់ចិត្ត និងក្ដីមេត្តា នៃការបម្រើ និងមិត្តភាពនៃក្ដីសប្បុរស និងភាពទន់ភ្លន់នោះ ។

ខណៈដែលបុណ្យគ្រីស្ទម៉ាស់នេះរុំព័ទ្ធដោយសិរីរបស់ខ្លួន សូមឲ្យយើងស្វែងរកពន្លឺផ្កាយមួយ ដើម្បីដឹកនាំយើងក្នុងការអបអរដល់ការប្រសូតរបស់ព្រះអម្ចាស់ដូចជាពួកហោរាដែរ ។ សូមឲ្យយើងធ្វើដំណើរទៅភូមិបេថ្លេហិមដោយវិញ្ញាណ ដោយយកជាប់នឹងខ្លួនយើងនូវចិត្តទន់ទាប ហើយខ្វល់ខ្វាយ ជាអំណោយថ្វាយដល់ព្រះគ្រីស្ទ ។ ■

*ដកស្រង់ចេញពីការប្រជុំធម្មនិដ្ឋានបុណ្យគ្រីស្ទម៉ាស់របស់គណៈប្រធានទីមួយឆ្នាំ ២០១៣ ។*

# « ខ្ញុំបានអធិស្ឋានទូលសុំអ្វីមួយដែលសំខាន់ ប៉ុន្តែខ្ញុំពុំដឹងឡើយថា ខ្ញុំបានទទួលចម្លើយឬអត់នោះ ។ តើខ្ញុំនឹងដឹងរឿងនេះយ៉ាងដូចម្ដេច ? »

ការទទួលបានចម្លើយចំពោះការអធិស្ឋានត្រូវបានពិពណ៌នាថាជាដំណើរការមួយ ៖ ដំបូងអ្នកសិក្សាសំណួររបស់អ្នកនៅក្នុងគំនិត បន្ទាប់មកអ្នកទូលសួរព្រះថា តើចម្លើយរបស់អ្នកត្រឹមត្រូវដែរឬទេ ។ ប្រសិនបើចម្លើយរបស់អ្នកត្រឹមត្រូវ ព្រះអម្ចាស់នឹង « និយាយដោយភាសាសុខសាន្ត » ( គ. និង ស. ៦:២៣ ) ។

ចុះប្រសិនបើអ្នកពុំមានអារម្មណ៍នៃភាពសុខសាន្តដ៏លើសលប់មួយវិញ ? ឬចុះប្រសិនបើអ្នកមានអារម្មណ៍ដូចជាអ្នកមានចម្លើយមួយហើយ ប៉ុន្តែអ្នកពុំប្រាកដថា វាគឺជាគំនិតរបស់អ្នក ឬមកពីព្រះវិញ្ញាណបរិសុទ្ធ ?

យោងតាមអែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « វិវរណៈកើតឡើងនៅក្នុងចំនួនដ៏តូចបន្តិចម្ដងៗ ហើយត្រូវបានផ្ដល់ឲ្យស្របតាមបំណងប្រាថ្នា ភាពសក្ដិសម និងការរៀបចំខ្លួនរបស់យើង »។[1] ជានិច្ចកាល វាពុំកើតឡើងភ្លាមៗនោះទេ ភាគច្រើនវាកើតឡើង « មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ » ( នីហ្វៃទី ២ ២៨:៣០ ) ហើយជារឿយៗ អ្នកត្រូវចាប់ផ្ដើមជាមុនសិន *ពីមុន* អ្នកមានអារម្មណ៍ថា អ្នកដូចជាមានចម្លើយមួយពេញលេញមួយដូច្នេះដែរ ។ ពេលខ្លះអ្នកអាចនឹងពុំទទួលបានចម្លើយសោះ — នោះគឺជាពេលដែលអ្នកត្រូវធ្វើដោយសេចក្ដីជំនឿថា ព្រះនឹងឆ្លើយតបក្នុងពេលវេលាត្រឹមត្រូវ ។

ប្រសិនបើអ្នកព្រួយបារម្ភចង់ដឹងថា តើចម្លើយរបស់អ្នកមកពីអ្នក ឬមកពីព្រះវិញ្ញាណបរិសុទ្ធនោះ សូមចងចាំថា ចម្លើយដ៏ល្អបំផុតនឹងជាចម្លើយមួយដែល « អញ្ជើញ ហើយញុះញង់ [ អ្នក ] ឲ្យធ្វើល្អ ហើយឲ្យស្រឡាញ់ព្រះ ហើយឲ្យបម្រើទ្រង់ » ។ ( មរ៉ូណៃ ៧:១៣ ) ។

កំណត់ចំណាំ

១. ដេវីឌ អេ បែដណា « *The Spirit of Revelation* » សន្និសីទទូទៅ ខែ មេសា ឆ្នាំ២០១១ ។



## សម្រេចចិត្ត ហើយរង់ចាំព្រះវិញ្ញាណ

នារដូវក្ដៅមួយខ្ញុំបានមានអារម្មណ៍ថា ដូចជាព្រះអម្ចាស់ពុំបានប្រទានចម្លើយដល់ខ្ញុំអំពីការសម្រេចចិត្តដ៏សំខាន់មួយឡើយ ។ ខ្ញុំបានអធិស្ឋានដោយចិត្តស្មោះរៀងរាល់ថ្ងៃដើម្បីដឹងពីព្រះទ័យរបស់ទ្រង់ចំពោះខ្ញុំ ហើយខ្ញុំបានទូលប្រាប់ទ្រង់អំពីអ្វីដែលខ្ញុំមានបំណងចង់ធ្វើ ។ ដោយនៅតែគ្មានទទួលបានចម្លើយជាក់លាក់មួយ ខ្ញុំបានធ្វើការសម្រេចចិត្តរបស់ខ្ញុំ ។ ភ្លាមនោះ ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណថ្លែងសាក្សីចំពោះខ្ញុំថា ការសម្រេចចិត្តដែលខ្ញុំធ្វើនឹងជួយខ្ញុំឲ្យរីកចម្រើន ហើយប្រែក្លាយកាន់តែដូចជាព្រះវរបិតារបស់ខ្ញុំដែលគង់នៅស្ថានសួគ៌ ។ ពេលខ្លះយើងត្រូវធ្វើសកម្មភាពដើម្បីទទួលបានចម្លើយមួយ — ព្រះវរបិតាសួគ៌គោរពដល់សិទ្ធិជ្រើសរើសរបស់យើង និងបំណងប្រាថ្នាដ៏សុចរិតរបស់យើង ។ ប្រសិនបើយើងនឹងរស់នៅដោយសក្ដិសម នោះព្រះវិញ្ញាណរបស់ទ្រង់នឹងដឹកនាំយើងនៅក្នុងបំណងប្រាថ្នារបស់យើង ដោយសារវានឹងស្របតាមព្រះទ័យរបស់ទ្រង់ ។

*អាម៉ែនដា អេជ អាយុ ១៦ ឆ្នាំ វ៉េយូថាហ៍ ស.រ.អា*



## អត់ធ្មត់ ហើយខ្ជាប់ខ្ជួន

មួយរយៈកាលពីមុន ខ្ញុំបានតាំងចិត្តខ្លួនឯងឲ្យអធិស្ឋានទូលសូមឱកាសបម្រើ ។ ខ្ញុំបានគិតអំពីរបៀបដែលខ្ញុំអាចជួយដល់មនុស្សដទៃ ប៉ុន្តែខ្ញុំពុំបានទទួលនូវអ្វីដែលខ្ញុំបានជឿថាជាការបំផុសគំនិតមួយនោះឡើយ ។ ខ្ញុំបានចាប់ផ្ដើមបាក់ទឹកចិត្ត បន្ទាប់មកអ្នកម្ដាយរបស់ខ្ញុំបានចែកចាយនឹងខ្ញុំនូវ អាលម៉ា ៥:៤០ ៖ « អ្វីក៏ដោយដែលល្អចេញមកពីព្រះ » ។ ខ្ញុំបានដឹងថា គំនិតស្ងប់ស្ងាត់នៃការបម្រើដែលខ្ញុំមានពិតជាការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ ។ ខ្ញុំដឹងថា ការអធិស្ឋាន



*ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និង ទស្សនវិស័យមិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*

របស់យើងតែងតែទទួលបានចម្លើយជានិច្ច យើងគ្រាន់តែត្រូវមានចិត្តអត់ធ្មត់ ខ្ជាប់ខ្ជួន ហើយទុកចិត្តលើព្រះអម្ចាស់ ។

*លីប៊ី ប៊ី អាយុ ១៦ ឆ្នាំ អូរីហ្គិន ស.រ.អា.*

### អធិស្ឋានសូមជំនួយ

ខ្ញុំធ្លាប់បានអធិស្ឋាន ហើយបានទទួលចម្លើយចំពោះរឿងជាច្រើន ប៉ុន្តែរឿងដែលខ្ញុំចងចាំបំផុតគឺជារឿងទាក់ទងនឹងកិច្ចការសាលា ។ ពីមុនការប្រឡង ខ្ញុំបានអធិស្ឋានឲ្យមានចិត្តស្ងប់ស្ងាត់ ហើយអាចនឹកចាំអ្វីៗដែលខ្ញុំបានសិក្សា ។ ជាច្រើនដងខ្ញុំបានចាំអំពីឃ្លាទាំងស្រុងនៃមេរៀនដែលខ្ញុំដឹងថាខ្ញុំនឹងពុំអាចចងចាំវាដោយគ្មានជំនួយរបស់ទ្រង់បានឡើយ ។ ទ្រង់បានប្រទានពរដល់ជីវិតរបស់ខ្ញុំ ហើយខ្ញុំឲ្យតម្លៃចំពោះអនុភាពនៃការអធិស្ឋាន និងព្រះចេស្ដារបស់ទ្រង់ដែលខ្ញុំបានទទួលតាមរយៈការអធិស្ឋាននោះ ។

*អេមិលី ប៊ី អាយុ ១៨ ឆ្នាំ ឃ្វីនស្លេន ប្រទេសអូស្ត្រាលី*



### ទុកចិត្តលើព្រះវិញ្ញាណ

ពេលអ្នករៀនទុកចិត្តលើព្រះវិញ្ញាណបរិសុទ្ធ ហើយអភិវឌ្ឍសមត្ថភាពដើម្បីស្គាល់អំពីរបៀបដែលព្រះវរបិតាសួគ៌ឆ្លើយតបដល់អ្នក នោះអ្នកនឹងឃើញថា អ្នកអាចមានព្រះវិញ្ញាណគ្រប់ពេល ។ សូរសៀងរបស់ទ្រង់បំផុសយើងយ៉ាងទន់ភ្លន់ថា ប្រសិនបើយើងគិតតែអំពីរឿងលោកិយ នោះយើងពុំសង្កេតឃើញនូវការខ្សឹបប្រាប់ និងអារម្មណ៍ដែលមកពីស្ថានសួគ៌ឡើយ ។ ប៉ុន្តែប្រសិនបើយើងនឹងរស់នៅតាមរបៀបដែលយើងគួររស់នៅ នោះយើងនឹងមានការសន្យានេះជានិច្ចថា យើងនឹងដឹងនៅក្នុងដួងចិត្តរបស់យើងនូវអ្វីដែលព្រះវិញ្ញាណនឹងមានបន្ទូលជាការឆ្លើយតបចំពោះការទូលអង្វររបស់យើង ។

*ស៊ិស្ទើរ វីប៊ីរ៉ូ អាយុ ២៤ ឆ្នាំ បេសកកម្មព័រតូអាឡេគ្រេប្រេស៊ីលខាងត្បូង*



### សាកល្បងវា ហើយចាំមើល !

ពេលខ្លះព្រះអម្ចាស់តម្រូវឲ្យយើងធ្វើសកម្មភាពស្របតាមសេចក្ដីជំនឿរបស់យើងពីមុនយើងទទួលបានចម្លើយដ៏ពេញលេញមួយ ។ តើអ្នកចង់ដឹងថា ពាក្យសម្ដីនៃប្រាជ្ញាវាងវៃពិតជាបទបញ្ញត្តិមួយមកពីព្រះដែរឬទេ ? ដូច្នេះ សូមរស់នៅតាមបទបញ្ញត្តិនោះ ។ តើអ្នកចង់ដឹងថា ព្រះគម្ពីរមរមនពិតដែរឬទេ ? ដូច្នេះ សូមអានព្រះគម្ពីរនេះ ! សូមទុកចិត្តលើការសន្យានៅក្នុងយ៉ូហាន ៧:១៧៖ « បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្ដីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ » ។

*ព្រេស្តុន អូ អាយុ ១៩ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា.*



### ដោយព្រះចេស្ដានៃព្រះគ្រីស្ទ

ខ្ញុំបានទស្សនាការចាក់ផ្សាយកម្មវិធីជួបសំណេះសំណាលជាមួយនឹងអែលឌើរ រ៉ាសបាន និងស៊ិស្ទើរ អូស្កាសុន ពេលយុវវ័យម្នាក់បានសួរសំណួរដូចគ្នានេះអំពីការទទួលបានចម្លើយនានា ។ ស៊ិស្ទើរ អូស្កាសុន បានដកស្រង់ពី ម៉ូរ៉ូណៃ ៧:១៦៖ តាមរយៈ « ព្រះចេស្ដា និងអំណោយទាននៃព្រះគ្រីស្ទ . . . អ្នករាល់គ្នាអាចដឹងដោយដំរិះដ៏ឥតខ្ចោះថាមកពីព្រះ » ។ បទគម្ពីរនោះបង្ហាញយើងថា យើងនឹងមានលទ្ធភាពដឹងអំពីព្រះទ័យរបស់ព្រះចំពោះយើងជាមួយនឹងដំរិះដ៏ឥតខ្ចោះ ។ សូមស្ដាប់តាមព្រះវិញ្ញាណ ហើយអ្នកនឹងដឹងអំពីចម្លើយ ។

*សារ៉ា អេស អាយុ ១៧ ឆ្នាំ សាន់តា កាតារីណា ប្រទេសប្រេស៊ីល*



**ការបំផុសគំនិតកើតឡើងមួយចំណែកម្ដងៗ**

« នៅពេលយើងស្វែងរកការបំផុសគំនិតដើម្បីជួយធ្វើការសម្រេចចិត្ត ព្រះអម្ចាស់ប្រទានការបំផុសគំនិតដ៏ផ្អែមល្ហែមទន់ភ្លន់ ។ ការណ៍ទាំងនេះតម្រូវឲ្យយើងគិត អនុវត្តសេចក្ដីជំនឿ ធ្វើតាមពេលខ្លះពុះពារ ហើយធ្វើសកម្មភាព ។ វាកម្រណាស់ដែលចម្លើយទាំងស្រុងចំពោះបញ្ហាដ៏សំខាន់ ឬស្មុគស្មាញបំផុតកើតមានឡើងក្នុងពេលតែមួយនោះ ។ ជានិច្ចកាល វាកើតឡើងមួយបន្តិចម្ដងៗ ដោយមានគំនិតមិនចេះចប់ឡើយ » ។

អែលឌើរ រីឆាដ ជី ស្កត ( ១៩២៨-២០១៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « *Learning to Recognize Answers to Prayer* » សន្និសីទទូទៅខែ តុលា ឆ្នាំ ១៩៨៩ ។

## សំណួរបន្ទាប់

« ពេលខ្លះ ខ្ញុំពុំមានអារម្មណ៍ថាសក្ដិសមដើម្បីទទួលបានសេចក្ដីស្រឡាញ់ពីព្រះអង្គសង្គ្រោះឡើយ ។ តើខ្ញុំអាចយកឈ្នះលើអារម្មណ៍នេះ ហើយស្គាល់តម្លៃរបស់ខ្លួនឯងតាមរបៀបណា ? »

ប្រសិនបើអ្នកមានបំណងឆ្លើយនឹងសំណួរនេះ សូមផ្ញើចម្លើយរបស់អ្នក និង រូបថតច្បាស់មួយសន្លឹកឲ្យបានត្រឹមថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨ ទៅកាន់គេហទំព័រ liahona.lds.org ( សូមចុច « Submit an Article » ) ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ ប្រសិនបើវាវែងពេក ឬមិនសូវច្បាស់លាស់ ។

# ទីកន្លែងរបស់យើង



## ការបង្កើតមិត្តភក្ដិថ្មី

ពេលឪពុកម្ដាយរបស់ខ្ញុំប្រាប់ខ្ញុំថា គ្រួសាររបស់ខ្ញុំនឹងផ្លាស់ប្ដូរលំនៅដ្ឋាន ខ្ញុំមានចិត្តរំភើបខ្លាំងណាស់ដើម្បីមានមិត្តភក្ដិថ្មី ។ ពេលយើងបានទៅដល់ទីក្រុងថ្មីរបស់យើង យើងបានទៅព្រះវិហារ ។ ខ្ញុំអាចមានអារម្មណ៍ពីព្រះវិញ្ញាណយ៉ាងខ្លាំងនៅទីនោះ ហើយខ្ញុំបានដឹងថា រឿងគ្រប់យ៉ាងនឹងបានល្អប្រសើរ ។

មិនយូរប៉ុន្មាន ខ្ញុំបានចាប់ផ្ដើមទៅសាលារៀនថ្មីរបស់ខ្ញុំ ។ ខ្ញុំគឺជាពួកមរមនតែម្នាក់គត់នៅក្នុងសាលានោះ ។ ពេលខ្ញុំបានដើរចូលទៅ ខ្ញុំមានអារម្មណ៍ពុំស្រណុកចិត្តសោះ ។ ខ្ញុំអាចដឹងថា ខ្ញុំខុសប្លែកពីសិស្សផ្សេងទៀត ។

ប៉ុន្មានសប្ដាហ៍ដំបូង ខ្ញុំបានព្យាយាមរកមិត្តភក្ដិ ។ ប៉ុន្តែខ្ញុំមានអារម្មណ៍ពុំស្រណុកក្នុងចិត្តទេ ! ខ្ញុំបានព្យាយាមអង្គុយក្បែរមនុស្សខុសៗគ្នានៅមុខវិជ្ជានីមួយៗ ហើយអង្គុយញ៉ាំអាហារថ្ងៃត្រង់នៅតុខុសៗគ្នារៀងរាល់ថ្ងៃ ។ វាទំនងដូចជាខ្ញុំចំណាយកម្លាំងដោយឥតប្រយោជន៍ ។

ខ្ញុំបានសម្រេចចិត្តខិតខំធ្វើជាគំរូល្អមួយដល់សិស្សរួមថ្នាក់របស់ខ្ញុំ ។ ខ្ញុំបានផ្ដោតលើការអភិវឌ្ឍខ្លួនរបស់ក្រុមយុវនារី និងការសិក្សាព្រះគម្ពីរដោយឧស្សាហ៍ ។ ពេលខ្ញុំបានខិតខំព្យាយាម ខ្ញុំបានយល់ដឹងយ៉ាងច្បាស់ថា ខ្ញុំគឺជាបុត្រីម្នាក់របស់ព្រះ ហើយថាទ្រង់ស្រឡាញ់ខ្ញុំ ។

កាលពេលវេលាចេះតែកន្លងទៅ ហើយខ្ញុំបានបន្តធ្វើទង្វើទាំងនេះ ខ្ញុំបានសម្គាល់ឃើញរឿងមួយគឺ ៖ ខ្ញុំបានចាប់ផ្ដើមមានមិត្តនៅឯសាលារៀន ។ វាហាក់ដូចជាមនុស្សជាច្រើនត្រូវបានទាក់ទាញឲ្យចូលមកជិតខ្ញុំ ។ ពួកគេបាននិយាយថា ខ្ញុំមានអំពីឥរិយាបថយ៉ាងល្អត្រឹមត្រូវ ។ ខ្ញុំបានដឹងថា វាកើតឡើងដោយសារខ្ញុំធ្វើឲ្យពន្លឺរបស់ខ្ញុំបានភ្លឺឡើង ។ ខ្ញុំមានឥរិយាបថខុសពីមិត្តរួមថ្នាក់របស់ខ្ញុំ ខ្ញុំបានស្លៀកពាក់សមរម្យ ខ្ញុំបានប្រើពាក្យសម្ដីល្អៗ ហើយខ្ញុំមានសណ្ដានចិត្តល្អចំពោះមនុស្សដទៃ ។

យើងទាំងអស់គ្នាគឺជាកូនចៅរបស់ព្រះ ។ ខ្ញុំមានអំណរគុណខ្លាំងណាស់ ដែលខ្ញុំបានធ្វើឲ្យពន្លឺរបស់ខ្ញុំបានភ្លឺឡើង ទោះជាខ្ញុំមានអារម្មណ៍ពុំស្រណុកក្នុងចិត្តក្ដី ។ ខ្ញុំដឹងថា យើងពុំដែលទុកឲ្យនៅតែឯងឡើយ ប្រសិនបើយើងនៅខាងព្រះអម្ចាស់ ! ■

*រេបេកា ស៊ី កោះព្រីនស៍ អេដវើឌ ប្រទេសកាណាដា*

# តើខ្ញុំអាចចែកចាយព្រះគម្ពីរមរមនបានដែរឬទេ ?

អំឡុងកម្មវិធីម៉ូតឆល យើងបានទទួលកិច្ចការមួយដើម្បីក្លាយជាអ្នកផ្សព្វផ្សាយសាសនាតាមរយៈការមានដៃគូម្នាក់ ដោយចែកចាយទីបន្ទាល់របស់យើងជាមួយនឹងបុគ្គលម្នាក់ដែលពុំមែនជាសមាជិក និងដោយការឲ្យព្រះគម្ពីរមរមនមួយក្បាលដល់មិត្តរបស់យើងដែលពុំមែនជាសមាជិក ។

បន្ទាប់ពីកម្មវិធីម៉ូតឆល ខ្ញុំបានសូមពាក្យទូន្មានខ្លះៗពីអ្នកម្ដាយរបស់ខ្ញុំ ។ គាត់បានសន្យាដល់ខ្ញុំថា ប្រសិនបើខ្ញុំបានអធិស្ឋានដោយសេចក្ដីជំនឿ ហើយសូមព្រះវរបិតាសួគ៌ នោះទ្រង់នឹងឆ្លើយតបជាប្រាកដ ។

ខ្ញុំបានចំណាយពេលពីរសប្ដាហ៍ ទើបបានរកឃើញមនុស្សម្នាក់ដែលសុខចិត្តទទួលយកព្រះគម្ពីរមរមន ។ ដំបូងឡើយ ខ្ញុំត្រូវបានគេបដិសេធម្ដងហើយម្ដងទៀត ។ ខ្ញុំមានចិត្តធុញទ្រាន់នឹងការឈឺចាប់រហូតដល់ខ្ញុំស្ទើរតែមិនចង់ធ្វើទៀតឡើយ ។

មានយប់មួយ ខ្ញុំបានសុបិនឃើញស្ត្រីម្នាក់ដែលជាមិត្តជិតស្និទ្ធនឹងគ្រួសាររបស់ខ្ញុំ ។ ពេលខ្ញុំបានសុបិន ខ្ញុំបានដឹងថា គាត់គឺជាមនុស្សម្នាក់ដែលខ្ញុំ និងដៃគូរបស់ខ្ញុំត្រូវទៅជួប ។ ពេលខ្ញុំបានក្រោកពីដំណេក ខ្ញុំបានអរគុណព្រះអម្ចាស់ដែលបានជួយដល់ខ្ញុំ ។

នៅកម្មវិធីម៉ូតឆលបន្ទាប់ទៀត ដៃគូរបស់ខ្ញុំ និងខ្ញុំបានសរសេរទីបន្ទាល់របស់យើងនៅទំព័រខាងមុខនៃព្រះគម្ពីរនោះ ហើយបានរៀបចំផ្លែឈើមួយកន្ត្រកយកទៅជូនស្ត្រីនោះ ។ យើងបានទៅផ្ទះរបស់គាត់ បានគោះទ្វាររបស់គាត់ ហើយបានរង់ចាំ ។ ទោះបីខ្ញុំមានការភ័យខ្លាចថាគាត់នឹងបដិសេធក្ដី ក៏ខ្ញុំបានប្រាប់ខ្លួនឯងឲ្យមានសេចក្ដីជំនឿខ្លះផងដែរ ។ នៅទីបំផុតគាត់បានចេញមកដោយទឹកមុខរីករាយ ហើយបានព្រមទទួលព្រះគម្ពីរមរមន ។

តាមរយៈបទពិសោធន៍នេះ ខ្ញុំបានរៀនថា ពេលអ្នកមានសេចក្ដីជំនឿបន្តិចទៀត ហើយអ្នកដឹងថា ព្រះវរបិតាសួគ៌ទ្រង់គង់នៅទីនោះ អ្នកអាចងាយនឹងទទួលអារម្មណ៍ថា រឿងដែលពុំធ្វើទៅបាន វានឹងអាចធ្វើបាន ។ ■

*រ៉ាផាន់ហ្សេល អិល សាម័រអាមេរិក*

# វិស្សមកាលរបស់ខ្ញុំពីការរៀនព្យាណូ

ខ្ញុំបានសម្រេចចិត្តយកពេលមួយសប្ដាហ៍ដើម្បីសម្រាកពីការហ្វឹកហាត់ព្យាណូ ។ គ្រូបង្រៀនព្យាណូរបស់ខ្ញុំពុំបានអនុញ្ញាតចំពោះការឈប់សម្រាកនេះទេ ហើយអ្នកម្ដាយរបស់ខ្ញុំក៏ពុំអនុញ្ញាតដូចគ្នាដែរ ។ អស់រយៈពេលមួយសប្ដាហ៍ពេញ ខ្ញុំពុំបានហ្វឹកហាត់សោះ ។ ខ្ញុំបានគិតថា វាជាពេលដ៏អស្ចារ្យណាស់ ដោយសារខ្ញុំមានពេលដ៏ល្អមួយដើម្បីសម្រាក ហើយធ្វើរឿងផ្សេងទៀត ។

ភាពរីករាយបានបញ្ចប់នៅយប់ថ្ងៃព្រហស្បតិ៍ ពេលអ្នកម្ដាយរបស់ខ្ញុំបានរំឭកខ្ញុំថា ខ្ញុំនឹងមានមេរៀនព្យាណូនៅព្រឹកស្អែក ។ ខ្ញុំបានគិតថា ខ្ញុំមានដំណោះស្រាយមួយ ៖ ខ្ញុំបានក្រោកពីដេកមួយម៉ោងមុន ហើយបានចាប់ផ្ដើមហ្វឹកហាត់ ។ ប៉ុន្តែខ្ញុំបានដឹងថា ការខិតខំរបស់ខ្ញុំមានតិចតួច ហើយយឺតពេល ។ ខ្ញុំបានរីករាយនឹងសេរីភាពក្នុងការជ្រើសរើស ប៉ុន្តែខ្ញុំពុំបានគិតពីផលវិបាកនោះទេ ។

លុះស្អែកឡើង ពេលខ្ញុំបានជួបនឹងគ្រូបង្រៀនរបស់ខ្ញុំ ផលវិបាកបានចាប់ផ្ដើមបើកបង្ហាញ ។ ខ្ញុំត្រូវសារភាពថា ខ្ញុំពុំបានហ្វឹកហាត់ទេ ហើយគ្រូបង្រៀនរបស់ខ្ញុំបានប្រាប់ខ្ញុំថា ខ្ញុំគួរបន្ថែមម៉ោងការហ្វឹកហាត់ដែលខ្ញុំបានខកខាននោះ ពីលើម៉ោងហ្វឹកហាត់ធម្មតារបស់ខ្ញុំ ។

ខ្ញុំមានអំណរគុណចំពោះមេរៀនដែលខ្ញុំបានរៀនអំពីសិទ្ធិជ្រើសរើស ភារកិច្ច និងការទទួលខុសត្រូវ ។ រាល់ការជ្រើសរើសមាននូវផលមួយ ហើយខ្ញុំបានរៀនថា ខ្ញុំនឹងធ្វើការសម្រេចចិត្តបានប្រសើរ ប្រសិនបើខ្ញុំចំណាយពេលពិចារណាពីផលវិបាកនោះជាមុនសិន ។ ■

*ប្លេក អេដ រដ្ឋយូថាហ៍ ស.រ.អា.*



## ដល់វេនអ្នកហើយ

ទស្សនាវដ្ដី *លីអាហូណា* សូមស្វាគមន៍បទពិសោធន៍ និងគំនិតរបស់អ្នក ។ តើមានបទគម្ពីរមួយដែលចូលចិត្តដែរឬទេ ? តើធ្លាប់បានទទួលចម្លើយមួយទៅនឹងការអធិស្ឋានដែរឬទេ ? តើធ្លាប់បង្ហាញភាពក្លាហាននៅក្នុងការរស់នៅតាមដំណឹងល្អដែរឬទេ ? សូមដាក់ស្នើដំណើររឿងរបស់អ្នកនៅ liahona.lds.org ( ចុច « Submit an Article or Feedback » ) ។

រចនារូបភាពដោយ ណាសាន ហាដខាសល

# ភ្ញៀវនៅថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់

*វាតែងតែជារាត្រីដ៏ល្អបំផុតក្នុងមួយឆ្នាំ ។ ឥឡូវនេះ វាបំផ្លាញអស់ហើយ !*



**ដោយ ហូលី ខេ វ៉ៃធីងតុន**

ផ្អែកទៅលើដំណើររឿងពិត

« *ច្រៀងចម្រៀងអំពីព្រះរាជកុមារព្រះគ្រីស្ទ ៖ ចូរឲ្យអ្នកជិតខាងរបស់អ្នកដឹងថាអ្នកខ្វល់ខ្វាយ* » ( Children’s Songbook, *ល.រ. ៥១* ) ។

គ្លែរ៉ា ចូលចិត្តទំនៀមទម្លាប់ថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់របស់គ្រួសារនាងណាស់ ។ ដំបូងពួកគេបានបរិភោគត្រីដុតសម្រាប់អាហារពេលល្ងាច និងនំឃុកឃីបុណ្យគ្រីស្ទម៉ាស់ជាបង្អែម ។ បន្ទាប់មក  ពួកគេបានទៅដើរលេងនៅផ្សារបុណ្យគ្រីស្ទម៉ាស់ ។ ពេលពួកគេបានមកដល់ផ្ទះ ពួកគេបានអានដំណើររឿងអំពីបុណ្យគ្រីស្ទម៉ាស់នៅក្នុងព្រះគម្ពីរប៊ីបរួមគ្នា ។ ហើយពីមុនពេលចូលដេក ពួកគេបំភ្លឺដើមគ្រីស្ទម៉ាស់ជាលើកដំបូង ហើយបើកអំណោយម្ដងមួយៗ ។ វាគឺជារាត្រីដែលគ្លែរ៉ាចូលចិត្តបំផុតក្នុងមួយឆ្នាំ ។ នាងស្ទើរតែពុំអាចរង់ចាំវាបានទេ !

រហូតដល់អ្នកម៉ាក់បានធ្វើការប្រកាសមួយឡើង ។

« នៅឆ្នាំនេះ យើងនឹងមានភ្ញៀវពិសេសម្នាក់សម្រាប់ថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់ ។ តើនៅចាំលោកស្រី រេនណើរ បានទេ ? »

គ្លែរ៉ាបានថ្ងូរ ។ « តើគាត់ជាអ្នកជិតខាង ដែលលោកប៉ាបានអញ្ជើញទៅព្រះវិហារកាលពីសប្ដាហ៍មុនមែនទេ ? »

« ត្រឹមត្រូវហើយ ។ ឥឡូវនេះ លោកប៉ាកំពុងតែទៅទទួលគាត់ » ។

គ្លែរ៉ាបានទម្លាក់ខ្លួនអង្គុយចុះលើកៅអី ។ តើនាងអាចបន្ធូរចិត្ត ហើយរីករាយពេលមានមនុស្សប្លែកមុខម្នាក់បានយ៉ាងដូចម្ដេច ? ថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់ពិតជាត្រូវបំផ្លាញអស់ហើយ ! មែនហើយ លោកស្រី រ៉េណើរ ពុំបានទៅព្រះវិហារទេ ពេលប៉ាបានអញ្ជើញគាត់នោះ ។ ប្រហែលជាគាត់ក៏ពុំមកពេលនេះដែរក៏ថាបាន ។

ប៉ុន្តែពេលលោកប៉ាចូលមកក្នុងផ្ទះ « ភ្ញៀវពិសេស » រូបនោះបានមកជាមួយនឹងគាត់ ។ លោកស្រី រ៉េណើរ ទំនងជានឿយហត់ ហើយពុំសប្បាយចិត្តទេ ។ គ្លែរ៉ាបាននិយាយពាក្យសួស្ដី ។ ប៉ុន្តែនាងពុំចង់និយាយអ្វីផ្សេងទៀតទេ ។ ដល់ពេលអាហារពេលល្ងាច នាងផ្ដោតតែលើចានអាហាររបស់នាង ខណៈដែលម៉ាក់ និងប៉ាជជែកជាមួយនឹងលោកស្រី រ៉េណើរ ។

មានសំឡេងដ៏ស្រទន់មួយបានសួរឡើងថា « តើក្មួយធ្លាប់ចូលរៀនថ្នាក់របាំទេ ? » ។ គ្លែរ៉ាបានសង្កេតឃើញថា លោកស្រី រ៉េណើរកំពុងរង់ចាំចម្លើយ



របស់នាង ។ នាងបានងក់ក្បាល ហើយមើលទៅចានអាហាររបស់នាងវិញ ។

លោកស្រី រ៉ណើរ បានខ្សឹបៗថា « អ៊ំក៏ធ្លាប់រៀនដែរ » ។ « តើរបៀបរាំអ្វីទៅដែលក្មួយចូលចិត្តជាងគេ ? »

គ្លែរ៉ាបានញាក់ស្មា ហើយរុញបន្លែលេងក្នុងចានរបស់នាង ។

លោកស្រី រ៉ណើរ បានតបថា « អ៊ំចូលចិត្តរបាំបាឡេ » ។ « កាលពីនៅរៀនសាកលវិទ្យាល័យ អ៊ំនៅក្នុងក្រុមរបាំមួយ ។ មានឆ្នាំមួយ យើងបានធ្វើដំណើរជុំវិញទ្វីបអឺរ៉ុប ។ វាអស្ចារ្យណាស់ » ។

គ្លែរ៉ាបានងើបមុខឡើង ។ រឿងនោះពិតជាអស្ចារ្យមែន ។

គ្លែរ៉ាបានសួរថា « តើអ៊ំចូលចិត្តអ្វីផ្សេងទៀតដែរទេ ? »

លោកស្រីរ៉ណើរបានញញឹមបន្តិច ។ « លេងព្យាណូ ។ និង គណិតវិទ្យា » ។

គ្លែរ៉ាបានបើកភ្នែកធំៗ ។ « ពិតមែនឬ ? គណិតវិទ្យាគឺជាមុខវិជ្ជាដែលខ្ញុំចូលចិត្ត ! »

សម្រាប់ពេលវេលាដែលនៅសល់អំឡុងអាហារពេលល្ងាច នោះគ្លែរ៉ាបាននិយាយនឹងលោកស្រី រ៉ណើរ រហូត ។ នាងបានដឹងថា លោកស្រី រ៉ណើរ មានសញ្ញាបត្រផ្នែកគណិតវិទ្យាពីមហាវិទ្យាល័យ ហើយបានសិក្សាដើម្បីក្លាយជាសាស្ត្រាចារ្យផ្នែកគណិតវិទ្យា ពេលគាត់បានជួបនឹងស្វាមីរបស់គាត់ ។ ស្វាមីរបស់គាត់បានធ្វើការជ្រើសរើសមិនល្អមួយចំនួន ហើយឥឡូវនេះនៅក្នុងមន្ទីរឃុំឃាំង ។

បន្ទាប់ពីអាហារពេលល្ងាចរួច គ្លែរ៉ាបាននៅក្បែរលោកស្រី រ៉ណើរ កាលពួកគេដើរមើលផ្សារលក់របស់របរបុណ្យគ្រីស្ទម៉ាស់ ។ ហើយពេលពួកគេបានអានដំណើររឿងអំពីបុណ្យគ្រីស្ទម៉ាស់ នាងបានចែកព្រះគម្ពីរជាមួយនឹងលោកស្រី រ៉ណើរ ដើម្បីគាត់អាចមើលតាម ។

មិនយូរប៉ុន្មាន ពេលវេលាបើកអំណោយក៏មកដល់ ។ គ្លែរ៉ាទទួលបានសម្លៀកបំពាក់ដេកយប់ដ៏កក់ក្តៅពណ៌ស្វាយមួយចំនួន ។ នាងអន្ទះសារចង់ពាក់វា ! ប៉ុន្តែនាងមានអារម្មណ៍អាណិតដល់លោកស្រី រ៉ណើរ ដោយសារគាត់គ្មានបានអំណោយអ្វីសោះ ។

រំពេចនោះ ម៉ាក់បានហុចអំណោយមួយទៅលោកស្រី រ៉ណើរ ។ លោកស្រី រ៉ណើរ បានញញឹមទាំងអៀនខ្មាស់ ហើយបើកបានស្រោមជើងពណ៌ខៀវមួយគូ ។ គាត់បានងើយមើលមុខអ្នកម៉ាក់ទាំងទឹកភ្នែករលីងរលោង ។ « សូមអរគុណ ។ លោកស្រីពុំចាំបាច់ឲ្យអ្វីមកខ្ញុំនោះទេ » ។

គ្លែរ៉ាបានទៅបន្ទប់ដេករបស់នាង ហើយពាក់ខោអាវដេកយប់ថ្មីរបស់នាង ។ នាងពុំអាចឈប់គិតពីលោកស្រី រ៉ណើរ បានឡើយ ។ គាត់ទំនងជាមានអំណរគុណខ្លាំងណាស់ ដែលទទួលបានស្រោមជើងសម្រាប់បុណ្យគ្រីស្ទម៉ាស់ !

ពេលនាងពាក់ស្រោមជើងរបស់នាង នាងបានឮតន្ត្រីដ៏ពីរោះចាប់ផ្តើមលេង ។ នាងបានរត់ចុះទៅក្រោមផ្ទះឃើញអ្នកម៉ាក់ និងលោកប៉ាច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ កាលលោកស្រី រ៉ណើរ លេងព្យាណូ ។ គ្លែរ៉ាបានចូលរួម ។ ពេលនាងបានច្រៀង អារម្មណ៍ដ៏កក់ក្តៅមួយបានផុសឡើងនៅក្នុងដួងចិត្តរបស់នាង ។ នាងបានគិតថា « ខ្ញុំគិតថា វាមិនអាក្រក់ទេ ដែលមានភ្ញៀវនៅថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់ » ។

នៅថ្ងៃអាទិត្យ លោកស្រីរ៉ណើរបានមកព្រះវិហារ ហើយអង្គុយជាមួយគ្រួសាររបស់គ្លែរ៉ាអំឡុងការប្រជុំសាក្រាម៉ង់ ។ គាត់មើលទៅដូចជារីករាយណាស់ ។ គ្លែរ៉ាបានញញឹម ពេលនាងបានចែកសៀវភៅទំនុកតម្កើងមើលជាមួយនឹងលោកស្រី រ៉ណើរ ។ ប្រហែលវាដល់ពេលដើម្បីបន្ថែមទំនៀមទម្លាប់ថ្មីមួយនៅថ្ងៃឆ្លងបុណ្យគ្រីស្ទម៉ាស់ហើយ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ អៃដាហូ ស.រ.អា ។*



ខ្ញុំបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកជិតខាងរបស់ខ្ញុំដែលរស់នៅម្នាក់ឯង ដោយទៅសួរសុខទុក្ខគាត់ ហើយគូររូបឲ្យគាត់មើល !
**ជិល យេ អាយុ ១០ ឆ្នាំ រដ្ឋ កាលីហ្វូញ៉ា ស.រ.អា**



# ចូរក្លាហាន ហើយ ចែកចាយ !

ដោយ អែលឌើរ
ផល ប៊ី ផៃបភើរ
ក្នុងពួកចិតសិបនាក់



គ្រួសាររបស់យើងបានរស់នៅកន្លែងជាច្រើនជុំវិញពិភពលោក ។ យើងបានជួបនឹងមនុស្សជាច្រើនប្រភេទ ហើយមានឱកាសជាច្រើនដើម្បីចែកចាយដំណឹងល្អ ។ កូនៗរបស់យើងបានផ្ដល់ពរជ័យដល់មនុស្សដទៃទៀតតាមរយៈការចែកចាយទីបន្ទាល់របស់ពួកគេ ។

ពេលកូនៗរបស់យើងនៅក្មេង យើងបានរស់នៅប្រទេសកាហ្សាក់ស្ថាន ។ នៅពេលនោះគ្មានពួកអ្នកផ្សព្វផ្សាយសាសនានៅក្នុងប្រទេសនោះទេ ។ ពេលមិត្តភក្ដិ និងអ្នកជិតខាងចង់ស្ដាប់អំពីដំណឹងល្អ នោះ *យើង* ត្រូវធ្វើជាពួកអ្នកផ្សព្វផ្សាយសាសនា !

កូនស្រីរបស់យើងឈ្មោះ ម៉ាណេ បានចែកចាយដំណឹងល្អនឹងមិត្តរបស់នាងឈ្មោះ អាលីយ៉ូណា ។ អាលីយ៉ូណា បានសម្រេចចិត្តជ្រមុជទឹកដោយមានការអនុញ្ញាតពីម្ដាយរបស់នាង ដែលក្រោយមកទៀត គាត់បានជ្រមុជទឹកជាមួយនឹងប្អូនស្រីរបស់អាលីយ៉ូណា ។ ថ្មីៗនេះ អាលីយ៉ូណា បានរៀបការនឹងយុវជនដ៏សុចរិតម្នាក់នៅក្នុងព្រះវិហារបរិសុទ្ធមែនហ៊ែតថិន នូវយ៉ោក ហើយម៉ាណេត្រូវទៅចូលរួមនៅទីនោះ ! នាងមានចិត្តរីករាយជាខ្លាំង ដោយសារនាងបានជួយមិត្តរបស់នាងឲ្យរៀនអំពីព្រះយេស៊ូវគ្រីស្ទ ។

ពេលយើងរស់នៅរដ្ឋ វើរជីញ៉ា ស.រ.អា. កូនប្រុសរបស់យើងឈ្មោះ គ្រីស ស្ថិតនៅក្នុងថ្នាក់កុមារ ។ មិត្តម្នាក់របស់គ្រីស និងគ្រួសាររបស់គាត់បានចាប់ផ្ដើមជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនា ។ គ្រីសបានជួយបង្រៀនគ្រួសារនោះ ។ គាត់បានត្រៀមខ្លួនពីមុនមេរៀននីមួយៗ ហើយបានជួយឆ្លើយសំណួររបស់ពួកគេ ។ គ្រួសារនោះបានសម្រេចចិត្តជ្រមុជទឹក ។ បន្ទាប់ពីនោះមក គ្រីស ពុំដែលបារម្ភថា គាត់ពុំអាចបម្រើបេសកកម្មបានឡើយ ។ គាត់បានដឹងថា គាត់អាចធ្វើកិច្ចការនេះបាន !

នៅគ្រាមួយទៀត មានបុរសម្នាក់បានមកធ្វើការនៅផ្ទះរបស់យើង ។ ភរិយារបស់ខ្ញុំបានអរគុណដល់គាត់ ពេលគាត់បានធ្វើកិច្ចការចប់ ។ នាងបានពោលថា « យើងចង់ឲ្យអំណោយមួយដល់លោក » ។ នាងបានឲ្យព្រះគម្ពីរមរមនមួយក្បាលទៅបុរសនោះ ។

បុរសនោះពុំសប្បាយចិត្តឡើយ ។ គាត់ពុំបានយល់អំពីអ្វីដែលយើងជឿនោះទេ ។ គាត់បានគិតថា យើងពុំជឿលើព្រះយេស៊ូវគ្រីស្ទទេ ។

គ្រីសមានចិត្តក្លាហាន ហើយបានចែកទីបន្ទាល់របស់គាត់ជាមួយនឹងបុរសនោះ ។ គ្រីស បានប្រាប់ថា គាត់គឺជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ គាត់បាននិយាយថា គាត់ជឿលើព្រះយេស៊ូវ ។

មានកូនចៅជាច្រើនរបស់ព្រះវរបិតាសួគ៌ពុំដឹងអំពីដំណឹងល្អនេះទេ ។ មានមនុស្សខ្លះទៀតពុំដឹងថា យើងជឿលើព្រះយេស៊ូវឡើយ ។ មនុស្សទាំងនេះត្រូវការមនុស្សម្នាក់ដែលមានសណ្ដានចិត្តល្អ ហើយនិយាយនឹងពួកគេ ។ យើងអាចមានភាពក្លាហាន ហើយចែកចាយទីបន្ទាល់របស់យើង ។ យើងអាចជួយមនុស្សដទៃទៀតឲ្យរៀនអំពីព្រះយេស៊ូវគ្រីស្ទបាន ! ■

# សាសនាចក្របច្ចុប្បន្ន

*សូមប្រើរូបភាពទាំងនេះ ដើម្បីចែកចាយ
រឿងនានាអំពីប្រវត្តិ សាសនាចក្រ !*








ប្រធានម៉នសុន

ពួកបរិសុទ្ធបានសាងសង់ទីក្រុងដ៏ស្រស់ស្អាតមួយនៅជ្រលងភ្នំ សលត៍ លេក ហើយបានចំណាយពេល ៤០ ឆ្នាំក្នុងការសាងសង់ព្រះវិហារបរិសុទ្ធ សលត៍ លេក នេះ ។ សាសនាចក្របានរីកចម្រើនយ៉ាងខ្លាំងចាប់តាំងពីពេលនោះមក ។ ឥឡូវនេះមានព្រះវិហារបរិសុទ្ធចំនួន ១៥៦ កន្លែងដែលបានសាងសង់ចប់សព្វគ្រប់នៅជុំវិញពិភពលោក ហើយព្រះគម្ពីរមរមនត្រូវបានបកប្រែជា ១១០ ភាសា ! ប្រធាន ថូម៉ាស អេស ម៉នសុន គឺ ជាព្យាការីរបស់យើងនៅសព្វថ្ងៃនេះ ។ តើអ្នកអាចជួយសាសនាចក្រឲ្យបន្តរីកចម្រើនតាមរបៀបណា ?

រចនារូបភាពដោយ បេត អឹម វ៉ាយតេកឃើរ

យើងសង្ឃឹមថា អ្នកបានរីករាយនឹងលំដាប់នៃរូបភាពប្រវត្តិសាសនាចក្រក្នុងឆ្នាំនេះ !
អ្នកអាចស្វែងរករូបភាព កាលពីមុននៅលើគេហទំព័រ liahona.lds.org ។

# សំបុត្រ ពណ៌ក្រហម



*អ៊ូ អ៊ូ! ដានីយ៉ែលបានបាត់សំបុត្រ*
*មួយទៀតហើយ ។*

ចេនារូបភាពដោយ ចន ម៉ានឌើរស៍

**ដោយ ដាស៊ី ជេនសិន ម័រីស**
ផ្អែកទៅលើដំណើររឿងពិត

« *ពេលណាខ្ញុំមានចិត្តល្អសប្បុរស ហើយជួយមនុស្សម្នាក់ដែលខ្ញុំឃើញ ខ្ញុំមានអារម្មណ៍រីករាយខ្លាំងណាស់* » ( *Children's Songbook*, ល.រ.១៩៧ ) ។

ម៉ាតេអូ បានមើលលំហាត់គណិតវិទ្យានៅលើក្ដារខៀន ហើយកត់វាយ៉ាងលឿនចូលក្នុងសៀវភៅរបស់គាត់ ។ គណិតវិទ្យាគឺជាមុខវិជ្ជាដែលគាត់ចូលចិត្ត ដូច្នេះគាត់ពិតជាចង់ផ្ដោតការយកចិត្តទុកដាក់ខ្លាំងណាស់ ។ ប៉ុន្តែគាត់ស្ដាប់ពុំសូវឮនូវអ្វីដែលលោកស្រីសាន់តូសកំពុងនិយាយឡើយ ដោយសារមិត្តរបស់គាត់ឈ្មោះដានីយ៉ែលកំពុងតែជជែកគ្នាដែរ ។

« ស្ងាត់ ! ដានីយ៉ែល គ្នាស្ដាប់មិនឮទេ ! » ម៉ាតេអូបាននិយាយខ្សឹបៗ ។ ប៉ុន្តែដានីយ៉ែលនៅតែនិយាយទៀត ។ នៅទីបំផុត អ្នកស្រីសាន់តូសបានឮគាត់ ។

លោកស្រីសាន់តូបាននិយាយថា « ដានីយ៉ែល កូនរំខានទៀតហើយ » ។ « កូនបានទទួលការព្រមានមួយរួចហើយ ។ ឥឡូវ កូនត្រូវឲ្យសំបុត្រមួយដល់អ្នកគ្រូ » ។

ដានីយ៉ែលបានដកយកសំបុត្រពណ៌ក្រហមចេញពីតុរបស់គាត់យឺតៗ ហើយឲ្យវាទៅលោកស្រីសាន់តូស ។ គាត់បានទម្លាក់ស្មាចុះ ហើយសម្លឹងមើលទៅកម្រាលឥដ្ឋ ។ លោកស្រីសាន់តូសបានឲ្យសំបុត្រទៅសិស្សដែលមានឥរិយាបថ

ល្អ ហើយស្តាប់បង្គាប់ ។ សិស្សទាំងឡាយបានសរសេរឈ្មោះរបស់ខ្លួននៅលើសំបុត្រ ហើយដាក់វានៅក្នុងថុមួយជារៀងរាល់ថ្ងៃ ។ ប៉ុន្តែត្រូវឲ្យសំបុត្រមួយទៅវិញ ប្រសិនបើមានឥរិយាបថមិនល្អ ។ រៀងរាល់ថ្ងៃសុក្រ លោកស្រីសាន់តូសបានលូកយកសំបុត្រមួយពីថុមក ហើយអ្នកដែលឈ្នះអាចជ្រើសយករង្វាន់នៅក្នុងហិបរង្វាន់របស់ថ្នាក់ ! ដានីយ៉ែលបានឲ្យសំបុត្រជាច្រើនត្រឡប់ទៅវិញដោយសារតែការនិយាយច្រើន ដូច្នេះជារឿយៗឈ្មោះរបស់គាត់មិនត្រូវបានទាញចាប់បានឡើយ ។ ម៉ាតេអូមិនសប្បាយចិត្តសោះ ដោយឃើញដានីយ៉ែលបាត់បង់សំបុត្រមួយទៀត ។

លុះដល់ពេលសម្រាក ម៉ាតេអូបានរត់ចេញទៅលេងបាល់នៅលើទីលានបាល់ទាត់ ។ គាត់បានឃើញដានីយ៉ែលកំពុងឈរតែម្នាក់ឯងនៅក្បែរទោង ។ គាត់អាចដឹងថា ដានីយ៉ែលកំពុងតែយំ ។ ម៉ាតេអូចង់ជួយគាត់ឲ្យមានអារម្មណ៍ល្អវិញ ។

ម៉ាតេអូ បានសួរថា « តើឯងចង់លេងបាល់ទាត់ទេ ? »

ដានីយ៉ែលមិននិយាយអ្វីទាំងអស់ ។ ម៉ាតេអូបានព្យាយាមនិយាយនឹងគាត់ថែមទៀត ប៉ុន្តែដានីយ៉ែលបានងាកចេញ ។

« មិនអីទេ គ្នានឹងនៅឯទីលានបាល់ទាត់ ប្រសិនបើឯងប្តូរចិត្ត » ។

ម៉ាតេអូបានទៅលេងបាល់ជាមួយនឹងមិត្តរបស់គាត់ផ្សេងទៀត ប៉ុន្តែគាត់នៅតែគិតដល់ដានីយ៉ែល ។ ម៉ាតេអូទើបតែមានអាយុប្រាំបីឆ្នាំ ហើយមិនយូរប៉ុន្មាននឹងត្រូវជ្រមុជទឹក ។ គាត់ចង់ក្លាយដូចជាព្រះយេស៊ូវ ហើយធ្វើជាមិត្តដ៏ល្អម្នាក់ ។ តើមានអ្វីមួយដែលគាត់អាចធ្វើដើម្បីជួយដល់ដានីយ៉ែលកុំឲ្យជួបនឹងបញ្ហាទៀតបានទេ ?

លុះស្អែកឡើង សិស្សទាំងអស់កំពុងអានដំណើររឿងមួយជាក្រុមតូចៗ ។ ប៉ុន្តែជំនួសឲ្យការអាន ដានីយ៉ែលបានបោះសៀវភៅរបស់គាត់ឡើងទៅលើយ៉ាងខ្ពស់ ។

ម៉ាតេអូបានព្យាយាមបញ្ឈប់គាត់ ។ « ដានីយ៉ែល យើងត្រូវអានសៀវភៅ កុំលេងច្រើនពេក » ។

ដានីយ៉ែលបានបោះសៀវភៅនោះម្តងទៀត ។ លោកស្រីសាន់តូសបានឃើញវាស្ទើរតែប៉ះនឹងពិដាន ។ គាត់បានដើរមករកដានីយ៉ែល ហើយបានហុចដៃគាត់ទារសុំសំបុត្រមួយ ។ ដានីយ៉ែលបានលូកដៃចូលទៅក្នុងតុរបស់គាត់ ។ គាត់មានទឹកមុខតក់ស្លុត កាលគាត់បន្តរាវរកសំបុត្រនោះ ។

« យ៉ាប់ហើយ ! គាត់ប្រាកដជាអស់សំបុត្រហើយ ! » ម៉ាតេអូបានគិត ។ ប្រសិនបើគ្មានសំបុត្រមានន័យថា ដានីយ៉ែលត្រូវនៅក្នុងថ្នាក់ពេលសម្រាក ។ ម៉ាតេអូចាប់ផ្តើមគិត ។ តើគាត់អាចធ្វើអ្វីខ្លះ ? រួចគាត់មានគំនិតល្អមួយ ។

លោកស្រីសាន់តូសបាននិយាយថា « ដានីយ៉ែល ប្រសិនបើកូនគ្មានសំបុត្រឲ្យអ្នកគ្រូទេ អញ្ចឹង — »

ម៉ាតេអូបានដកដង្ហើមវែងៗ ។ គាត់បានសួរថា « អ្នកគ្រូសាន់តូស តើខ្ញុំអាចឲ្យជំនួសគាត់បានទេ ? »

សិស្សផ្សេងបានស្ងាត់ ។ គ្មានសិស្សណាម្នាក់ធ្លាប់សួរអ្នកគ្រូបែបនេះពីមុននោះឡើយ ។ ម៉ាតេអូមិនប្រាកដក្នុងចិត្តថា អ្នកគ្រូនឹងតបវិញយ៉ាងណាទេ ។

លោកស្រីសាន់តូសទំនងមានការភ្ញាក់ផ្អើល ។ បន្ទាប់មក គាត់បានញញឹម ។ « កូនជាមិត្តដ៏ល្អម្នាក់ ។ ពិតជាបាន កូនអាចឲ្យសំបុត្រជំនួសដានីយ៉ែលបាន » ។ ម៉ាតេអូបានហុចសំបុត្ររបស់គាត់មួយឲ្យទៅលោកស្រីសាន់តូស ។

ដានីយ៉ែលបាននិយាយថា « អរគុណ ម៉ាតេអូ ។

ម៉ាតេអូបានតបថា « មិនអីទេ ! » « តើឥឡូវនេះឯងចង់អានជាមួយគ្នាទេ ? »

ដានីយ៉ែលបានងក់ក្បាល ហើយបានរើសសៀវភៅគាត់ឡើង ។

កាលដានីយ៉ែលបានចាប់ផ្តើមអាន ម៉ាតេអូបានមានអារម្មណ៍កក់ក្តៅ ហើយរីករាយនៅក្នុងចិត្ត ។ គំនិតល្អនោះកើតចេញមកពីព្រះវិញ្ញាណបរិសុទ្ធ ! ម៉ាតេអូបានដឹងថា ព្រះយេស៊ូវសព្វព្រះទ័យឲ្យគាត់ជួយដល់ដានីយ៉ែល — ដោយសារទ្រង់ក៏ស្រឡាញ់ដានីយ៉ែល ។ ហើយម៉ាតេអូទទួលអារម្មណ៍ពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវផងដែរ ! ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*



## ព្រះយេស៊ូវបានបង់ថ្លៃជួសយើង

ម៉ាតេអូបានឲ្យសំបុត្រជំនួសដានីយ៉ែល ដោយសារគាត់ខ្វល់ខ្វាយពីដានីយ៉ែល ។ យើងពុំអាចបង់ថ្លៃជួសអំពើបាបរបស់មនុស្សម្នាក់ផ្សេងទៀតបានឡើយ ប៉ុន្តែព្រះយេស៊ូវគ្រីស្ទអាច ! ដោយសារទ្រង់ស្រឡាញ់យើង ព្រះយេស៊ូវបានបង់ថ្លៃជួសនៅរាល់អំពើបាបទាំងឡាយរបស់យើង ។ ពេលយើងធ្វើអ្វីមួយខុស យើងអាចប្រែចិត្ត ហើយទទួលបានការអភ័យទោស ។ ព្រះយេស៊ូវអាចជួយយើងឲ្យប្រព្រឹត្តកាន់តែប្រសើរ !

ចម្លើយមកពីសាវក



ដោយអែលឌើរ
ឌេល ជី រេនឡាន់
ក្នុងកូរ៉ុមនៃពួក
សាវកដប់ពីរនាក់

# តើការប្រែចិត្តអាចជួយ ខ្ញុំឲ្យមានចិត្ត រីករាយតាមរបៀបណា ?



ការប្រែចិត្តមានន័យថា យើងងាកចេញពីអំពើបាប ហើយបង្វែរដួងចិត្តរបស់យើងមករកព្រះ វិញ ។

ព្រះយេស៊ូវ អាចអភ័យទោស ឲ្យយើងបាន ដោយសារទ្រង់បានបង់ថ្លៃអំពើបាបរបស់យើង រួច ហើយ ។ ទ្រង់មានព្រះទ័យចង់ អភ័យទោសឲ្យ យើង ដោយសារទ្រង់ស្រឡាញ់យើង ។

ទ្រង់មានព្រះទ័យរីករាយ ពេលយើង ជ្រើសរើសដើម្បីប្រែចិត្ត ។

ពេលទ្រង់អភ័យទោសឲ្យយើង នោះ យើង អាចមានអារម្មណ៍រីករាយផងដែរ ។

ដកស្រង់ពី « *Repentance: A Joyful Choice* » Liahona, ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ១២១–១២៤ ។

រចនារូបភាពដោយ ឌីលីន ម៉ាស្ស

# ផាវ



ពេលអែលឌើរ ឌែល ជី រេនឡាន់ មានអាយុ ១២ ឆ្នាំ គ្រួសាររបស់លោកបានរស់នៅក្នុងប្រទេសស៊ុយអែត ។ នៅថ្ងៃអាទិត្យមួយ មិត្តរបស់ឌែល ឈ្មោះ ស្ទេហ្វាន បានយកផាវដ៏ធំមួយ និងឈើគូស ចូលទៅក្នុងអគារសាសនាចក្រ ។ ឌែល រំភើបចិត្តណាស់ ។ ឌែល បាន យក ផាវនោះមក ហើយដុតឆ្នូនរបស់វា ។ លោកចង់ពន្លត់ឆ្នូននោះ ប៉ុន្តែលោកបានធ្វើឲ្យលោកម្រាមដៃ ហើយក៏ជ្រុះ ផាវនោះទៅនឹងឥដ្ឋ ! ឌែល និងស្ទេហ្វាន បានមើលដោយការភ័យស្លុត ពេលឆ្នូននោះបន្តឆេះ ។

ផាវនោះក៏បានផ្ទុះឡើង ! ក្លិនដ៏អាក្រក់មួយបាន សាយភាយពេញសាលប្រជុំ ។ រំពេចនោះ ឌែល និងស្ទេហ្វាន បានរើសកម្ទេចផាវនោះ ហើយបានបើកបង្អួចឲ្យក្លិនហើរចេញ ។ ពួកគាត់ បាន សង្ឃឹមថា នឹងគ្មាននរណាម្នាក់កត់សម្គាល់ពួកគាត់ឡើយ ។

ពេលមនុស្សបានមកការប្រជុំសាក្រាម៉ង់ ពួកគេ *បាន* ដឹង ។ ក្លិននោះខ្លាំងណាស់រហូតធ្វើមនុស្សទាំងនោះពុំអាចផ្តោតអារម្មណ៍លើការប្រជុំបានឡើយ ។ ឌែល មានអារម្មណ៍ខ្មាស់អៀន និងអាម៉ាស់ជាខ្លាំង ។ លោកបានដឹងថា អ្វីដែលលោកបានធ្វើនោះគឺធ្វើឲ្យព្រះវរបិតាសួគ៌អាក់អន់ព្រះទ័យ ។

បន្ទាប់ពីម៉ោងព្រះវិហារ ប្រធាន លីនប៊ឹក ជាប្រធានសាខាបានសុំឲ្យឌែលទៅការិយាល័យរបស់គាត់ ដោយសារ គាត់ ដឹងថាមានរឿងអ្វីមួយដែលមិនប្រក្រតី ។ ឌែល បានប្រាប់ប្រធាន លីនប៊ឹក ពីការសោកស្តាយដែលគាត់មានចំពោះរឿងផាវនោះ ។

ប្រធាន លីនប៊ឹក ជាមនុស្សមានសណ្ដានចិត្តល្អ ។ គាត់បានបើកព្រះគម្ពីរ ហើយបានសុំឲ្យឌែលអានខគម្ពីរមួយចំនួនដែលមានគូសបន្ទាត់ពីក្រោម ។ ឌែល បានអានថា « មើលចុះ អ្នកណាដែលប្រែចិត្តពីអំពើ បាបទាំងឡាយរបស់ខ្លួន អ្នកឈ្មោះថាបានអត់ទោសឲ្យហើយ ហើយយើងជាព្រះអម្ចាស់មិនចាំពីអំពើបាបទាំងនោះទៀតទេ ។ តាមរបៀបនេះ អ្នករាល់គ្នាអាចដឹងបើសិនជាមនុស្សណាម្នាក់ប្រែចិត្ត ពីអំពើបាបទាំងឡាយរបស់ខ្លួនមែន ឬអត់ — មើលចុះអ្នកនោះនឹងសារភាពអំពីអំពើបាបទាំងឡាយ ហើយលះបង់ចោលអំពើបាបទាំងនោះ » ( គ. និង ស. ៥៨:៤២–៤៣ ) ។

ពេលឌែលបានបញ្ចប់ការអាន លោកបានឃើញប្រធាន លីនប៊ឹក ញញឹម ។ ពេល ឌែល បានចាកចេញពីការិយាល័យនោះ លោកបានមានចិត្តរីករាយ ។ លោកបានទទួលអារម្មណ៍ថា លោកទទួលបានការអភ័យទោសឲ្យ ។

អែលឌើរ រេនឡាន់ បានរៀនថា លោកអាចទទួលបានការអភ័យទោស ពេលលោកបានធ្វើអ្វីមួយខុសឆ្គង ។ លោកអាចមានចិត្តរីករាយ ពេលលោកបានប្រែចិត្ត ហើយគោរពបទបញ្ញត្តិរបស់ព្រះវរបិតាសួគ៌ ។ ■



**១១ ធ្នូ ៖**
« យើងជាអ្នកដទៃ ហើយ អ្នករាល់គ្នាបានទទួលយើង »
( ម៉ាថាយ ២៥:៣៥ ) ។

**១២ ធ្នូ ៖**
« មានពរហើយ អស់អ្នកដែលយំសោក ដ្បិតអ្នកទាំងនោះនឹងបានសេចក្ដីកំសាន្តចិត្ត »
( ម៉ាថាយ ៥:៤ ) ។

**១៣ ធ្នូ ៖**
« អស់ទាំងការអ្វីដែលអ្នករាល់គ្នាចង់ឲ្យមនុស្សលោកប្រព្រឹត្តនឹងខ្លួន នោះត្រូវឲ្យអ្នកប្រព្រឹត្តនឹងគេដូច្នោះដែរ »
( ម៉ាថាយ ៧:១២ ) ។

**១៤ ធ្នូ ៖**
« កុំឲ្យថ្កោលទោសគេឡើយ ដើម្បីមិនឲ្យមានគេថ្កោលអ្នកវិញ »
( ម៉ាថាយ ៧:១ ) ។

**១៥ ធ្នូ ៖**
« មានពរហើយ អស់អ្នកដែលមានចិត្តមេត្តាករុណា »
( ម៉ាថាយ ៥:៧ ) ។

**១៦ ធ្នូ ៖**
« យើងនៅអាក្រាត ហើយអ្នករាល់គ្នាបានស្លៀកពាក់ឲ្យយើង »
( ម៉ាថាយ ២៥:៣៦ ) ។

**១៧ ធ្នូ ៖**
« អ្នករាល់គ្នាត្រូវរួមគ្នាប្រជុំជាញឹកញាប់ »
( នីហ្វៃទី ៣ ១៨:២២ ) ។

**១៨ ធ្នូ ៖**
« អ្នករាល់គ្នាត្រូវចាំយាម ហើយអធិស្ឋានជានិច្ច »
( នីហ្វៃទី ៣ ១៨:១៥ ) ។

**១៩ ធ្នូ ៖**
« ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ »
( ម៉ាថាយ ៥:១២ ) ។

**២០ ធ្នូ ៖**
« ចូរខំស្វែងរកនគរព្រះវិញ »
( លូកា ១២:៣១ ) ។

**២១ ធ្នូ ៖**
« អត់ទោសចំពោះការរំលងច្បាប់ដែលមនុស្សលោកប្រព្រឹត្តធ្វើ » ( ម៉ាថាយ ៦:១៤ ) ។

**២៥ ធ្នូ ៖**
« ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺទៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អដែលអ្នករាល់គ្នាប្រព្រឹត្តរួចសរសើរតម្កើងដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌ » ( ម៉ាថាយ ៥:១៦ ) ។

**២២ ធ្នូ ៖**
« កិច្ចការទាំងឡាយដែលអ្នករាល់គ្នាបានឃើញយើងធ្វើយ៉ាងណា នោះអ្នករាល់គ្នាត្រូវធ្វើយ៉ាងនោះដែរ » ( នីហ្វៃទី ៣ ២៧:២១ ) ។

**២៣ ធ្នូ ៖**
« យើងបានឈឺ ហើយអ្នករាល់គ្នាបានមកសួរយើង » ( ម៉ាថាយ ២៥:៣៦ ) ។

**២៤ ធ្នូ ៖**
« មានសេចក្ដីចែងទុកមកដូច្នេះ ដំណាក់អញត្រូវហៅថា ជាទីសម្រាប់អធិស្ឋាន » ( ម៉ាថាយ ២១:១៣ ) ។

*រៀងរាល់ថ្ងៃ សូមអានអ្វីមួយដែលព្រះយេស៊ូវបានបង្រៀន រួចហើយគិតអំពីរបៀបដែលអ្នកអាចធ្វើតាមការបង្រៀនរបស់ទ្រង់ ។ បន្ទាប់មកផាត់ពណ៌ផ្កាយនោះ !*

នៅឆ្នាំក្រោយ យើងនឹងប្រមូលផ្កាយពីកុមារមកពីជុំវិញពិភពលោក ! សូមផ្ញើផ្កាយមួយមកឲ្យយើង ហើយប្រាប់យើងអំពីរបៀបដែលអ្នកគឺជាគំរូដ៏ភ្លឺត្រចះត្រចង់មួយ ។ សូមកុំភ្លេចដាក់បញ្ចូលរូបថតមួយសន្លឹក ប្រសិនបើអ្នកមាន ។ សូមផ្ញើវាតាមគេហទំព័រ liahona.lds.org ។


រូបភាពមកពី GETTY IMAGES

សូមស្វែងរកបន្ថែមទៀតអំពីការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទនៅ Mormon.org នៅខែធ្នូ !

១០ ថ្ងៃ ដំបូងនៃសកម្មភាពនេះអាចរកបានជាអត្ថបទនៅក្នុងអ៊ិនធើណែតនៅលើគេហទំព័រ liahona.lds.org ឬនៅក្នុងកម្មវិធីបណ្ណាល័យដំណឹងល្អ Gospel Library app ។

# មានពេលថ្វាយទ្រង់

បទ ដោយឡារី ហិល្លី
ទំនុកភ្លេងដោយ ម៉ៃឃើល អេហ្វ ម៉ូឌី




© ឆ្នាំ ២០១៧ ដោយស្ទីហ្វិន ខេ និងម៉ៃឃើល អេហ្វ ម៉ូឌី
បទចម្រៀងនេះ អាចថតចម្លងប្រើប្រាស់ជាជំនួយក្នុងព្រះវិហារ ឬនៅគេហដ្ឋានដែលពុំមានលក្ខណៈជាពាណិជ្ជកម្មឡើយ ។
សេចក្ដីជូនដំណឹងនេះត្រូវបិទនៅលើសំណៅថតចម្លងនីមួយៗ ។

# ទំព័ររបស់យើង



*យើងបាននិយាយអំពីសារៈសំខាន់នៃព្រះវិហារបរិសុទ្ធនៅក្នុងជីវិត និងគ្រួសាររបស់យើង ។ យើងបានសង់គំរូនៃព្រះវិហារបរិសុទ្ធជាមួយនឹងក្រុមគ្រួសាររបស់យើង ។*

កុមារនៃអង្គការបឋមសិក្សាក្នុងវួដមួយនៅទីក្រុងសៅ ប៉ូឡូ ប្រទេស ប្រេស៊ីល



*យើងបានទៅលេងនៅឆ្នេរសមុទ្រពេលវិស្សមកាលរបស់យើង ហើយបានធ្វើខែល រ.ផ.ត. មួយនៅលើខ្សាច់ ។*

សូហ្វៀ, ម៉ាធីអាស និងថូម៉ាស អូ ប្រទេសអាហ្សង់ទីន



## ព្រះដ៏មានមហិទ្ធិឫទ្ធិ

*មនុស្សគ្រប់គ្នាបានសួរខ្លួនឯងថា « តើព្រះ ដ៏ មាន*
*មហិទ្ធិឫទ្ធិ ទ្រង់គឺ ជានរណា ? »*
*មនុស្សជា ច្រើនពុំដឹងពីរឿងនេះទេ ។*
*ពួកគេពុំដឹងថា ទ្រង់គង់នៅក្នុងកែវភ្នែករបស់កុមារឡើយ ។*
*ពេលអ្នកមានអារម្មណ៍ពី ការខ្សឹបប្រាប់ ល្ងើយៗ*
*នៅក្នុងដួងចិត្តនៃភាពអង់អាច*
*នៅក្នុងស្នាមញញឹមនៃមនុស្សជាទីស្រឡាញ់របស់អ្នក*
*ហើយអ្នកពុំគ្រាន់តែហៅទ្រង់ថា « ព្រះ » ឬ*
*« ព្រះ ដ៏ មាន មហិទ្ធិឫទ្ធិ » ប៉ុណ្ណោះទេ*
*ប៉ុន្តែអ្នកក៏ហៅទ្រង់ថា . . . « ព្រះវរបិតាសួគ៌*
*របស់ខ្ញុំ » ផងដែរ ។*

អាទ្រីយ៉ាណា ជី អាយុ ៩ ឆ្នាំ ប្រទេស ឈីលី



*ខ្ញុំតែងតែបង្ហាញសេចក្តីស្រឡាញ់ចំពោះបងប្អូនប្រុសស្រីរបស់ខ្ញុំជានិច្ច តាមរយៈការជួយពួកគេឲ្យធ្វើកិច្ចការសាលារបស់ពួកគេ ។ សូមញញឹម !*

បេនយ៉ាមីន អេស អាយុ ១១ ឆ្នាំ ប្រទេសកេនយ៉ា



រឿងអំពីព្រះយេស៊ូវ

# ព្រះយេស៊ូវប្រសូតក្នុងភូមិបេថ្លេហិម

ដោយ គីម វេប រីដ



មានទេវតាមួយអង្គបានមកជួបនឹងម៉ារា ហើយបាន ប្រាប់នាងថា ព្រះសព្វព្រះទ័យនឹងនាង ។ នាងនឹង ក្លាយជាមាតារបស់ព្រះយេស៊ូវ !



ម៉ារា និងយ៉ូសែបបានធ្វើដំណើរទៅ ភូមិបេថ្លេហិម ។ វាហៀបនឹងដល់ ពេលវេលាដែលព្រះយេស៊ូវប្រសូតមក ហើយ ។ ដូច្នេះមានមនុស្សជា ច្រើន បានទៅលេងភូមិបេថ្លេហិម រហូតដល់ ម៉ារា និងយ៉ូសែបពុំអាចរកបន្ទប់ស្នាក់ នៅបាន ។ មានម្ចាស់ផ្ទះសំណាក់ម្នាក់បានទទួលឲ្យពួកគាត់ស្នាក់នៅ ក្នុងក្រោលសត្វមួយ ។

រូបភាពដោយ អាប៊ើល ស្មីត



មិនយូរប៉ុន្មាន ព្រះយេស៊ូវបានប្រសូតមក ។ ផ្កាយថ្មីដ៏ភ្លឺត្រចះត្រចង់មួយបានលេចឡើង ដើម្បីប្រាប់ដល់មនុស្សគ្រប់គ្នាថា ទ្រង់ដែលជាពន្លឺនៃលោកិយបានយាងមកកាន់ផែនដីហើយ ។



មានទេវតាមួយអង្គបានប្រាប់ដល់ពួកគង្វាលមួយចំនួនថា ព្រះយេស៊ូវបានប្រសូតមកហើយ ។ ពួកគេបានប្រញាប់ប្រញាល់ទៅមើលព្រះឱរសយេស៊ូវកំពុងផ្ទុំនៅក្នុងស្នូក ។



ព្រះយេស៊ូវបានយាងមកផែនដី ដោយសារទ្រង់ស្រឡាញ់ខ្ញុំ ។ ខ្ញុំនឹងដើរតាមពន្លឺរបស់ទ្រង់នៅបុណ្យគ្រីស្ទម៉ាស់នេះ និងពេញមួយឆ្នាំ ! ■

*ដកស្រង់ពី លូកា ១:២៦–៣៨, ២:១–២០*



« [ ពួកគង្វាល ] ក៏ទៅជាប្រញាប់ឃើញ ម៉ារា និង យ៉ូសែប នៅទីនោះ
ព្រមទាំងព្រះឱរសផ្ដេកនៅក្នុងស្នូកផង » ( លូកា ២:១៦ ) ។

រចនារូបភាពដោយ អាបរីល ស្ដុត



ដោយ យ៉ូសែប ស្ម៊ីធ
( ១៨០៥–៤៤ )
ប្រធានទីមួយនៃសាសនាចក្រ

# ក្លាហាននៅក្នុងបុព្វហេតុនៃព្រះគ្រីស្ទ

*អ្នកត្រូវធ្វើជាមនុស្សល្អ ។*

ខ្ញុំគឺជាមនុស្សម្នាក់ដែលស្រឡាញ់បុព្វហេតុនៃព្រះគ្រីស្ទ និងនៃគុណធម៌ ព្រហ្មចារីភាព ព្រមទាំងលំនាំអាកប្បកិរិយាដែលខ្ជាប់ខ្ជួន និងការដើរដោយបរិសុទ្ធ ។

ខ្ញុំជឿលើការរស់នៅក្នុងជីវិតមួយដែលមានគុណធម៌ ស្លូតត្រង់ ហើយបរិសុទ្ធចំពោះព្រះ ហើយមានអារម្មណ៍ថា វាគឺជាករណីយកិច្ចរបស់ខ្ញុំដើម្បីទាក់ទាញ [ មនុស្ស ] ទាំងអស់ឲ្យអស់ពីលទ្ធភាពរបស់ខ្ញុំ ដើម្បីធ្វើរឿងដូចគ្នានេះ ដើម្បីពួកគេអាចឈប់ធ្វើអំពើអាក្រក់ ហើយរៀនធ្វើល្អវិញ ហើយបញ្ឈប់អំពើបាបដោយសេចក្តីសុចរិត ។

តាមរយៈការពង្រឹងសេចក្តីជំនឿរបស់យើងដោយដាក់បន្ថែមនូវរាល់គុណសម្បត្តិល្អៗដែលបំពាក់លើកូនចៅនៃព្រះយេស៊ូវដ៏មានពរ នោះយើងអាចអធិស្ឋាននៅក្នុងគ្រានៃការអធិស្ឋាន យើងអាចស្រឡាញ់អ្នកជិតខាងរបស់យើងឲ្យដូចខ្លួនយើង ហើយស្មោះត្រង់នៅក្នុងសេចក្តីទុក្ខលំបាក ដោយដឹងថា រង្វាន់នៃកិច្ចការបែបនេះគឺធំជាងនៅក្នុងនគរស្ថានសួគ៌ ។ ឱ វាគឺជាការលួងលោមចិត្តមួយអ្វីម្ល៉េះ ! ឱ វាគឺជាអំណរមួយអ្វីម្ល៉េះ ! ចូរឲ្យខ្ញុំរស់នៅក្នុងជីវិតនៃមនុស្សសុចរិត ហើយចូរឲ្យរង្វាន់របស់ខ្ញុំបានដូចជាទ្រង់ ! . . .



ក្នុងនាមជាមនុស្សម្នាក់ដែលប្រាថ្នាចង់បានសេចក្តីសង្គ្រោះដល់មនុស្សយ៉ាងខ្លាំង ចូរឲ្យខ្ញុំរំឭកដល់អ្នកទាំងអស់គ្នាឲ្យខិតខំដោយភាពវៀសវៃមកពីព្រះសម្រាប់គុណធម៌ បរិសុទ្ធភាព និងបទបញ្ញត្តិរបស់ព្រះអម្ចាស់ ។ ចូរធ្វើជាមនុស្សល្អ ឈ្លាសវៃ មានយុត្តិធម៌ មានសេរីភាព [ តាមមធ្យោបាយរបស់អ្នក ] ហើយសំខាន់បំផុតនោះ ចូរមានចិត្តសប្បុរស ដែលសម្បូរទៅដោយរាល់កិច្ចការល្អជានិច្ច ។ . . .

ចូរមានចិត្តរាបសា ហើយទន់ភ្លន់ ស្លូតត្រង់ ហើយបរិសុទ្ធ ផ្តល់អំពើល្អជំនួសឲ្យអំពើអាក្រក់ ។ . . . ចូរមានចិត្តរាបសា ហើយអត់ធ្មត់នៅគ្រប់កាលៈទេសៈនៃជីវិត នោះយើងនឹងមានជ័យជំនះកាន់តែរុងរឿង ។

យើងទទួលអារម្មណ៍ឲ្យដាស់តឿនដល់បងប្អូនប្រុស [ និងបងប្អូនស្រី ] របស់យើងដោយភាពអង់អាច ឲ្យពួកគេមានចិត្តរាបសា និងប្រកបដោយការអធិស្ឋាន ឲ្យដើរដោយពិតក្នុងនាមជាកូនចៅនៃពន្លឺ និងនៃថ្ងៃ ដើម្បីឲ្យពួកគេអាចមានព្រះគុណដើម្បីទ្រាំទ្ររាល់ការល្បួង ហើយយកឈ្នះនូវរាល់អំពើអាក្រក់នៅក្នុងព្រះនាមដ៏សក្តិសមនៃព្រះអម្ចាស់របស់យើង គឺព្រះយេស៊ូវគ្រីស្ទ ។

គំនិតដែលមនុស្សគ្រប់រូបត្រូវទទួលស្របតាមភាពឧស្សាហ៍ និងកិច្ចខិតខំជាបន្តរបស់ខ្លួនកាលនៅក្នុងចម្ការទំពាំងបាយជូរ គួរបំផុសគំនិតដល់មនុស្សគ្រប់រូបដែលត្រូវបានហៅឲ្យធ្វើជាអ្នកបម្រើម្នាក់នៅក្នុងដំណឹងដ៏រីករាយទាំងនេះ ។ . . .

ការទុកចិត្តរបស់យើងគឺនៅក្នុងព្រះ ហើយយើងត្រូវតាំងចិត្ត ដោយមានព្រះគុណរបស់ទ្រង់ជួយដល់យើង ដើម្បីថែទាំបុព្វហេតុនេះ ហើយនៅស្មោះត្រង់រហូតចុងបញ្ចប់ ដើម្បីយើងអាចទទួលបានមកុដនៃសិរីល្អសេឡេស្ទាល ហើយបានចូលទៅក្នុងទីសម្រាកដែលបានរៀបចំសម្រាប់កូនចៅរបស់ព្រះ ។ . . .

អ្នកត្រូវធ្វើជាមនុស្សល្អ ។ ភាពអត់ធ្មត់មានភាពល្អវិសេស ការគោរពប្រតិបត្តិមានភាពថ្លៃថ្នូរ ការអភ័យទោសភាពមេត្តា ហើយភាពតម្កើងឡើងមានភាពបរិសុទ្ធ ហើយជនណាដែលនៅស្មោះត្រង់ដល់ចុងបំផុតនឹងពុំបាត់បង់រង្វាន់របស់ខ្លួនឡើយ ។ បុរស [ ឬ ស្ត្រី ] ដ៏ល្អម្នាក់នឹងស៊ូទ្រាំគ្រប់ការណ៍ទាំងអស់ដើម្បីគោរពឲ្យតម្លៃដល់ព្រះគ្រីស្ទ ។ ■

*ដកស្រង់ពី* Teachings of Presidents of the Church: Joseph Smith ( *ឆ្នាំ ២០១១ ) ទំព័រ ៣៥២–៥៦ ។*



***ព្រះយេស៊ូវត្រូវបានយកទៅបង្ហាញនៅក្នុងព្រះវិហារបរិសុទ្ធ***
**ដោយ គ្រីស្ទិន ឱលហ្វាដ**

*« ឥឡូវនេះ ឱព្រះដ៏ជាម្ចាស់អើយ សូមបើកឲ្យបាវបំរើទ្រង់ទៅដោយសុខសាន្ត តាមព្រះបន្ទូលទ្រង់ចុះ*
*« ដ្បិតភ្នែកទូលបង្គំបានឃើញសេចក្ដីសង្គ្រោះរបស់ផងទ្រង់*
*« ដែលទ្រង់បានរៀបចំនៅមុខបណ្ដាជនទាំងឡាយ*
*« ជាពន្លឺសំរាប់បំភ្លឺដល់សាសន៍ដទៃហើយ ជាសិរីល្អរបស់អ៊ីស្រាអែលជារាស្ត្រទ្រង់ » ។*
*— លូកា ២:២៩–៣២, សូមមើលផងដែរ ខទី ២៥–៣៥ ។*

# មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ

### អំណោយរបស់ខ្ញុំថ្វាយព្រះអង្គសង្គ្រោះ

ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ខ្ញុំមានអារម្មណ៍ថាខ្ញុំនៅមានភាពទន់ខ្សោយ ។ បន្ទាប់មកខ្ញុំបានដឹងថា ខ្ញុំត្រូវឈប់ផ្តោតលើខ្លួនឯង ហើយចាប់ផ្តើមផ្តោតលើព្រះអង្គសង្គ្រោះវិញ ។




ទំព័រ ៤៨

## សម្រាប់យុវវ័យ

ទំព័រ ៥៤



### ហេតុផលប្រាំបីយ៉ាងដែលបុណ្យគ្រីស្ទម៉ាស់គឺជា**គ្រាដ៏អស្ចារ្យ**មួយដើម្បីធ្វើជា**អ្នកផ្សព្វផ្សាយសាសនា**

តើអ្នកធ្លាប់ចង់ចែកចាយដំណឹងល្អជាមួយនឹងមិត្តភក្តិរបស់អ្នក ប៉ុន្តែពុំដឹងពីរបៀបដើម្បីធ្វើវាដែរឬទេ ? នេះគឺជាហេតុផលដែលរដូវកាលបុណ្យគ្រីស្ទម៉ាស់ គឺជាគ្រាដ៏ងាយស្រួលបំផុតមួយនៅក្នុងឆ្នាំ ដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ !

## សម្រាប់កុមារ

### ការបង្រៀនរបស់ព្រះយេស៊ូវ

សូមរៀបចំសម្រាប់បុណ្យគ្រីស្ទម៉ាស់នៅខែនេះដោយប្រើផ្កាយទាំងនេះដើម្បីធ្វើតាមការបង្រៀនរបស់ព្រះយេស៊ូវ ។



ទំព័រ ៧២

CAMBODIAN
4 02144 52258 3

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ